# របាយការណ៍
# ការចាប់ផ្តើមអនុវត្តគម្រោង

TA-8179 កម្ពុជា

## ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ ទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍

## កញ្ចប់សេវាកម្មទី ១


**រៀបចំសម្រាប់៖** ក្រសួងបរិស្ថាន រាជរដ្ឋាភិបាលកម្ពុជា
និងធនាគារអភិវឌ្ឍន៍អាស៊ី

**រៀបចំដោយ៖** មជ្ឈមណ្ឌលអន្តរជាតិសម្រាប់គ្រប់គ្រងបរិស្ថាន
ដោយសហការជាមួយ FRASER-THOMAS



**ខែកក្កដា ឆ្នាំ២០១៥**

| | |
|---|---|
| រៀបចំដោយ | ICEM |
| រៀបចំសម្រាប់ | ADB |
| រក្សាសិទ្ធិ | © ២០១៥ ICEM |
| ការស្នើសរសេរឯកសារយោង | ICEM ២០១៥ ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍នៅកម្ពុជា (TA 8179-CAM) កញ្ចប់ទី ១ រៀបចំសម្រាប់ធនាគារអភិវឌ្ឍន៍អាស៊ី ដោយមជ្ឈមណ្ឌលអន្តរជាតិសម្រាប់គ្រប់គ្រងបរិស្ថាន ហាណូយ វៀតណាម |

របាយការណ៍ចាប់ផ្តើមគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍នៅកម្ពុជា (TA 8179-CAM) កញ្ចប់ទី១រួមមានឧបសម្ព័ន្ធចំនួន៤ត្រូវបានចងក្រងជាសៀវភៅ
ដោយឡែកដោយសាររបាយការណ៍នេះមានចំនួនច្រើនទំព័រ។
របាយការណ៍នេះ មានមាតិកាសំខាន់ៗដូចជា៖

- ផ្នែកសំខាន់ៗនៃរបាយការណ៍ចាប់ផ្តើមគម្រោង ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ (TA 8179-CAM)
- ឧបសម្ព័ន្ធទី៥៖ ព័ត៌មានស្ថាប័នស្តីពីក្រសួងអនុវត្តគម្រោងវិនិយោគក្រោមកម្មវិធី SPCR
- ឧបសម្ព័ន្ធទី៨៖ ការវាយតម្លៃតម្រូវការកសាងសមត្ថភាពសម្រាប់ក្រសួងអនុវត្តគម្រោងវិនិយោគក្រោមកម្មវិធី SPCR
- ឧបសម្ព័ន្ធទី៩៖ ផែនការទំនាក់ទំនងផ្សព្វផ្សាយចំណេះដឹង និងផែនការសម្រាប់ការចូលរួមរបស់អ្នកពាក់ព័ន្ធ
- ឧបសម្ព័ន្ធទី១០៖ ការព្យាករណ៍ការប្រែប្រួលអាកាសធាតុសម្រាប់កម្ពុជា


សម្រាប់ព័ត៌មានបន្ថែម www.icem.com.au | info@icem.com.au

មជ្ឈមណ្ឌលអន្តរជាតិសម្រាប់គ្រប់គ្រងបរិស្ថាន (ICEM )
6A Lane 49, Tô Ngoc Vân
Tay Ho, HA NOI,
សាធារណរដ្ឋសង្គមនិយមវៀតណាម

ក្រុមការងារគម្រោង Peter-John Meynell, Jeremy Carew-Reid, Ian Hancock, Tarek Ketelsen, Kathleen McLaughlin, សៀក សូផាត, ឡាយ ចន្នី, ហាក់ យូ, យូ ប៉ោនី, ឈុន ប៊ុនឡុង, ង៉ែត សុភា, ណុំ សោភារិទ្ធិ, ម៉ក់ សិទ្ធិរិទ្ធ, យង់ ភក្រ្ត

# តារាងពាក្យកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី ( Asian Development Bank ) |
| AF | មូលនិធិការបន្សាំ ( Adaptation Fund ) |
| AP | ការរៀបចំផែនការបន្សាំ ( Adaptation Planning ) |
| AWG | ក្រុមការងារការបន្សាំ ( Adaptation Working Group ) |
| CAM | វិធីសាស្ត្រការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ( Climate change adaptation and mitigation methodology ( ICEM ) |
| CARD | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ( Council for Agricultural and Rural Development ) |
| CC | ការប្រែប្រួលអាកាសធាតុ ( Climate Change ) |
| CCAP | ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ ( Climate Change Action Plan by sector ) |
| CCCA | កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ( Cambodia Climate Change Alliance ) |
| CCCSP | ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ( Cambodia's Climate Change Strategic Plan ) |
| DCC | នាយកដ្ឋានប្រែប្រួលអាកាសធាតុ ( Department of Climate Change ) |
| CCTT | ក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ ( Climate Change Technical Committee ) |
| CCWG | ក្រុមការងារប្រែប្រួលអាកាសធាតុ ( Climate Change Working Group ) |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ( Council for Development of Cambodia ) |
| CIF | មូលនិធិវិនិយោគអាកាសធាតុ ( Climate Investment Funds ) |
| CSO | អង្គការសង្គមស៊ីវិល ( Civil Society Organization ) |
| CSIRO | អង្គការស្រាវជ្រាវឧស្សាហកម្ម និងវិទ្យាសាស្ត្រចក្រភពអង់គ្លេស ( Commonwealth Scientific and Industrial Research Organisation ) |
| DANIDA | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក ( Danish International Development Agency ) |
| DMF | ក្របខណ្ឌបង្កើតគម្រោង និងការពិនិត្យតាមដាន ( Design and Monitoring Framework ) |
| DRR | ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ( Disaster Risk Reduction ) |
| GCCA | សម្ព័ន្ធភាពការប្រែប្រួលអាកាសធាតុសកល ( Global Climate Change Alliance ) |
| GCF | មូលនិធិអាកាសធាតុបៃតង ( Green Climate Fund ) |
| GEF | មូលនិធិបរិស្ថានពិភពលោក ( Global Environment Facility ) |
| GIS | ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ( Geographic Information System ) |
| GMS | មហាអនុតំបន់ទន្លេមេគង្គ ( Greater Mekong Sub-region ) |
| ICEM | មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការគ្រប់គ្រងបរិស្ថាន ( International Centre for Environmental Management ) |
| I/NGO | អង្គការអន្តរជាតិមិនមែនរដ្ឋាភិបាល ( International Non-Government Organization ) |
| ITC | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ( Institute of Technology of Cambodia ) |

| | |
|---|---|
| IUCN | អង្គការសហភាពអន្តរជាតិសម្រាប់ការអភិរក្សធម្មជាតិ (International Union for Conservation of Nature) |
| KMIS | ប្រព័ន្ធគ្រប់គ្រងចំណេះដឹង និងព័ត៌មាន (Knowledge Management and Information System) |
| M & E | ការពិនិត្យតាមដាន និងវាយតម្លៃ (Monitoring and Evaluation) |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (Ministry of Agriculture, Forestry and Fisheries) |
| MCRDP | ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ (Mainstreaming Climate Resilience into Development Planning) |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (Ministry of Economy and Finance) |
| MOE | ក្រសួងបរិស្ថាន (Ministry of Environment) |
| MOEYS | ក្រសួងអប់រំ យុវជន និងកីឡា (Ministry of Education, Youth and Sports) |
| MOH | ក្រសួងសុខាភិបាល (Ministry of Health) |
| MOI | ក្រសួងមហាផ្ទៃ (Ministry of Interior) |
| MOP | ក្រសួងផែនការ (Ministry of Planning) |
| MOWA | ក្រសួងកិច្ចការនារី (Ministry of Woman Affairs) |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម (Ministry of Water Resources and Meteorology) |
| MPWT | ក្រសួងសាធារណការ និងដឹកជញ្ជូន (Ministry of Public Works and Transport) |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ (Ministry of Rural Development) |
| NAP | ផែនការជាតិការបន្សាំ (National Adaptation Plan) |
| NAPA | កម្មវិធីសកម្មភាពជាតិបន្សុាំនឹងការប្រែប្រួលអាកាសធាតុ (National Adaptation Program of Action) |
| NCCC | គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (National Committee on Climate Change) |
| NCCNC | បណ្តាញជាតិប្រែប្រួលអាកាសធាតុកម្ពុជា (National Climate Change Network Cambodia) |
| NCDD | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (National Council for sub-national Democratic Development) |
| NCDM | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (National Committee for Disaster Management) |
| NCGG | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង (National Council on Green Growth) |
| NCSD | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (National Council for Sustainable Development) |

| | |
|---|---|
| NGO | អង្គការមិនមែនរដ្ឋាភិបាល ( Non-Government Organization ) |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ( National Strategic Development Plan ) |
| PD | ប្រធានដឹកនាំគម្រោង ( Program Director ) |
| PM | ប្រធានគ្រប់គ្រងគម្រោង ( Program Manager ) |
| PPCR | កម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ ( Pilot Program for Climate Resilience ) |
| RGC | រាជរដ្ឋាភិបាលកម្ពុជា ( Royal Government of Cambodia ) |
| RUA | សាកលវិទ្យាល័យភូមិន្ទកសិកម្ម ( Royal University of Agriculture ) |
| RUPP | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ( Royal University of Phnom Penh ) |
| SAPA | អភិក្រមការរៀបចំផែនការការបន្សាំតាមវិស័យ ( Sector Adaptation Planning Approach ) |
| SCCSP | ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ ( Sectoral Climate Change Strategic Plan ) |
| SIDA | ភ្នាក់ងារស៊ុយអែតសម្រាប់ប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ ( Swedish International Development Cooperation Agency ) |
| SPCR | កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ ( Strategic Program for Climate Resilience ) |
| TA | ហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស ( Technical Assistance ) |
| TBC | នឹងត្រូវកំណត់នៅពេលក្រោយ ( To be confirmed ) |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ( United Nations Development Program ) |
| UNEP | កម្មវិធីបរិស្ថានសហប្រជាជាតិ ( United Nations Environment Program ) |
| UNFCCC | អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ( United Nations Framework Convention on Climate Change ) |
| UN-REDD | សហប្រជាជាតិ- ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ ( United Nations - Reducing Emissions from Deforestation and Forest Degradation ) |
| USAID | ភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ ( United States Agency for International Development ) |
| VA | ការវាយតម្លៃភាពងាយរងគ្រោះ ( Vulnerability Assessment ) |

# សេចក្តីសង្ខេប

## សេចក្តីផ្តើម

1. ធនាគារអភិវឌ្ឍន៍អាស៊ីបានចុះកិច្ចសន្យាសេវាកម្មជាមួយ ICEM - មជ្ឈមណ្ឌលអន្តរជាតិសម្រាប់គ្រប់គ្រងបរិស្ថាន និងដៃគូ ហ្វ្រេហ្សរ៍-ថូម៉ាស (Fraser-Thomas) ដើម្បីផ្តល់ជំនួយបច្ចេកទេស (TA) ដល់នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព(NCSD) ក្រសួងបរិស្ថាន(MOE) តាមរយៈការអនុវត្តគម្រោងដែលមានឈ្មោះថា "*ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ (TA 8179-CAM) កញ្ចប់ ១*"។ ជំនួយបច្ចេកទេសនេះ គាំទ្រដល់ NCSD និង MOE ដើម្បីអនុវត្តកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ(SPCR) នៃរាជរដ្ឋាភិបាលកម្ពុជា(RGC)។ របាយការណ៍នេះផ្តល់ជាផែនការពិស្តារមួយសម្រាប់ការអនុវត្តគម្រោងនេះប្រកបដោយជោគជ័យ រហូតដល់កាលបរិច្ឆេទនៃការគ្រោងបញ្ចប់នៅខែមេសា ឆ្នាំ២០១៩។
2. សមិទ្ធផលនៃ TA នេះត្រូវបានរំពឹងថា បង្កើនភាពធន់នឹងភាពងាយរងគ្រោះនៃអាកាសធាតុ និងការប្រែប្រួលអាកាសធាតុ ដែលនឹងនាំឱ្យមានការកែលម្អជីវភាពរស់នៅ ជាពិសេសសម្រាប់ក្រុមប្រជាជនងាយរងគ្រោះ ដូចជា ស្ត្រី និងកុមារ ។ លទ្ធផលរំពឹងទុកនៃ TA នេះគឺ ការពង្រឹងសមត្ថភាពស្ថាប័ន និងបច្ចេកទេស ដើម្បីរួមបញ្ចូលរាល់កង្វល់នៃការប្រែប្រួលអាកាសធាតុដើម្បីបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ ។ កញ្ចប់ទី១នៃTAនេះ មានធាតុចេញចំនួនបី ដែលធាតុចេញនីមួយៗផ្សំដោយសកម្មភាពមួយចំនួន។
3. **លទ្ធផលទី ១ - ពង្រឹងការសម្របសម្រួល SPCR, ការគាំទ្របច្ចេកទេស និងសមត្ថភាព ដើម្បីបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍។** លទ្ធផលទី១ ផ្តោតលើការពង្រឹងការងារសម្របសម្រួលកម្មវិធី SPCR ជាមួយក្រសួងសំខាន់ៗដែលជាគោលដៅ និងកសាងសមត្ថភាព អ្នកកសាងគោលនយោបាយនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត បុគ្គលិកបច្ចេកទេស និងអង្គការសង្គមស៊ីវិល (CSOs) លើភាពធន់នឹងអាកាសធាតុសម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍។
4. ក្រសួងគោលដៅសំខាន់ៗសម្រាប់ SPCR គឺក្រសួង ស្ថាប័ននានាដែលធ្វើការក្នុងវិស័យកសិកម្ម ធនធានទឹក និង ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងការអភិវឌ្ឍក្រុង ពោលគឺ ក្រសួងធនធានទឹក និងឧតុនិយម (MoWRAM), ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ក្រសួងសាធារណការ និងដឹកជញ្ជូន (MWPT) និងក្រសួងអភិវឌ្ឍន៍ជនបទ (MRD)។ គម្រោងនេះនឹងផ្តោតផងដែរលើក្រសួង ស្ថាប័នដទៃទៀត ដែលមានតំណាងនៅក្នុងក្រុមការងារសម្របសម្រួលក្នុងកម្មវិធី SPCR រួមមាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ក្រសួងផែនការ (MOP) ក្រសួងកិច្ចការនារី (MOWA)

ក្រសួងមហាផ្ទៃ (MOI) ជាពិសេស គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD) និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM)។

5. **លទ្ធផលទី ២ - ធ្វើការសិក្សាលម្អិតពីលទ្ធភាពរៀបចំគម្រោងបន្សុាំ NAPA មួយចំនួន និងការរៀបចំផែនការជាតិបន្សុាំនឹងការប្រែប្រួលអាកាសធាតុ (NAP) ។** លទ្ធផលទី២នេះ នឹងមានលទ្ធផលនៃការសិក្សាពីលទ្ធភាពសម្រាប់រៀបចំគម្រោងបន្សុាំយ៉ាងហោចណាស់ចំនួនពីរ ដែលនឹងត្រូវរៀបចំជាសំណើស្វែងរកថវិកាពីមូលនិធិបន្សុាំពិភពលោក។ នៅក្រោមលទ្ធផលនេះ RGC នឹងបានទទួលការគាំទ្រ ក្នុងការរៀបចំផែនការជាតិបន្សុាំនឹងការប្រែប្រួលអាកាសធាតុ (NAP) របស់កម្ពុជា ដែលជាផ្នែកមួយនៃដំណើរការ UNFCCC NAP សម្រាប់កំណត់នូវតម្រូវការ និងយុទ្ធសាស្ត្របន្សុាំរយៈពេលមធ្យម និងរយៈពេលវែង។

6. **លទ្ធផលទី ៤ - រៀបចំផលិតឯកសារចំណេះដឹងពីការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ និងផ្សព្វផ្សាយ។** លទ្ធផលទី៤ នឹងប្រើប្រាស់សកម្មភាពនានាពីលទ្ធផលទី១ និង២ ក៏ដូចជា ពីប្រភពដទៃទៀតផងដែរ ដើម្បីបង្កើតផលិតផលចំណេះដឹង និងផ្សព្វផ្សាយព័ត៌មានអំពីវិធីសាស្ត្រនានា និងលទ្ធផលនៃគម្រោងនេះ។

7. TA នេះក៏នឹងមានលទ្ធផលមួយផ្សេងទៀតផងដែរ ដែលកំពុងអនុវត្តដោយអង្គការភ្លែនអន្តរជាតិ(Plan International) នៅក្រោមកញ្ចប់ទី២ នៃTAនេះ ជាលទ្ធផល *៣ - ពង្រឹងយន្តការគាំទ្រសង្គមស៊ីវិល និងសមត្ថភាពរបស់ NGOs និង CSOs ដើម្បីបញ្ជ្រាបការបន្សុាំនឹងប្រែប្រួលអាកាសធាតុ (CCA) និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR) ទៅក្នុងប្រតិបត្តិការរបស់ខ្លួន។* ចំណែកកញ្ចប់សកម្មភាពបន្ថែមមួយទៀត(កញ្ចប់ទី៣)ស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ការតាមដាន និងវាយតម្លៃ និងការបញ្ជ្រាបនៅថ្នាក់ក្រោមជាតិ កំពុងស្ថិតក្នុងការរៀបចំ ដែលជាផ្នែកមួយនៃកម្មវិធី SPCR នឹងត្រូវអនុវត្តស្របជាមួយកញ្ចប់ទី១ និង ២ ផងដែរ។

8. សេចក្តីសង្ខេបនេះចែកជាបួនផ្នែក ដែលអធិប្បាយអំពី (i) បរិបទទាក់ទងនឹងស្ថាប័ន និងប្រធានបទនៃគម្រោង (ii) វិធីសាស្ត្រ និងគោលការណ៍របស់ក្រុមអ្នកអនុវត្តគម្រោង (iii) ផែនការអនុវត្តពិស្តារសម្រាប់សកម្មភាពនីមួយៗរបស់គម្រោង (iv) អនុសាសន៍សម្រាប់ការអនុវត្តគម្រោង ដោយជោគជ័យ សម្រាប់ការពិចារណា និងការគាំទ្រដោយ ADB ក្រសួងបរិស្ថាន និងដៃគូផ្សេងទៀតរបស់រដ្ឋាភិបាល។

## បរិបទគម្រោង

### កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ

9. ជំនួយបច្ចេកទេស (TA8179-CAM កញ្ចប់ទី១) គឺជាផ្នែកមួយនៃសមាសភាគ ៤ របស់កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុនៅកម្ពុជា (SPCR) នៅក្រោមកម្មវិធីសាកល្បងសម្រាប់ភាព

ធន់នឹងអាកាសធាតុ (PPCR) នៃមូលនិធិវិនិយោគអាកាសធាតុ។ គម្រោងនេះនឹងរៀបចំជាមេរៀនបទពិសោធន៍នានាដែលទទួលបាននៅក្នុងដំណាក់កាលទីមួយនៃ PPCR នៅកម្ពុជា ដែលបានអនុវត្តនៅរវាងឆ្នាំ ២០១០ និង ២០១២។

10. បន្ថែមលើជំនួយបច្ចេកទេសនេះដែលផ្តល់នៅក្រោម TA8179 កម្មវិធីSPCR រួមបញ្ចូលគម្រោងវិនិយោគមួយចំនួនដែលនឹងមានសកម្មភាពជាក់លាក់នៅក្រោមគម្រោង ដើម្បីពង្រឹងភាពធន់នឹងអាកាសធាតុ។ ទឹកប្រាក់វិភាជន៍ ការគាំទ្រដល់ PPCR សរុបនៅកម្ពុជា មានប្រមាណ ៩៦លានដុល្លារសហរដ្ឋអាមេរិក (៦០លានដុល្លារជាជំនួយហិរញ្ញប្បទានឥតសំណង ៣៦លានដុល្លារហិរញ្ញប្បទានជាឥណទាន និង៥លានដុល្លារដែលកំពុងត្រូវស្វែងរកបន្ថែម)។ គម្រោងវិនិយោគនៅក្រោម SPCR គ្រោងចំណាយសរុប ៥៥៤,៣១លានដុល្លារ ដែលមកទល់ពេលនេះបានកៀរគរទឹកប្រាក់បន្ថែមចំនួន ៤៦៣,៣១លានដុល្លារ ដែលរួមទាំង ៥៣លានដុល្លារពីរដ្ឋាភិបាលផងដែរ)។

## ការប្រែប្រួលអាកាធាតុនៅកម្ពុជា

11. SPCR ឆ្លើយតបនឹងតម្រូវការឱ្យមានសកម្មភាព ដើម្បីកសាងសមត្ថភាពរបស់ RGC និងសមត្ថភាពកាន់ នៅកម្ពុជា ដើម្បីដោះស្រាយការគំរាមកំហែងនៅក្រោមលក្ខខណ្ឌប្រែប្រួលអាកាធាតុ។ ដើម្បីស្វែងយល់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុពីអតីតកាល និងអនាគតមកលើកម្ពុជា ការសិក្សាសំខាន់ៗជាបន្តបន្ទាប់ក៏បានធ្វើរួចមកហើយដែរ។ ការសិក្សាទាំងនេះរួមបញ្ចូល ការបង្រួមមាត្រដ្ឋានពីថ្នាក់តំបន់ និងការវាយតម្លៃភាពងាយរងគ្រោះ និងការវាយតម្លៃមួយចំនួននៅថ្នាក់ជាតិ និងថ្នាក់ខេត្តក្នុងប្រទេសកម្ពុជា ដោយបានស្រង់ព័ត៌មានចេញពីនិទស្សន៍នៅថ្នាក់តំបន់ និងបានកែសម្រួល និងបកស្រាយទិន្នន័យទាំងនេះធៀបនឹងស្ថានភាពជាប្រវត្តិសាស្ត្រកន្លងមកនៅក្នុងមូលដ្ឋាន។ ការសិក្សាទាំងនេះផ្តល់លទ្ធផលដូចគ្នា និងបង្ហាញថាកម្ពុជាគឺជាចំណុចក្តៅនៃការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់នេះ។

12. មេរៀនចំបងៗពីការវាយតម្លៃទាំងនេះគឺថា ១) ការធ្វើម៉ូដែល និងនិទស្សន៍អំពីការប្រែប្រួលអាកាសធាតុកំពុងតែបានកែលម្អជាបន្តបន្ទាប់។ ២) ប្រការសំខាន់ដែលត្រូវពិចារណានៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ គឺនិន្នាការ និងរបត់នៃការប្រែប្រួល ប៉ុន្តែមិនត្រឹមតែនិទស្សន៍ជាក់លាក់នោះទេ និង ៣)ការសិក្សាភាគច្រើនមកទល់បច្ចុប្បន្ននេះ ពុំបានផ្តល់ទិន្នន័យដែលងាយស្រួលសម្រាប់អ្នកប្រើប្រាស់ផ្ទាល់នៅឡើយទេ ដូចជាស្ថាប័នហេដ្ឋារចនាសម្ព័ន្ធ និងអភិវឌ្ឍន៍ ដែលត្រូវរួមបញ្ចូលការប្រែប្រួលអាកាសធាតុនៅក្នុងការរៀបចំប្លង់បទដ្ឋានសាងសង់ និងការគ្រប់គ្រងការវិនិយោគនានារបស់ពួកគេ។ របកគំហើញពាក់ព័ន្ធមួយផ្សេងទៀត ពីការវាយតម្លៃកន្លងមក អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅកម្ពុជាគឺថាការវាយតម្លៃទាំងនេះ មិនសុទ្ធតែត្រូវបានយកមកប្រើប្រាស់ភ្លាមៗទៅតាមតម្រូវការជាក់

លាក់នៅតាមទីតាំងនានាពីសំណាក់ក្រុមវិស្វករសាងសង់ផ្លូវថ្នល់ឬស្ពាននោះឡើយ។ ដើម្បីផ្តល់ព័ត៌មានបានសមស្របដល់ការរៀបចំប្លង់ និងការអនុវត្តគម្រោង អ្នកអនុវត្តតម្រូវឱ្យមានការវាយតម្លៃដែលផ្តោតចំគោលដៅនៅតាមទីតាំងជាក់លាក់នានាឱ្យបានកាន់តែច្រើនថែមទៀត។ ការធ្វើម៉ូដែលជលសាស្រ្តមានសារៈសំខាន់ជាពិសេស ដើម្បីអាចឱ្យវិស្វករមើលឃើញថា តើការប្រែប្រួលអាកាសធាតុដូចដែលបានធ្វើនិទស្សន៍កន្លងមក មានតួនាទីបែបណានៅតាមទីតាំងដែលជាចំណាប់អារម្មណ៍របស់ពួកគេ ។

13. គម្រោងនេះនឹងផ្តល់ឱកាសដើម្បីដោះស្រាយបេកគំហើញ ដោយធ្វើការតាមរយៈគម្រោងវិនិយោគ SPCR និងគម្រោងបន្ស៊ាំថ្មីៗ ដើម្បីកំណត់តម្រូវការជាក់លាក់ខាងព័ត៌មានអំពីការប្រែប្រួលអាកាសធាតុនៅក្នុងការរៀបចំប្លង់នៃហេដ្ឋារចនាសម្ព័ន្ធ និងក្នុងការអនុវត្ត។ ក្រុមអ្នកអនុវត្តគម្រោងនេះក៏លើកស្នើឱ្យមានការពង្រីកវិសាលភាពគ្របដណ្តប់នៃTAនេះ ដើម្បីរួមបញ្ចូលការរៀបចំឧបករណ៍គាំទ្រការធ្វើសេចក្តីសម្រេចចិត្តអំពីការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិផងដែរ ដោយផ្អែកលើប្រព័ន្ធ GIS និងពឹងផ្អែកលើឧបករណ៍ដែលក្រសួងMoWRAM បានបង្កើតឡើងនៅពេលថ្មីៗនេះ។ សកម្មភាពថ្មីនេះរួមមានការធ្វើបច្ចុប្បន្នភាពឧបករណ៍របស់ក្រសួងMoWRAM ដោយប្រើប្រាស់ទិន្នន័យថ្មីៗបំផុតដើម្បីបង្រួមមាត្រដ្ឋាននៅថ្នាក់តំបន់ពីCSIRO ដែលនឹងក្លាយជាផលិតផលស្នូលសម្រាប់រយៈពេលវែងផ្សាភ្ជាប់គម្រោងនេះ។

## ការរៀបចំស្ថាប័នសម្រាប់ដោះស្រាយការប្រែប្រួលអាកាសធាតុនៅកម្ពុជា

14. បន្ថែមនេះទៀត ដើម្បីស្វែងយល់ឱ្យបានច្បាស់លាស់អំពីផលប៉ះពាល់សក្តានុពលពីការប្រែប្រួលអាកាសធាតុ ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុប្រកបដោយជោគជ័យ ពាក់ព័ន្ធជាមួយសកម្មភាពនៅក្នុង និងរវាងអភិបាលកិច្ចតាមរបៀបខុសៗគ្នា ស្ថាប័ននយោបាយ បច្ចេកទេស និងវប្បធម៌។ នៅក្នុងពេលធ្វើសេចក្តីរាយការណ៍ រចនាសម្ព័ន្ធស្ថាប័នរបស់ RGC សម្រាប់ដោះស្រាយការប្រែប្រួលអាកាសធាតុកំពុងស្ថិតក្នុងការចាត់ចែងឡើងវិញ។ អង្គភាពចំបងៗចំនួនពីរដែលមានភារកិច្ចសម្របសម្រួលទិសដៅជាយុទ្ធសាស្រ្ត និងសកម្មភាពប្រែប្រួលអាកាសធាតុគឺ (i) គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និង(ii) ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង កំពុងស្ថិតក្នុងដំណើរការនៃការកែសម្រួល ដោយនឹងត្រូវជំនួសដោយក្រុមប្រឹក្សាអភិវឌ្ឍន៍ដោយចីរភាព (NCSD)។

15. ការបង្កើត NCSD នឹងមានតួនាទីសំខាន់នៃរចនាសម្ព័ន្ធស្ថាប័នរបស់ក្រសួងបរិស្ថាន និងការរៀបចំស្ថាប័នសម្រាប់ TAនេះ។ ប្រការសំខាន់បំផុតគឺ ដៃគូសំខាន់ៗនៃក្រុមអ្នកអនុវត្តគម្រោងនៅក្នុងនាយកដ្ឋានប្រែប្រួលអាកាសធាតុ ឥឡូវនេះកំពុងធ្វើការដោយផ្ទាល់នៅក្រោមលេខាធិការដ្ឋាន NCSD។

16. ក្នុងក្របខ័ណ្ឌរដ្ឋាភិបាលទាំងមូល នៅពេលថ្មីៗនេះ កម្ពុជាបានអនុម័តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP)។ នៅថ្នាក់មូលដ្ឋាន ក្រសួងស្ថាប័នពាក់ព័ន្ធមួយចំនួនដែលរួមទាំង MAFF MoWRAM MRD MPWT NCDM និង NCDD បានរៀបចំផែនការសកម្មភាពប្រែប្រួលអាកាសធាតុតាមវិស័យ និងបានបង្កើតក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ (TWG-CC) ដើម្បីគាំទ្រដល់ការអនុវត្តរបស់ខ្លួន។ ផែនការ CCCSP គឺជាក្របខ័ណ្ឌដ៏សំខាន់មួយសម្រាប់រដ្ឋាភិបាលទាំងមូលនៅក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ និងត្រូវបានរៀបចំឡើងជាក្របខ័ណ្ឌយុទ្ធសាស្ត្រចម្រុះមួយ ដែលស៊ីសង្វាក់គ្នាជាមួយគោលនយោបាយ និងផែនការនានាផ្សេងទៀតផងដែរ ដូចជា NAPA ផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ (SNAP) សម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR) គោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍បៃតង និងផែនការអភិវឌ្ឍន៍តាមវិស័យ។

17. ជាតុផ្សំដ៏សំខាន់មួយនៃវិធីសាស្ត្ររបស់ក្រុម TA គឺត្រូវធ្វើការជាមួយ MoE NCSD និងស្ថាប័នតាមវិស័យនានាដើម្បីពង្រឹងកិច្ចប្រឹងប្រែងអនុវត្ត CCCSP។ គោលបំណងជាយុទ្ធសាស្ត្រមួយចំនួននៅក្រោម CCCSP ក៏ត្រូវបានបន្សីុគ្នាជិតស្និទ្ធជាមួយគោលបំណង និងសកម្មភាព TA8179 ក្នុងកញ្ចប់ ១ ផងដែរ។ សកម្មភាពនៅក្នុងកញ្ចប់ ១ នឹងរួមចំណែកទៅក្នុងផែនការសកម្មភាពរយៈពេលមធ្យមនៃ CCCSP សម្រាប់ឆ្នាំ ២០១៤-២០១៨ផងដែរ ជាពិសេស ទាក់ទងនឹងសកម្មភាពនានាដើម្បីអភិវឌ្ឍន៍សមត្ថភាព ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុតាមវិស័យ ដោយផ្អែកលើ SCCSPs កំណត់កាលានុវត្តភាពដើម្បីផ្តល់ហិរញ្ញវត្ថុបន្ថែមទៀតសម្រាប់សកម្មភាពបន្សុាំ និងការអនុវត្តក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ការបន្សុាំ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

## វិធីសាស្ត្រ និងអភិក្រម

### ការផ្តោតលើហេដ្ឋារចនាសម្ព័ន្ធបៃតង

18. កម្មវិធី SPCR កំណត់វិស័យគន្លឹះចំនួនបី៖ ១) ធនធានទឹកដែលធន់នឹងអាកាសធាតុ ២) កសិកម្មដែលធន់នឹងអាកាសធាតុ និង ៣)ហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ ជាពិសេស រចនាសម្ព័ន្ធដឹកជញ្ជូន(ផ្លូវថ្នល់) និងហេដ្ឋារចនាសម្ព័ន្ធក្រុង។ កិច្ចប្រឹងប្រែងជារួមរបស់គម្រោង គឺសំដៅលើការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការគម្រោងប្លង់ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងវិស័យទាំងនេះ។ សមាសភាពសំខាន់ៗ នៃការអភិវឌ្ឍដទៃទៀតមានដូចជា៖ បច្ចេកទេសនៃការដាំដុះដំណាំ វិធានការអភិរក្សទឹក និងការគ្រប់គ្រងទីជម្រាល នឹងត្រូវដោះស្រាយ ដែលជាផ្នែកនៃវិធីសាស្ត្រចម្រុះ និងពហុបំណងនៃការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ។

19. ប្រធានបទពាក់ព័ន្ធនឹងគម្រោង គឺចាំបាច់ត្រូវយល់ដឹងប្រព័ន្ធធម្មជាតិ ថាជាមូលដ្ឋានគ្រឹះសំខាន់មួយសម្រាប់ការអភិវឌ្ឍ និងលើកកំពស់ និងដើម្បីស្តារធម្មជាតិឡើងវិញ ដែលជាយុទ្ធសាស្ត្រគន្លឹះមួយសម្រាប់បង្កើតនិរន្តរភាព និងភាពធន់នៅកម្ពុជា។ ភាពចាំបាច់ទាំងពីរនោះ - ភាពធន់ និងនិរន្តរភាព - មានការផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធ។ ដំណោះស្រាយចំពោះភាពចាំបាច់មួយ នឹងអាចឆ្លើយតបចំពោះភាពចាំបាច់នៃលក្ខខណ្ឌមួយទៀតផងដែរ។

20. គម្រោងនេះនឹងរកឱកាសដើម្បីជម្រុញហេដ្ឋារចនាសម្ព័ន្ធបៃតងដែលផ្សាភ្ជាប់ ដ៏សំខាន់មួយនៅក្នុងដំណោះស្រាយចំពោះការប្រែប្រួលអាកាសធាតុ ដោយផ្អែកលើកត្តាធម្មជាតិ។ ហេដ្ឋារចនាសម្ព័ន្ធបៃតង គឺមួយចំនួនដែលមានសារៈសំខាន់ជាសារវន្ត និងនៅក្នុងដំណោះស្រាយខ្លះៗ និងជាវិធីសាស្ត្រជំនួសហេដ្ឋារចនាសម្ព័ន្ធធម្មតាដែលធ្លាប់ធ្វើអនុវត្តពីមុន។ ហេដ្ឋារចនាសម្ព័ន្ធបៃតង សំដៅលើបណ្តាញលំហបៃតង ដែលបានធ្វើផែនការ និងបានគ្រប់គ្រងជាយុទ្ធ សាស្ត្រ និងលក្ខណៈបរិស្ថានជុំវិញផ្សេងៗទៀត និងបច្ចេកវិទ្យាចាំបាច់សម្រាប់និរន្តរភាពនៃប្រព័ន្ធ និងវិស័យ ហេដ្ឋារចនាសម្ព័ន្ធ។ ហេដ្ឋារចនាសម្ព័ន្ធបៃតង ប្រើប្រាស់រុក្ខជាតិ ដី ដំណើរការធម្មជាតិ និងបច្ចេកវិទ្យាទំនើបៗ ដើម្បីគ្រប់គ្រងទឹក ដី សីតុណ្ហភាព និងគុណភាពខ្យល់ សម្រាប់បង្កើតបរិស្ថានដែលមានសុខភាពល្អ និងធន់នឹងបរិស្ថាន ជុំវិញ។

## ការផ្តោតលើភូមិសាស្ត្រ

21. ទំនើបកម្មថ្មីៗ គម្រោងនេះ នឹងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍របស់ខ្លួនក្នុងការអនុវត្តការបង្ហាញ ការបណ្តុះបណ្តាល និងការសិក្សាដោយផ្ទាល់នៅទីតាំងជាក់ស្តែង។ ការងារនៅមូលដ្ឋានរួមមាន៖ ការវាយតម្លៃភាពងាយរងគ្រោះ និងការសាងគម្រោងបន្សាំ ការពិនិត្យឡើងវិញ និងរៀនពីបទពិសោធន៍គម្រោងនៃកម្មវិធី SPCR និងស្វែងយល់ពី និងការណែនាំនានាដែលចាំបាច់សម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុ។ ដើម្បីសម្រេច បាននូវបទបង្ហាញ និងការសិក្សារៀនសូត្រនៅក្នុងក្របខ័ណ្ឌធនធានគម្រោងនេះ ក្រុមការងារ នឹងធ្វើការពន្យល់ឱ្យ បានច្បាស់លាស់ និងកែតម្រូវផ្តោតលើទីតាំងភូមិសាស្ត្រ។

22. នៅក្នុងដំណាក់កាលចាប់ផ្តើមគម្រោងនេះ ដំណើរការពិគ្រោះយោបល់ប្រកបដោយតម្លាភាពមួយ ត្រូវបានអនុវត្តជាបន្តបន្ទាប់ ដើម្បីកំណត់បណ្តាខេត្តដែលសមស្របបំផុត សម្រាប់ជ្រើសធ្វើជាគោលដៅសម្រាប់សកម្មភាពរបស់គម្រោងនៅមូលដ្ឋាន។ ដំណើរការនេះពាក់ព័ន្ធជាមួយការពិគ្រោះយោបល់ជាបន្តបន្ទាប់ជាមួយដៃគូគម្រោង និងត្រូវបានរៀបចំឡើងដើម្បីឱ្យមានការមូលមតិគ្នាក្នុងចំណោមក្រសួងសំខាន់ៗ ដោយផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រមួយរឹងមាំ ។ ដំណើរការជ្រើសរើស និងលក្ខណៈវិនិច្ឆ័យត្រូវបានកំណត់ដោយផ្អែកលើកត្តានានារួមមាន៖ តំបន់អេកូឡូស៊ី (សណ្ឋានដី) ភាពងាយរងគ្រោះ និងវត្តមាននៃសកម្មភាពគម្រោងនៃកម្មវិធី SPCRដែលមានស្រាប់។ ខេត្តចំនួនប្រាំមួយ ត្រូវបាន

កំណត់នៅក្នុងដំណាក់កាលដំបូងនេះគឺៈ បាត់ដំបង ពោធិសាត់ កោះកុង កំពង់ចាម ព្រៃវែង និងខេត្ត មណ្ឌលគិរី។




**រូបទី ES-1 ខេត្តចំនួនប្រាំមួយ សម្រាប់សកម្មភាពការងារនៅមូលដ្ឋាន**

**វិធីសាស្ត្រកសាងសមត្ថភាព**

23. ការកសាងសមត្ថភាពគឺជាវិធីសាស្ត្រចំបងសម្រាប់បញ្ជ្រាបភាពធន់នឹងអាកាសធាតុនៅក្នុងក្រសួងគោលដៅនានា។ ដើម្បីស្វែងយល់អំពីសមត្ថភាពដែលមានស្រាប់ និងតម្រូវការសមត្ថភាព សម្រាប់ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ ក្រុមការងារគម្រោង បានប្រើប្រាស់ប្រព័ន្ធវិភាគ 7S ដែលយកចិត្តទុកដាក់សមាសភាពសំខាន់ៗបន្តបន្ទាប់នៃ សមត្ថភាពស្ថាប័ន ដូចជាៈ យុទ្ធសាស្ត្រ រចនាសម្ព័ន្ធ ប្រព័ន្ធរបៀបរបបការងារ បុគ្គលិក ជំនាញ និងការគាំទ្រ។

24. ការវិភាគ 7S មានគោលបំណងច្រើន។ តាមរយៈវិធីនេះ នឹងបង្ហាញភាពខ្លាំង និងភាពខ្សោយនៅក្នុងសមាសភាពនៃសមត្ថភាពស្ថាប័ន នឹងត្រូវបានកំណត់ នឹបញ្ជាក់ពីសកម្មភាពជាក់លាក់អាចត្រូវបានបង្កើតឡើងសម្រាប់ក្រសួងដែលមាន SCCSPស្រាប់ ក្នុងការពង្រឹងភាពធន់នឹងអាកាសធាតុបន្ថែមទៀត។ ការវិភាគនេះក៏ជាវិធានការគោលមួយ ដែលអាចយកទៅប្រើប្រាស់ដើម្បីតាមដានវឌ្ឍនភាពនៃការកសាងសមត្ថភាពនៅក្នុងរយៈពេលអនុវត្តគម្រោង ព្រមទាំងស្នើឱ្យមានការកែសម្រួលដែលអាចធ្វើ

ឡើងជាប្រចាំផងដែរ។ ទីបញ្ចប់ វិធីសាស្ត្រដែលក្រុមគម្រោងយកមកប្រើប្រាស់នេះ ផ្អែកលើលក្ខខណ្ឌជាតម្រូវការសម្រាប់តាមដាន ត្រួតពិនិត្យ និងធ្វើរបាយការណ៍ CIF មានន័យថា វិធីសាស្ត្រនេះនឹងរួមចំណែកដោយផ្ទាល់សម្រាប់បំពេញលក្ខខណ្ឌរាយការណ៍ជាប្រចាំរបស់ RGC ទៅ CIF។

25. ជាផ្នែកមួយនៃដំណាក់កាលចាប់ផ្តើម ក្រុមអ្នកអនុវត្តគម្រោងបានប្រើប្រាស់7Sសម្រាប់ធ្វើការវាយតម្លៃពិស្តារអំពីតម្រូវការកសាងសមត្ថភាព។ របាយការណ៍ CBNA ដែលបានដាក់បញ្ចូលជាឧបសម្ព័ន្ធនៅក្នុងរបាយការណ៍នេះ ផ្តល់សេចក្តីពិស្តារអំពីរបៀបវាយតម្លៃសមត្ថភាពរបស់ក្រសួងសំខាន់ៗ និងការកំណត់សកម្មភាពដែលមានសក្តានុពលដើម្បីបង្កើតជាមូលដ្ឋានគ្រឹះនៃផែនការកសាងសមត្ថភាពដែលនឹងត្រូវអនុវត្តក្រោមការគាំទ្រពីក្រុមអ្នកអនុវត្តគម្រោង។ រូបខាងក្រោមបង្ហាញពីតួលេខមធ្យមនៃលក្ខខណ្ឌគោល ដែលធ្វើឡើងនៅក្នុងដំណាក់កាលចាប់ផ្តើមនៃគម្រោងនេះ។




រូបទី ES-2 ការវាយតម្លៃកម្រិតមធ្យមនៃតម្រូវការសមត្ថភាពនៅក្នុងក្រសួងសំខាន់ៗ ដោយប្រើប្រាស់វិធី 7S

**ការចូលរួមជាមួយគម្រោងនានានៅក្រោម SPCR និងការវាយតម្លៃចម្រុះ**

26. គម្រោងវិនិយោគទាំង ៧ នៅក្រោម SPCR និងការសិក្សាលទ្ធភាពនៃគម្រោងបន្សាំនិងសំណើផ្សេងៗ នឹងផ្តល់ឱកាសពិសេសមួយដល់ក្រុមអ្នកអនុវត្តគម្រោងដើម្បីសិក្សា និងអនុវត្តការងារកសាងសមត្ថភាពនៅមូលដ្ឋានជាមួយការវាយ តម្លៃភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ និងការរៀបចំផែនការបន្សុំ (VA&AP)។

27. គម្រោង SPCR កំពុងស្ថិតក្នុងដំណាក់កាលខុសៗគ្នានៃការអនុវត្ត និងបានបង្កើតវិធី និងដំណើរការ VA&AP រៀងៗខ្លួន។ ក្រុមអនុវត្តគម្រោង TA នឹងធ្វើការជាមួយគម្រោង SPCRនិមួយៗ និងប្រើប្រាស់វិធី និងដំណើរការទាំងនេះជាមូលដ្ឋានគ្រឹះសម្រាប់ការបណ្តុះបណ្តាល និងការងារអនុវត្តនៅមូលដ្ឋានដែលពាក់ព័ន្ធជាមួយក្រសួងនិងក្រុមSPCR។ ការសិក្សាលទ្ធភាពនិងសំណើគម្រោងបន្សាំ (គម្រោង NAPA និង NAP) ដែលត្រូវរៀបចំឡើង ជាមួយក្រសួងនានាជាដៃគូ នឹងផ្តល់ឱកាសបន្ថែមដើម្បីបង្ហាញអំពីរបៀបវាយតម្លៃភាពងាយរងគ្រោះ និងរបៀបអនុវត្តវិធានការបន្សាំ។ ការងារជាមួយគម្រោង SPCR និងការវាយតម្លៃភាពងាយរងគ្រោះ និងការរៀបចំផែនការបន្សាំ នឹងនាំទៅរកការកំណត់អត្តសញ្ញាណការអនុវត្តចាំបាច់នានាខាងគោលនយោបាយ នីតិវិធី និងប្រព័ន្ធការពារសុវត្ថិភាពនៅក្នុងស្ថាប័នពាក់ព័ន្ធនីមួយៗ។

28. នៅក្នុងសកម្មភាពអនុវត្តបង្ហាញទាំងនេះ ក្រុមអ្នកអនុវត្តគម្រោងនឹងប្រើប្រាស់វិធីសាស្ត្រវាយតម្លៃភាពងាយរងគ្រោះ និងបន្សាំរបស់ ICEM (CAM)។ វិធីនេះគឺជាដំណើរការមួយដែលមានភាពបត់បែនបាន និងសំណុំឧបករណ៍/វិធីសាស្ត្រដែលអាចយកទៅប្រើប្រាស់នៅក្នុងវិស័យនានា ទីកន្លែង និងសហគមន៍នានា រហូតដល់កម្រិតហេដ្ឋារចនាសម្ព័ន្ធជាក់លាក់នីមួយៗ។ វិធីសាស្ត្រនេះក៏អាចយកមកប្រើប្រាស់នៅក្នុងមាត្រដ្ឋានខុសៗគ្នានៃការវាយតម្លៃផងដែរ ដោយរាប់ចាប់ពីគម្រោងនៅតាមមូលដ្ឋាននានា រហូតដល់ទីប្រជុំជនកម្រិតទីក្រុង និងដល់ឯកត្តារៀបចំផែនការរូបវន្ត ដូចជា ទីជម្រាល និងខេត្តផងដែរ។ សម្រាប់សកម្មភាពអនុវត្តបង្ហាញ វិធីសាស្ត្រនេះនឹងត្រូវរួមបញ្ចូលជាមួយវិធីនានាដែលមានស្រាប់ដែលកំពុងប្រើប្រាស់នៅកម្ពុជា ដែលក្រុមការងារថ្នាក់ជាតិ និងអ្នកពាក់ព័ន្ធនានា បានរៀបចំឡើង និងកែសម្រួលឱ្យស្របតាមលក្ខខណ្ឌនៅមូលដ្ឋាន។ ការវាយតម្លៃចម្រុះ និងលំហាត់រៀបចំផែនការចំនួនប្រាំមួយ ដែលទាក់ទងនឹងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ និងដែលលើកស្នើថ្មី នឹងផ្តល់ជាមូលដ្ឋានសម្រាប់ការសិក្សាលទ្ធភាពនិងការរៀបចំសំណើគម្រោងបន្សាំ។

29. សកម្មភាពអនុវត្តបង្ហាញ និងមេរៀននានាដែលទទួលបានពីគម្រោង 7 SPCR នឹងផ្តល់ការណែនាំសម្រាប់ការកែសម្រួលគោលការណ៍ណែនាំតាមវិស័យ និងការបង្កើតស្តង់ដារ និងការកែប្រែដទៃទៀតដើម្បីបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការតាមវិស័យនិមួយៗ។

## ការបង្កើតក្រុមការងារបន្សាំ

30. ដើម្បីបង្កើតភាពជាដៃគូ និងការសម្របសម្រួលឱ្យមានប្រសិទ្ធភាព ជាមួយស្ថាប័នដែលចូលរួមមកពីវិស័យនីមួយៗ ក្រុមការងារគម្រោងនៅក្នុង MOE នឹងបង្កើតក្រុមការងារបន្សាំ (AWG) SPCR ដែលបានមកពីក្រុមការងារប្រែប្រួលអាកាសធាតុនៅក្នុងក្រសួងនីមួយៗ។ មន្ត្រីបច្ចេកទេសចំនួនបីនាក់មកពីក្រសួងសំខាន់នីមួយៗ នឹងបង្កើតជាក្រុមស្នូលនៃអ្នកជំនាញបច្ចេកទេសទាំងនេះ ដោយមានតំណាងម្នាក់មកពីក្រសួងផ្សេងទៀតនីមួយៗ ដែលសម្របសម្រួល SPCR ពោលគឺ MEF, MOP និង MOI។ សមាសភាពនៃក្រុមការងារបន្សាំ មានបង្ហាញជូន




រូបទី ES-3 ក្រុមការងារបច្ចេកទេសបន្សាំការប្រែប្រួលអាកាសធាតុ SPCR

ក្នុងរូបទី ES-3។

## ចំណេះដឹង និងការប្រាស្រ័យទាក់ទង

31. សកម្មភាពពីធាតុចេញទី១ និង ២ ដែលរួមទាំងការងារ បន្សាំ និងការរៀនសូត្រពីការងារ បន្សាំ នៅក្នុងគម្រោងវិនិយោគ SPCR និងការអនុវត្តបង្ហាញ អំពីការវាយតម្លៃ ភាពងាយរងគ្រោះ និងវិធីសាស្រ្តនៃការរៀបចំផែនការបន្សាំនៅក្នុង ការរៀបចំការសិក្សាសក្ខីកម្ម គម្រោងនឹងត្រូវប្រើប្រាស់ ដើម្បីបង្កើតជាផលិតផលចំណេះដឹង និងប្រព័ន្ធនានាសម្រាប់ជូនដំណឹងដល់អ្នកពាក់ព័ន្ធនានា និងសាធារណជនជាទូទៅអំពីសកម្មភាពគម្រោង និងគុណតម្លៃនៃកិច្ចប្រឹងប្រែង ដើម្បីពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ ក្រុមអ្នកអនុវត្តគម្រោងនឹងចម្រាញ់យកមេរៀន និងបទពិសោធន៍ពីការវិភាគករណីនៃគម្រោងវិនិយោគនានានៅក្រោម SPCR ដើម្បីបញ្ចូលក្នុងកម្រងឯកសារណែនាំស្តីពីវិធីសាស្រ្តក្នុងមូលដ្ឋានសម្រាប់ភាពធន់នឹងអាកាសធាតុ។ យុទ្ធសាស្រ្តពិស្តារមួយអំពីការគ្រប់គ្រងចំណេះដឹង ការប្រាស្រ័យទាក់ទង និងការចូលរួមនៃអ្នកពាក់ព័ន្ធ ត្រូវបានរួមបញ្ចូលជាឧបសម្ព័ន្ធនៅក្នុងរបាយការណ៍នេះ។

32. ជាផ្នែកមួយនៃការងារពង្រឹងសមត្ថភាព និងការផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធសំខាន់ៗ ក្រុមអនុវត្តគម្រោងនឹងធ្វើការជាមួយសកលវិទ្យាល័យនានា ដើម្បីកសាងសមត្ថភាពសម្រាប់បង្រៀនអំពីការប្រែប្រួលអាកាសធាតុ។ វិធីសាស្រ្តនេះ រួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីសិក្សា នឹងពឹងផ្អែកលើផលិតផលចំណេះដឹង និងមេរៀននានាដែលទទួលបានពីគម្រោងនេះ ក៏ដូចជា សម្ភារៈសម្រាប់កម្មវិធីសិក្សា ដែលបានរៀបចំឡើងដោយកម្មវិធីប្រែប្រួលអាកាសធាតុនៅកម្ពុជាផងដែរ។

## ការអនុវត្តការចាត់ចែង

33. កញ្ចប់ទី ១ នៃTAនេះ នឹងអនុវត្តដោយក្រុមមួយដែលមានអ្នកជំនាញការពេញម៉ោង និងមិនពេញម៉ោងសរុបចំនួន ១៤នាក់ ក្នុងនោះ អ្នកជំនាញការអន្តរជាតិមិនពេញម៉ោងចំនួនប្រាំរូប និងអ្នកជំនាញការជាតិចំនួន ៩ រូបផងដែរ។ ក្រុមនេះនឹងគាំទ្រដល់ការិយាល័យកម្មវិធី SPCR និងមន្រ្តីជាតិសម្របសម្រួល SPCR នៅក្នុងនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃ NCSD។ គម្រោងនេះត្រូវបានគេមើលឃើញថាជាផ្នែករួមមួយនៃអាណត្តិ និងកម្មវិធីរបស់ CCD។

## ដំណាក់កាលចាប់ផ្តើម

34. គិតចាប់តាំងពីពេលចាប់ផ្តើមនៅរវាងខែកុម្ភៈ និងឧសភា ឆ្នាំ២០១៥ ក្រុមជំនាញការអនុវត្តគម្រោងនេះបានធ្វើការពិគ្រោះ យោបល់ទូលំទូលាយជាបន្តបន្ទាប់ជាមួយអ្នកពាក់ព័ន្ធក្នុងគម្រោង និងបានបូកសរុបការវាយតម្លៃសមត្ថភាពដើមគ្រា និងតម្រូវការសមត្ថភាពនៅក្នុងក្រសួងគោលដៅសំខាន់ៗ។ ក្រុម

ជំនាញការអនុវត្តគម្រោងក៏បានរៀបចំផែនការពិស្តារមួយផងដែរដើម្បីអនុវត្តគម្រោងនេះដោយភាពជោគជ័យ។

## ផែនការអនុវត្ត

35. ឆ្លើយតបនឹងបញ្ហាប្រឈមសំខាន់ៗ និងគោលការណ៍ណែនាំសម្រាប់ការអនុវត្ត ដែលបានរៀបចំដោយក្រុមជំនាញការ វិធីសាស្ត្រអនុវត្តបានតម្រូវឱ្យមានការកែសម្រួលក្នុងការបែងចែក និងរៀបតាមលំដាប់លំដោយនៃកញ្ចប់ជាតុចេញ និងសកម្មភាពរបស់វា ដូចបានកំណត់នៅក្នុងការរៀបចំ TA8179 និងក្របខណ្ឌត្រួតពនិត្យ (DMF) របស់ TA នេះ។ តាមគោលបំណងនៃការអនុវត្ត TA នេះ គឺក្រុមជំនាញការគម្រោងនេះបានចាត់សកម្មភាពនានានៅក្រោម DMF ជាក្រុមៗ តាមសកម្មភាពដែលមានភាពពាក់ព័ន្ធ និងពង្រឹងគ្នាទៅវិញទៅមក និងជំរុញភាពធន់នឹងអាកាសធាតុដែលមានលក្ខណៈជាប្រព័ន្ធ (រូបទី ES-4)។




**រូបទី ES-4 សង្ខេបផែនការអនុវត្តកញ្ចប់ទី ១ នៃ TA 8179**

36. ការងារផ្នែកទី១ ***ការជំរុញគោលនយោបាយ ដើម្បីជំរុញភាពធន់នឹងអាកាសធាតុ តាមរយៈការប្រើប្រាស់ឧបករណ៍វិភាគហានិភ័យអាកាសធាតុ និងការរៀបចំគម្រោង*** នឹងត្រូវអនុវត្តក្នុងរយៈពេលប្រមាណពីរឆ្នាំ

កន្លះ និងបង្កើតមូលដ្ឋានគ្រឹះនៃកញ្ចប់សកម្មភាពការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ។ ការងារផ្នែកនេះនឹងចែកចេញ និងអនុវត្តដោយការងាររងចំនួនបី។

37. ***ការបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្តដោយជោគជ័យ*** - ការងាររងនេះ រួមមានដំណាក់កាលចាប់ផ្តើមគម្រោង ដែលប្រមូលផ្តុំនៅក្នុងសិក្ខាសាលាចាប់ផ្តើមគម្រោង និងរបាយការណ៍ចុងក្រោយអំពីការចាប់ផ្តើមគម្រោង។

38. ***ការប្រើប្រាស់ការវាយតម្លៃភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ និងដំណើរការរៀបចំផែនការបន្សុាំតាមវិស័យហេដ្ឋារចនាសម្ព័ន្ធ*** - នៅក្នុងអំឡុងពេលអនុវត្តការងាររងនេះ ក្រុមអ្នកអនុវត្តគម្រោងនឹងធ្វើការបង្ហាញអំពីការប្រើប្រាស់វិធីសាស្រ្តវាយតម្លៃភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ និងវិធីសាស្រ្តរៀបចំផែនការបន្សុាំសម្រាប់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗនៅថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន។ សកម្មភាពបង្ហាញទាំងនេះនឹងត្រូវរួមបញ្ចូល ដើម្បីចងក្រងជាឯកសារមេរៀនដែលបានរៀនសូត្រពីគម្រោងវិនិយោគរបស់ SPCR ការកសាងសមត្ថភាព និងសកម្មភាពសិក្សាលទ្ធភាពគម្រោងសម្រាប់ក្រសួងវិស័យគោលដៅ ដើម្បីលើកទឹកចិត្តឱ្យមានការប្រើប្រាស់ និងរៀនសូត្របានពេញលេញ និងពង្រឹងសមត្ថភាពសម្រាប់បំប្លែងការវាយតម្លៃនៅតាមមូលដ្ឋាន ឱ្យទៅជាកិច្ចផ្តួចផ្តើមប្រកបដោយជោគជ័យក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ។

39. ***ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ និងគោលការណ៍ណែនាំតាមវិស័យគោលដៅ***- នៅក្នុងអំឡុងពេលអនុវត្តការងាររងទីបី បទពិសោធន៍ដែលទទួលបានពីសកម្មភាពអនុវត្តបង្ហាញនឹងត្រូវប្រើប្រាស់ដើម្បីជាព័ត៌មានសម្រាប់ការកែទម្រង់គោលនយោបាយ និងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅកម្រិតវិស័យ។ ជាផ្នែកមួយនៃដំណើរការនេះ ការសិក្សាលទ្ធភាពគម្រោង គឺបានបង្កើតឡើងតាមរយៈសកម្មភាពអនុវត្តបង្ហាញ នឹងបង្កើតជាមូលដ្ឋានសម្រាប់គោលគំនិតអំពីគម្រោងនេះ ដើម្បីគាំទ្រដល់សកម្មភាពនានាបន្ថែមទៀត ដើម្បីបញ្ជ្រាបភាពធន់នឹងការប្រែប្រួលអាកាសធាតុនៅក្នុងការធ្វើសេចក្តីសម្រេចអំពីការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ។

40. ការងារផ្នែកទីពីរ***សកម្មភាពអន្តរវិស័យ*** នឹងត្រូវអនុវត្តនៅក្នុងអាយុកាលទាំងមូលនៃគម្រោងនេះ និងផ្តោតលើការ ទាក់ទងសកម្មភាពរបស់គម្រោង និងត្រួតពិនិត្យការអនុវត្តគម្រោង។ ការងារផ្នែកនេះពាក់ព័ន្ធជាមួយការងាររងចំនួនបួន។

41. ***ការពង្រឹងការសម្របសម្រួល SPCRនិងស្ថាប័នសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការ និងការអនុវត្ត*** - ការងាររងនេះមានគោលដៅសម្របសម្រួលឱ្យមានការកែលម្អការសម្របសម្រួលជាតុផ្សំសំខាន់ៗ នៃកម្មវិធី SPCR តាមរយៈការប្រជុំជាទៀងទាត់របស់នៃសមាជិកក្រុមការងារសម្របសម្រួល SPCR និងការចុះពិនិត្យនៅមូលដ្ឋាននៃសមាជិកក្រុមការងារនេះ ដើម្បីស្វែង

យល់ពីសកម្មភាព SPCR និងគាំទ្រដល់សកម្មភាពដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ នៅថ្នាក់ជាតិ ដោយផ្សារភ្ជាប់ទៅនឹងកម្មវិធី SPCR។

42. ***ការកសាងសមត្ថភាពក្នុងវិស័យនានា ដើម្បីពង្រឹងភាពធន់នឹងអាកាសធាតុជាលក្ខណៈប្រព័ន្ធ*** - ការកសាងសមត្ថភាពគឺបង្កាញក្នុងសកម្មភាពនីមួយៗនៅក្នុងកញ្ចប់ ១។ នៅក្នុងដំណាក់កាលចាប់ផ្ដើម ក្រុមអ្នកអនុវត្តគម្រោងបានធ្វើការវាយតម្លៃពីតម្រូវការសមត្ថភាពដំបូង ដោយផ្ដោតលើសមត្ថភាពស្ថាប័ននៃក្រសួងជាគោលដៅ សម្រាប់រួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងសេចក្ដីសម្រេចអំពីការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ។ ការវាយតម្លៃនេះនឹងត្រូវធ្វើបច្ចុប្បន្នភាពជាទៀងទាត់ ដើម្បីផ្ដល់ព័ត៌មានកាន់តែប្រសើរសម្រាប់ការបណ្ដុះបណ្ដាល និងសកម្មភាពកសាងសមត្ថភាព ជាមួយក្រុមអ្នកអនុវត្តការងារបន្សាំ និងការអនុវត្តសកម្មភាពបង្ហាញ និងការបញ្ជ្រាបកិច្ចការកែទម្រង់។ ដូចគ្នានេះដែរ ការវាយតម្លៃជាទៀងទាត់នឹងត្រូវប្រើប្រាស់សម្រាប់តាមដានវឌ្ឍនភាពនៃការបញ្ជ្រាបនៅក្នុងក្រសួងទាំងនេះផងដែរ។

43. ***ការទំនាក់ទំនងរវាងសកម្មភាព និងលទ្ធផលគម្រោង*** - តាមរយៈសកម្មភាពទាំងនេះ ក្រុមអ្នកអនុវត្តគម្រោងនឹងស្រង់យកមេរៀនជាមួយគ្នាពីសកម្មភាពបង្ហាញនៅក្នុងការងារផ្នែកទីមួយ ដើម្បីបង្កើតផលិតផលទំនាក់ទំនង និង ចំណេះដឹង និងប្រព័ន្ធជូនដំណឹងដល់អ្នកពាក់ព័ន្ធ និងសាធារណៈជនទូទៅអំពីសកម្មភាពគម្រោង និងគុណតម្លៃនៃកិច្ចប្រឹងប្រែងដើម្បីពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

44. ***ការបង្កើតមូលដ្ឋានគ្រឹះរឹងមាំដើម្បីត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធិផលនៃគម្រោង*** - ការងារនេះនឹងប្រមូលផ្ដុំសកម្មភាពនៅក្នុងជាតុចេញ សម្រាប់រៀបចំជាឧបករណ៍ វិធីសាស្ត្រ ប្រព័ន្ធ និងធនធាន ដើម្បីត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពក្នុងកញ្ចប់ទី ១។ ការបង្កើតដំណើរការតាមដានការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការងាររបស់នាយកដ្ឋាននៃក្រសួងនីមួយៗ ក៏ជាផ្នែកមួយនៃដំណើរការបញ្ជ្រាបនេះផងដែរ។

45. ***ការបែងចែកលម្អិត និងជាលំដាប់លំដោយនៃសកម្មភាពក្នុង DMF*** គឺអនុលោមតាមចរន្តការងារ និងសកម្មភាពនានាតាមដំណាក់កាលនីមួយៗ ដូចបានបញ្ចូលក្នុងតារាងខាងក្រោមនេះ។ ទោះបីគោលគំនិតអំពីសកម្មភាព DMF ដូចមានអធិប្បាយនៅទីនេះ មិននាំឱ្យមានការកែប្រែច្រើនក៏ដោយ តែវាអាចនាំឱ្យមានការកែប្រែជាបន្តបន្ទាប់លើសកម្មភាពមួយចំនួន ដែលវាមានឥទ្ធិពលដល់ការបញ្ចប់ផលិតផល ដូចជារបាយការណ៍បច្ចេកទេស ដែលក្រុមអ្នកអនុវត្តគម្រោងត្រូវរៀបចំ និងដាក់ជូន។ នេះក៏មានន័យផងដែរថា ជាការកែសម្រួលខ្លះៗចំពោះរបៀបដែលក្រុមអនុវត្តគម្រោងនេះចាត់ចែងខ្លួនឯងផងដែរ។

តារាង ES-1 ការបែបចែកសកម្មភាព DMF ដោយចរន្តការងារនៃផែនការអនុវត្ត

| ចរន្តការងារ | សកម្មភាព DMF ដែលពាក់ព័ន្ធ |
|---|---|
| **ការជូនដំណឹងដល់គោលនយោបាយដើម្បីពង្រឹងភាពធន់នឹងអាកាសធាតុ តាមរយៈការប្រើប្រាស់ឧបករណ៍ជ្រើសរើសហានិភ័យអាកាសធាតុ និងការរៀបចំគម្រោង** | |
| ១. ការបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្តដោយជោគជ័យ | ១.១ |
| ២. ការប្រើប្រាស់ការវាយតម្លៃភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ និងដំណើររៀបចំផែនការបន្សាំសម្រាប់ហេដ្ឋារចនាសម្ព័ន្ធតាមវិស័យ | ១.៨, ២.១, ១.៦, ២.២, ១.៩ |
| ៣. ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ និងគោលការណ៍ណែនាំតាមវិស័យជាគោលដៅ | ២.៤, ២.៦, ១.១០, ១.៥, ២.៥, ១.៣, ២.៧, ១.១១ |
| **សកម្មភាពអន្តរវិស័យ** | |
| ៤. ការពង្រឹងការសម្របសម្រួល និងស្ថាប័ន SPCR សម្រាប់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការ និងការអនុវត្ត | ១.២ |
| ៥. ការកសាងសមត្ថភាពក្នុងវិស័យនានា ដើម្បីពង្រឹងភាពធន់នឹងអាកាសធាតុជាលក្ខណៈប្រព័ន្ធ | **ទាំងអស់** |
| ៦. ការទំនាក់ទំនងសកម្មភាព និងលទ្ធផលគម្រោង | ៤.៤, ៤.៣, ៤.៥, ៤.៦, ៤.៧ |
| ៧. ការបង្កើតមូលដ្ឋានគ្រឹះរឹងមាំដើម្បីត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលគម្រោង | ១.៤, ៤.១, ១.៧, ២.៣, ៤.២ |

## អនុសាសន៍

46. ជាផ្នែកមួយនៃដំណាក់កាលចាប់ផ្តើមអនុវត្តគម្រោង ក្រុមការងារTAបានពិនិត្យឡើងវិញលើក្របខណ្ឌរៀបចំគម្រោង និងពិនិត្យតាមដាន សកម្មភាពគម្រោង រយៈពេលអនុវត្តគម្រោង ការចំណាយការធ្វើដំណើរ ការគាំទ្រប្រតិបត្តិការ និងលក្ខខណ្ឌការងាររបស់សមាជិកក្រុមការងារ។ ផ្អែកលើការពិនិត្យនេះ អនុសាសន៍មួយចំនួនត្រូវបានស្នើឡើងសម្រាប់ការពិចារណារបស់ក្រសួងបរិស្ថាន និងធនាគារអភិវឌ្ឍន៍អាស៊ី។ អនុសាសន៍ត្រូវបានបែងចែកទៅតាមផ្នែកដែលត្រូវអនុវត្ត (I) និងកិច្ចព្រមព្រៀង និងថវិកា (C) ត្រូវបានពិភាក្សាលម្អិតក្នុងផ្នែកទី៩ ក្នុងរបាយការណ៍នេះ។

47. អនុសាសន៍សង្ខេបត្រូវបានដាក់ចូលទៅក្នុងតារាង ES-2 ៖

តារាង ES-2 អនុសាសន៍របាយការណ៍ចាប់ផ្តើមអនុវត្តគម្រោង

| លេខរៀង អនុសាសន៍ | ការពិពណ៌នា | ផ្នែកពាក់ព័ន្ធ របាយការណ៍ |
|---|---|---|
| | **ការអនុវត្ត** | |
| I.1 | យោងតាមគម្រោងកម្មវិធីសកម្មភាពបន្សុំានឹងការប្រែប្រួលអាកាសធាតុក្នុងក្របខណ្ឌរៀបចំគម្រោង និងពិនិត្យតាមដាន ត្រូវបានស្នើឡើងឲ្យដាក់បញ្ចូលគម្រោងបន្សុំាឲ្យកាន់តែទូលំទូលាយ។ | ផ្នែក 8.1.1 |
| I.2 | សកម្មភាពមួយត្រូវបានបន្ថែមក្រោមធាតុចេញទី១ ដើម្បីបង្កើតប្រព័ន្ធព័ត៌មានភូមិសាស្ត្រផ្អែកលើឧបករណ៍គាំទ្រការធ្វើសេចក្តីសម្រេចចិត្តការប្រែប្រួលអាកាសធាតុដោយផ្អែកលើទិន្នន័យចុងក្រោយដែលមិនទាន់វិភាគសម្រាប់បង្រួញមាត្រដ្ឋានថ្នាក់តំបន់ ហើយថវិកាបន្ថែមរបស់TAដែលមានក្នុងកញ្ចប់ទី១របស់ទីប្រឹក្សាត្រូវយកមកអនុវត្តសកម្មភាពនេះ។ | ផ្នែក 8.1.2 |
| I.3 | ថវិកាបន្ថែមរបស់TAដែលមានក្នុងកញ្ចប់ទី១របស់ទីប្រឹក្សាដើម្បីពង្រឹងសមត្ថភាពក្រុមការងាររបស់គម្រោងក្នុងការវិភាគសេដ្ឋកិច្ចសង្គមដោយមានបន្ថែមអ្នកឯកទេសជាតិ និងអន្តរជាតិផ្នែកសេដ្ឋកិច្ចសង្គម។ | ផ្នែក 8.1.3 |
| I.4 | ការបែងចែកថវិកា និងសកម្មភាពគម្រោងដែលលម្អិតក្នុងតារាងទី 6-1 ត្រូវបានទទួលស្គាល់ជាមូលដ្ឋានសម្រាប់ផែនការការងារគម្រោងសម្រាប់រយៈពេលដែលនៅសល់។ | ផ្នែក 8.2.1 |
| I.5 | កាលបរិច្ឆេទផ្តល់របាយការណ៍បច្ចេកទេសត្រូវបានកែសម្រួលដូចក្នុងតារាង 8 1។ | ផ្នែក 8.2.2 |
| I.6 | ដំណើរការឯកភាពសម្រាប់របាយការណ៍បច្ចេកទេសដែលជាប់កិច្ចព្រមព្រៀងបានគូសបញ្ជាក់ក្នុងរបាយការណ៍នេះ ត្រូវបានយល់ព្រម។ | ផ្នែក 8.2.3 |
| I.7 | ដំណើរការអនុម័តសម្រាប់របាយការណ៍បច្ចេកទេសដែលជាប់កិច្ចព្រមព្រៀងបានគូសបញ្ជាក់ក្នុងរបាយការណ៍នេះ ត្រូវបានយល់ព្រម។ | ផ្នែក 8.2.3 |
| I.8 | ប្រសិនបើអនុសាសន៍ I.2 ត្រូវបានយល់ព្រម លក្ខខណ្ឌការងារសម្រាប់ទីប្រឹក្សាបន្ថែមនឹងត្រូវបានរៀបចំ។ | ផ្នែក 8.3.1 |
| I.9 | ប្រសិនបើអនុសាសន៍ I.3 ត្រូវបានយល់ព្រម លក្ខខណ្ឌការងារសម្រាប់ទីប្រឹក្សាជាតិ និងអន្តរជាតិផ្នែកសេដ្ឋកិច្ចសង្គម នឹងត្រូវបានរៀបចំ។ | ផ្នែក 8.3.1 |

| | | |
|---|---|---|
| I.10 | ការកែសម្រួលតួនាទីក្រុមការងារគម្រោង និងលក្ខខណ្ឌការងារត្រូវបានកំណត់ក្នុងរបាយការណ៍នេះ ត្រូវបានយល់ព្រម។ | ផ្នែក 8.3.2 |
| I.11 | ក្រុមការងារគម្រោង និងកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា នឹងអនុវត្តតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងសហប្រតិបត្តិការ ដូចបានបង្ហាញជូនក្នុងរបាយការណ៍នេះ។ | ផ្នែក 8.4.1 |
| I.12 | ក្រុមការងារគម្រោងកញ្ចប់ទី១ បង្កើតកិច្ចព្រមព្រៀងច្បាស់លាស់សម្រាប់កិច្ចសហការជាមួយក្រុមការងារទីប្រឹក្សាកញ្ចប់ទី២ និងកញ្ចប់ទី៣។ | ផ្នែក 8.4.2 |
| | **កិច្ចព្រមព្រៀង និងថវិកា** | |
| C.1 | ប្រសិនបើអនុសាសន៍ I.2, I.3, I.8 និង I.9 សម្រាប់ការបង្កើតប្រព័ន្ធព័ត៌មានភូមិសាស្ត្រផ្អែកលើឧបករណ៍គាំទ្រការធ្វើសេចក្តីសម្រេចចិត្តការប្រែប្រួលអាកាសធាតុ និងធាតុចូលរបស់អ្នកសេដ្ឋកិច្ចសង្គមត្រូវបានឯកភាព ថវិកាយថាភាពនឹងត្រូវបានបែងចែកដល់ខ្ទង់ថវិកាទីប្រឹក្សាសម្រាប់សកម្មភាពបន្ថែមនេះ។ | ផ្នែក 8.5 |
| C.2 | ប្រសិនបើអនុសាសន៍ I.4 ត្រូវបានយល់ព្រម ការកែសម្រួលនឹងត្រូវដាក់ចេញទៅក្នុងកញ្ចប់ទី១របស់ទីប្រឹក្សា ដើម្បីឆ្លុះបញ្ចាំងកាលបរិច្ឆេទផ្តល់របាយការណ៍បច្ចេកទេសជាប់កិច្ចព្រមព្រៀងដែលនឹងត្រូវបង្កើតក្នុងរបាយការណ៍នេះ។ | ផ្នែក 8.5 |

# មាតិកាអត្ថបទ

**តារាងពាក្យកាត់** ........ III
**សេចក្តីសង្ខេប** ........ VI
**មាតិកាអត្ថបទ** ........ XXII
**បញ្ជីតារាង** ........ XXVI
**បញ្ជីរូបភាព** ........ XXVII
**1 សេចក្តីផ្តើម** ........ 1
1.1 គោលបំណងនៃគម្រោង ........ 1
1.2 ទម្រង់របាយការណ៍ ........ 1
**2 អំពីគម្រោង** ........ 2
2.1 លទ្ធផល និងគោលដៅ ........ 2
2.2 សាវតានៃកម្មវិធីយុទ្ធសាស្រ្តភាពធន់នឹងអាកាសធាតុនៅកម្ពុជា ........ 9
*2.2.1 កម្មវិធីសាកល្បងភាពធន់អាកាសធាតុដំណាក់កាលទី១ (PPCR Phase 1) ........ 10*
2.3 ផែនការយុទ្ធសាស្រ្តសម្រាប់ភាពធន់អាកាសធាតុ ........ 11
*2.3.1 គម្រោងវិនិយោគកម្មវិធីយុទ្ធសាស្រ្តសម្រាប់ភាពធន់នឹងអាកាសធាតុ ........ 11*
*2.3.2 ការសម្របសម្រួលកម្មវិធីយុទ្ធសាស្រ្តភាពធន់នឹងអាកាសធាតុ ........ 12*
2.4 ដំណាក់កាលទី ២៖ សកម្មភាពផែនការយុទ្ធសាស្រ្តភាពធន់អាកាសធាតុនៅចុងឆ្នាំ ២០១៤ 13
2.5 ដំណាក់កាលចាប់ផ្តើមគម្រោងរបស់ ICEM ........ 13
*2.5.1 ផែនការសម្រាប់ដំណាក់កាលចាប់ផ្តើមគម្រោង ........ 13*
*2.5.2 គោលបំណង និងសកម្មភាពដំណាក់កាលចាប់ផ្តើមគម្រោង ........ 14*
2.6 កញ្ចប់ទី ១៖ រចនាសម្ព័ន្ធក្រុម និងការចាប់ផ្តើមដំណើរការ ........ 19
*2.6.1 កញ្ចប់ទី ១៖ រចនាសម្ព័ន្ធក្រុមការងារគម្រោង ........ 19*
*2.6.2 ការចាប់ផ្តើមដំណើរការរបស់ក្រុមការងារ ........ 22*
**3 បរិបទរបស់ស្ថាប័ន** ........ 23
3.1 រចនាសម្ព័ន្ធស្ថាប័នថ្នាក់ជាតិ ........ 23
*3.1.1 ការផ្លាស់ប្តូររចនាសម្ព័ន្ធនៃ ក្រសួងបរិស្ថាន និងស្ថាប័ន សម្រាប់ការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ ........ 23*
*3.1.2 ក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព (NCSD) ........ 24*
3.2 សកម្មភាពជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ........ 25
*3.2.1 ផែនការយុទ្ធសាស្រ្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP) ........ 25*
*3.2.2 ផែនការយុទ្ធសាស្រ្ត និងសកម្មភាពនៃវិស័យ ........ 27*

*3.2.3* គោលនយោបាយពាក់ព័ន្ធនានា ដែលឆ្លើយតបការប្រែប្រួលអាកាសធាតុនៅកម្ពុជា ........ *28*
3.2.4 គោលនយោបាយ គោលការណ៍ណែនាំ ស្តង់ដារតាមវិស័យ និងក្រុមការងារនានាពាក់ ព័ន្ធការប្រែប្រួលអាកាសធាតុ ........ *31*
3.3 សម្ព័ន្ធការប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) – អ្នកជាដៃគូរសំខាន់ ........ 38
3.4 ការផ្តួចផ្តើមរបស់ដៃគូរអភិវឌ្ឍន៍ ដែលធ្វើការលើការប្រែប្រួលអាកាសធាតុ ........ 39
4 **ដំណោះស្រាយ និង វិធីសាស្ត្រ** ........ **41**
4.1 ការពិនិត្យមើលលើវិធីសាស្ត្របញ្ជ្រាបការប្រែប្រួលអាកាសធាតុ ........ 41
4.2 ការរៀបចំគោលនយោបាយ និងការចងក្រងអនុសាសន៍ ........ 44
4.3 ការវាយតម្លៃសេដ្ឋកិច្ច ........ 47
4.4 ការសម្របសម្រួលកម្មវិធី SPCR ........ 48
4.5 វិស័យផ្តោត – វិធីសាស្ត្របង្កើតក្រុមការងារបន្សាំរបស់ SPCR ........ 49
4.6 ការកំណត់ភូមិសាស្ត្រ ........ 50
*4.6.1* ដំណើរការជ្រើសរើសខេត្តគោលដៅ ........ *51*
*4.6.2* ការកំណត់លក្ខណៈវិនិច្ឆ័យជ្រើសរើស ........ *52*
*4.6.3* ការវិភាគដោយប្រើពហុលក្ខណៈវិនិច្ឆ័យ ........ *53*
4.7 ហេដ្ឋារចនាសម្ព័ន្ធបៃតងសម្រាប់ធ្វើឲ្យមានភាពធន់ និងចីរភាព ........ 60
4.8 ការដាក់បញ្ចូលវិធីសាស្ត្រទៅក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំការប្រែប្រួលអាកាសធាតុ ........ 63
4.9 ការចូលរួមជាមួយគម្រោង កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ ........ 66
4.10 ការវាយតម្លៃហេដ្ឋារចនាសម្ព័ន្ធចម្រុះតាមខេត្តដែលបានជ្រើសរើស ........ 68
4.11 ការចូលទៅកាន់មូលនិធិអាកាសធាតុ ........ 73
4.12 ការកសាងសមត្ថភាព ........ 77
*4.12.1* គោលការណ៍សម្រាប់ការកសាងសមត្ថភាព ........ *77*
*4.12.2* និតិវិធី ៧S ........ *79*
*4.12.3* វិធីសាស្ត្រដែលប្រើសម្រាប់ការវាយតម្លៃតម្រូវការសមត្ថភាពឲ្យចំគោលដៅ ........ *81*
*4.12.4* ការកសាងផែនការពង្រឹងសមត្ថភាព ........ *85*
*4.12.5* វិធីសាស្ត្រសម្រាប់ការកសាងសមត្ថភាព ........ *86*
4.13 ការគ្រប់គ្រងចំណេះដឹង ការទំនាក់ទំនង និងការចូលរួមរបស់ភាគីពាក់ព័ន្ធ ........ 87
*4.13.1* ការគ្រប់គ្រងចំណេះដឹងនិងការទំនាក់ទំនង ........ *88*
*4.13.2* ការបង្កើតផលិតផលចំណេះដឹង ........ *89*
*4.13.3* ការរក្សាទុកចំណេះដឹង - ប្រព័ន្ធព័ត៌មានគ្រប់គ្រងចំណេះដឹង ........ *90*
*4.13.4* ការចែករំលែកចំណេះដឹង - លទ្ធផលនៃការទំនាក់ទំនងនិងការអនុវត្តល្អបំផុត ........ *91*
*4.13.5* អភិវឌ្ឍន៍កម្មវិធីសិក្សា ........ *92*

**5 ការព្យាករណ៍ទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុនិងការវាយតម្លៃភាពងាយរងគ្រោះ ........ 94**
5.1 ការសិក្សាការប្រែប្រួលអាកាសធាតុនិងការព្យាករណ៍កន្លងមក ........ 94
5.2 ផ្លាស់ប្តូរអាកាសធាតុ និងឧបករណ៍ ម៉ូដែលនិង GIS ជលសាស្ត្រ........ 98
5.3 ការចាត់ចំណាត់ថ្នាក់ការគំរាមកំហែងនិងការវាយតម្លៃភាពងាយរងគ្រោះសម្រាប់អាកាសធាតុ 100
5.4 ការវាយតម្លៃភាពងាយរងគ្រោះកន្លងមកនៅក្នុងប្រទេសកម្ពុជា........102
5.5 ជំហានទី2 ការវាយតម្លៃភាពងាយរងគ្រោះ ........107
**6 ការអនុវត្ត ........ 115**
6.1 ទំនាក់ទំនងរវាងលទ្ធផលនិងសកម្មភាព ........115
6.2 ការជូនដំណឹងគោលនយោបាយពង្រឹកធន់អាកាសធាតុ ........122
*6.2.1* អនុចរន្តការងារ*1* - ការបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្តទទួលបានជោគជ័យ ........*122*
*6.2.2* អនុចរន្តការងារ ២ - ការអនុវត្តដំណើរការវាយតម្លៃភាពងាយរងគ្រោះការប្រែប្រួលអាកាសធាតុនិងការធ្វើផែនការការសម្របសម្រួលទៅនឹងវិស័យហេដ្ឋារចនាសម្ព័ន្ធ ........*127*
*6.2.3* អនុចរន្តការងារ ៣ – ការលើកកម្ពស់ចំណឹងដឹងស្តីពីការប្រែប្រួលអាកាសធាតុក្នុងផ្នែកគោលនយោបាយ ........*139*
6.3 សកម្មភាពអន្តរវិស័យ ........159
*6.3.1* ការពង្រឹង *SPCR* សំរបសំរួលនិងស្ថាប័នសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការនិងការអនុវត្ត ........*159*
*6.3.2* ការកសាងសមត្ថភាពជាមួយវិស័យដើម្បីបង្កើនភាពធន់អាកាសធាតុនៅក្នុងវិធីជាប្រព័ន្ធ *161*
*6.3.3* ការទំនាក់ទំនងសកម្មភាពគម្រោងនិងលទ្ធផល ........*163*
*6.3.4* បង្កើតមូលដ្ឋានគ្រឹះរឹងមាំង សម្រាប់តាមដាន និង វាយតម្លៃលទ្ធផលគ្រោង *(Outcome): 178*
6.4 តាមដានត្រួតពិនិត្យ និង វាយតម្លៃ........187
**7 ផែនការការងារសម្រាប់រយៈពេល៦ខែបន្ទាប់ ........ 208**
**8 អនុសាសន៍នានាសម្រាប់ការអនុវត្តដែលមានប្រសិទ្ធភាព........ 209**
8.1 ការបកស្រាយក្របខណ្ឌបង្កើតគម្រោង និងការត្រួតពិនិត្យតាមដាន........ 209
*8.1.1* ការកែសម្រួលពាក្យ "កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ*NAPA*" ទៅជា" "គម្រោងការបន្សាំ"........ *209*
*8.1.2* សកម្មភាពបន្ថែមដើម្បីបង្កើតប្រព័ន្ធព័ត៌មានភូមិសាស្ត្រដែលផ្អែកលើឧបករណ៍គាំទ្រការធ្វើសេចក្តីសម្រេចចិត្តការប្រែប្រួលអាកាសធាតុ ........ *209*
*8.1.3* ពង្រឹងអ្នកជំនាញការគម្រោងដើម្បីវិភាគសេដ្ឋកិច្ចសង្គម........*210*
8.2 ផែនការការងារ និងសកម្មភាព និងរបាយការណ៍បច្ចេកទេស........211

*8.2.1* ការបែងចែកថវិកា និងសកម្មភាពគម្រោង......*211*
*8.2.2* កាលបរិច្ឆេទនៃការផ្តល់របាយការណ៍បច្ចេកទេស និងការអនុម័ត ......*211*
*8.2.3* ការអនុម័តរបាយការណ៍បច្ចេកទេស ដើម្បីវាស់វែងការចំណាយថវិកាដែលមានគោលដៅ *213*
*8.2.4* ការអនុម័តរបាយការណ៍បច្ចេកទេស ដោយគណៈកម្មការសម្របសម្រួលកម្មវិធី*SPCR*...*215*
8.3 ការរៀបចំក្រុមការងារ និងធាតុចូល......216
*8.3.1* ទីប្រឹក្សាបន្ថែម......*217*
*8.3.2* ការធ្វើឱ្យប្រសើរឡើងលក្ខខណ្ឌការងាររបស់ក្រុមការងារគម្រោង......*217*
8.4 កិច្ចសហការជាមួយគំនិតផ្តួចផ្តើមការប្រែប្រួលអាកាសធាតុផ្សេងទៀត......217
*8.4.1* កិច្ចសហការជាមួយកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា......*218*
*8.4.2* ការសហការជាមួយកញ្ចប់ទី២ ......*219*
*8.4.3* ការសហការជាមួយកញ្ចប់ទី៣ ......*220*
8.5 អនុសាសន៍នានាសម្រាប់កិច្ចសន្យាការងារទីប្រឹក្សា និងថវិកា......220

Annex 1: Dmf And Performance Indicators With Revised Dates ...... **222**
Annex 2: Scope & Lessons Learnt Entry Points For Spcr Projects ...... **239**
Annex 3: Government Counterparts And Focal Points For Ministries And Departments.... **281**
Annex 4: Other Initiatives On Climate Change Adaptation ...... **284**
Annex 5: Further Institutional Information On Spcr Ministries ...... **298**
Annex 6: Tor For Adaptation Working Group ...... **299**
Annex 7: Template For Climate Funds Briefing Paper...... **304**
Annex 8: Capacity Needs Assessment For Key Spcr Ministries ...... **305**
Annex 9: Knowledge Management, Communication And Dissemination Plan Stakeholder Engagement Plan ...... **305**
Annex 10: Climate Change Projections For Cambodia...... **305**
Annex 11: Revised Team Member Tors ...... **306**
Annex 12: Spcr And Ccca Collaborative Agreement ...... **321**
Annex 13: Bibliography And References ...... **325**

# បញ្ជីតារាង

តារាង 4-3: ខេត្តដែលត្រូវបានជ្រើសរើស .......... 57
តារាង 4-4: ការវិភាគលក្ខខ័ណ្ឌចម្រុះក្នុងការជ្រើសរើសខេត្តសម្រាប់អនុវត្តគម្រោង .......... 59
តារាង 6-11: ទិដ្ឋភាពទូទៅនៃសកម្មភាព 2.4 .......... 141
តារាង 6-12: ទិដ្ឋភាពទូទៅនៃសកម្មភាព 2.6 .......... 143
តារាង 6-13: សកម្មភាព 1.10 ព្រឹត្តិការនានា លទ្ធផល និង របាយការណ៍ដែលរំពឹងទុក .......... 145
តារាង6-14: ទិដ្ឋភាពទូទៅនៃសកម្មភាព 1.5 ព្រឹត្តិការ ផលិតផលនិងរបាយការណ៍បច្ចេកទេស តាមកិច្ចសន្យា .......... 147
តារាង6-16: ទិដ្ឋភាពទូទៅនៃសកម្មភាព 1.3 ព្រឹត្តិការ ផលិតផលនិងរបាយការណ៍បច្ចេកទេសបានធ្វើកិច្ចសន្យា .......... 151
តារាង6-17: ទិដ្ឋភាពទូទៅនៃសកម្មភាព 2.7 និងលទ្ធផលដែលត្រូវគ្នា និង ផលិតផល .......... 153
តារាង 6-18: ទិដ្ឋភាពទូទៅនៃសកម្មភាព 1.11 ព្រឹត្តិការ, ផលិតផលនិងរបាយការណ៍បច្ចេកទេសបានធ្វើកិច្ចសន្យា .... 154
តារាង 6-19 ផែនការការងារលម្អិត .......... 156
តារាង 6-28 ផែនការការងារលម្អិត .......... 176
តារាង 0-10: ទិដ្ឋភាពនៃសកម្មភាព 1.4: ព្រឹត្តិការ លទ្ធផល និង របាយការណ៍បច្ចេកទេសចជាប់កិច្ចសន្យា .......... 179
តារាង7-1 ផែនការការងារសម្រាប់រយៈពេល៦ខែពីខែសីហា ឆ្នាំ២០១៥ ដល់ខែមករា ឆ្នាំ២០១៦ .......... 208
តារាង 8.1 ៖ កាលបរិច្ឆេទត្រូវបានកែសម្រួលសម្រាប់របាយការណ៍បច្ចេកទេសដែលជាប់កិច្ចព្រមព្រៀង 174

# បញ្ជីក្រាហ្វិច

ក្រាហ្វិច ៖ លទ្ធផល និងជាតុចេញរបស់គម្រោង 1 ... 4
ក្រាហ្វិច ទៅនឹងកញ្ចប់ដទៃទៀត លទ្ធផល និងជាតុចេញរបស់គម្រោង ១៖ ទំនាក់ទំនងនៃកញ្ចប់ទី 2 ... 5
ក្រាហ្វិច 3: រចនាសម្ព័ន្ធក្រុមការងារគម្រោងកញ្ចប់ទី១ និងទំនាក់ទំនងទៅនឹងកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ របស់ប្រទេសកម្ពុជា ... 21
ក្រាហ្វិច 4: រចនាសម្ព័នថ្មីរបស់ក្រសួងបរិស្ថាន និង NCSD ដែលស្ថិតនៅក្រោមរដ្ឋមន្ត្រីក្រសួងបរិស្ថាន ... 23
ក្រាហ្វិច 5: រចនាសម្ព័ន្ធរបស់ NCSD ... 24
ក្រាហ្វិច 6: ទំនាក់ទំនងរវាងជាតុចេញនៃកញ្ចប់ទី១ និង CCCSP ... 26
ក្រាហ្វិច 7: ដំណាក់កាលរបស់ CCCSP និងសកម្មភាពសមស្រប ... 27
ក្រាហ្វិច ៖ ការពិនិត្យលើវិធីសាស្ត្រអនុវត្ត8 ... 42
ក្រាហ្វិច ៖ ចំនុចចាប់ផ្តើម និង៩បករណ៍សម្រាប់ដោះស្រាយ9ភាពធន់នឹងអាកាសធាតុក្នុងវដ្តនៃការកសាងផែនការ ដែលជាផ្នែកមួយនៃវិធីសាស្ត្រកសាងផែនការបន្សុាំ ... 45
ក្រាហ្វិច ៖10 ការបង្កើតក្រុមការងារបច្ចេកទេសបន្សុាំ ... 50
ក្រាហ្វិច 11៖ ការដាក់បញ្ចូលគ្នា DRR និង CCA ... 64
ក្រាហ្វិច 12: ទស្សនទាននៃការដាក់បញ្ចូលការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សុាំការប្រែប្រួលអាកាសធាតុទៅក្នុងវិស័យកសិកម្ម ... 66
ក្រាហ្វិច តបឆ្លើយយុទ្ធសាស្ត្រវិធីកម្មរបស់ងារការធ្វើការនេះ ប្រព័ន្ធ13 នឹងការប្រែប្រួលអាកាសធាតុតាមបណ្តាលខេត្ត ទាំង៦របស់គម្រោងវិនិយោគ ... 68
ក្រាហ្វិច ៖14ប្រព័ន្ធនៃការវាយតម្លៃចម្រុះក្នុងខេត្តពីរ ដែលជាខេត្តដំបូងក្នុងការអនុវត្តគម្រោង ... 73
ក្រាហ្វិច ៖ សំបុកពីងពាងសរុបពិន្ទុៈជាមធ្យម157S សម្រាប់ក្រសួងសំខាន់ទាំងប្រាំ ... 82
ក្រាហ្វិច ៖ ការអនុវត្តការគ្រប់គ្រងនិយមន័យចំណេះដឹងសំខាន់16 ... 89
ក្រាហ្វិច ៖ ប្រព័ន្ធគ្រប់គ្រងចំណេះដឹង17 ... 91
ក្រាហ្វិច ៖ ចំណុចចូលរួមដើម្បីបង្កើនការរៀនអំពីការប្រែប្រួលអាកាសធាតុ18 ... 94
ក្រាហ្វិច ៖ ការវាយតម្លៃភាពងាយរងគ្រោះនិងបន្សុាំទៅនឹងវិធីសាស្ត្រ19ICEM របស់(CAM) ... 109
ក្រាហ្វិច ៖ ទិដ្ឋភាពទូទៅនៃ20 TA8179 កញ្ចប់ទី1 ចន្លោការងារនិងសកម្មភាព ... 117
ក្រាហ្វិច ៖21 ការពិនិត្យឡើងវិញបច្ចេកទេសដែលជាប់កិច្ចព្រមព្រៀង និងដំណើរការអនុម័ត ... 215
ក្រាហ្វិច សដែលជាប់កិច្ចព្រមព្រៀង៖ ដំណើរការអនុម័តរបាយការណ៍បច្ចេកទេ22 ... 216

# បញ្ជីរូបភាព

រូបភាព ៖ ទីតាំងគម្រោងវិនិយោគ1 SPCR ... 56
រូបភាព 2: តំបន់អេកូឡូស៊ីនៃប្រទេសកម្ពុជា ... 58
រូបភាព 3: ខេត្តដែលត្រូវបានជ្រើសរើសសម្រាប់គម្រោងអនុវត្តន៍ ... 58

# 1 សេចក្តីផ្តើម

## 1.1 គោលបំណងនៃគម្រោង

1. របាយការណ៍ចាប់ផ្តើមគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសស្តីពី ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផ្ទើផែនការអភិវឌ្ឍន៍ (TA 8179-CAM) កញ្ចប់ទី ១ ត្រូវបានរៀបចំឡើងដោយ មជ្ឈមណ្ឌលអន្តរជាតិដើម្បីគ្រប់គ្រងបរិស្ថាន សម្រាប់ក្រសួងបរិស្ថាន ធនាគារអភិវឌ្ឍន៍អាស៊ី និងក្រសួងពាក់ព័ន្ធដទៃទៀត ។

2. គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស TA 8179 កញ្ចប់ទី ១ មានរយៈពេល ៤,៥ ឆ្នាំ ស្ថិតនៅក្រោមការដឹកនាំដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន និងចាត់ចែងដោយធនាគារអភិវឌ្ឍន៍អាស៊ី ។ គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសនេះ គឺអនុវត្តដោយក្រសួងបរិស្ថាន ដែលមានការគាំទ្របច្ចេកទេសដោយ ជាផ្នែកមួយនៃកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ(SPCR) នៅកម្ពុជា ។ គម្រោងនេះមានគោលបំណង ពង្រឹងសមត្ថភាពស្ថាប័ន និងបច្ចេកទេស ដើម្បីសមាហរណកម្មការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សុាំ ទៅក្នុងការរៀបចំផ្ទើផែនការអភិវឌ្ឍន៍ ។

3. របាយការណ៍ចាប់ផ្តើមគម្រោងនេះមាន គោលបំណងបីសំខាន់ៗ ដូចជាៈ
   (i) ដើម្បីជម្រាបជូនគ្រប់ដៃគូរពាក់ព័ន្ធទាំងអស់អំពីអភិក្រមដែលបានស្នើឡើងដោយទីប្រឹក្សាបច្ចេកទេស ដើម្បីអនុវត្តគម្រោងឲ្យបានជោគជ័យ ជាពិសេសឆ្លើយតបទៅនឹងការពិគ្រោះយោបល់ ដែលបានរៀបចំឡើងក្នុងដំណាក់កាលរៀបចំគម្រោង
   (ii) ដើម្បីបង្ហាញឲ្យឃើញពីបញ្ហាប្រឈមទាំងឡាយ ដែលជាឧបសគ្គដល់ការអនុវត្តគម្រោង និងលើកឡើងពីអនុសាសន៍ដំណោះស្រាយ ដើម្បីជម្នះរាល់បញ្ហាប្រឈមនេះ និង
   (iii) ដើម្បីកត់ត្រាអំពីព្រឹត្តិការណ៍ និងសកម្មភាព TA ក្នុងអំឡុងពេលនៃដំណាក់កាលរៀបចំគម្រោង គឺចាប់ពី ខែកុម្ភៈ ដល់ខែឧសភា ២០១៥

4. ជាសង្ខេប របាយការណ៍នេះមានគោលបំណង បង្ហាញជូនពីវិធីសាស្ត្រជាក់លាក់ ដើម្បីអនុវត្តគម្រោងឲ្យជោគជ័យ រហូតដល់ចុងបញ្ចប់នៃគម្រោងនៅខែមេសា ២០១៩។

## 1.2 ទម្រង់របាយការណ៍

5. របាយការណ៍នេះ ត្រូវបានចែកចេញជាជំពូក គឺមានលក្ខណៈជាលំហូរ ទៅតាមវិធីសាស្ត្រនៃការអនុវត្តគម្រោងៈ
   (i) អំពីគម្រោងៈ លក្ខណៈទូទៅនៃគម្រោង
   (ii) កម្ពុជា និងការប្រែប្រួលអាកាសធាតុៈ បរិបទនៃបទពិសោធន៍អតីតកាល និងប្រភពទិន្នន័យនៅកម្ពុជា ដើម្បីលើកឡើងពីភាពងាយរងគ្រោះ និងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ
   (iii) បរិបទស្ថាប័នៈ ការពណ៌នាពីរចនាសម្ព័ន្ធស្ថាប័ន គោលនយោបាយ និងយុទ្ធសាស្ត្រដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំង រចនាសម្ព័ន្ធថ្មីក្នុងក្រសួងបរិស្ថាន

(iv) អភិក្រមៈ យុទ្ធសាស្ត្រសំខាន់ៗ សម្រាប់អនុវត្តន៍គម្រោង រួមមាន ហេដ្ឋារចនាសម្ព័ន្ធបៃតង ទីតាំងភូមិសាស្ត្រ ការចូលរួមជាមួយគម្រោងវិនិយោគ SPCR ដទៃទៀត ការវាយតម្លៃចម្រុះហេដ្ឋារចនាសម្ព័ន្ធ ការស្វែងរកមូលនិធិអាកាសធាតុ ការកសាងសមត្ថភាព និងការគ្រប់គ្រង និងផ្សព្វផ្សាយចំណេះដឹង

(v) វិធីសាស្ត្រអនុវត្តន៍ដែលនឹងប្រើប្រាស់ដោយគម្រោងនេះ រួមមាន អនុសាសន៍គោលនយោបាយ និងនីតិក្រម ការប្រើប្រាស់ទិន្នន័យអាកាសធាតុ ការវាយតម្លៃភាពងាយរងគ្រោះនិងបន្សាំ ការកសាងសមត្ថភាព និងការគ្រប់គ្រងចំណេះដឹង

(vi) ដំណើរការអនុវត្តន៍ រួមមាន ការកែតម្រូវនៃដំណាក់កាលអនុវត្តន៍ និងការគ្រប់គ្រងការងារ និងផលិតផល ព្រមទាំងការពិពណ៌នាពីវិធីសាស្ត្រសូចនាករ និងទិន្នន័យនៃការត្រួតពិនិត្យ និងវាយតម្លៃ

(vii) សេចក្តីពង្រាងផែនការសម្រាប់រយៈ ៦ខែបន្ទាប់

(viii) អនុសាសន៍ ដើម្បីបង្កើនការអនុវត្តឲ្យមានប្រសិទ្ធិភាពខ្ពស់ រួមមាន ការកែតម្រូវទៅតាមក្របខណ្ឌត្រួតពិនិត្យគម្រោង ពិធីសារគ្រប់គ្រងគម្រោង និងសហប្រតិបត្តិការ។

6. របាយការណ៍នេះ រួមបញ្ចូលឧបសម្ព័ន្ធជាច្រើន ដែលចងក្រងដាច់ដោយឡែក ដូចជា ឧបសម្ព័ន្ធទី៥ (ព័ត៌មានបន្ថែមអំពីក្រសួង SPCR) ឧបសម្ព័ន្ធទី៨ (ការវាយតម្លៃតម្រូវការកសាងសមត្ថភាពសម្រាប់ក្រសួង SPCR) ឧបសម្ព័ន្ធទី៩ (ផែនការគ្រប់គ្រងចំណេះដឹង និងការចូលរួមរបស់អ្នកពាក់ព័ន្ធ) និង ឧបសម្ព័ន្ធទី១០ (ការព្យាការការប្រែប្រួលអាកាសធាតុសម្រាប់កម្ពុជា) ។

# 2 អំពីគម្រោង

## 2.1 លទ្ធផល និងគោលដៅ

7. ផលប៉ះពាល់រំពឹងទុកនៃTA នេះ គឺថាប្រទេសកម្ពុជាបានបង្កើនភាពធន់នឹងវិសមរូបអាកាសធាតុ និងការប្រែប្រួលអាកាសធាតុដែលក្នុងនោះជួយជំរុញមុខរបរចិញ្ចឹមជីវិតឲ្យកាន់តែប្រសើរឡើង ជាពិសេស ក្រុមងាយរងគ្រោះ ដូចជា ស្ត្រី និងកុមារ។ លទ្ធផលរំពឹងទុកនៃTA នេះ គឺថា សមត្ថភាពបច្ចេកទេស និងស្ថាប័ននឹងមាននិរន្តរភាព ដើម្បីធ្វើសមាហរន្តកម្មកម្មវិធីបន្សាំទៅក្នុងផែនការអភិវឌ្ឍន៍។ ជាងនេះទៅទៀត នៅពេលបញ្ចប់នៃគម្រោង យើងនឹងរំពឹងថាៈ

(១) ឧបករណ៍វិភាគហានិភ័យនឹងត្រូវអនុវត្តសម្រាប់រាល់គម្រោងនៃវិស័យ ធារាសាស្ត្រ ការបង្ការទឹកជំនន់ កសិកម្ម ជីវចម្រុះ ផ្លូវ ការផ្គត់ផ្គង់ទឹកនិងអនាម័យ និងការអភិវឌ្ឍជីក្រុង

(២) ការវាយតម្លៃភាពងាយរងគ្រោះដែលត្រូវបានដាក់បញ្ចូល នូវព័ត៌មានអាកាសធាតុ នឹងត្រូវបានអនុវត្តចំពោះគម្រោងទាំងឡាយណាដែលបានវិភាគឃើញថា មានហានិភ័យនៅក្នុងវិស័យសំខាន់ៗ ។

8. គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស TA 8179 កញ្ចប់ទី ១ មានធាតុចេញចំនួន បី ហើយធាតុចេញនីមួយៗមានសកម្មភាព ដូចបានភ្ជាប់នៅក្នុង ឧបសម្ព័ន្ធ ១៖

**លទ្ធផលទី ១ - ពង្រឹងការសម្របសម្រួល SPCR, ការគាំទ្របច្ចេកទេស និងសមត្ថភាព ដើម្បីបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍។**

9. លទ្ធផលទី១ មាន១១ សកម្មភាព និងផ្តោតលើការកសាងសមត្ថភាព អ្នកកសាងគោលនយោបាយនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត បុគ្គលិកបច្ចេកទេស និងអង្គការសង្គមស៊ីវិល(CSOs) លើភាពធន់នឹងអាកាសធាតុសម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍ ។ លទ្ធផលទី១នេះ នឹងសម្រេចបានតាមរយៈ វគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ការបណ្តុះបណ្តាលពេលកំពុងធ្វើការ និងព្រមទាំងផ្តល់ការគាំទ្រដល់ការសម្របសម្រួល និងការគាំទ្រផ្នែកបច្ចេកទេស សម្រាប់គម្រោងវិនិយោគហេដ្ឋារចនា សម្ព័ន្ធ ។ វានឹងជួយគាំទ្រដល់ការធ្វើបច្ចុប្បន្នភាព គោលការណ៍ណែនាំធ្វើផែនការ និងស្តង់ដារបច្ចេកទេសរៀបចំគម្រោងដែលបានគិតគូរពីភាពធន់ និងបន្សាំនឹងអាកាសធាតុ ។

**លទ្ធផលទី ២ - ធ្វើការសិក្សាពីលទ្ធភាពពិស្តារសម្រាប់រៀបចំគម្រោងបន្សាំ NAPA មួយចំនួន និងការរៀបចំផែនការជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAP)**[1]

10. លទ្ធផលទី ២ រួមមាន ការសិក្សាពីលទ្ធភាពរៀបចំគម្រោងបន្សាំមានអាទិភាពខ្ពស់ ចំនួន ៦ គម្រោង ដែលក្នុងនោះ យ៉ាងហោចណាស់ ២គម្រោងលើកឡើងពីក្រុមងាយរងគ្រោះ ដូចជា ស្ត្រី និងកុមារ និងព្រមទាំង កម្មវិធី SPCR អាទិភាពដែលពុំមានថវិកាដើម្បីអនុវត្ត ។ លទ្ធផលទី ២នេះ នឹងរៀបចំសំណើរគម្រោងបន្សាំ យ៉ាងហោចណាស់ ចំនួន ២ ដែលចេញមកពីលទ្ធផលនៃការសិក្សាពីលទ្ធភាពពិស្តារ ដើម្បីដាក់ស្នើដោយរាជរដ្ឋាភិបាលទៅមូលនិធិបន្សាំអាកាសធាតុសាកលលោក។ចំណុចសំខាន់មួយទៀតនៃ TA កញ្ចប់ទី១ នេះដែលបានលើកឡើងក្នុងពេលដេញថ្លៃ គឺមានបញ្ចូលសកម្មភាពស្តីពីការរៀបចំផែនការជាតិបន្សាំសម្រាប់កម្ពុជា គឺជាផ្នែកមួយនៃដំណើរការរបស់ UNFCCC ដើម្បីបង្ហាញឲ្យឃើញពីយុទ្ធសាស្ត្រ និងតម្រូវការបន្សាំរយៈពេលមធ្យម និងរយៈពេលវែង ។

---

[1] Through the inception phase consultations it was agreed that "NAPA" should be replaced by "adaptation" given that national and sector climate change strategies and action plans have been developed since the NAPA was prepared some ten years ago.

## លទ្ធផលទី ៤[2] - រៀបចំផលិតផលចំណេះដឹងអំពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងផ្សព្វផ្សាយ

11. លទ្ធផលទី៤ នឹងប្រើប្រាស់សកម្មភាពពីលទ្ធផលទី១ និង២ ព្រមទាំងពីប្រភពដទៃទៀត ដើម្បីរៀបចំផលិតចំណេះដឹង និងផ្សព្វផ្សាយព័ត៌មានអំពីអភិក្រម និងលទ្ធផលគម្រោង ។ អភិក្រមទាំងនេះនឹងកសាង និងជួយពង្រឹងក្រសួងបរិស្ថាន និងយន្តការផ្សព្វផ្សាយរបស់ក្រសួងសំខាន់ៗដែលអាចទៅដល់អ្នកពាក់ព័ន្ធ ។ លទ្ធផលនេះនឹងអភិវឌ្ឍប្រព័ន្ធចងក្រង ផ្ទុក និង ផ្សព្វផ្សាយផលិតផលចំណេះដឹងផងដែរ។ វាក៏នឹងរៀបចំករណីសិក្សា និងផលិតផលចំណេះដឹងដែលបង្ហាញពីការអនុវត្តភាពធន់នឹងការប្រែប្រួលអាកាសធាតុទៅតាមករណីនិមួយៗ និងឆ្លើយតបទៅតាមយេនឌ័រ និងរាប់បញ្ចូលចំណេះដឹងប្រពៃណី និងជនជាតិដើមភាគតិច ។ លទ្ធផលនេះនឹងគាំទ្រការផ្តួចផ្តើមដល់ការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាថ្នាក់មធ្យមសិក្សា និងឧត្តមសិក្សា ដែលទាក់ទងនឹងភាពធន់នឹងអាកាសធាតុ និងជួយបង្កើតជាកម្លាំងចលករួមជាមួយកម្មវិធីការប្រែប្រួលអាកាសធាតុដទៃទៀត និងព្រមទាំងពឹងផ្អែកលើចំណេះដឹងដែលបង្កើតឡើងដោយគម្រោងនេះ ។

### ក្រាហ្វិច 1 ៖ លទ្ធផល និងធាតុចេញរបស់គម្រោង




12. TA នេះក៏មានធាតុចេញ(លទ្ធផល)មួយផ្សេងទៀតផងដែរ ដែលកំពុងត្រូវបានអនុវត្តដោយអង្គការផ្លែនអន្តរជាតិ (Plan International) នៅក្រោមកញ្ចប់ទី២នៃ TA នេះ។ នោះគឺ៖ *ធាតុចេញ (លទ្ធផល)ទី៣-ពង្រឹងយន្តការគាំទ្រសង្គមស៊ីវិល និងសមត្ថភាពរបស់ អង្គការមិនមែនរដ្ឋាភិបាល*

[2] Output 3 is being implemented by Plan International and focuses on CBA capacity building and a small grant program.

*(NGOs) និងអង្គការសង្គមស៊ីវិល (CSOs) ដើម្បីបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុ (CCA) និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR) ទៅក្នុងប្រតិបត្តិការរបស់ខ្លួន។*

13. កញ្ចប់សកម្មភាពបន្ថែមមួយទៀត(កញ្ចប់ទី៣)ស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ និងការតាមដាន និងវាយតម្លៃ កំពុងស្ថិតក្នុងការរៀបចំ នឹងត្រូវអនុវត្តស្របជាមួយកញ្ចប់ទី១ និង ២ ផងដែរ។ កិច្ចប្រតិបត្តិការ និងការសម្របសម្រួលផ្នែកបច្ចេកទេសយ៉ាងជិតស្និទ្ធ និងកិច្ចសហការ នឹងត្រូវការចាំបាច់ រវាងក្រុមនៃកញ្ចប់ ១ ២ និង ៣។

14. ទិដ្ឋភាពទូទៅនៃទំនាក់ទំនងសកម្មភាពរវាងកញ្ចប់ទាំងបីនេះ មានបង្ហាញនៅ។

**ក្រាហ្វិច 2 ៖ ទំនាក់ទំនងនៃកញ្ចប់ទី១ ទៅនឹងកញ្ចប់ដទៃទៀត លទ្ធផល និងធាតុចេញរបស់គម្រោង**




15. ដូច្នេះ កញ្ចប់ទាំងបីរួមមាន៖

ក. កញ្ចប់ទី១ ផ្តោតទៅលើការសម្របសម្រួលកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ និងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ ក្នុងក្រសួងទាំង ៥ ដែលអនុវត្តកម្មវិធីយុទ្ធសាស្ត្រភាពធន់អាកាសធាតុ ការអភិវឌ្ឍគម្រោងបន្សាំផ្សេងៗដែលជាការអនុវត្តតាម NAPA/NAP ព្រមទាំងអភិវឌ្ឍផលិតផលចំណេះដឹង និងផ្សព្វផ្សាយ ដែលរួមមាន ការអភិវឌ្ឍកម្មវិធីសិក្សាកម្រិតសាកលវិទ្យាល័យផងដែរ។

ខ កញ្ចប់ទី ២ គាំទ្រទៅដល់សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល។ វាមានគោលបំណងដើម្បីជួយបង្កើតក្របខណ្ឌថ្នាក់ជាតិមួយសម្រាប់ឲ្យមានការចូលរួមពីអង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងសាធារណជននៅក្នុងដំណើរការដែលមានការចូលរួមមួយ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុដែលគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព។ គោលបំណងរបស់វា

គឺ ដើម្បីកសាងសហគមន៍ដែលមានសុវត្ថិភាព និងភាពធន់ ដែលក្នុងនោះមានការចូលរួមយ៉ាងសកម្មពីបុរស ស្ត្រី កុមារា និងកុមារី នៅក្នុងការគ្រប់គ្រងហានិភ័យនៃការប្រែប្រួលអាកាសធាតុមួយដែលមានគោលបំណងដាក់លាក់ក្នុងការពង្រឹងសមត្ថភាពអង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល ជាពិសេសនៅក្នុងតំបន់នៃប្រទេសកម្ពុជាដែលងាយរងគ្រោះបំផុតពីអាកាសធាតុ ដើម្បីអនុវត្តសកម្មភាពបន្សាំការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដោយផ្អែកលើសហគមន៍ ព្រមទាំងដើម្បីបញ្ជ្រាបការបន្សាំ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយចូលទៅក្នុងប្រតិបត្តិការរបស់ខ្លួន។ គម្រោងនេះនឹងមានលទ្ធផលសំខាន់ពីរនៅក្នុងការបណ្តុះបណ្តាលអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសហគមន៍ ពីផលប៉ះពាល់ និងភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងគោលនយោបាយនិងជម្រើសការបន្សាំ ឧបករណ៍សម្រាប់វាយតម្លៃការបន្សាំដោយផ្អែកលើសហគមន៍ (CBA) ព្រមទាំងការអភិវឌ្ឍគម្រោង និងការគ្រប់គ្រងវដ្តគម្រោង និងការអនុវត្តគម្រោងជំនួយខ្នាតតូចដែលស្ថិតលើបរិបទCBA ។ វានឹងអភិវឌ្ឍ និងផ្សព្វផ្សាយផលិតផលចំណេះដឹងស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុដោយផ្អែកលើសហគមន៍ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

គ. កញ្ចប់ទី៣គឺរួមមាន ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ នៅក្នុងកម្រិតថ្នាក់ក្រោមជាតិ (MoI/NCDD) ដោយដាក់បញ្ចូលយ៉េនឌ័រក្នុងការបន្សាំការប្រែប្រួលអាកាសធាតុ (MOWA) និងការត្រួតពិនិត្យ ព្រមទាំងការរាយការណ៍ និងវាយតម្លៃគម្រោងវិនិយោគការប្រែប្រួលអាកាសធាតុ (MOP/NIS)។ គម្រោងនេះរំពឹងទុកថានឹងចាប់ផ្តើមនៅចុងឆ្នាំ ២០១៥ នេះ។

16. ផ្នែកផ្សេងៗដែលត្រូវសហការក្នុងចំណោមកញ្ចប់ជំនួយបច្ចេកទេសទាំងបីនេះមាន៖

ក. ការវាយតម្លៃភាពងាយរងគ្រោះគឺត្រូវបានធ្វើឡើងដើម្បីគម្រោងដែលមានហានិភ័យ។ ការវាយតម្លៃភាពងាយរងគ្រោះតាមវិធីសាស្ត្រពីមជ្ឈិម (មជ្ឈការ) និងពីមូលដ្ឋាន (វិមជ្ឈការ) ការសហប្រតិបត្តិការជាមួយសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល (កញ្ចប់ទី២) និងរដ្ឋបាលថ្នាក់ក្រោមជាតិ គឺចំបាច់ណាស់។

ខ. ការបញ្ជ្រាបយ៉េនឌ័រទៅក្នុងគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ ការសហការជាមួយនឹងកញ្ចប់ទី៣ ដើម្បីធានាថា ក្តីកង្វល់ពីយ៉េនឌ័រត្រូវបានដាក់បញ្ចូលយ៉ាងបានពេញលេញទៅក្នុងការសិក្សាពីលទ្ធភាព។

គ. ការត្រួតពិនិត្យ និងវាយតម្លៃ៖ កញ្ចប់ទី១ផ្តោតទៅលើការត្រួតពិនិត្យ និងវាយតម្លៃទៅលើសូចនាករជំនួយបច្ចេកទេស DMF និងជួយក្នុង ១) ការគ្រប់គ្រង និងការអភិវឌ្ឍបណ្តុំទិន្នន័យទូលំទូលាយមួយសម្រាប់ត្រួតពិនិត្យសូចនាករ និងលទ្ធផលនៃគម្រោងវិនិយោគកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុទាំង៧ និង ២) កំណត់ទិសដៅការអនុវត្ត និងសូចនាកររបស់វា ដែលរួមមាន សូចនាកររបស់យ៉េនឌ័រសម្រាប់គម្រោងវិនិយោគទាំង ៧ នៃកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ ដោយមានកិច្ចសហប្រតិបត្តិការពីមកពី

ក្រុមការងារបច្ចេកទេស នៃគម្រោងវិនិយោគកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ និងទាំងមកពីកញ្ចប់ទី៣ ផងដែរ។

17. ក្រសួងបរិស្ថានមានតួនាទីសម្របសម្រួលទូទៅទៅលើការប្រែប្រួលអាកាសធាតុអន្តរក្រសួងដែលទទួលខុសត្រូវអនុវត្តដោយនាយកដ្ឋានការប្រែប្រួលអាកាសធាតុនៃក្រសួង។ តួនាទី និងភារៈកិច្ចរបស់ក្រុមប្រឹក្សាយោបល់ ICEM គឺគាំទ្រ និងជួយក្រសួងបរិស្ថានអនុវត្តកញ្ចប់ទី១ និងជួយក្នុងការកសាងសមត្ថភាពរបស់អាជ្ញាធរ CCD។ ខណៈពេលដែលមានភាពមិនប្រក្រតីមួយចំនួននៅក្នុងការរាយការណ៍ជាបណ្តាញស្ថាប័នសម្រាប់គម្រោងនេះ វាច្បាស់ណាស់ថាជំនួយបច្ចេកទេសផែនការយុទ្ធសាស្ត្រភាពធន់អាកាសធាតុគឺជាផ្នែកសំខាន់មួយនៃនាយកដ្ឋានប្រែប្រួលអាកាសធាតុ និងកម្មវិធីរបស់ខ្លួនក្នុងការងារនេះ។ សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) ចំបាច់ណាស់ក្នុងការបង្កើតការរៀបចំការងារពីមួយថ្ងៃទៅមួយថ្ងៃដោយមានការសហការជាមួយនឹងគំនិតផ្តួចផ្តើមរបស់ CCD ។

18. កម្មវិធីផែនការយុទ្ធសាស្ត្រភាពធន់អាកាសធាតុកំណត់វិស័យគន្លិះសំខាន់ចំនួនបីដែលផ្តោតលើះ

- ធនធានទឹក
- វិស័យកសិកម្ម
- ហេដ្ឋារចនាសម្ព័ន្ធដែលផ្តោតលើការដឹកជញ្ជូន (ផ្លូវថ្នល់) និងហេដ្ឋារចនាសម្ព័ន្ធទីក្រុង

19. ក្រសួងបរិស្ថានជាក្រសួងសាមីលើគម្រោងនេះ ហើយបានកំណត់យកក្រសួងដៃគូរបួនសំខាន់ផ្សេងទៀតក្នុងធ្វើសកម្មភាពបញ្ជ្រាបះ

- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងសាធារណៈការ និងដឹកជញ្ជូន
- ក្រសួងអភិវឌ្ឍន៍ជនបទ

20. ភ្នាក់ងារអនុវត្តផ្សេងទៀតនៃជំនួយបច្ចេកទេសមានដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រសួងមហាផ្ទៃ ជាពិសេសគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

21. កត្តាសំខាន់ផ្តោតទៅលើការកសាងភាពធន់អាកាសធាតុនៅក្នុងវិស័យ និងភ្នាក់ងារផ្សេងៗ ទាំងនោះរួមបញ្ចូលផងដែរនូវហេដ្ឋារចនាសម្ព័ន្ធ។ ហេដ្ឋារចនាសម្ព័ន្ធត្រូវបានគិតគូរខ្លាំងបំផុត ដែលរួមបញ្ចូលរចនាសម្ព័ន្ធរូបវន្ត ជីវវិស្វកម្ម និងការបន្សាំដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ី ព្រមទាំងការអន្តរាគមលើចំណេះដឹង ការគ្រប់គ្រង និងអន្តរាគមទំរង់ដទៃទៀតនៃការអភិវឌ្ឍ ដូចជា ទំលាប់ធ្វើកសិកម្ម និងការអនុវត្ត ឬវិធានការការអភិរក្សធនធានទឹក និងគ្រប់គ្រងទីជម្រាល។ ទាំងនេះនឹងត្រូវបានចាត់ទុកជាកន្លែងដែលសមស្របមួយ ហើយទាមទារឲ្យមានការអនុវត្តដោយក្រសួង

សំខាន់ៗ។ ទិសដៅរួមនៃជំនួយបច្ចេកទេសនេះគឺ ដើម្បីឆ្ពោះទៅរកការបញ្ជ្រាបភាពធន់អាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងការធ្វើផែនការ និងម្រោងការអភិវឌ្ឍ។

22. គម្រោងនេះផ្តោតសំខាន់លើការគាំទ្រដល់ក្រសួង និងមន្ទីរចំណុះក្រសួងអំពីរបៀបដែលផែនការអភិវឌ្ឍ និងគម្រោងរបស់ពួកគេអនុវត្តនៅក្នុងទីវាលលើការប្រែប្រួលអាកាសធាតុ។ គម្រោងនេះគឺមិនត្រូវបានផ្តោតទៅលើការបន្សាំដោយផ្អែកលើសហគមន៍នោះទេ បើទោះជាវាមានសារៈសំខាន់ចំពោះភ្នាក់ងាររដ្ឋាភិបាលជាតិតាមវិស័យក្នុងការបន្តអាណត្តិរបស់ខ្លួន។ ការវាយតម្លៃភាពងាយរងគ្រោះ និងការធ្វើផែនការបន្សាំបានធ្វើឡើងជាផ្នែកមួយនៃភ្នាក់ងាររដ្ឋាភិបាលនៅថ្នាក់ជាតិ និងមានការចូលរួមជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងសហគមន៍តែតម្រូវឱ្យមានវិធីសាស្រ្តសម្រាប់ធ្វើវា ដែលគម្រោងនេះត្រូវបានផ្តោតទៅលើការកសាងសមត្ថភាពក្នុងស្ថាប័នជាតិ ហើយផ្ទេរទៅឱ្យភ្នាក់ងារថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធផ្សេងទៀតតាមរយៈស្ថាប័នជាតិនេះ ។

23. ការកសាងសមត្ថភាពជាវិធីសាស្រ្តគោលការណ៍សម្រាប់បញ្ជ្រាបភាពធន់អាកាសធាតុនៅក្នុងក្រសួងទាំងនេះ។ ការកសាងសមត្ថភាពគឺមិនមែនគ្រាន់តែបណ្តុះបណ្តាល និងអភិវឌ្ឍជំនាញរបស់បុគ្គលិកបច្ចេកទេសនោះទេ តែវាគួរតែដោះស្រាយឱ្យបានទូលំទូលាយចំពោះបញ្ហាប្រឈម និងឱកាសសម្រាប់បញ្ជាក់ភស្តុតាងចេញពីអាកាសធាតុនៅក្នុងការធ្វើផែនការអភិវឌ្ឍន៍។ បញ្ហាប្រឈមអាចមានទាក់ទងទៅនឹងឧបសគ្គក្នុងស្ថាប័ន ឬគោលនយោបាយដូចជា កង្វះនូវយុត្តិកម្មហិរញ្ញវត្ថុ និងសេដ្ឋកិច្ចសម្រាប់វិធានការបន្សាំ យន្តការ និងការលើកទឹកចិត្តបុគ្គលិកដើម្បីលើកទឹកចិត្តក្នុងការផ្តួចផ្តើមការបន្សាំ ព្រមទាំងភាពខ្វះខាតព័ត៌មាន និងឧបករណ៍សម្រាប់ធ្វើការវាយតម្លៃភាពងាយរងគ្រោះ និងការបន្សាំ។ ការបណ្តុះបណ្តាលគឺជាយុទ្ធសាស្រ្តសំខាន់មួយសម្រាប់ការកសាងសមត្ថភាព។ ដូចគ្នានេះផងដែរក៏នៅមានគោលនយោបាយ ការបង្កើតរចនាសម្ព័ន្ធថ្មី ការណែនាំនៃឧបករណ៍ថ្មី នីតិវិធី និងបទដ្ឋានស្តង់ដា ការបង្កើតថវិកា និងការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ចទៀត។ គ្រប់ទម្រង់នៃការកសាងសមត្ថភាពទាំងអស់នេះគឺជាផ្នែកមួយនៃជំនួយបច្ចេកទេសនេះ។

24. មានឱកាសនៃការកសាងសមត្ថភាពសំខាន់ចំនួន ២ នៅក្នុងក្របខណ្ឌការងារនៃផែនការយុទ្ធសាស្រ្តភាពធន់អាកាសធាតុ ដែលឱកាសទាំងពីរនេះនឹងផ្តល់មូលដ្ឋានគ្រឹះសម្រាប់ការសិក្សា ក៏ដូចជាករណីសិក្សា និងការបង្កើតថ្មីមួយ។ ទាំងនេះរួមបញ្ចូលទាំងគម្រោងទាំង ៧ របស់ផែនការយុទ្ធសាស្រ្តភាពធន់អាកាសធាតុដែលក្នុងនោះមានដំណាក់កាលនៃការអនុវត្តផ្សេងគ្នា និងដោយប្រើវិធីសាស្រ្តក្នុងការវាយតម្លៃភាពងាយរងគ្រោះ និងការបន្សាំការប្រែប្រួលអាកាសធាតុផ្សេងៗគ្នា។ ជំនួយបច្ចេកទេសនេះនឹងធ្វើការលើគម្រោងទាំងនេះ និងប្រើវាជាគំរូមួយសម្រាប់ការបណ្តុះបណ្តាល និងជាលំហាត់នៅទីវាលជាមួយនឹងក្រសួងសាម៉ី និង ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តផែនការយុទ្ធសាស្រ្តភាពធន់អាកាសធាតុផ្សេងទៀត។

25. ឱកាសផ្សេងទៀតគឺត្រូវការក្នុងការរៀបចំការសិក្សាលទ្ធភាពដែលអាចធ្វើទៅបាន និងគម្រោងសំណើសម្រាប់គម្រោងបន្សាំការប្រែប្រួលអាកាសធាតុ (គម្រោងក្នុង NAPA និង NAP)។ ការ

អភិវឌ្ឍសំណើទាំងនេះនឹងត្រូវបានអនុវត្តជាមួយក្រសួងសាមី ហើយផ្តល់ឱកាសសម្រាប់ធ្វើការឧទហរណ៍នៃការវាយតម្លៃភាពងាយរងគ្រោះ និងផែនការបន្សាំ ជាមួយនឹងការស្វែងរកគោលនយោបាយ និងក្របខ័ណ្ឌនីតិវិធីការងារគាំទ្រទាំងឡាយដែលបានតម្រូវឱ្យមាននៅថ្នាក់ជាតិ ។

## 2.2 សាវតានៃកម្មវិធីយុទ្ធសាស្ត្រភាពធន់នឹងអាកាសធាតុនៅកម្ពុជា

**ប្រអប់ 2.1៖ លទ្ធផល និងការសម្រេចបានសំខាន់ៗក្រោមគម្រោង PPCR ដំណាក់កាលទី១**

- គោលការណ៍ណែនាំស្តីពីការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ និងការកាត់បន្ថយភាពងាយរងគ្រោះក្នុងដំណាក់កាលការធ្វើផែនការវិនិយោគជាតិ (MEF)
- គោលការណ៍ណែនាំស្តីពីការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ និងការកាត់បន្ថយភាពងាយរងគ្រោះក្នុងការធ្វើផែនការថ្នាក់ជាតិ (ក្រសួងផែនការ)
- អត្ថបទពិភាក្សាស្តីពី ទំនាក់ទំនងការប្រែប្រួលអាកាសធាតុ និងការធ្វើផែនការថ្នាក់ជាតិ (ក្រសួងផែនការ)
- ឧបករណ៍វាយតម្លៃបឋមអាកាសធាតុ (ក្រសួងផែនការ)
- ការពង្រឹងរបស់ SPCR ដើម្បីជាការទាញបញ្ចូល CSO ក្នុងការបញ្ជ្រាបការយល់ដឹងពីភាពធន់នៃអាកាសធាតុក្នុងគម្រោង SPCR
- បង្កើតទម្រង់ផែនការមេស្តីពី វិស័យយេនឌ័រ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ (ក្រសួងកិច្ចការនារី)
- វិសាលភាពនៃការសិក្សាក្នុងវិស័យឯកជន៖ លើកកម្ពស់ការចូលរួមរបស់វិស័យឯកជនក្នុងផែនការវិនិយោគការបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- របាយការណ៍សំយោគស្តីពី HMIS សម្រាប់ប្រទេសកម្ពុជា៖ ផ្តោតសំខាន់លើការគ្រប់គ្រងមហន្តរាយធម្មជាតិ និងការបន្សាំលើការប្រែប្រួលអាកាសធាតុ
- របាយការណ៍វិភាគករណីសង្ខេបស្តីពី Value of Multi-Model Downscaled Climate Scenarios សម្រាប់ប្រទេសកម្ពុជា សម្រាប់ការបង្កើតគោលនយោបាយ និងការធ្វើផែនការផ្សេងៗ
- របាយការណ៍វិភាគករណីសង្ខេបស្តីពី ការវាយតម្លៃភាពងាយរងគ្រោះ និងការបន្សាំក្នុងផ្នែកសំខាន់ៗ ដូចជាផ្នែកយុទ្ធសាស្ត្រ និងអនុសាសន៍ក្នុងការកែតម្រូវបន្ថែមជាដើម
- របាយការណ៍លម្អិតស្តីពី និរន្តរភាព និងភាពជាប់ពាក់ព័ន្ធនៃឧបករណ៍គាំទ្រការសម្រេចចិត្តភាពធន់នឹងការប្រែប្រួលអាកាសធាតុពេលបច្ចុប្បន្នក្នុងប្រទេសកម្ពុជា
- ក្របខ័ណ្ឌគោលគំនិតសម្រាប់ការបញ្ចូល SESA ក្នុងគម្រោងភាពធន់ និងការបន្សាំការប្រែប្រួលអាកាសធាតុនៅកម្ពុជា
- សំណើស្រាវជ្រាវសង្ខេបសម្រាប់ការរៀបចំទម្រង់ M&E ក្នុងគម្រោង PPCR ដំណាក់កាលទី២ ក្នុងតម្រូវការសម្រាប់ស្ថាប័ន ToR និងគោលការណ៍ណែនាំបច្ចេកទេស
- ការវាយតម្លៃ Rapid End-User តាមរយៈគេហទំព័ររបស់ PPCR

26. កម្មវិធីសាកល្បងភាពធន់អាកាសធាតុនៃមូលនិធិវិនិយោគការប្រែប្រួលអាកាសធាតុបានផ្តល់ធនធានក្នុងការអភិវឌ្ឍផែនការយុទ្ធសាស្ត្រភាពធន់អាកាសធាតុសាកលលោកមួយ។ ផែនការយុទ្ធសាស្ត្រភាពធន់អាកាសធាតុសម្រាប់ប្រទេសកម្ពុជាបានកំណត់ឱកាសវិនិយោគខ្នាតធំ ព្រមទាំងការពង្រឹងសមត្ថភាពដែល នឹងជំរុញភាពធន់របស់ប្រទេស។ ជំនួយបច្ចេកទេសនេះ (TA 8179-CAM កញ្ចប់ទី១) ជាផ្នែកមួយនៃកម្មវិធី ផែនយុទ្ធសាស្ត្រភាពធន់អាកាសធាតុនៅក្នុងប្រទេសកម្ពុជា ។ ជំនួយបច្ចេកទេសនេះបានកសាងមេរៀនក្នុងអំឡុងដំណាក់កាលដំបូងនៃផែនយុទ្ធសាស្ត្រភាពធន់អាកាសធាតុនៅក្នុងប្រទេសកម្ពុជាដែលត្រូវបានអនុវត្តនៅចន្លោះឆ្នាំ២០១២ និងឆ្នាំ ២០១៣។

### 2.2.1 កម្មវិធីសាកល្បងភាពធន់អាកាសធាតុដំណាក់កាលទី១ (PPCR Phase 1)

27. ដំណាក់កាលទី១ នៃកម្មវិធីសាកល្បងភាពធន់អាកាសធាតុ បានគាំទ្រការបង្កើតក្រុមសម្របសម្រួលអន្តរវិស័យនៃកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR) និងអង្គភាពគាំទ្របច្ចេកទេសកម្មវិធីសាកល្បងភាពធន់អាកាសធាតុ (ស្ថិតនៅក្រសួងបរិស្ថាន)។ អង្គភាពនេះត្រួតពិនិត្យលើការរៀបចំខ្លួនរបស់ស្ថាប័នក្នុងការបញ្ជ្រាបក្តីកង្វល់ពីអាកាសធាតុនៅថ្នាក់ជាតិ និង

ថ្នាក់ក្រោមជាតិ និងកំណត់ឱកាសដើម្បីឲ្យសង្គមស៊ីវិល និងវិស័យឯកជនមានការចូលរួមយ៉ាងមានប្រសិទ្ធភាពដើម្បីដាក់បញ្ចូលការគិតគូរយេនឌ័រទៅក្នុងគម្រោងបន្សុាំ។ ការវាយតម្លៃភាពងាយរងគ្រោះនៅក្នុងខេត្តដែលបានជ្រើសរើសត្រូវបានធ្វើឡើងដើម្បីជាមូលដ្ឋាន សម្រាប់ការរៀបចំធ្វើផែនការគម្រោងបន្សុាំនេះឲ្យមានប្រសិទ្ធភាព។

28. ផលិតផល និងសមិទ្ធផលសំខាន់ៗរបស់គម្រោងPPCR ដំណាក់កាលទី១ បានសង្ខេបជូនក្នុងប្រអប់ ២.១។ គម្រោង ដំណាក់កាលទី២នេះ នឹងអនុវត្តដោយផ្អែកទៅតាមសមិទ្ធផលទាំងនេះ។

## 2.3 ផែនការយុទ្ធសាស្ត្រសម្រាប់ភាពធន់អាកាសធាតុ

### *2.3.1 គម្រោងវិនិយោគកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ*

29. កម្ពុជាត្រូវបានចាត់ទុកថាងាយរងគ្រោះខ្លាំងពីផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុដោយសារតែសេដ្ឋកិច្ចកម្ពុជាអាស្រ័យទៅលើវិស័យ ដែលពឹងផ្អែកលើអាកាសធាតុដែលងាយប្រែប្រួល និងប្រព័ន្ធសន្សុាំ និងសមត្ថភាពប្រជាជននៅមានកម្រិតទាប ដូច្នេះទើបអនុគណៈកម្មការនៃកម្មវិធីសាកល្បងភាពធន់អាកាសធាតុបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រសម្រាប់ភាពធន់អាកាសធាតុកម្ពុជានៅខែមិថុនា ឆ្នាំ២០១១។ ការបែងចែកជំនួយ និងឥណទានទៅឲ្យកម្មវិធីសាកល្បងភាពធន់អាកាសធាតុ ជាមួយនឹងប្រភពថវិការបន្ថែមសម្រាប់គម្រោងវិនិយោគផែនការយុទ្ធសាស្ត្រសម្រាប់ភាពធន់អាកាសធាតុមានរៀបរាប់នៅក្នុងតារាង៣.៣។ ចំនួនទឹកប្រាក់សរុបរបស់កម្មវិធីសាកល្បងភាពធន់អាកាសធាតុ ដែលផ្តល់ទៅឲ្យកម្ពុជាគឺមានទៅដល់ ៩៦ លានដុល្លាអាមេរិក (៦០ លានដុល្លាជាជំនួយ និង៣៦ លានជាឥណទាន ហើយ៥ លានដុល្លាកំពុងស្ថិតក្នុងការបែងចែកនៅឡើយ)។ ម្យ៉ាងវិញទៀត គម្រោងវិនិយោគនៃផែនការយុទ្ធសាស្ត្រសម្រាប់ភាពធន់អាកាសធាតុ បានគៀងគរថវិកាចំនួន ៤៦៣,៣១ លានដុល្លារបន្ថែម និង ៥៣ លានដុល្លារបានមកពីរដ្ឋាភិបាល ហើយទឹកប្រាក់សរុបទាំងអស់មានចំនួន ៥៥៤,៣១ លានដុល្លារ។

30. សមាសភាពជំនួយនៃកម្មវិធីសាកល្បងសម្រាប់ភាពធន់អាកាសធាតុ (PPCR) មានបំណងធ្វើការអន្តរាគមន៍ផ្នែកចំណេះដឹង/ភាពទន់ ដូចជាគាំទ្រលើគោលនយោបាយ ការប្រឹក្សា និងការពង្រឹងសមត្ថភាពខណៈពេលដែលគោលបំណងសំខាន់នៃការផ្តល់ឥណទានផ្តោតទៅលើការធ្វើឲ្យប្រសើរឡើងនូវភាពធន់នៃហេដ្ឋារចនាសម្ព័ន្ធ។

31. នៅក្នុងការកែសម្រួលផែនការយុទ្ធសាស្ត្រភាពធន់អាកាសធាតុនៅខែធ្នូ ឆ្នាំ២០១៣ បានស្នើឡើងមិនឲ្យបញ្ចូលគម្រោងភាពធន់អាកាសធាតុទៅនឹងធនធានទឹកទៅក្នុង ផែនការយុទ្ធសាស្ត្រភាពធន់នឹងអាកាសធាតុ (ការគ្រប់គ្រងហានិភ័យពីអាកាសធាតុ និងការធ្វើឲ្យប្រសើរឡើងនូវគម្រោងធារាសាស្ត្រក្នុងខេត្តកំពង់ធំ បន្ទាយមានជ័យ និងសៀមរាប) ហើយដាក់បញ្ចូលជំនួសវិញនូវគម្រោងភាពធន់នឹងអាកាសធាតុនៃហេដ្ឋារចនាសម្ព័ន្ធ គឺគម្រោងលេខ ៤ ដែលផ្តោតលើភាពធន់អាកាសធាតុលើហេដ្ឋារចនាសម្ព័ន្ធជនបទក្នុងខេត្តកំពង់ចាម ដែលជាផ្នែកមួយនៃគម្រោងនៃការធ្វើ

ឲ្យប្រសើរឡើងផ្លូវថ្នល់ជនបទ (RRIP II) ក្រោមក្រសួងអភិវឌ្ឍន៍ជនបទ។ គម្រោងចំនួន ៥ ក្នុងចំណោមគម្រោងទាំង ៨ របស់ផែនការយុទ្ធសាស្ត្រភាពធន់អាកាសធាតុត្រូវបានអនុម័តដោយអនុគណៈកម្មការកម្មវិធីសាកល្បងសម្រាប់ភាពធន់អាកាសធាតុ (PPCR) និងក្រុមប្រឹក្សាភិបាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ព័ត៌មានលម្អិតអំពីស្ថានភាពបច្ចុប្បន្ននៃការអនុវត្តគម្រោងផែនការយុទ្ធសាស្ត្រភាពធន់អាកាសធាតុដែលបានអនុម័តមាននៅក្នុងតារាង៤.៣ ហើយព័ត៌មាននៃវត្ថុបំណង និងសកម្មភាពសំខាន់ៗត្រូវបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ២។

32. គម្រោងវិនិយោគនៃវិស័យឯកជននៅកម្ពុជាចំនួន ២ ត្រូវបានបង្កើតឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់ផ្តល់ជំនួយតាមរយៈ CIF "មូលនិធិប្រកួតប្រជែងនៃកម្មវិធីសាកល្បងសម្រាប់ភាពធន់អាកាសធាតុ"។ គម្រោងទាំងនោះគឺ ការដាក់បញ្ចូលភាពធន់អាកាសធាតុទៅក្នុងគម្រោងចង្វាក់តម្លៃស្រូវរបស់សហគមន៍នៅកម្ពុជា និងគម្រោងប្រមូលទឹកភ្លៀង និងការបើកទឹកក្នុងជារាសាស្ត្រដើម្បីឲ្យបានផលិតផលដំណាំមានតម្លៃខ្ពស់នៅក្នុងប្រទេសកម្ពុជា។ គម្រោងទាំងនោះគ្រោងនឹងអនុវត្តចាប់ពីឆ្នាំ ២០១៥ នេះតទៅ។ ក្រុមការងារ TA 8179 នឹងគួរលើបទពិសោធន៍ក្នុងគម្រោងវិស័យឯកជនក្នុងវិធីដែលស្រដៀងគ្នាទៅនឹងគម្រោងវិនិយោគរបស់យុទ្ធសាស្ត្រភាពធន់នឹងអាកាសធាតុផ្សេងទៀតដែរ ហើយឲ្យពួកគេចូលរួមក្នុងសកម្មភាពរបស់គម្រោងឲ្យបានសមស្រប។ ទាំងនេះគឺត្រូវបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ២។

### *2.3.2 ការសម្របសម្រួលកម្មវិធីយុទ្ធសាស្ត្រភាពធន់នឹងអាកាសធាតុ*

33. គណៈកម្មការសម្របសម្រួលកម្មវិធីយុទ្ធសាស្ត្រភាពធន់អាកាសធាតុ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៣ សម្រាប់ការគ្រប់គ្រង និងការអនុវត្តកម្មវិធីយុទ្ធសាស្ត្រភាពធន់អាកាសធាតុ ហើយគណៈកម្មការប្រចាំធមាសនេះបានជួបប្រជុំគ្នាចំនួន ២ លើករួចមកហើយ ដែលកិច្ចប្រជុំលើកទី១ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៤ និងកិច្ចប្រជុំលើកទី២ នៅថ្ងៃទី០២ ខែមីនា ឆ្នាំ ២០១៥។

34. វាគឺជាស្ថាប័នអន្តរក្រសួងមួយ ដែលមានសមាជិកមកពីក្រសួងពាក់ព័ន្ធនានាដែលធ្វើការលើផែនការយុទ្ធសាស្ត្រភាពធន់អាកាសធាតុ។ ភារកិច្ចសំខាន់របស់ខ្លួនរួមមាន៖ ១) ត្រួតពិនិត្យ និងគាំទ្រការទំនាក់ទំនង និងផែនការកសាងសមត្ថភាព ២) ដឹកនាំការអនុវត្តគម្រោង និងត្រួតពិនិត្យការគាំទ្រផ្នែកបច្ចេកទេសនៃកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ ដើម្បីធ្វើការពិគ្រោះយោបល់ និងផ្សព្វផ្សាយព័ត៌មានជាមួយភាគីពាក់ព័ន្ធនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ ដូចជា សាធារណៈជន វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាលដៃគូអភិវឌ្ឍន៍ និងជាពិសេសអង្គការមិនមែនរដ្ឋាភិបាលជាអ្នកផ្តល់សេវាកម្មសង្គម ៣) ធ្វើការវាយតម្លៃតម្រូវការការកសាងសមត្ថភាពរបស់ក្រុមអ្នកបង្កើតគោលនយោបាយ អ្នកជំនាញ និងអង្គការសង្គមស៊ីវិលជាតិនិងថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការសកម្មភាព ផែនការថវិកា និងការអនុវត្តវិធានការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងឯកភាពលើកម្មវិធីការងារ ផែនការកសាងសមត្ថភាព និងផែនការចូលរួម និងការទំនាក់ទំនងរបស់ភាគីពាក់ព័ន្ធ ៤) ត្រួតពិនិត្យរបាយការណ៍វឌ្ឍនភាព គោលការណ៍ណែនាំ និងរបាយការណ៍បច្ចេកទេសសម្រាប់ការបញ្ជ្រាបការបន្សុំនឹងអាកាសធាតុទៅក្នុងផែនការ

អភិវឌ្ឍន៍ និងកែតម្រូវផែនការដែលពាក់ព័ន្ធនានាផ្សេងទៀត និង ៥) ត្រួតពិនិត្យ និងយល់ព្រម លើគម្រោងបន្សាំអាទិភាពដែលបានស្នើឡើងក្រោម NAPA និងជួយសម្របសម្រួលដល់កិច្ចព្រមព្រៀងស្ដីពីការអនុវត្តផែនការយុទ្ធសាស្ត្រភាពធន់នឹងអាកាសធាតុសម្រាប់ក្រសួង រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន។

## 2.4 ដំណាក់កាលទី ២៖ សកម្មភាពផែនការយុទ្ធសាស្ត្រភាពធន់នឹងអាកាសធាតុនៅចុងឆ្នាំ ២០១៤

35. ការអនុវត្តគម្រោងនេះបានចាប់ផ្ដើមនៅក្នុងខែកញ្ញា ឆ្នាំ២០១៣។ ការអនុវត្តនេះត្រូវបានផ្អាកនៅក្នុងខែមេសា ឆ្នាំ២០១៤ ដោយសារតែការរំលាយកិច្ចសន្យារបស់ក្រុមហ៊ុនប្រឹក្សាយោបល់មុនដែលរំលោភកិច្ចសន្យា។ ក្រុមអ្នកបច្ចេកទេសនេះត្រូវបានប្រកាសជ្រើសរើសម្ដងទៀតនៅក្នុងឆ្នាំ ២០១៤ ហើយ ICEM ត្រូវបានប្រគល់តួនាទីដើម្បីដឹកនាំការអនុវត្តនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៥ ហើយក្រុមការងារគម្រោងក៏បានប្រគល់កម្មវិធីការងាររយៈពេល ៦ខែ និងការប៉ាន់ប្រមាណចំណាយ (ថ្ងៃទី០១ ខែកុម្ភៈ ដល់ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៥) ផងដែរ។

36. សេចក្ដីព្រាងរបាយការណ៍ចាប់ផ្ដើមគម្រោង ត្រូវបានផលិតឡើងដោយក្រុមហ៊ុនប្រឹក្សាមុន ប៉ុន្តែមិនដែលត្រូវបានអនុម័ត ។ ICEM ត្រូវបានស្នើឱ្យបង្កើតរបាយការណ៍ចាប់ផ្ដើមគម្រោងថ្មីមួយដែលផ្ដើមចេញពីរបាយការណ៍ដែលបានព្រាងមុន ប៉ុន្តែត្រូវឆ្លើយតបទៅនឹងដែនកំណត់របស់វា និងមានភាពជាក់លាក់ដើម្បីបំពេញនឹងស្ថានភាព និងតម្រូវការនាពេលបច្ចុប្បន្ន។ របាយការណ៍ចាប់ផ្ដើមគម្រោងថ្មីនេះ គឺជាលទ្ធផលនៃការងារ និងការពិគ្រោះយោបល់រយៈពេល ៤,៥ខែ ដែលចាប់ផ្ដើមពីពាក់កណ្ដាលខែកុម្ភៈ រហូតដល់ចុងខែមិថុនាឆ្នាំ២០១៥។ វាបង្កើតក្របខណ្ឌមួយដែលគម្រោងនេះនឹងត្រូវបានអនុវត្ត និងកំណត់យ៉ាងច្បាស់ទៅលើការងារដែលត្រូវផ្ដោតសម្រាប់រយៈពេល ៤,៥ឆ្នាំបន្ទាប់ឱ្យដល់ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៩។

## 2.5 ដំណាក់កាលចាប់ផ្ដើមគម្រោងរបស់ ICEM

### *2.5.1 ផែនការសម្រាប់ដំណាក់កាលចាប់ផ្ដើមគម្រោង*

37. ពេលវេលាកំណត់សម្រាប់ការផ្ដល់របាយការណ៍ចាប់ផ្ដើមគម្រោងថ្មីនេះមានរយៈពេល១០សប្ដាហ៍ចាប់ពីពេលផ្ដើមគម្រោងក្នុងខែកុម្ភៈ ឆ្នាំ២០១៥។ ទោះយ៉ាងណា បន្ទាប់ពីការពិភាក្សាដំបូងៗជាស៊េរីមួយជាមួយក្រសួងបរិស្ថាន ភាគីពាក់ព័ន្ធរដ្ឋាភិបាលដទៃទៀត និងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី បានបង្ហាញច្បាស់ថាគួរបន្ថែមពេលវេលាបន្ថែមទៀតដើម្បីឲ្យមានការពិគ្រោះយោបល់បានគ្រប់គ្រាន់ និងដើម្បីធានាថារបាយការណ៍ចាប់ផ្ដើមគម្រោងនេះអាចទទួលយកបានសម្រាប់រដ្ឋាភិបាល និងផ្ដល់នូវផែនការល្អបំផុតសម្រាប់ការអនុវត្តគម្រោងប្រកបដោយជោគជ័យ។ ដោយមានការគាំទ្រពីក្រសួងបរិស្ថាន ក្រុមការងារគម្រោងនេះបានដាក់សំណើផែនការការងារលម្អិតដើម្បីពន្យាពេល ២២ សប្ដាហ៍បន្ថែមទៀតនៅលើដំណាក់កាលចាប់ផ្ដើមនៅថ្ងៃទី១០ ខែមេសា ឆ្នាំ ២០១៥ ហើយ សំណើនេះត្រូវបានអនុម័តដោយធនាគារអភិវឌ្ឍន៍អាស៊ី។

### *2.5.2 គោលបំណង និងសកម្មភាពដំណាក់កាលចាប់ផ្តើមគម្រោង*

38. គោលបំណងជាក់លាក់នៃដំណាក់កាលចាប់ផ្តើមមាន៖

i) ដើម្បីធ្វើការពិគ្រោះយោបល់ទូលំទូលាយជាមួយនឹងក្រសួងគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជា និងអ្នកពាក់ព័ន្ធ និងអភិវឌ្ឍគំរូអនុវត្តដែលមានការយល់ស្របមួយសម្រាប់គម្រោងនេះ

ii) ដើម្បីបង្កើតសូចនាករ និងព័ត៌មានមូលដ្ឋានក្នុងការតាមដានយ៉ាងមានប្រសិទ្ធិភាពទៅលើការរីកចម្រើនរបស់គម្រោងក្នុងអាយុកាលរបស់វា

iii) ដើម្បីបង្កើតមូលដ្ឋានគ្រឹះសម្រាប់សកម្មភាពអភិវឌ្ឍន៍សមត្ថភាពទៀងទាត់តាមវិស័យ ដោយការវាយតម្លៃតម្រូវអភិវឌ្ឍន៍សមត្ថភាពលក្ខណៈជាប្រព័ន្ធមួយ

iv) ដើម្បីរៀបចំផែនការអនុវត្តន៍ និងវិធីសាស្ត្រសម្រាប់ការសិក្សាលម្អិតពីលទ្ធភាពគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុ និង

v) ដើម្បីរៀបចំការចូលរួមរបស់ភាគីពាក់ព័ន្ធ ការទំនាក់ទំនង និងផែនការគ្រប់គ្រងចំណេះដឹងដែលសមស្របគ្នាជាមួយសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដោយភ្នាក់ងាររដ្ឋាភិបាលកម្ពុជាដទៃទៀត និងគម្រោងផ្សេងៗ។

39. សកម្មភាពដំណាក់កាលការចាប់ផ្តើមគម្រោងត្រូវបានបែងចែកទៅជាប្រាំផ្នែក ដែលផ្នែកនីមួយៗមានសកម្មភាពជាស៊េរី និងអនុសកម្មភាព ។

## តារាង 2-1: មូលនិធិ និងស្ថានភាពអនុវត្តគម្រោងវិនិយោគកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ

| ឈ្មោះគម្រោង | ក្រសួង | ខេត្តគោលដៅ | | | | | | | ថវិកាគិតជាដុល្លាសហរដ្ឋអាមេរិក |
|---|---|---|---|---|---|---|---|---|---|
| | | | កម្មវិធីPPCR | | | | | | |
| **ភាពធន់នឹងអាកាសធាតុនៃធនធានទឹក** | | | **ហិរញ្ញប្បទានឥតសំណង** | **ហិរញ្ញប្បទានឥណទាន** | **ធនាគារអភិវឌ្ឍន៍អាស៊ី** | **រាជរដ្ឋាភិបាល** | **ថវិកាបដិភាគផ្សេងៗ** | TA | (ដុល្លាសហរដ្ឋអាមេរិក) |
| បង្កើនការគ្រប់គ្រងហានិភ័យគ្រោះទឹកជំនន់ និងរាំងស្ងួតក្នុងខេត្តពោធិ៍សាត់ | ក្រសួងធនធានទឹក និងឧតុនិយម | ពោធិ៍សាត់ | ៥.៨លាន | ៤លាន | ៣៥លាន | ២.៩៥លាន | | | ៤៧.៧៥លាន |
| **ភាពធន់នឹងអាកាសធាតុនៃកសិកម្ម** | | | | | | | | | |
| បង្កើនភាពធន់នឹងអាកាសធាតុលើវិស័យកសិកម្មក្នុងខេត្តកោះកុងនិងមណ្ឌលគីរី<br>ជាផ្នែកមួយនៃគម្រោងរបៀងអភិរក្សជីវៈចម្រុះមហាអនុតំបន់ទន្លេមេគង្គ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន | កោះកុង និង មណ្ឌលគិរី | ៨លាន | | ១៩លាន | ១.៤លាន | ០.៥លាន | | ២៨.៩លាន |
| បង្កើនភាពធន់ហេដ្ឋារចនាសម្ព័ន្ធកសិកម្ម និងមុខជំនួញផ្តោតលើការបន្សាំនឹងការប្រែប្រួលអាកាសធាតុ<br>ជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មស្រូវធន់នឹងអាកាសធាតុ | ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | កំពង់ធំ ព្រៃវែង បាត់ដំបង | ៤,៥លាន | ៥លាន | ៥៥លាន | ៨.៣លាន | ១៤.៦លាន | | ៨៧.៤លាន |
| **ភាពធន់នឹងអាកាសធាតុនៃហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | | | |
| ផ្លូវធន់នឹងអាកាសធាតុក្នុងខេត្តព្រៃវែង ស្វាយរៀង កំពង់ឆ្នាំង និងកំពង់ស្ពឺ<br>ជាផ្នែកមួយនៃគម្រោងអភិវឌ្ឍន៍ផ្លូវខេត្ត | ក្រសួងសាធារណការ និងដឹកជញ្ជូន | ព្រៃវែង ស្វាយរៀង កំពង់ឆ្នាំង កំពង់ស្ពឺ | ៧លាន | ១០លាន | ៥២លាន | | ៩.៨លាន | ០.៥លាន | ៧៩.៣លាន |
| ហេដ្ឋារចនាសម្ព័ន្ធផ្លូវធន់នឹងអាកាសធាតុនៅសេដ្ឋកិច្ចក្រុងរបៀងខាងត្បូងៈបាត់ដំបង បាវិត អ្នកលឿង និងប៉ោយប៉ែត<br>ជាផ្នែកមួយនៃគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចក្រុងរបៀងខាងត្បូងនៅមហាអនុតំបន់ទន្លេមេគង្គ | ក្រសួងសាធារណការ និងដឹកជញ្ជូន | បាត់ដំបង បាវិត អ្នកលឿង ប៉ោយប៉ែត | ៤.៥លាន | ៥លាន | ៣៧លាន | ៦.៨៨លាន | ១.៥លាន | | ៥៤.៧៨លាន |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធភាពធន់នឹងទឹកជំនន់ក្នុងក្រុងពោធិសាត់និងកំពង់ឆ្នាំង ជាផ្នែកមួយនៃគម្រោងកែលម្អបរិស្ថានក្រុងនៅបឹងទន្លេសាប | ក្រសួងសាធារណការ និងដឹកជញ្ជូន | ពោធិ៍សាត់ កំពង់ឆ្នាំង | ៥លាន | ៥លាន | ៣៧លាន | ៥.៤លាន | ០.២លាន | | ៥២.៦លាន |
| ហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទធន់នឹងអាកាសធាតុក្នុងខេត្តកំពង់ចាម ជាផ្នែកមួយនៃគម្រោងកែលម្អផ្លូវជនបទជំហានទី ២ | ក្រសួងអភិវឌ្ឍន៍ជនបទ | កំពង់ចាម ត្បូងឃ្មុំ តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ | ៩លាន | ៧លាន | | | | | ១៦លាន |
| **គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស** | | | | | | | | | |
| កញ្ចប់ទី១៖ ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ | ក្រសួងបរិស្ថាន | ថ្នាក់ជាតិ | | | | | | | ៧លាន |
| កញ្ចប់ទី២៖ ការគាំទ្រអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល | ក្រសួងបរិស្ថាន | ថ្នាក់ជាតិ | | | | | | | ២លាន |
| កញ្ចប់ទី៣៖ ការតាមដាន និងវាយតម្លៃ យេនឌ័រ និងថ្នាក់ក្រោមជាតិ | ក្រសួងបរិស្ថាន | ថ្នាក់ជាតិ | | | | | | | |

40. **ការគ្រប់គ្រងគម្រោង និងការចូលរួមរបស់ភាគីពាក់ព័ន្ធ៖** សកម្មភាពទាក់ទងនឹងការគ្រប់គ្រងគម្រោងនិងការចូលរួមរបស់ភាគីពាក់ព័ន្ធមានបំណងដើម្បីកសាងការប្តេជ្ញាចិត្ត និងការចាប់អារម្មណ៍ទៅលើគម្រោង ដើម្បីបង្កើតយន្តការ និងរបៀបធ្វើការ ដើម្បីធានាថាសកម្មភាពរបស់គម្រោងនេះគឺស្របជាមួយនឹងតម្រូវការរបស់ក្រសួងបរិស្ថាន និងធនាគារអភិវឌ្ឍន៍អាស៊ី និងឱ្យត្រូវជាមួយនឹងសកម្មភាពការប្រែប្រួលអាកាសធាតុដែលមានស្រាប់ដែលកំពុងដំណើរការនៅក្នុងក្រសួងគោលដៅ។ អនុសកម្មភាពសំខាន់ៗនៅក្នុងចំណុចនេះរួមមាន កិច្ចប្រជុំទៀងទាត់ជាមួយក្រសួងបរិស្ថាន នាយកដ្ឋានប្រែប្រួលអាកាសធាតុ និងធនាគារអភិវឌ្ឍន៍អាស៊ី និងរាយការណ៍ជាទៀងទាត់នូវវឌ្ឍនភាព និងកម្មវិធីនៃការពិគ្រោះយោបល់ និងកិច្ចប្រជុំតុមូលជាមួយភាគីពាក់ព័ន្ធ។

**តារាង 2-2៖ ក្រសួងគោលដៅ និងក្រសួងគាំទ្រសម្រាប់ប្រជុំតុមូល**

| **ក្រសួងសំខាន់ៗ៖** | **ក្រសួងដែលគាំទ្រ៖** |
|---|---|
| ក្រសួងបរិស្ថាន<br>ក្រសួងអភិវឌ្ឍន៍ជនបទ<br>ក្រសួងសាធារណការ និងដឹកជញ្ជូន<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្រសួងធនធានទឹក និងឧតុនិយម | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងផែនការ<br>ក្រសួងកិច្ចការនារី<br>ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ<br>គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

41. **វត្ថុបំណងនៃកិច្ចពិភាក្សាតុមូលមានដូចខាងក្រោម៖**

i) ដើម្បីបង្កើត និងអភិវឌ្ឍទំនាក់ទំនងការងារជាមួយនឹងក្រសួងដែលអនុវត្តផែនការយុទ្ធសាស្ត្រភាពធន់អាកាសធាតុនីមួយៗ

ii) ដើម្បីបង្ហាញពីវិសាលភាពនៃTA 8179 CAM និងការភ្ជាប់ខ្លួនរបស់វាជាមួយក្រសួង ដែលអនុវត្តផែនការយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ

iii) ដើម្បីកំណត់ពីតម្រូវការអភិវឌ្ឍសមត្ថភាពសម្រាប់ក្រសួង និងមន្ទីរសំខាន់ៗនីមួយៗក្នុងការអនុវត្តផែនការសកម្មភាពការប្រែប្រួលអាកាសធាតុរបស់ខ្លួន

iv) ដើម្បីពិភាក្សាគ្នាអំពីគម្រោងបន្សាំដែលមានសក្តានុពលសម្រាប់មូលនិធិភាពធន់នឹងអាកាសធាតុ

42. **លទ្ធផល ១៖** ក្នុងដំណាក់កាលចាប់ផ្តើម សកម្មភាពមួយចំនួនផ្តោតលើមូលដ្ឋានគ្រឹះសម្រាប់សកម្មភាពនានាពេលអនាគតនៅក្នុងលទ្ធផលទី១។ ជាពិសេសនោះគឺដើម្បីពង្រឹងការសម្របសម្រួលក្នុងផែនការយុទ្ធសាស្ត្រភាពធន់នឹងអាកាសធាតុ និងដើម្បីកសាងសមត្ថភាពសម្រាប់ការវាយតម្លៃភាពងាយរងគ្រោះពី

ការប្រែប្រួលអាកាសធាតុ និងការធ្វើផែនការបន្សុំាសម្រាប់ដាក់បញ្ចូលហេដ្ឋារចនាសម្ព័ន្ធទៅក្នុងក្រសួងគោលដៅរបស់គម្រោង។ ដំណាក់កាលចាប់ផ្ដើមនេះ បានដាក់បញ្ចូលកម្មវិធីនៃកិច្ចប្រជុំតុមូលមួយថ្ងៃពេញជាមួយក្រុមការងារការប្រែប្រួលអាកាសធាតុ នៃក្រសួងដែលអនុវត្តផែនការយុទ្ធសាស្ត្រភាពធន់អាកាសធាតុនីមួយៗ។ វាក៏បានបញ្ចូលផងដែរនូវកិច្ចប្រជុំតុមូលពេញលេញថ្ងៃជាមួយនឹងក្រុមគម្រោងវិនិយោគ PMUs និងក្រុមដែលដឹកនាំឱ្យមានកិច្ចព្រមព្រៀងសហការសម្រាប់កិច្ចប្រជុំទៀងទាត់ និងការរៀបចំការងារ។

43. ក្នុងអំឡុងឆ្នាំ២០១១ និង២០១២ ក្រុមផ្សេងគ្នាបានវាយតម្លៃតម្រូវការបណ្តុះបណ្តាលរបស់ក្រសួងគោលដៅដែលផ្តោតទៅលើការប្រែប្រួលអាកាសធាតុ ដែលរួមបញ្ចូលទាំងការពិគ្រោះយោបល់បច្ចេកទេសពីមុន និងគម្រោងផែនការយុទ្ធសាស្ត្រភាពធន់នឹងអាកាសធាតុ - កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា។ ការវាយតម្លៃទាំងនេះបានគូសបញ្ជាក់ថា នៅមានខ្វះខាតការអភិវឌ្ឍសមត្ថភាព ជាពិសេសតម្រូវការអភិវឌ្ឍជំនាញក្នុងការវាយតម្លៃភាពងាយរងគ្រោះ និងការធ្វើផែនការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ និងសម្រាប់ការអភិវឌ្ឍគោលការណ៍ណែនាំ និងនីតិវិធីស្តង់ដារដែលពាក់ព័ន្ធនានា។ ការវាយតម្លៃតម្រូវការអភិវឌ្ឍសមត្ថភាពដែលបានធ្វើឡើងក្នុងអំឡុងពេលដំណាក់កាលចាប់ផ្តើមនេះ បានផ្តោតលើសមត្ថភាពជាក់លាក់ដែលបានទាមទារសម្រាប់ការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងការវិនិយោគគម្រោងអភិវឌ្ឍនៅក្នុងក្រសួងគោលដៅ។

44. **លទ្ធផល ២៖** នៅក្នុងដំណាក់កាលចាប់ផ្តើមនេះ សកម្មភាពនៃលទ្ធផលទី ២ ត្រូវបានផ្តោតទៅលើការបង្កើតផែនការអនុវត្តរឹងមាំឆ្លើយតបនឹងការធ្វើការសិក្សាលម្អិតពីលទ្ធភាពដែលអាចធ្វើទៅបានការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ និងរៀបចំសំណើគម្រោង។ សកម្មភាពគន្លឹះនៅក្នុងដំណាក់កាលនេះរួមមាន ការពិនិត្យឡើងវិញនៃកម្មវិធីសកម្មភាពជាតិបន្សុាំនឹងការប្រែប្រួលអាកាសធាតុ (NAPA) ផែនការសកម្មភាពជាតិ (NAP) និងផែនការសកម្មភាពការប្រែប្រួលអាកាសធាតុរបស់ក្រសួងគោលដៅដើម្បីកំណត់គម្រោងបន្សុាំ និងការអភិវឌ្ឍនៃលក្ខណៈវិនិច្ឆ័យដើម្បីកំណត់អាទិភាពគម្រោងបន្សុាំ ពណ៌នាអំពីវិធីសាស្ត្រដើម្បីធ្វើការសិក្សាលម្អិតពីលទ្ធភាពដែលអាចធ្វើទៅបាន និងពិនិត្យឡើងវិញនៃប្រភពជំនួយសក្តានុពលក្នុងការគាំទ្រដល់គម្រោងនេះ។ វាបានបញ្ចូលទាំងការបង្កើតក្រុមការងារ CCD ដែលមានសមាជិកមកពី CCCA CCD និងក្រុម SPCR។ ក្រុមនេះបានជួបប្រជុំគ្នាជាច្រើនដងរួចមកហើយ និងកំពុងធ្វើការសហការគ្នាដើម្បីរៀបចំសេចក្តីសង្ខេបទៅលើមូលនិធិការប្រែប្រួលអាកាសធាតុសំខាន់ៗ និងវិធីដើម្បីទទួលបានមូលនិធិនោះ ដូចជាចំណេះដឹងគម្រោង និងសិក្ខាសាលាបណ្តុះបណ្តាលនាពេលអនាគត។

45. **លទ្ធផល ៤៖** នៅក្នុងដំណាក់កាលចាប់ផ្តើមនេះ សកម្មភាពរបស់លទ្ធផលទី៣ ត្រូវបានរៀបចំឡើងជាមូលដ្ឋានក្នុងការចាត់ថ្នាក់ចំណេះដឹង និងមុខងារនៃការទំនាក់ទំនងដែលនឹងត្រូវបានអនុវត្តនៅក្នុងគម្រោង

នេះ។ បន្ថែមលើនោះទៀត ដើម្បីអភិវឌ្ឍផែនការសម្រាប់ការចូលរួមរបស់ភាគីពាក់ព័ន្ធ ការទំនាក់ទំនង និងការគ្រប់គ្រងចំណេះដឹង ក្រុមការងារគម្រោងបានចាប់ផ្តើមចំណាត់ថ្នាក់ធនធាននៃ GIS (៤ ផែនទីសម្រាប់ការពិភាក្សាលើភូមិសាស្រ្ត) និង៤ឧបករណ៍បង្កើនចំណេះដឹងរួមមាន ខិត្តប័ណ្ណផ្សព្វផ្សាយ និងផ្ទាំងរូបភាពរបស់គម្រោងសម្រាប់ការផ្សព្វផ្សាយ និងការប្រើប្រាស់ក្នុងសិក្ខាសាលា និងព្រឹត្តិការផ្សេងៗ។ ក្រុមការងារបានរៀបចំផែនការមួយសម្រាប់ការអនុវត្តការអភិវឌ្ឍកម្មវិធីសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សាសំខាន់ៗ ដែលភ្ជាប់ទៅនឹងវិស័យគោលដៅរបស់គម្រោងនេះ តាមរយៈការពិគ្រោះយោបល់ដែលមានការចូលរួមពីអង្គការផ្សេងៗ។

46. លទ្ធផលនៃសកម្មភាពទាំងនេះត្រូវបានអភិវឌ្ឍដើម្បីដាក់បញ្ចូលទៅក្នុងរបាយការណ៍ចាប់ផ្តើមគម្រោងថ្មីនេះ។ របាយការណ៍នេះបានបង្កើតចេញពីរបាយការណ៍មុន ដែលបានរៀបចំឡើងដោយអ្នកពិគ្រោះយោបល់បច្ចេកទេសមុន ហើយបញ្ចូលការផ្លាស់ប្តូរផ្សេងៗ ព្រមទាំងផែនការវាយតម្លៃលម្អិត និងគម្រោងកសាងសមត្ថភាពទៅក្នុងរចនាសម្ព័ន្ធរបស់ស្ថាប័ន សម្រាប់ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការអភិវឌ្ឍវិស័យគោលដៅ ដូចជាធនធានទឹក កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងការអភិវឌ្ឍក្រុង។ សេចក្តីព្រាងនៃរបាយការណ៍នេះត្រូវបានបង្ហាញនៅខែកក្កដា នៅក្នុងសិក្ខាសាលាចាប់ផ្តើម ហើយទទួលបានមតិយោបល់លម្អិតពីធនាគារអភិវឌ្ឍន៍អាស៊ី។ កំណែចុងក្រោយនេះបានឆ្លើយតបទៅនឹងការពិគ្រោះយោបល់ និងមតិ។

## 2.6 កញ្ចប់ទី ១៖ រចនាសម្ព័ន្ធក្រុម និងការចាប់ផ្តើមដំណើរការ

### *2.6.1 កញ្ចប់ទី ១៖ រចនាសម្ព័ន្ធក្រុមការងារគម្រោង*

47. កញ្ចប់ ទី ១ នឹងត្រូវបានអនុវត្តដោយក្រុមអ្នកជំនាញមួយក្រុមចំនួន ១៤នាក់ ដែលរួមមានអ្នកជំនាញអន្តរជាតិក្រៅម៉ោងចំនួន ៥នាក់ និងអ្នកជំនាញជាតិចំនួន ៩នាក់។ ដើម្បីធានាបាននូវការគ្រប់គ្រង និងការផ្សព្វផ្សាយផ្តល់សេវាបច្ចេកទេសនេះឱ្យមានប្រសិទ្ធភាព ប្រធានក្រុមនឹងទទួលខុសត្រូវរួមក្នុងការគ្រប់គ្រង និងការសម្របសម្រួលកាលវិភាគរបស់ក្រុមការងារបច្ចេកទេស និងបែងចែកកិច្ចការ និងលទ្ធផលដល់ក្រុម។ អនុប្រធានត្រូវធ្វើការពេញម៉ោងដើម្បីជួយប្រធានក្រុមដោយផ្ទាល់។ អនុប្រធានក្រុមនឹងទទួលខុសត្រូវក្នុងការគ្រប់គ្រងក្រុមអ្នកជំនាញជាតិ និងទំនាក់ទំនងជាមួយនឹងអ្នកបច្ចេកទេសពាក់ព័ន្ធនានា ។

48. ជំនួយបច្ចេកទេសបន្ថែម និងការគ្រប់គ្រងទូទៅនៃគំនិតរបស់អ្នកជំនាញទៅក្នុងការងារបច្ចេកទេសនេះនឹងត្រូវបានផ្តល់ដោយការិយាល័យរបស់ ICEM នៅភ្នំពេញ។ អ្នកគ្រប់គ្រងគម្រោង ICEM នឹងត្រូវធ្វើការនៅទីក្រុងភ្នំពេញ និងទីក្រុងហាណូយដែលមានទីស្នាក់ការកណ្តាលរបស់ខ្លួន និងមានការិយាល័យហិរញ្ញវត្ថុ និងរដ្ឋបាល។ ការគាំទ្របច្ចេកទេស ការប្រតិបត្តិការ និងកិច្ចការរដ្ឋបាលនឹងត្រូវផ្តល់ដោយប្រធានគម្រោង ICEM អ្នកសម្របសម្រួល និងហិរញ្ញិករបស់គម្រោងដែលធ្វើការនៅទីក្រុងហាណូយ។ ការគាំទ្រ

នេះនឹងរួមបញ្ចូលទាំងការពិនិត្យ និងការត្រួតពិនិត្យគុណភាពដោយនាយក ICEM ព្រមទាំងបញ្ហាគណនេយ្យ និងការកសាងសមត្ថភាពពីប្រធានហិរញ្ញវត្ថុ ICEM និងកាប្រតិបត្តិការ និងកិច្ចការរដ្ឋបាលពីអ្នកសម្របសម្រួលគម្រោង ICEM ។

49. ក្រុមគម្រោងនេះនឹងគាំទ្រដល់ការិយាល័យកម្មវិធីផែនការយុទ្ធសាស្ត្រភាពធន់អាកាសធាតុ ដែលមានទីតាំងស្ថិតនៅក្នុងនាយកដ្ឋានប្រែប្រួលអាកាសធាតុ និងនៅក្នុងក្រុមសម្របសម្រួល ផែនការយុទ្ធសាស្ត្រភាពធន់អាកាសធាតុជាតិរបស់ក្រសួងបរិស្ថាន (រូបទី២.៤) ។ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សាបូ អូហ្សាណូ ដែលជារដ្ឋលេខាធិការត្រូវបានតែងតាំងជាអ្នកសម្របសម្រួលផែនការយុទ្ធសាស្ត្រភាពធន់អាកាសធាតុថ្នាក់ជាតិ ដើម្បីត្រួតពិនិត្យការអនុវត្តកម្មវិធីសាកល្បងភាពធន់អាកាសធាតុ និងរាយការណ៍ទៅរដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធាន NCCC ។ ការិយាល័យកម្មវិធី ផែនការយុទ្ធសាស្ត្រភាពធន់អាកាសធាតុនៅក្នុងនាយកដ្ឋានប្រែប្រួលអាកាសធាតុត្រូវបានដឹកនាំដោយនាយកគម្រោងផែនការយុទ្ធសាស្ត្រភាពធន់អាកាសធាតុ គឺលោក មាស សុផល។ លោក សុផល ត្រូវបានគាំទ្រដោយ លោកអ៊ូ ច័ន្ទធារិទ្ធិ អ្នកគ្រប់គ្រងកម្មវិធីផែនការយុទ្ធសាស្ត្រភាពធន់អាកាសធាតុ នៅនាយកដ្ឋានប្រែប្រួលអាកាសធាតុ។ ក្រុមការងារគម្រោងនេះនឹងគាំទ្រដល់ នាយកគម្រោងផែនការយុទ្ធសាស្ត្រភាពធន់អាកាសធាតុ ក្នុងការអនុវត្តសកម្មភាពរបស់កញ្ចប់ទី ១ និងជួយក្នុងការសម្របសម្រួលសកម្មភាពជាមួយនឹងកញ្ចប់ផែនការយុទ្ធសាស្ត្រភាពធន់អាកាសធាតុផ្សេងទៀត និងគម្រោង និងភាគីពាក់ព័ន្ធដទៃទៀត។

## ក្រាហ្វិច 3: រចនាសម្ព័ន្ធក្រុមការងារគម្រោងកញ្ចប់ទី១ និងទំនាក់ទំនងទៅនឹងកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ របស់ប្រទេសកម្ពុជា




50. ក្រុមការងារគម្រោង នឹងគាំទ្រការិយាល័យអនុវត្តគម្រោង ក្នុងការជួយសម្របសម្រួលជាមួយសមាជិកក្រុមការងារសម្របសម្រួលកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ រួមទាំងគាំទ្រការរៀបចំការប្រជុំក្រុមការងារជាប្រចាំផងដែរ។ ក្រុមការងារសម្របសម្រួលមានប្រធានដឹកនាំមកពី អ្នកសម្របសម្រួល SPCR ថ្នាក់ជាតិ និងមានសមាជិកមកពីតំណាងក្រសួងដែលអនុវត្តកម្មវិធី SPCR គម្រោងវិនិយោគទាំង ៧ និងកញ្ចប់ជំនួយបច្ចេកទេសដទៃទៀត ។ ក្រុមការងារសម្របសម្រួលបានដើរតួនាទីជាអ្នកផ្តល់ដំបូន្មានក្នុងការអនុវត្ត និងត្រួតពិនិត្យប្រតិបត្តិការរបស់ផ្នែកអនុវត្តគម្រោងនៅក្រសួងបរិស្ថាន។ ក្រុមការងារសម្របសម្រួលនេះ តាមរយៈនាយកកម្មវិធី PPCR គឺជួយទទួលខុសត្រូវក្នុងការដាក់បញ្ជូនរបាយការណ៍តាមដាន និងត្រួតពិនិត្យមូលនិធិវិនិយោគអាកាសធាតុ និងធនាគារអភិវឌ្ឍន៍អាស៊ី ។

51. ក្រុមការងារគម្រោង នឹងស្ថិតនៅក្រោមការដឹកនាំដោយអ្នកជំនាញការប្រែប្រួលអាកាសធាតុ ដែលទទួលបន្ទុកតំបន់អាស៊ីអាគ្នេយ៍ និងធ្វើការយ៉ាងជិតស្និទ្ធជាមួយបណ្តាញគាំទ្រនៃទីប្រឹក្សាធនាគារអភិវឌ្ឍន៍អាស៊ី ដែលកំពុងគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុទាំងអស់ក្នុងប្រទេសកម្ពុជា ។

### *2.6.2 ការចាប់ផ្តើមដំណើរការរបស់ក្រុមការងារ*

52. ការចាប់ដំណើរការនៃក្រុមការងារគម្រោង គឺស្ថិតនៅលើដំណាក់កាលចាប់ផ្តើមគម្រោង ដែលស្របជាមួយនឹងសកម្មភាពដទៃទៀតរបស់គម្រោងនឹងត្រូវអនុវត្ត ។ ការកត់ត្រាអំពីការចាប់ផ្តើមបំពេញការងាររបស់អ្នកឯកទេសនីមួយៗត្រូវបង្ហាញជូនក្នុងតារាងទី២.២ ខាងក្រោមនេះ។

**តារាង 2-3 ក្រុមការងារគម្រោង និងកាលបរិច្ឆេទចាប់ផ្តើមរបស់ពួកគេ**

| ឈ្មោះ | ថ្នាក់ជាតិ/ អន្តរជាតិ | តួនាទី | ម៉ោងបម្រើការងារ | ចំនួនខែ | ថ្ងៃខែចូលធ្វើការដំបូង |
|---|---|---|---|---|---|
| Peter-John Meynell | អន្តរជាតិ | ប្រធានក្រុម និងអ្នកជំនាញបច្ចេកទេសវិស័យធនធានទឹកអន្តរជាតិ និងការងារបន្សាំនឹងការប្រែប្រួលអាកាសធាតុ | ក្រៅម៉ោង | 18 | 16-កុម្ភៈ-15 |
| Ian Hancock | អន្តរជាតិ | អ្នកជំនាញបច្ចេកទេសផ្នែកកសិកម្មអន្តរជាតិ និងការប្រែប្រួលអាកាសធាតុ | ក្រៅម៉ោង | 16 | 2-ឧសភា-15 |
| Tarek Ketelsen | អន្តរជាតិ | អ្នកជំនាញបច្ចេកទេសផ្នែកហេដ្ឋារចនាសម្ព័ន្ធអន្តរជាតិ និងការប្រែប្រួលអាកាសធាតុ | ក្រៅម៉ោង | 16 | 11-ឧសភា-15 |
| Kathleen McLaughlin | អន្តរជាតិ | អ្នកជំនាញបច្ចេកទេសវិស័យគ្រប់គ្រង និងទំនាក់ទំនងអន្តរជាតិ | ក្រៅម៉ោង | 16 | 1-មិថុនា-15 |
| Jeremy Carew-Reid | អន្តរជាតិ | អ្នកជំនាញគ្រប់គ្រង និងអភិវឌ្ឍន៍គម្រោងកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ | ក្រៅម៉ោង | 16 | 16-កុម្ភៈ-15 |
| Seak Sophat | ជាតិ | អ្នកជំនាញជាន់ខ្ពស់គ្រប់គ្រងកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ | ពេញម៉ោង | 50 | 15-មីនា-15 |
| Mak Sithirith | ជាតិ | អ្នកជំនាញផ្នែកកសិកម្ម ធនធានទឹក និងការប្រែប្រួលអាកាសធាតុ | ពេញម៉ោង | 50 | 27-មេសា-15 |
| Hak You | ជាតិ | អ្នកជំនាញផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងការប្រែប្រួលអាកាសធាតុ | ពេញម៉ោង | 50 | 2-មីនា-15 |
| Porny You | ជាតិ | អ្នកជំនាញផ្នែកវិស័យគ្រប់គ្រង និងទំនាក់ទំនង | ពេញម៉ោង | 50 | 1-មេសា-15 |
| Lay Chanthay | ជាតិ | អ្នកជំនាញទីមួយផ្នែកគ្រប់គ្រង និងអភិវឌ្ឍន៍គម្រោងកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ | ក្រៅម៉ោង | 30 | 9-មីនា-15 |
| Nom Sophearith | ជាតិ | អ្នកជំនាញទីពីរផ្នែកគ្រប់គ្រង និងអភិវឌ្ឍន៍គម្រោងកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ | ក្រៅម៉ោង | 30 | 18-ឧសភា-15 |
| Vina Touch | ជាតិ | អ្នកជំនាញ GIS | ក្រៅម៉ោង | 25 | 2-មីនា-15 |
| Kong Somvannda | ជាតិ | អ្នកជំនាញផ្នែកព័ត៌មានវិទ្យា | ក្រៅម៉ោង | 25 | 4-ឧសភា-15 |

| | | | | | |
|---|---|---|---|---|---|
| Pheak Young | ជាតិ | អ្នកជំនាញផ្នែកត្រួតពិនិត្យ និងតាមដាន | ក្រៅម៉ោង | 10 | 18-ឧសភា-15 |

# 3 បរិបទរបស់ស្ថាប័ន

53. ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុដែលនឹងទទួលបានជោគជ័យ គឺការចូលរួមក្នុងសកម្មភាពចម្រុះ និងរវាង ស្ថាបន័រដ្ឋាភិបាល នយោបាយ បច្ចេកទេស និងវប្បធម៌។ ការយល់ដឹងយ៉ាងច្បាស់អំពី បរិបទនៃស្ថាប័ន ដែលត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីដោះស្រាយបញ្ហានៃការប្រែប្រួលអាកាសធាតុ គឺជាការសំខាន់សម្រាប់ការអនុវត្តប្រកបដោយជោគជ័យនៃគម្រោងជំនួយបច្ចេកទេសTA ៨១៧៩នេះ។ ខាងក្រោមនេះ គឺបង្ហាញពី ស្ថាប័នជាតិ និងថ្នាក់ក្រោមជាតិ ដែលនឹងត្រូវបានចូលរួមដោយក្រុមជំនួយការបច្ចេកទេស ក្នុងអំឡុងពេលនៃការអនុវត្ត កញ្ចប់ទី1នៃគម្រោង។

## 3.1 រចនាសម្ព័ន្ធស្ថាប័នថ្នាក់ជាតិ

### *3.1.1 ការផ្លាស់ប្តូររចនាសម្ព័ន្ធនៃក្រសួងបរិស្ថាន និងស្ថាប័ន សម្រាប់ការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ*

54. រចនាសម្ព័ន្ធនៃស្ថាប័នសម្រាប់ការដោះស្រាយការប្រែប្រួលអាកាសធាតុនៅព្រះរាជាណាចក្រកម្ពុជា គឺស្ថិតនៅក្រោមការរៀបចំឡើងវិញ។ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើត ស្ថាប័នពីរសំខាន់ៗ ដើម្បីសម្របសម្រួលទិសដៅយុទ្ធសាស្រ្ត និង សកម្មភាពការប្រែប្រួលអាកាសធាតុ៖ (i) គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (គ.ជ.គ.ប.អ.) និង (ii) ក្រុមប្រឹក្សាជាតិស្តីពីការអភិវឌ្ឍបៃតង។ ទោះយ៉ាងណា នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតរចនាសម្ព័ន្ធថ្មីមួយ ដែលមានឈ្មោះថា ក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព (NCSD) ដែលនឹងជំនួសរចនាសម្ព័ន្ធទាំងពីរ។

ក្រាហ្វិច 4: រចនាសម្ព័នថ្មីរបស់ក្រសួងបរិស្ថាន និង NCSD ដែលស្ថិតនៅក្រោមរដ្ឋមន្ត្រីក្រសួងបរិស្ថាន



### *3.1.2 ក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព (NCSD)*

55. NCSD ត្រូវបានបង្កើតឡើងនៅក្នុងខែឧសភាឆ្នាំ២០១៥ ហើយរចនាសម្ព័ន្ធ និងអាណត្តិរបស់ខ្លួនត្រូវបានរៀបចំឡើងដោយយកតាមគំរូក្រុមប្រឹក្សានៃប្រទេសដទៃ។ នាយករដ្ឋមន្ត្រី គឺជាប្រធានកិត្តិយស ហើយរដ្ឋមន្ត្រីក្រសួងបរិស្ថាន បម្រើការជាប្រធាន។ ការប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា ត្រូវបានគ្រប់គ្រងដោយអគ្គលេខាធិការដ្ឋាន។ ក្រុមប្រឹក្សានេះ នឹងកំណត់គោលដៅ សម្រាប់គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ(NCCC) និង ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង(NCGG) ប៉ុន្តែបានបញ្ជាក់ និងបន្ថែមចំណុចសំខាន់ៗផ្សេងទៀតដូចជា ការលើកកម្ពស់ដល់ការអភិវឌ្ឍដោយចីរភាពដែលជាចម្បង នាំឱ្យមានតុល្យភាព សសរស្តម្ភទាំងបួននៃការអភិវឌ្ឍ - សេដ្ឋកិច្ច បរិស្ថាន សង្គមនិងវប្បធម៌។ ក្រុមប្រឹក្សាថ្មីនេះមានសមាសភាពស្រដៀងគ្នា នៃសមាជិកមកពីក្រសួងស្ថាប័នអន្តរវិស័យ។

56. ការបង្កើត NCSD នេះនឹងមានឥទ្ធិពលយ៉ាងសំខាន់លើការរៀបចំស្ថាប័នរបស់ក្រសួងបរិស្ថាន និងការរៀបចំស្ថាប័នសម្រាប់គម្រោងជំនួយបច្ចេកទេសនេះ។ កាលពីមុន នាយកដ្ឋានប្រែប្រួលអាកាសធាតុ (CCD) នៃក្រសួងបរិស្ថាន បានបម្រើការងារនៅក្រោម NCCC ដើម្បីសម្របសម្រួលសកម្មភាព និងការអភិវឌ្ឍជាចាំបាច់ក្នុងជំនួយគោលនយោបាយ / ច្បាប់ និង គោលការណ៍ណែនាំសម្រាប់ដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុនៅព្រះរាជាណាចក្រកម្ពុជា។ ក្រោមរចនាសម្ព័ន្ធថ្មីនេះ CCD រួមទាំងមន្ទីរ បួនផ្សេងទៀត នឹងត្រូវផ្លាស់ពីក្រសួងបរិស្ថាន ដើម្បីទៅគាំទ្រដោយផ្ទាល់ដល់ NSCD។ ឥឡូវនេះ ក្រសួងបរិស្ថាននឹងប្រតិបត្តិការស្របគ្នានឹង NCSD និង ដោយពង្រីកបន្ថែម CCD ។

**ក្រាហ្វិច 5: រចនាសម្ព័ន្ធរបស់ NCSD**



57. នៅក្នុងឆ្នាំ២០១០ ក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ(CCTT) ត្រូវបានបង្កើតឡើង ដើម្បីគាំទ្រដល់គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ(NCCC) ដែលជាស្ថាប័ននៃអន្តរក្រសួង ដែលមានសមាជិកជាមន្រ្តីបច្ចេកទេសមកពីក្រសួង និងភ្នាក់ងារដែលប្រតិបត្តិពាក់ព័ន្ធទៅនឹងការប្រែប្រួលអាកាសធាតុ និងការមានកាតព្វកិច្ចអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។ តួនាទីសំខាន់ៗនៃ CCTT គឺផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេស និងមតិយោបល់ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងការដាក់ស្នើទៅ NCCC សម្រាប់ការពិចារណា និងសកម្មភាពសមស្រប។ ដែលរំពឹងថានៅក្រោមរចនាសម្ព័ន្ធថ្មីនេះ CCTT នឹងត្រូវបានបង្កើតឡើងវិញ។

58. ឈ្មោះរបស់សមាជិកនៃគណៈកម្មាធិការផ្សេងៗទៀត ដែលជាប់ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងកម្មវិធីយុទ្ធសាស្រ្តសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR) នេះ ត្រូវបានរាយនៅក្នុងឧបសម្ព័ន្ធទី៣។

## 3.2 សកម្មភាពជាតិស្តីពីការប្រែប្រួលអាកាសធាតុ

59. ព្រះរាជាណាចក្រកម្ពុជា ថ្មីៗនេះបានអនុម័តយុទ្ធសាស្រ្តជាតិសម្រាប់ការប្រែប្រួលអាកាសធាតុ នៅតាមវិស័យមួយចំនួននៃក្រសួង និងស្ថាបន័ពាក់ព័ន្ធ រួមមាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណៈការ និងដឹកជញ្ជូន គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានរៀបចំយុទ្ធសាស្រ្ត និងផែនការសកម្មភាពសម្រាប់ការប្រែប្រួលអាកាសធាតុ និងបានបង្កើតក្រុមការងារការប្រែប្រួលអាកាសធាតុ (CCWG) ដើម្បីគាំទ្រដល់ការអនុវត្តរបស់ខ្លួន។ ធាតុចូលនៃយុទ្ធសាស្រ្តទាំងនេះនឹងត្រូវ បានពិភាក្សាលម្អិតបន្ថែមទៀតនៅខាងក្រោម។ ព័ត៌មានបន្ថែមអំពីក្រសួងគន្លឹះៗទាំងនោះ ត្រូវបានអធិប្បាយជាច់ដោយឡែកនៅក្នុងឧបសម្ព័ន្ធ៥។

### *3.2.1 ផែនការយុទ្ធសាស្រ្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP)*

60. CCCSP បានចូលជាធរមាននៅថ្ងៃទី៥ខែវិច្ឆិកាឆ្នាំ២០១៣ បន្ទាប់ពីការប្រកាសជាផ្លូវការដោយនាយករដ្ឋមន្រ្តី នៅក្នុងវេទិកាថ្នាក់ជាតិ លើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ (ថ្ងៃទី៥-៧ ខែវិច្ឆិកាឆ្នាំ២០១៣)។ CCCSP មានសារៈសំខាន់ចំពោះក្របខ័ណ្ឌទាំងមូលនៃរាជរដ្ឋាភិបាល សម្រាប់ការដោះស្រាយការប្រែប្រួលអាកាសធាតុ ដែលត្រូវបានរចនាឡើងដើម្បីជាយុទ្ធសាស្រ្តដែលជាប់ទាក់ទងគ្នា និងរួមបញ្ចូលគ្នាស្របជាមួយនឹងគោលនយោបាយ និងផែនការផ្សេងៗទៀត ដូចជា NAPA ផែនការយុទ្ធសាស្រ្តសកម្មភាពជាតិ (SNAP) សម្រាប់ការកាត់បន្ថយ ហានិភ័យគ្រោះមហន្តរាយ (DRR) គោលនយោបាយជាតិរបស់រាជរដ្ឋាភិបាលកម្ពុជាលើការអភិវឌ្ឍបៃតង និងផែនការអភិវឌ្ឍន៍នៃវិស័យ។

61. គោលបំណងនៃ CCCSP គឺ ១) កាត់បន្ថយភាពងាយរងគ្រោះ (ធម្មជាតិ និងសង្គម) នៃប្រព័ន្ធសំខាន់ៗ និង ក្រុមងាយរងគ្រោះខ្ពស់ ទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ ២) ឆ្ពោះទៅរកការអភិវឌ្ឍបៃតង តាមរយៈការលើកកម្ពស់ការអភិវឌ្ឍកាបូនទាប និងបច្ចេកវិទ្យា។ និង ៣) ការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការចូលរួមក្នុងការងារនៃការប្រែប្រួលអាកាសធាតុ។ គោលដៅនីមួយៗគឺត្រូវបានគាំទ្រដោយគោលបំណងនៃយុទ្ធសាស្រ្តមួយចំនួន។

62. កត្តាសំខាន់នៃវិធីសាស្ត្ររបស់ក្រុមការងារជំនួយបច្ចេកទេស គឺនឹងត្រូវធ្វើការជាមួយនឹងក្រសួងបរិស្ថាន NCSD និងស្ថាប័ននៃវិស័យ ដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្ត CCCSP នេះ។ ចំនួននៃគោលដៅយុទ្ធសាស្ត្រនៃCCCSPនេះបានសម្របយ៉ាងជិតស្និទ្ធជាមួយនឹងសកម្មភាពរបស់កញ្ចប់ទី១ (រូបទី៣-៣)។

## ក្រាហ្វិច 6: ទំនាក់ទំនងរវាងជាតុចេញនៃកញ្ចប់ទី១ និង CCCSP




63. CCCSP នេះនឹងត្រូវបានអនុវត្តនៅក្នុងបីដំណាក់កាល និងសង្កត់ធ្ងន់លើការកសាងសមត្ថភាពស្ថាប័ន និងចំណេះដឹង វិទ្យាសាស្ត្រ សម្រាប់ការដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការលើកកំពស់ សកម្មភាពនៃការបន្សាំ និងសកម្មភាពនៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ សកម្មភាពរបស់កញ្ចប់ទី១នេះ នឹងរួមចំណែកដល់ ផែនការសកម្មភាពនៃ CCCSP រយៈពេលមធ្យម ពីឆ្នាំ ២០១៤-២០១៨។ ជាពិសេសនៅក្នុងទំនាក់ទំនងទៅនឹងសកម្មភាពអភិវឌ្ឍសមត្ថភាព ការបញ្ជ្រាបការងារទាក់ទងនឹងការប្រែប្រួលអាកាសធាតុដែលមានមូលដ្ឋានលើSCCSPs នៅតាមវិស័យ។ កំណត់

ឱកាសដើម្បីទទួលហិរញ្ញប្បទានសម្រាប់ សកម្មភាពបន្សុាំ និង ការប្រតិបត្តិប្រពន្ធ័តាមដានត្រួតពិនិត្យ និងវាយតម្លៃបន្ថែមទៀត សម្រាប់បន្សុាំនឹងការប្រែប្រួលអាកាសធាតុ។

**ក្រាហ្វិច 7: ដំណាក់កាលរបស់ CCCSP និងសកម្មភាពសមស្រប**




### *3.2.2 ផែនការយុទ្ធសាស្ត្រ និងសកម្មភាពនៃវិស័យ*

64. ស្របជាមួយនឹងការរៀបចំ CCCSP នេះ CCD ដោយមានការគាំទ្រពី កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) បានធ្វើការសម្របសម្រួលផងដែរ ជាមួយនឹងក្រសួងពាក់ពន្ធ័ ដើម្បីអភិវឌ្ឍផែនការយុទ្ធសាស្ត្រ (CCSP) និង ផែនការសកម្មភាព (CCAP) សម្រាប់ការប្រែប្រួលអាកាសធាតុទៅតាមវិស័យរបស់ខ្លួន។ CCSPs និង CCAPs នៃក្រសួងពាក់ពន្ធ័ទាំងនេះ ត្រូវបានបញ្ចប់នៅក្នុងត្រីមាសដំបូងនៃឆ្នាំ ២០១៤។ ឯកសារទាំងនោះបង្ហាញនូវបញ្ហាសំខាន់ៗនៃការប្រែប្រួលអាកាសធាតុ និងកំណត់យុទ្ធសាស្ត្រដើម្បីដោះស្រាយសម្រាប់វិស័យរបស់ខ្លួន។ ឯកសារទាំងនោះក៏បានផ្ដល់នូវ ការបង្ហាញ ពីសមត្ថភាព និង ធនធានដែលមានស្រាប់ របស់ក្រសួងនិមួយៗ ដើម្បីអនុវត្តនូវយុទ្ធសាស្ត្រ និងសកម្មភាពដែលបានកំណត់ទាំងនោះ។ ហើយក៏បានបង្ហាញពីវិធីសាស្ត្រ សកម្មភាពជាអាទិភាព ដោះស្រាយ ឧបសគ្គសំខាន់ៗ និងរៀបរាប់អំពីការគាំទ្រផ្នែកហិរញ្ញវត្ថុដែលចាំបាច់ ដើម្បីឆ្ពោះទៅមុខជាមួយនឹងផែនការ សកម្មភាព។

65. វិស័យគន្លឹះដែលបានបង្កើតផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ការប្រែប្រួលអាកាសធាតុទាំង នោះរួមមាន:

(i) ផែនការសកម្មភាពជាអាទិភាព សម្រាប់ការប្រែប្រួលអាកាសធាតុ សម្រាប់ វិសយ័កសិកម្ម រុក្ខាប្រមាញ់និង នេសាទ ឆ្នាំ២០១៤ - ឆ្នាំ២០១៨, ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ

(ii) ផែនការសកម្មភាពសម្រាប់ការប្រែប្រួលអាកាសធាតុ សម្រាប់វិស័យអភិវឌ្ឍន៍ជនបទ, ២០១៤ - ២០១៨, ក្រសួងអភិវឌ្ឍន៍ជនបទ

(iii) ផែនការសកម្មភាពសម្រាប់ការប្រែប្រួលអាកាសធាតុ សម្រាប់វិស័យដឹកជញ្ជូន, ២០១៤ - ២០១៨, ក្រសួងសាធារណៈការ និង ដឹកជញ្ជូន

(iv) ផែនការសកម្មភាពសម្រាប់ការប្រែប្រួលអាកាសធាតុ សម្រាប់វិស័យធនធានទឹក និងឧតុនិយម ២០១៤ - ២០១៨, ក្រសួងធនធានទឹក និងឧតុនិយម

(v) ផែនការយុទ្ធសាស្រ្តសម្រាប់ការប្រែប្រួលអាកាសធាតុ សម្រាប់វិស័យវិស័យការអប់រំ (២០១៣) និង

(vi) ផែនការសកម្មភាពសម្រាប់ការប្រែប្រួលអាកាសធាតុ សម្រាប់វិស័យអប់រំ (២០១៤), ក្រសួងអប់រំ យុវជន និងកីឡា

66. ក្រុមការងារការប្រែប្រួលអាកាសធាតុ (CCWG) របស់ក្រសួងគឺធ្វើការសម្របសម្រួល និងពិនិត្យលើសកម្មភាព និងត្រួតពិនិត្យភាពរីកចម្រើនលើការអនុវត្តផែនការយុទ្ធសាស្រ្តឆ្លើយតបការប្រែប្រួលអាកាសធាតុលើវិស័យរបស់គេ។ ក្រុមការងារនេះ គឺមានសមាជិកមកពីនាយកដ្ឋានសំខាន់ៗពាក់ព័ន្ធកិច្ចការការប្រែប្រួលអាកាសធាតុរបស់ក្រសួង។ ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុរបស់ក្រសួង គឺពាក់ព័ន្ធរាល់នាយកដ្ឋានទាំងអស់ ហើយក្រុមការងារនេះគឺធ្វើការសម្របសម្រួលរវាងនាយកដ្ឋាននានាក្នុងក្រសួង ដើម្បីអនុវត្តយុទ្ធសាស្រ្ត សកម្មភាព និងគម្រោងការប្រែប្រួលអាកាសធាតុក្នុងក្រសួង។

67. ក្រុមការងារការប្រែប្រួលអាកាសធាតុ គឺបានបង្កើតឡើង ជាពិសេសតាមក្រសួងដែលទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុខ្លាំងជាងគេ និងជាក្រសួងដែលអនុវត្តគម្រោងវិនិយោគ SPCR។ ក្រុមការងារនេះបានសម្របសម្រួលក្នុងការរៀបចំផែនការយុទ្ធសាស្រ្ត និងផែនការសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុរបស់ក្រសួង ដោយទទួលបានការគាំទ្របច្ចេកទេស និងថវិកាពីសម្ព័ន្ធភាពការប្រែប្រួលអាកាសធាតុកម្ពុជា (CCCA)។ ជាងនេះទៅទៀត សមាជិកក្រុមការងារនេះ គឺជាក្រុមគោលដៅរបស់ក្រសួងដែលជួយ និងសម្របសម្រួលរាល់ការងារ និងគម្រោងនានាដែលពាក់ព័ន្ធសកម្មភាពការប្រែប្រួលអាកាសធាតុជាមួយក្រសួងបរិស្ថាន (MOE) និងជាមួយដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត។ ក្រសួងពាក់ព័ន្ធកម្មវិធី SPCR ដែលមានក្រុមការងារការប្រែប្រួលអាកាសធាតុមានដូចជា ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងធនធានទឹក និងឧត្តុនិយម ក្រសួងផែនការ ក្រសួងកិច្ចការនារី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មាធិការដើម្បីភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD) និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM)។

### *3.2.3 គោលនយោបាយពាក់ព័ន្ធនានា ដែលឆ្លើយតបការប្រែប្រួលអាកាសធាតុនៅកម្ពុជា*

**យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល**

68. យុទ្ធសាស្រ្តចតុកោណឆ្លើយតបកិច្ចអភិវឌ្ឍន៍ ការងារ សមភាព និងប្រសិទ្ធិភាពដំណាក់កាលទី៣ (២០១៣-២០១៨) ត្រូវបានអនុម័តដោយរដ្ឋសភាជាតិ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០១៣ និងដាក់ចេញនូវទស្សនៈវិស័យអភិវឌ្ឍន៍យូរអង្វែងរបស់កម្ពុជា។ ដោយមើលឃើញពីការការគំរាមកំហែងពីការប្រែប្រួលអាកាសអាតុ ដែលវាបង្កជាបញ្ហាដល់ប្រព័ន្ធអេកូឡូស៊ី និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកម្ពុជា យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ គឺបានកំណត់កាប្រែប្រួលអាកាសធាតុជាបញ្ហាប្រឈមមួយដ៏សំខាន់ដែលត្រូវដោះស្រាយ។ ជាពិសេស ការគ្រប់គ្រងប្រកបដោយចីរភាពលើបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ត្រូវបានចាត់ទុកជាបញ្ហាបរិស្ថានគន្លឹះដែលត្រូវគិតគូរជាមុន សម្រាប់ការអភិឌ្ឍន៍នៅក្រោមយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣នេះ។

## ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ

69. ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ គឺជាឯកសារណែនាំគោលនយោបាយអភិវឌ្ឍន៍ជាតិរយៈពេល៥ឆ្នាំ ហើយឯកសារនេះគឺចងក្រងចេញពីយុទ្ធសាស្រ្តរបស់ក្រសួងវិស័យនីមួយៗនៃរាជរដ្ឋាភិបាលកម្ពុជា។ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិនេះ គឺបានបញ្ចប់ និងដាក់ប្រើប្រាស់នៅខែ កក្កដា ឆ្នាំ ២០១៤។ ឯកសារនេះក៏បានផ្តោតលើបញ្ហាការប្រែប្រួលអាកាសធាតុដែលត្រូវដោះស្រាយតាមរយៈការអភិវឌ្ឍ និងការពង្រឹងសមត្ថភាព ការសម្របសម្រួល ការអនុវត្តផែនការយុទ្ធសាស្រ្តការប្រែប្រួលអាកាសធាតុ ការស្វែងរកថវិកា ការអប់រំ និងការលើកកម្ពស់ការយល់ដឹង។

### កម្មវិធីសកម្មភាពជាតិបន្សាំការប្រែប្រួលអាកាសធាតុកម្ពុជា (NAPA)

70. កម្មវិធីសកម្មភាពជាតិបន្សាំការប្រែប្រួលអាកាសធាតុ (NAPA) ដែលបានដាក់ជូនទៅកាន់ក្របខណ្ឌគណៈកម្មាធិការការប្រែប្រួលអាកាសធាតុអង្គការសហប្រជាជាតិ (UNFCCC) នៅឆ្នាំ២០០៦ គឺជាឯកសារក្របខណ្ឌគោលនយោបាយដំបូង ស្តីពីសកម្មភាពការប្រែប្រួលអាកាសធាតុកម្ពុជា។ កម្មវិធីសកម្មភាពជាតិបន្សាំការប្រែប្រួលអាកាសធាតុនេះ គឺមានសារៈសំខាន់សម្រាប់កម្មវិធី SPCR។ ឯកសារនេះ បានកំណត់គម្រោងអាទិភាពសំខាន់ៗចំនួន២០ ឆ្លើយតបជាបន្ទាន់លើតម្រូវការបន្សាំ និងការព្រួយបារម្ភណ៍របស់ប្រជាពលរដ្ឋទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន។ អាទិភាពគឺគ្របដណ្តប់ទូលំទូលាយទៅលើវិស័យសំខាន់ៗ នៃសមាសភាពប្រព័ន្ធធម្មជាតិ និងសង្គមដូចជា កសិកម្ម ធនធានទឹក អេកូឡូស៊ីតំបន់ឆ្នេរ និងសុខភាពមនុស្ស។ គម្រោងចំនួន១៦ ក្នុងចំណោមគម្រោងទាំងនេះ គឺជាប់ពាក់ព័ន្ធនឹងវិស័យដែលជំនួយបច្ចេកទេសនេះកំពុងផ្តោតលើ រួមទាំងគម្រោងលើវិស័យកសិកម្ម ធនធានទឹក តំបន់ឆ្នេរ និងគម្រោងពហុវិស័យ។

71. គោលនយោបាយរបស់រដ្ឋាភិបាលផ្សេងៗទៀត ដែលពាក់ព័ន្ធកិច្ចខិតខំប្រឹងប្រែងបញ្ជ្រាបការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា គឺបានបង្ហាញក្នុងតារាង ៣.១

**តារាង ៣.១៖ គោលនយោបាយ និងកិច្ចផ្តួចផ្តើមផ្សេងៗពាក់ព័ន្ធការបញ្ជ្រាបភាពធន់ និងការបន្សាំការប្រែប្រួលអាកាសធាតុ ក្នុងប្រទេសកម្ពុជា**

| ចំណងជើងឯកសារ | ការពិពណ៌នា/ភាពពាក់ព័ន្ធនៃឯកសារ |
|---|---|
| ផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ (SNAP) ២០០៨ -២០១៣ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ | ឯកសារនេះដាក់ប្រើប្រាស់នៅឆ្នាំ២០០៨ ជាមួយគោលបំណងដើម្បីបញ្ជ្រាបការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយទៅក្នុងគោលនយោបាយ និងផែនការវិនិយោគតាមវិស័យ |
| កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) ២០១០-២០១៩ | ជាដំណើរការកែទម្រង់ស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលការកែទម្រង់នេះគឺបង្កឥទ្ធិពលដល់ស្ថាប័នជាតិផ្សេងៗទៀតដែរ។ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) បានរៀបចំឡើងដើម្បីជម្រុញ ពង្រឹងសមត្ថភាព និងភាពជាម្ចាស់នៃក្រុមប្រឹក្សាថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង និងការអភិវឌ្ឍនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ នេះរួមបញ្ចូលទាំងការអភិវឌ្ឍ និងការកសាងសមត្ថភាពធនធានមនុស្ស ដើម្បីគាំទ្រមុខងាររបស់ក្រុមប្រឹក្សា ការផ្ទេរមុខងារ និងធនធានពីថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការពង្រឹងការគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋនៅថ្នាក់ក្រោមជាតិ។ កម្មវិធីជាតិនេះ ត្រូវបានអនុវត្តដោយចែកចេញជាបីពាជំហានធំៗ។ ជំហានទី១ គឺផែនការអនុវត្តរយៈពេល៣ឆ្នាំ (IP3) ជំហានទី២ គឺផែនការអនុវត្តរយៈពេល៣ឆ្នាំ (IP3) ដំណាក់កាលទី២ និងជំហានចុងក្រោយគឺផែនការអនុវត្តរយៈពេល៤ឆ្នាំ (IP4)។ កម្មវិធីជាតិនេះត្រូវបានអនុវត្តប្រចាំឆ្នាំដោយផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ (AWPB)។ ផែនការអនុវត្តរយៈពេល៣ឆ្នាំ (IP3) ជំហានទី២ និងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ (AWPB) ដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន គឺបានបញ្ចូលសកម្មភាពបញ្ជ្រាបការបន្សាំការប្រែប្រួលអាកាសធាតុសម្រាប់ការអនុវត្ត។ |
| ផែនទីចង្អុលផ្លូវនៃការអភិវឌ្ឍន៍ជាតិបៃតង | ជាគោលនយោបាយមួយដែលផ្តោតលើដំណើរការរីកចម្រើនសេដ្ឋកិច្ចប្រកបដោយចីរភាពផ្នែកអេកូឡូស៊ី តាមរយៈការជម្រុញការបញ្ចេញកាបូនតិចក្នុងការអភិវឌ្ឍសង្គម |
| ច្រករបៀងសេដ្ឋកិច្ចមហា | ជាច្រករបៀងដឹកជញ្ជូនដ៏សំខាន់ (និងការអភិវឌ្ឍទីក្រុងច្រករបៀងទី២ផងដែរ) ដែល |

| | |
|---|---|
| អនុតំបន់ទន្លេមេគង្គ | ផ្តោតសំខាន់សម្រាប់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា |
| ផែនការយុទ្ធសាស្ត្រយេនឌ័រ និងការប្រែប្រួលអាកាសធាតុ | គោលដៅគឺដើម្បីបញ្ជ្រាបការពិចារណាយេនឌ័រទៅក្នុងសកម្មភាពអភិវឌ្ឍន៍ការប្រែប្រួលអាកាសធាតុ |
| ផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយធម្មជាតិ (NAP-DRR) ២០១៤-២០១៨ | ផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយធម្មជាតិ (NAP-DRR) បានរៀបចំឡើងដោយផ្អែកលើការអនុវត្តផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ ២០០៨-២០១៣ ដែលផែនការសកម្មភាពជាតិនេះ គឺបានដាក់ប្រើប្រាស់នៅឆ្នាំ ២០១៤។ ផែនការសកម្មភាពជាតិនេះ មានគោលដៅជម្រុញការបញ្ជ្រាបសកម្មភាពកាត់បន្ថយហានិភ័យគ្រោះមហន្តរាយធម្មជាតិទៅក្នុងគោលនយោបាយ និងកម្មវិធីនានារបស់ក្រសួង ស្ថានប័ននានា និងបង្កើននូវសន្តិសុខស្បៀងសម្រាប់ភាពធន់របស់សហគមន៍។ វាក៏ពង្រឹងនូវយន្តការ ប្រសិទ្ធភាព និងភាពពាក់ព័ន្ធលើការសម្របសម្រួលគ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមបញ្ចូលទាំងស្ថាប័នរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសង្គមស៊ីវិល។ ផែនការសកម្មភាពជាតិនេះ គឺសង្កត់ធ្ងន់លើការបន្តការអភិវឌ្ឍធនធានមនុស្ស និងសមត្ថភាព ដើម្បីលើកកម្ពស់ការឆ្លើយតបគ្រោះមហន្តរាយ ជាពិសេសគាំទ្រក្រុមជនងាយរងគ្រោះ ក្នុងអំឡុងពេល និងក្រោយពេលគ្រោះមហន្តរាយកើតឡើង តាមរយៈការពង្រឹងស្ថាប័នពាក់ព័ន្ធ និងយន្តការក្នុងការអនុវត្តកម្មវិធីកាត់បន្ថយហានិភ័យគ្រោះធម្មជាតិនៅសហគមន៍មូលដ្ឋាន។ |

### *3.2.4 គោលនយោបាយគោលការណ៍ណែនាំស្តង់ដារតាមវិស័យ និងក្រុមការងារនានាពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ*

72. គោលនយោបាយ គោលការណ៍ណែនាំ ស្តង់ដារ និងក្រុមការងារតាមវិស័យនានា គឺជាមធ្យោបាយគន្លឹះរបស់ក្រសួងវិស័យក្នុងការពង្រឹងភាពធន់ឆ្លើយតបការប្រែប្រួលអាកាសធាតុ។ ការងារសំខាន់របស់ក្រុមជំនួយបច្ចេកទេស នឹងពាក់ព័ន្ធសកម្មភាពពិនិត្យឡើងវិញនូវគោលការណ៍ណែនាំពាក់ព័ន្ធនានាតាមវិស័យ និងរៀបចំស្តង់ដារ និងចងក្រងជាអនុសាសន៍ដើម្បីបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងផែនការតាមវិស័យ។

73. តារាងខាងក្រោម (តារាង៣.២) បង្ហាញពីស្ថានភាពនៃគោលនយោបាយ សៀវភៅណែនាំ គោលការណ៍ណែនាំ និងស្តង់ដាខុសៗគ្នា ដែលពាក់ព័ន្ធនឹងសកម្មភាពកញ្ចប់ទី១ និងត្រូវបានចាត់ជាផ្នែកនៃសកម្មភាពបញ្ជ្រាបរបស់កញ្ចប់ទី១។

តារាង ៣.២៖ គោលការណ៍ណែនាំ ស្តង់ដារ និងក្រុមការងារតាមក្រសួង

| គោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធ ដែលឆ្លើយតបការប្រែប្រួលអាកាសធាតុ | គោលការណ៍បច្ចេកទេស ឬប្រតិបត្តិការ និងស្តង់ដារ ដែលពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ ដែលត្រូវពិនិត្យ | ស្ថានភាពនៃក្រុមការងារការប្រែប្រួលអាកាសធាតុ |
|---|---|---|
| **ក្រសួងបរិស្ថាន** | | |
| ក្រសួងបរិស្ថានបានបញ្ចប់ និងដាក់ប្រើប្រាស់នូវផែនការយុទ្ធសាស្ត្រឆ្លើយតបការប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP) ២០១៤ - ២០២៣ នៅឆ្នាំ២០១៤<br><br>ក្រសួងបរិស្ថានបានសម្របសម្រួលក្រសួងពាក់ព័ន្ធសំខាន់ៗនានា ក្នុងការរៀបចំ និងដាក់ប្រើប្រាស់នូវផែនការយុទ្ធសាស្ត្រតាមវិស័យ និងផែនការសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុ។<br><br>ក្រសួងបរិស្ថានកំពុងរៀបចំផែនការសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុសម្រាប់វិស័យបរិស្ថាន។ ក្រសួងគ្រោងបញ្ចប់ផែនការសកម្មភាពនេះ នៅខែកក្កដា ឆ្នាំ ២០១៥។<br><br>ឯកសារច្បាប់ផ្សេងៗទៀតដែលជាប់ពាក់ព័ន្ធការប្រែប្រួលអាកាសធាតុរួមមាន៖ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ច្បាប់ស្តីពីការគ្រប់គ្រងបរិស្ថាន | ឧបករណ៍ជ្រើសរើសហានិភ័យអាកាសធាតុ និងសេណារីយ៉ូបង្រួមមាត្រដ្ឋាន អាកាសធាតុសម្រាប់អនុវត្តក្នុងការបង្កើតផែនការ និងគោលនយោបាយ គឺស្ថិតក្នុងលក្ខខណ្ឌ ត្រូវកែសម្រួលឡើងវិញ<br><br>ភាពធន់នឹងអាកាសធាតុនាពេលបច្ចុប្បន្នគឺកំពុងអនុវត្តជាចំបងនៅកម្រិតគម្រោង<br><br>ឯកសារណែនាំពីការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ និងការកាត់បន្ថយហានីភ័យគ្រោះមហន្តរាយទៅក្នុងផែនការវិនិយោគថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គឺស្ថិតក្នុងស្ថានភាពត្រូវកែសម្រួលឡើងវិញ។<br><br>ឯកសារណែនាំស្តីពីភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធ | ក្រុមការងារការប្រែប្រួលអាកាសធាតុបានបង្កើតឡើង និងដឹកនាំដោយលោកស៊ុំ ធីប្រធាននាយកដ្ឋានការប្រែប្រួលអាកាសធាតុ។ សមាជិកពីរនាក់ទៀត គឺលោក ជា ចាន់ធូ អនុប្រធាននាយកដ្ឋានការប្រែប្រួលអាកាសធាតុ និងលោកហាក់ ម៉ៅ ប្រធានការិយាល័យ។ |

| គោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធ ដែលឆ្លើយតបការប្រែប្រួលអាកាសធាតុ | គោលការណ៍បច្ចេកទេស ឬប្រតិបត្តិការ និងស្តង់ដារ ដែលពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ ដែលត្រូវពិនិត្យ | ស្ថានភាពនៃក្រុមការងារការប្រែប្រួលអាកាសធាតុ |
|---|---|---|
| និងការអភិរក្សធនធានធម្មជាតិ អនុក្រឹត្យស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងអនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង និងសំណល់រាវ។ | ស្រោចស្រព និងគោលការណ៍ណែនាំដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ថ្នាក់ឃុំក្នុងឆ្នាំ ២០១៤។ | |
| **ក្រសួងធនធានទឹក និងឧតុនិយម** | | |
| - គោលនយោបាយជាតិស្តីពីធនធានទឹក(2004) ;<br>- ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក (2007);<br>- ផែនការយុទ្ធសាស្ត្រលើវិស័យកសិកម្ម និងទឹកសម្រាប់ឆ្នាំ 2006-2010 (2007) និង 2009-2013 (2010);<br>- គោលនយោបាយជាតិលើការគ្រប់គ្រងធនធានទឹក (2004);<br>- ការអភិវឌ្ឍ និងការគ្រប់គ្រងប្រព័ន្ធស្រោចស្រពតាមបែបចូលរួម (PIMD);<br>- ប្រកាសលេខ ៣០៦ សម្រាប់ការបង្កើតសហគមន៍មូលដ្ឋានគ្រប់គ្រងទឹក -<br>- សារាចរលេខ១ ស្តីពីការអនុវត្តគោលនយោបាយប្រព័ន្ធស្រចស្រពដោយចីរភាព (2000);<br>- អនុក្រឹត្យស្តីពីដំណើរការសម្រាប់ | ក្រោមជំនួយបច្ចេកទេសនៃគម្រោង CDTA7610-CAM គោលការណ៍ណែនាំជាច្រើនទាក់ទងនឹងការប្រែប្រួលអាកាសធាតុត្រូវបានបង្កើតឡើង ដូចជា៖<br>1) គោលការណ៍ណែនាំ និងដំណើរការបញ្ជ្រាបបន្សុំការប្រែប្រួលអាកាសធាតុទៅក្នុងការគ្រប់គ្រងធនធានទឹកតាមបែបរួមបញ្ចូល។<br>2) សេដ្ឋកិច្ចនៃប្រតិបត្តិការនិងថែទាំប្រព័ន្ធស្រោចស្រព និង<br>3) ឧបករណ៍ GIS និងដំណើរការនៃការប្រែប្រួលអាកាសធាតុកម្ពុជាសម្រាប់គម្រោងក្រសួងធនធានទឹក និងក្រសួងបរិស្ថានដើម្បីវាយតម្លៃភាពងាយរងគ្រោះការប្រែប្រួលអាកាសធាតុ និងការបន្សុំក្នុង | ឆ្លើយតបការងារពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ ក្រសួងធនធានទឹកបានបង្កើតក្រុមការងារបច្ចេកទេសគ្រប់គ្រងទឹក និងការប្រែប្រួលអាកាសធាតុដែលទទួលបន្ទុករៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុសម្រាប់វិស័យធនធានទឹក ដែលបានដាក់ប្រើប្រាស់នៅឆ្នាំ ២០១២ និងឆ្នាំ២០១៤។.<br><br>ក្រុមការងារនេះគឺដឹកនាំដោយលោក អ៊ំ រីណា ប្រធាននាយកដ្ឋានឧតុនិយម។ ក្រុមការងារបានបញ្ចប់ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុរបស់ក្រសួង។ |

| គោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធ ដែលឆ្លើយតបការប្រែប្រួលអាកាសធាតុ | គោលការណ៍បច្ចេកទេស ឬប្រតិបត្តិការ និងស្តង់ដារ ដែលពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ ដែលត្រូវពិនិត្យ | ស្ថានភាពនៃក្រុមការងារការប្រែប្រួលអាកាសធាតុ |
|---|---|---|
| ការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក (FWUC); <br>- ការគ្រប់គ្រងអាងទន្លេ; <br>- គោលនយោបាយ និងច្បាប់ផ្សេងៗទៀត រួមមាន៖ (ក) ការអនុញ្ញាតបែងចែកទឹក និងប្រើប្រាស់ទឹក និង (ខ) វិញ្ញាបនប័ត្រទឹក និងគុណភាពទឹក។ | ការគ្រប់គ្រងធនធានទឹក។ | |
| **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតយុទ្ធសាស្ត្រតាមវិស័យជាពីរកម្រិតគឺ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (ASSDP) 2006–2010 និងយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក 2010–2013. <br>ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (ASSDP) 2006–2010 គឺជាគោលនយោបាយជាក់លាក់មួយលើផ្នែកកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលឆ្លើយតបនឹង RS និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ <br>ការប្រែប្រួលអាកាសធាតុគឺមិនបានបញ្ជ្រាបចូលទៅក្នុងក្របខណ្ឌច្បាប់ គោលនយោបាយ និងដំណើរការផែនការក្នុងក្រសួង MAFF។ | មិនមានគោលការណ៍ណែនាំសំខាន់ៗ និងឧបករណ៍ស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់កសិកម្មណា ត្រូវបានបង្កើតឡើងដោយក្រុមការងារការប្រែប្រួលអាកាសធាតុ របស់ MAFF នៅឡើយទេ។ | MAFF បានបង្កើតក្រុមការងារបច្ចេកទេសការប្រែប្រួលអាកាសធាតុតាំងពីខែវិច្ឆិកា ឆ្នាំ ២០១១ ហើយក្រុមការងារនេះមានសមាជិក១៨នាក់មកពីនាយកដ្ឋានពាក់ព័ន្ធសំខាន់ៗ និងនាយកដ្ឋានរដ្ឋបាលផងដែរ។ សមត្ថភាពក្រុមការងារដែលទើបបង្កើតថ្មីនេះ គឺនៅមានកម្រិត។ ក្រោមការជួយថវិកាពីសម្ព័ន្ធភាពការប្រែប្រួលអាកាសធាតុកម្ពុជា គឺបង្កអោយក្រុមការងារនេះបានអនុវត្តនូវសកម្មភាពរបស់ខ្លួនរួមបញ្ចូលទាំងការកសាងសមត្ថភាពមន្ត្រីរបស់ក្រសួង។ |

| គោលនយោបាយ និងយុទ្ធសាស្រ្ត ពាក់ព័ន្ធ ដែលឆ្លើយតបការប្រែប្រួលអាកាសធាតុ | គោលការណ៍បច្ចេកទេស ឬ ប្រតិបត្តិការ និងស្តង់ដារ ដែលពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ ដែលត្រូវពិនិត្យ | ស្ថានភាពនៃក្រុមការងារការប្រែប្រួលអាកាសធាតុ |
|---|---|---|
| **ក្រសួងសាធារណការ និងដឹកជញ្ជូន** | | |
| ច្បាប់និងគោលនយោបាយរួមមាន៖ (i) គោលនយោបាយសុវត្ថិភាពផ្លូវជាតិ (កុម្ភៈ ឆ្នាំ 2014); (ii) ច្បាប់ស្តីពីផ្លូវ (មេសា ឆ្នាំ 2014); (iii) ច្បាប់ស្តីពីចរាចរផ្លូវគោក (មករា ឆ្នាំ2007)<br><br>ផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិ (**NSDP**)<br><br>ផែនការយុទ្ធសាស្រ្តឆ្លើយតបការប្រែប្រួលអាកាសធាតុរបស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន<br><br>ផែនការយុទ្ធសាស្រ្តឆ្លើយតបការប្រែប្រួលអាកាសធាតុសម្រាប់ការបន្សាំការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងវិស័យដឹកជញ្ជូន, ខែធ្នូ ឆ្នាំ ២០១២<br><br>ផែនការយុទ្ធសាស្រ្តឆ្លើយតបការប្រែប្រួលអាកាសធាតុរបស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន<br><br>ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុសម្រាប់វិស័យដឹកជញ្ជូន២០១៤ ២០១៨ ( ឧសភា ២០១៤ ) | ស្តង់ដារសាងសង់ផ្លូវ – Part Geometry, CAM PW 03.101.99, Year 2003;<br>ស្តង់ដារសាងសង់ផ្លូវ – Part Pavement, CAM PW 03.102.99, Year 2003;<br>ស្តង់ដារសាងសង់ផ្លូវ – Part Drainage, CAM PW 03.103.99, Year 2003;<br>ស្តង់ដារសាងសង់ស្ពាន, CAM PW 04.102.99, Year 2003;<br>សម្ភារៈសាងសង់ ឆ្នាំ 2003;<br>ក្រសួងសាធារណៈការ និងដឹកជញ្ជូនកំពុងរៀបចំ i) ផែនការទីបង្ហាញពីផ្លូវងាយរងគ្រោះ និង ii) ការផ្លាស់ប្តូរស្តង់ដារសាងសង់ផ្លូវ ការចាក់/ក្រាលកៅស៊ូ លូទឹកស្អុយ ស្ពាន និងសម្ភារៈសាងសង់, ក្រោមកម្ចី ADB Loan No. 2839-CAM (SF) \ No. 8254-CAM. | បង្កើតដោយឯកឧត្តម ផែង សុវិជ្ជាណូ អនុរដ្ឋលេខាធិការ និងដឹកនាំដោយនាយកដ្ឋានផែនការនៃអគ្គនាយកដ្ឋានរដ្ឋបាល។ |

| គោលនយោបាយ និងយុទ្ធសាស្ត្រ ពាក់ព័ន្ធ ដែលឆ្លើយតបការប្រែប្រួលអាកាសធាតុ | គោលការណ៍បច្ចេកទេស ឬ ប្រតិបត្តិការ និងស្តង់ដារ ដែល ពាក់ព័ន្ធការប្រែប្រួលអាកាស ធាតុ ដែលត្រូវពិនិត្យ | ស្ថានភាពនៃក្រុមការងារការប្រែប្រួល អាកាសធាតុ |
|---|---|---|
| **ក្រសួងអភិវឌ្ឍជនបទ** | | |
| គោលនយោបាយ និងច្បាប់ដែល ពាក់ព័ន្ធរួមមាន៖<br>(i) យុទ្ធសាស្ត្រជាតិ សម្រាប់ផ្គត់ ផ្គង់ទឹកស្អាត អនាម័យ និងការធ្វើ អនាម័យ ឆ្នាំ២០១១-២០១៥ (មេសា ឆ្នាំ២០១១) (ii)ផែនការ យុទ្ធសាស្ត្រអភិវឌ្ឍជនបទសម្រាប់ បន្សាំការប្រែប្រួលអាកាសធាតុក្នុង ប្រទេសកម្ពុជា (កញ្ញា ឆ្នាំ២០១២) (iii) គោលនយោបាយអភិវឌ្ឍន៍ ធនធានមនុស្ស (ធ្នូ ឆ្នាំ២០១២)។ គោលនយោបាយ ដែលបានក្លាយ ជាអណត្តិនាពេលបច្ចុប្បន្នរបស់ ក្រសួងអភិវឌ្ឍជនបទ ដូចជាគោល នយោបាយស្តីពីជនជាតិភាគតិច គោលនយោបាយការអភិវឌ្ឍជនបទ គោលនយោបាយនៃការផ្គត់ផ្គង់ទឹក ជនបទ។<br>ផែនការយុទ្ធសាស្ត្រការប្រែប្រួល អាកាសធាតុនៃក្រសួងអភិវឌ្ឍន៍ ជនបទ៖ ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជនបទ សម្រាប់ការបន្សាំ ការប្រែប្រួលអាកាសធាតុក្នុង ប្រទេសកម្ពុជា កញ្ញា ឆ្នាំ ២០១២<br>ផែនការយុទ្ធសាស្ត្រការប្រែប្រួល អាកាសធាតុ សម្រាប់វិស័យអភិវឌ្ឍ | បទដ្ឋានបច្ចេកទេសសម្រាប់ រៀបចំប្លង់ផ្លូវលំ តែត្រូវការកែ លម្អ<br>គោលនយោបាយផ្លូវលំជនបទ បានព្រាងគោលការណែនាំពី គុណភាពទឹកបានដាក់ប្រើ ប្រាស់<br>គោលការណ៍ណែនាំក្រុមប្រើ ប្រាស់ទឹកគឺមានសម្រាប់ការ ផ្គត់ផ្គង់ទឹកជនបទ<br>ទស្សនទានគឺបានបញ្ចូលទៅ ក្នុងការរៀបចំប្លង់ ក៏ប៉ុន្តែ ឧបករណ៍ និងគោលការណ៍ ណែនាំនានាគឺមិនទាន់បាន រៀបចំឡើងនៅឡើយ។ | ក្រុមការងារការប្រែប្រួលអាកាសធាតុ៖ ក្រសួងអភិវឌ្ឍន៍ជនបទបានបង្កើតក្រុម ការងារការប្រែប្រួលអាកាសធាតុ (CCWG) ដែលមានឯកឧត្តម លូ ស៊ីមអៀម អនុរដ្ឋ លេខាធិការ គឺជាប្រធាន បណ្ឌិតដោក ដូម៉ា នាយដ្ឋានទឹកស្អាតជនបទ និង លោក ស្រ៊ុន ភីទូ នាយកដ្ឋានផែនការ និងទំនាក់ ទំនងសសារណៈ ជាអនុប្រធាន និង សមាជិកមកពីនាយកដ្ឋានពាក់ព័ន្ធ។ ក្រសួងអភិវឌ្ឍន៍ជនបទ បានបង្កើត ការិយាល័យសុវត្ថិភាពសង្គម និងបរិស្ថាន |

| គោលនយោបាយ និងយុទ្ធសាស្រ្ត ពាក់ព័ន្ធ ដែលឆ្លើយតបការប្រែប្រួលអាកាសធាតុ | គោលការណ៍បច្ចេកទេស ឬ ប្រតិបត្តិការ និងស្តង់ដារ ដែលពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ ដែលត្រូវពិនិត្យ | ស្ថានភាពនៃក្រុមការងារការប្រែប្រួលអាកាសធាតុ |
|---|---|---|
| ជនបទ ២០១៤ ២០១៨ (MRD’s CCAP), ឆ្នាំ២០១៤ | | |
| **គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** (ក្រសួងមហាផ្ទៃ) | | |
| | NCDD អនុវត្តកម្មវិធីជាតិប្រចាំឆ្នាំ តាមរយៈផែនការការងារ និងថវិកាប្រចាំឆ្នាំ (AWPB)។ សកម្មភាពការប្រែប្រួលអាកាសធាតុគឺបានឆ្លុះបញ្ចាំងនៅក្នុង AWPB។<br><br>សៀវភៅណែនាំពីការអនុវត្តគម្រោងគឺជាឯកសារណែនាំពេញលេញសម្រាប់កសាង និងអនុវត្តគម្រោងអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់ឃុំ សង្កាត់។ NCDD ក៏បានពិចារណាផងដែរក្នុងការបញ្ចូលការបន្សាំការប្រែប្រួលអាកាសធាតុទៅក្នុងសៀវភៅណែនាំនេះ។<br>NCDD បានបញ្ចប់ និងដាក់ប្រើប្រាស់នូវគោលការណ៍ណែនាំលើការបន្សាំការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ។ សៀវភៅបណ្តុះបណ្តាលលើគោលការណ៍ណែនាំនេះ ក៏ | ក្រុមការងារការប្រែប្រួលអាកាសធាតុបានបង្កើតឡើង និងមានសមាជិកមកពីអង្គភាពគាំទ្រ និងគ្រប់គ្រងកម្មវិធីនៃលេខាធិការដ្ឋានគណកម្មាធិការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ |

| គោលនយោបាយ និងយុទ្ធសាស្ត្រ ពាក់ព័ន្ធ ដែលឆ្លើយតបការប្រែប្រួលអាកាសធាតុ | គោលការណ៍បច្ចេកទេស ឬ ប្រតិបត្តិការ និងស្តង់ដារ ដែល ពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ ដែលត្រូវពិនិត្យ | ស្ថានភាពនៃក្រុមការងារការប្រែប្រួលអាកាសធាតុ |
|---|---|---|
| | បានបញ្ចប់ផងដែរ។ | |

## 3.3 សម្ព័ន្ធការប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) – អ្នកជាដៃគូរសំខាន់

74. សម្ព័ន្ធការប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) ក៏ដូចជាកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR) គឺអនុវត្តការងារនៅក្រោមនាយកដ្ឋានការប្រែប្រួលអាកាសធាតុ និងមានអាណត្តិខុសពី SPCR។ CCCA គឺសំដៅលើការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុនៅកម្រិតយុទ្ធសាស្ត្រ និងគោលនយោបាយ (ដែលSPCR គឺផ្តោតលើការបញ្ជ្រាបការបន្សាំការប្រែប្រួលអាកាសធាតុនៅកម្រិតគម្រោង (គម្រោងវិនិយោគ) លើវិស័យកសិកម្ម ធនធានទឹក ការដឹកជញ្ជូន និងអភិវឌ្ឍន៍ទីក្រុង។

75. CCCA គឺអនុវត្តដោយក្រសួងបរិស្ថាន ដែលជាប្រធានដឹកនាំគណៈកម្មាការជាតិការប្រែប្រួលអាកាសធាតុតាមរយៈនាយកដ្ឋានការប្រែប្រួលអាកាសធាតុ ក្រោមជំនួយបច្ចេកទេស និងថវិកាពី UNDP, EU, និង Sweden។ កម្មវិធីគឺបន្ស៊ីគ្នាយ៉ាងជិតស្និទ្ធជាមួយស្ថាប័នថ្នាក់ជាតិដែលទទួលបន្ទុកការប្រែប្រួលអាកាសធាតុ។ កម្មវិធី CCCA គឺអនុវត្តវិធីសាស្ត្រគ្រប់ជ្រុងជ្រោយ និងតាមបច្ចេកវិទ្យាថ្មីៗក្នុងការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ CCCA គឺដឹកនាំដោយគណៈគ្រប់គ្រង CCCA ដែលមានរដ្ឋមន្ត្រីក្រសួងបរិស្ថានជាប្រធាន។ ដំណាក់កាលទី១នៃកម្មវិធីនេះ គឺទើបតែបានបញ្ចប់ ហើយដំណាក់កាលទី២ គឺទើបតែបានចាប់ផ្តើម។ ដំណាក់ថ្មីនៃកម្មវិធី គឺមានគោលដៅពង្រឹងសមត្ថភាព និងប្រព័ន្ធនៅថ្នាក់ជាតិ ដើម្បីគាំទ្រការសម្របសម្រួល និងការអនុវត្តការឆ្លើយតបការប្រែប្រួលអាកាសធាតុកម្ពុជា។

76. CCCA គឺគាំទ្រលើផ្នែកបច្ចេកទេស ប្រឹក្សាលើគោលនយោបាយ និងគាំទ្រផ្នែកថវិកាសកម្មភាពផ្តល់ថវិការបស់ខ្លួន។ ផ្នែកសំខាន់ៗដែល CCCA ផ្តល់កិច្ចអន្តរាគមន៍រួមមាន ក្របខណ្ឌច្បាប់លើការប្រែប្រួលអាកាសធាតុ ក្របខណ្ឌត្រួតពិនិត្យ និងវាយតម្លៃថ្នាក់ជាតិ និងតាមវិស័យ ការអនុវត្តសាកល្បង និងការបែងចែកវិធីសាស្ត្របន្សាំ/ការកាត់បន្ថយ ការពង្រឹងប្រព័ន្ធធ្វើផែនការ និងថវិកាសម្រាប់បញ្ជ្រាបហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ និងគាំទ្រដល់ការស្រាវជ្រាវ អភិវឌ្ឍន៍ និងការរៀនសូត្រ។

77. CCCA គឺផ្តោតសំខាន់លើការធ្វើប្រសើរឡើងនូវការសម្របសម្រួលជាមួយក្រសួងសំខាន់ៗ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុតាមវិស័យ។ CCCA ជួយពង្រឹងសមត្ថភាពចចារបស់កម្ពុជាលើបញ្ហាការប្រែប្រួលអាកាសធាតុ និងយុទ្ធសាស្ត្រអប់រំ និងបង្កើនការយល់ដឹងលើការប្រែប្រួលអាកាសធាតុ។ សកម្មភាពសំខាន់គឺការផ្តល់ថវិកាលើគម្រោង ដែលបន្ស៊ីជាអាទិភាពជាតិលើការប្រែប្រួលអាកាស

ធាតុ។ CCCAផ្តល់ថវិកាដល់ក្រសួងវិស័យ ក្នុងការរៀបចំផែនការសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុតាមក្រសួងវិស័យរបស់ខ្លួន។

## 3.4 ការផ្តួចផ្តើមរបស់ដៃគូរអភិវឌ្ឍន៍ ដែលធ្វើការលើការប្រែប្រួលអាកាសធាតុ

78. មានការផ្តួចផ្តើមមួយចំនួន លើការបន្សាំការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា។ ព័ត៌មានពីការផ្តួចផ្តើម គឺមានបង្ហាញនៅក្នុងតារាងឧបសម្ព័ន្ធទី៤។

79. ការផ្តួចផ្តើមសំខាន់ៗមួយចំនួនមានដូចជា៖

80. គំនិតបន្សាំការប្រែប្រួលអាកាសធាតុ (CCAI) នៃគណៈកម្មាធិការទន្លេមេគង្គ *(*MRC*)* គាំទ្រដោយ AusAID, DANIDA, SIDA, Luxemburg, និង Finnida។ គម្រោងនេះ គឺអនុវត្តដោយគណៈកម្មាធិការទន្លេមេគង្គកម្ពុជា ជំនាញការជាតិ ដៃគូរក្រុមការងារការប្រែប្រួលអាកាសធាតុ។ ខេត្តព្រៃវែងត្រូវបានជ្រើសរើសសម្រាប់សកម្មភាពអនុវត្តផ្ទាល់ក្នុងតំបន់ ជាមួយការផ្តោតលើវិធីសាស្ត្រសមាហរណកម្មការគ្រប់គ្រងធនធានទឹក។ TA8179 អាចធ្វើការតាមរយៈក្រសួងអនុវត្តកម្មវិធី SPCR ដែលពាក់ព័ន្ធកម្មវិធី គំនិតបន្សាំការប្រែប្រួលអាកាសធាតុរបស់ MRC។

81. មូលនិធិគ្រប់គ្រងហានិភ័យអាកាសធាតុ គឺអនុវត្តតាមរយៈគណកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) និងក្រសួងបរិស្ថាន (MoE) និងគាំទ្រដោយ UNDP។ ខេត្តគោលដៅគឺព្រៃវែង ក្រចេះ សៀមរាប កំពង់ធំ និងកំពង់ឆ្នាំង។ គម្រោងផ្តួចផ្តើមនេះ គឺកំពុងអភិវឌ្ឍទិន្នន័យស្តីពីការខូចខាតពីគ្រោះមហន្តរាយក្នុងខេត្តចំនួន៥ ដោយមានការគាំទ្រពី CCCA លើការបញ្ជ្រាបការប្រែប្រួលអាកាសធាតុតាមវិស័យ។ TA8179 គឺធ្វើការងារតាមរយៈក្រសួងអនុវត្តកម្មវិធី SPCR និង NCDM។

82. ផែនការបន្សាំ និងភាពធន់អាកាសធាតុនៅតំបន់ឆ្នេរ បានអនុវត្តដោយក្រសួងបរិស្ថាន ជាមួយការគាំទ្រពីថវិកា GEF/LDCF តាមរយៈ UNEP។ គម្រោងមានគោលដៅដើម្បីបង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុរបស់សហគមន៍ និងអេកូឡូស៊ីនៅតំបន់ឆ្នេរ តាមរយៈផែនការបន្សាំ ការអន្តរាគមន៍លើការអនុវត្តនៅសហគមន៍គោលដៅ និង បទពិសោធន៍ដែលផ្តល់ពីការរៀនសូត្រអនុវត្តជាក់ស្តែង ក្នុងការរៀបចំផែនការបន្សាំទៅក្នុងគណៈកម្មាធិការកាប្រែប្រួលអាកាសធាតុជាតិ និងនាយកដ្ឋានការប្រែប្រួលអាកាសធាតុ។

83. គម្រោងកសាងសមត្ថភាពកាត់បន្ថយគ្រោះមហន្តរាយក្នុងវិស័យកសិកម្មនៅអាស៊ីអាគ្នេយ៍។ គម្រោងនេះគឺផ្តួចផ្តើមដោយប្រទេសជាច្រើន ដូចជាកម្ពុជា ឡាវ ហ្វីលីពីន និង DPRK និងគាំទ្រថវិកាដោយសហគមន៍អឺរ៉ុប តាមរយៈអង្គការ FAO។ នៅក្នុងប្រទេសកម្ពុជា គម្រោងនេះគឺអនុវត្តដោយអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម នៅក្នុងខេត្តកំពង់ស្ពឺ និងខេត្តឧត្តមានជ័យ។ សកម្មភាពចំបងនៃគម្រោងនេះគឺដើម្បី៖ (ក) អភិវឌ្ឍផែនការសកម្មភាពឆ្លើយតបការកាត់បន្ថយគ្រោះមហន្តរាយក្នុងវិស័យកសិកម្ម (លើរាល់អនុវិស័យទាំងអស់) (ខ) លើកកម្ពស់ការតស៊ូមតិ និងការយល់ដឹងស្តីពីសមាហរណកម្មការកាត់បន្ថយគ្រោះមហន្តរាយទៅក្នុងវិស័យកសិកម្ម (គ) ការសាកល្បង ការផ្ទៀងផ្ទាត់ និងការអនុវត្តល្អៗការដាំដុះដំណាំ (ឃ) កែលម្អការប្រើប្រាស់ធនធានទឹកឆ្លើយតបគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់។ ក្រុម

ការងារ TA8179 គឺធ្វើការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈគម្រោងវិនិយោគ SPCR ក្នុងការគាំទ្រការកសាងសមត្ថភាពមន្ត្រីពាក់ព័ន្ធ ការកសាងគោលការណ៍ណែនាំ ដំណើរការ និង ការរៀបចំស្តង់ដាកសិកម្មឆ្លើយតបការប្រែប្រួលអាកាសធាតុ។ អ្នកឯកទេសផ្នែកកសិកម្ម និងធនធានទឹក នៃ TA8179 នឹងផ្តល់ជំនួយបច្ចេកទេសចាំបាច់ដល់ក្រសួងកសិកម្មនៅពេលមានតម្រូវការ។

84. ការអភិវឌ្ឍន៍យុទ្ធសាស្ត្របន្សាំការប្រែប្រួលអាកាសធាតុចម្រុះមាត្រដ្ឋាន សម្រាប់សហគន៍ដាំដុះដំណាំក្នុង ប្រទេសកម្ពុជា ឡាវ បង់ក្លាដែស និងប្រទេសឥណ្ឌា។ គម្រោងចម្រុះប្រទេសនេះគឺគាំទ្រថវិកាដោយ AusAID/ACIAR តាមរយៈ CSIRO និងអនុវត្តដោយ CARDI នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានកសិកកម្មដាំដុះ)។ គោលបំណងគឺដើម្បីចម្លងភាពខ្វះចន្លោះ នៅក្នុងប្រទេសទាំងនេះរវាង មាត្រដ្ឋានភាពងាយរងគ្រោះការប្រែប្រួលអាកាសធាតុជាតិ និងការវាយតម្លៃផលប៉ះពាល់ និងការ អន្តរាគមន៍លើការបន្សាំនៅកម្រិតគ្រួសារ និងសហគមន៍។ TA8179 នឹងប្រើប្រាស់ចាំបាច់នូវទិន្នន័យ បង្រួមមាត្រដ្ឋានពីគម្រោងក្នុងការវាយតម្លៃពីភាពងាយរងគ្រោះ និងការធ្វើផែនការបន្សាំ។

85. ដំណើរការផែនការជាតិបន្សាំការប្រែប្រួលអាកាសធាតុ *(NAP)* និងកម្មវិធីហិរញ្ញប្បទានអាកាសធាតុ គឺ អនុវត្តដោយនាយកដ្ឋានការប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន ជាមួយការគាំទ្រពី CCCA GIZ និង USAID ដោយផ្តោតលើការលើការរៀបចំដំណើរការផែនការជាតិបន្សាំការប្រែប្រួលអាកាសធាតុ ហើយ TA 8179 នឹងសហការយ៉ាងជិតស្និទ្ធជាមួយអ្នកពាក់ព័ន្ធយ៉ាងសំខាន់ក្នុងការរៀបចំដំណើរការផែនការជាតិ បន្សាំការប្រែប្រួលអាកាសធាតុនេះ ក្នុងគោលដៅដើម្បីអភិវឌ្ឍន៍សំណើរគម្រោងបន្សាំមួយចំនួន ដើម្បី ស្វែងរកថវិកាពីមូលនិធិអាកាសធាតុ។ សមាជិកក្រុមការងារគឺបានចូលរួមក្នុងសិក្ខាសាលាដែលបាន រៀបចំនៅខែមិថុនា ឆ្នាំ ២០១៥ នៅក្រុងសៀមរាប។ លើសពីនេះអ្នកឯកទេសនៃ TA8179 និង CCCA បានកំពុងសហការរួមគ្នារៀបចំសេចក្តីសង្ខេបព័ត៌មានសំខាន់ៗនៃមូលនិធិអាកាសធាតុពិភពលោកមួយ ចំនួនដែលមានសក្តានុពលសម្រាប់កម្ពុជាក្នុងការស្វែងរកថវិកាអនុវត្តគម្រោង និងសកម្មភាពឆ្លើយតបការ ប្រែប្រួលអាកាសធាតុ។

86. គម្រោង HARVEST គឺគាំទ្រដោយថវិកាដោយ USAID តាមរយៈ Fintrac។ គម្រោងនេះគឺកំពុងអនុវត្ត នៅក្នុងខេត្តបាត់ដំបង កំពង់ធំ ពោធិ៍សាត់ និងសៀមរាប។ គោលបំណងនៃគម្រោងគឺដើម្បីស្វែងរកនូវ ដំណោះស្រាយល្អៗឆ្លើយតបទិន្នផលទាបនៃផលដំណាំ ការបាត់បង់ផលប្រមូល postharvest losses ការខ្វះជីវជាតិ malnutrition ការខ្វះទីផ្សារ ការអន់ថយផ្នែកបរិស្ថាន និងឥទ្ធិពលនៃការប្រែប្រួលអាកាស ធាតុលើប្រជាពលរដ្ឋដែលងាយរងគ្រោះនៅជនបទ។ TA8179 នឹងស្វែងរកលទ្ធភាពក្នុងការចូលរួមការងារ ក្នុងវិស័យកសិកម្ម ជាពិសេសតាមរយៈគម្រោងវិនិយោគ SPCR ដែលអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

87. ការលើកកម្ពស់ការអនុវត្តភាពធន់នឹងអាកាសធាតុក្នុងវិស័យកសិកម្ម និងការគ្រប់គ្រងធនធានទឹកក្នុងទី ជនបទនៃប្រទេសកម្ពុជា (គម្រោងអនុវត្ត NAPA) ជំហានទី១ និងជំហានទី២។ គម្រោងនេះគឺគាំទ្រ ថវិកាដោយ GEF/LDCF តាមរយៈ UNDP និង CIDA និងសហការអនុវត្តជាមួយក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទនៅក្នុងខេត្តក្រចេះ និងខេត្តព្រះវិហារ។ វាជាគម្រោងអនុវត្តសាកល្បង បញ្ជ្រាបការ

បន្សាំការប្រែប្រួលអាកាសធាតុទៅក្នុងផែនការ ជាការរៀនសូត្រ និងលើកកម្ពស់ការយល់ដឹងដោយផ្តោតជាសំខាន់លើផ្នែកកសិកម្ម និងធនធានទឹក។ TA8179 អាចផ្តល់ជាជំនួយចាំបាច់លើការធ្វើកសិកម្មឆ្លើយតបការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍន៍ភាពធន់នឹងអាកាសធាតុក្នុងវិស័យធនធានទឹក តាមរយៈការចងក្រងអនុសាសន៍គោលនយោបាយ ការកសាងគោលការណ៍ណែនាំ ដំណើរការ និងការរៀបចំស្តង់ដារសម្រាប់វិស័យកសិកម្ម និងធនធានទឹក។

88. គម្រោងគ្រប់គ្រងធនធានទឹក (WRMP) គឺគាំទ្រថវិកាដោយមូលនិធិអភិវឌ្ឍន៍Nordic (NDF) និងអនុវត្តដោយក្រសួងធនធានទឹក និងឧតុនិយម (MOWRAM)។ គោលបំណងនៃគម្រោងនេះ គឺដើម្បីបញ្ជ្រាបកាបន្សាំការប្រែប្រួលអាកាសធាតុទៅក្នុងផែនការ និងការគ្រប់គ្រងនៅកម្រិតគោលនយោបាយ និងការអនុវត្តដោយការគិតគូរនិទស្សន៍ពីការប្រែប្រួលលើអាកាសធាតុ។ គម្រោងនេះ គឺបានអភិវឌ្ឍន៍ប្រព័ន្ធទិន្នន័យស្តីពីការប្រែប្រួលអាកាសធាតុ ដែលTA8179 នឹងប្រើប្រាស់ប្រព័ន្ធទិន្នន័យនេះរបស់ MoWRAM សម្រាប់ធ្វើអន្តរាគមន៍ជំនួយបច្ចេកទេសសមស្របតាមតម្រូវការរបស់គម្រោង។ សក្តានុពលកិច្ចសហប្រតិបត្តិការជាមួយ TA គឺតាមរយៈការចងក្រងអនុសាសន៍គោលនយោបាយ ការកសាងគោលការណ៍ណែនាំ ដំណើរការ និងរៀបចំស្តង់ដារសម្រាប់វិស័យកសិកម្ម និងធនធានទឹក។

89. វិធីសាស្ត្របន្សាំក្នុងវិស័យដឹកជញ្ជូន ដែលគាំទ្រដោយមូលនិធិអភិវឌ្ឍន៍Nordic (NDF) តាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី អនុវត្តដោយក្រសួងសាធារណការ និងដឹកជញ្ជូន។ គោលបំណងនៃគម្រោងនេះ គឺដើម្បីជួយប្រទេសកម្ពុជាក្នុងការឆ្លើយតបការប្រែប្រួលអាកាសធាតុ ស្របតាមគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់រដ្ឋាភិបាល។ ការចូលរួមដំបូងរបស់គម្រោងគឺដើម្បីលើកកម្ពស់សមត្ថភាពស្ថាប័ន និងបច្ចេកទេសដើម្បីបន្សាំការប្រែប្រួលអាកាសធាតុក្នុងវិស័យដឹកជញ្ជូន។ TA 8179 នឹងធ្វើការជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន តាមរយៈសកម្មភាពនានារបស់ SPCR។

# 4 ដំណោះស្រាយ និងវិធីសាស្ត្រ

## 4.1 ការពិនិត្យមើលលើវិធីសាស្ត្របញ្ជ្រាបការប្រែប្រួលអាកាសធាតុ

90. ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ គឺមានបញ្ហាប្រឈមសំខាន់ៗចំនួនបី ដែលត្រូវដោះស្រាយជាបន្ទាន់ រួមមានភាពស្មុគស្មាញលើបច្ចេកទេស ភាពស្មុគស្មាញលើស្ថាប័ន និងសមត្ថភាពមានកម្រិតក្នុងការបញ្ជ្រាប។ ការពិនិត្យមើលលើបញ្ហាប្រឈមទាំងនេះ និងវិធីសាស្ត្រដែលត្រូវអនុវត្តដើម្បីដោះស្រាយ គឺត្រូវបានបង្ហាញក្នុងក្រាហ្វិច៤.១ ខាងក្រោម៖

**ក្រាហ្វិច ៩៖** ការពិនិត្យលើវិធីសាស្ត្រអនុវត្ត



91. បង្ហាញពីប្រសិទ្ធភាពបច្ចេកទេស និងវិធីសាស្ត្រជាប្រព័ន្ធ ដើម្បីបញ្ជ្រាបភាពធន់នឹងអាកាសធាតុ៖ ការប្រែប្រួលអាកាសធាតុបង្ហាញពីបញ្ហាប្រឈមបច្ចេកទេស សម្រាប់អ្នកធ្វើគោលនយោបាយ ដែលក្នុងនោះបញ្ហាប្រឈមមួយគឺភាពមិនប្រាកដប្រជា (uncertainty)។ ការបញ្ជ្រាបវិធានការការប្រែប្រួលអាកាសធាតុ ដើម្បីជម្រុញការបញ្ជ្រាបភាពធន់នឹងអាកាសធាតុក្នុងផែនការអភិវឌ្ឍន៍របស់រដ្ឋាភិបាលគឺកាត់បន្ថយភាពមិនប្រាកដប្រជាទាំងនេះជាប្រព័ន្ធ។ ការកែទម្រង់ស្ថាប័ន និងការកសាងសមត្ថភាពបន្ថែមរបស់រដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាប្រឈមនានាទាក់ទិននឹងការប្រែប្រួលអាកាសធាតុ គឺត្រូវការមូលដ្ឋានភស្តុតាង និងបច្ចេកទេសឆ្លើយតបសមស្រប។

92. ក្រុមការងារគម្រោងនឹងអនុវត្តជំហានមួយចំនួនរួមមាន ការចុះសិក្សានៅមូលដ្ឋាន ការប្រមូលទិន្នន័យ និងការធ្វើបណ្ណាល័យសាស្ត្រ ដើម្បីចងក្រងជាឯកសារព័ត៌មានចុងក្រោយបង្អស់ស្តីពីផលប៉ះពាល់ការប្រែប្រួលអាកាសធាតុតាមវិស័យគោលដៅ។ ក្រុមការងារគម្រោង នឹងប្រើប្រាស់វិធីសាស្ត្រដែលមានលក្ខណៈបត់បែនតាមបរិបទជាក់លាក់ និងផ្តោះទៅរកវិស័យ ដើម្បីអភិវឌ្ឍន៍ចំណេះដឹងលើការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ ដែលធ្វើលើសកម្មភាពដែលមានស្រាប់ និងកិច្ចខិតខំនៃអ្នកអភិវឌ្ឍន៍ផ្សេងៗទៀត។ សកម្មភាពកញ្ចប់ទី១ គឺមិនបានរាប់បញ្ចូលការអភិវឌ្ឍន៍លើការបង្រួមមាត្រដ្ឋានអាកាសធាតុ និងម៉ូឌែលទឹកសម្រាប់កម្ពុជាទាំងមូល ឬសម្រាប់ទីតាំងគម្រោងណាមួយនោះទេ។ ដើម្បីដោះស្រាយបញ្ហានេះ តាមលទ្ធភាព គឺក្រុមការងារគម្រោងនឹងរៀបចំសកម្មភាពនៅមូលដ្ឋានទីតាំងដែលមានព័ត៌មាន ដើម្បីអនុវត្ត

ផ្ទាល់នូវការបន្ថែមតម្លៃនៃព័ត៌មានម៉ូឌែល ក្នុងការរៀបចំវាយតម្លៃពីភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងដំណើរការផែនការបន្សាំ។

93. ការយល់ដឹងពីស្ថាប័នបរិស្ថាន និងការអនុវត្ត និងកិច្ចសម្របសម្រួលកិច្ចសហការសម្រាប់ការកែទម្រង់៖ ជាការពិតស្ថាប័នមានទំនោរទៅរកការរៀបចំតាមវិស័យជាជាងការសមាហរណកម្មបញ្ចូលគ្នា ដូចនេះកិច្ចការអន្តរវិស័យអាចក្លាយកិច្ចខិតខំប្រឹងប្រែងដ៏ស្មុគស្មាញ ដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការកសាងផែនការ និងគោលនយោបាយ។ ការប្រែប្រួលអាកាសធាតុគឺមានផលប៉ះពាល់លើវិស័យច្រើន និងជាលទ្ធផលគឺតម្រូវការឆ្លើយតប និងការរៀបចំតាមបែបចូលរួមពីពហុស្ថាប័ន។ វិធីសាស្ត្របែបចូលរួម និងទំនាក់ទំនងបើកចំហររវាងអ្នកអនុវត្តគម្រោង រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធរបស់គម្រោងនឹងពន្យល់ពីសកម្មភាពក្រុមការងាររបស់គម្រោង។ ដើម្បីធានាពីភាពជាម្ចាស់នៃរដ្ឋាភិបាល និងសង្គមស៊ីវិលលើសកម្មភាព និងផលសម្រេចបានរបស់គម្រោង ដៃគូរដ្ឋាភិបាល ក៏ដូច NGOs, CSOs និងវិស័យឯកជន ក្រុមគោលដៅនឹងចូលរួមជាមួយគ្នាក្នុងកិច្ចប្រជុំសាមញ្ញ ក្នុងគម្រោងកសាងសមត្ថភាពការអភិវឌ្ឍន៍គម្រោងបន្សាំ និងសកម្មភាពកសាងផែនការជាតិបន្សាំការប្រែប្រួលអាកាសធាតុ។

94. ក្រុមការងារគម្រោងនឹងធ្វើការជាមួយភ្នាក់ងារតាមវិស័យ ដើម្បីរួមបញ្ចូល និងអនុវត្តការកឃើញ និងអនុសាសន៍នៃសកម្មភាពរបស់គម្រោងទៅក្នុងគោលនយោបាយ ផែនការ និងឯកសារគោលការណ៍ណែនាំរបស់ក្រសួងវិស័យ។ ផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុតាមវិស័យ ដែលបានរៀបចំឡើងដើម្បីគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ គឺជាឯកសារណែនាំមួយក្នុងចំណោមឯកសារណែនាំជាច្រើនទៀត។ មេរៀន បទពិសោធន៍នានានឹងទាញពីការពិនិត្យឡើងវិញលើគោលការណ៍ណែនាំ និងការរៀបចំស្តង់ដាតាមវិស័យ ការវាយតម្លៃសមិទ្ធិផលតាមវិស័យ ឬអភិវឌ្ឍន៍វិធីសាស្ត្រនៅមូលដ្ឋាន។ ការរៀនសូត្រទាំងនេះ នឹងចងក្រងទៅជាអនុសាសន៍ ថាតើត្រូវបញ្ជ្រាបភាពធន់នឹងអាកាសធាតុយ៉ាងដូចម្តេចទៅក្នុងផែនការតាមវិស័យ។ វិធីសាស្ត្រនេះនឹងផ្តល់ដោយគម្រោងវិនិយោគ SPCR និងការអភិវឌ្ឍសកម្មភាពគម្រោងការប្រែប្រួលអាកាសធាតុក្នុងតំបន់គម្រោង។ លទ្ធផលចុងក្រោយ នឹងពង្រឹងការកសាងក្របខណ្ឌផែនការជាបន្តបន្ទាប់សម្រាប់វិស័យសំខាន់ៗ ដែលស្របតាមគោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងរចនាសម្ព័ន្ធគ្រប់គ្រងសម្រាប់ដោះស្រាយការប្រែប្រួលអាកាសធាតុ។

95. ការកសាងយន្តការ និងសមត្ថភាពដើម្បីធានាពីការផ្លាស់ប្តូរយូរអង្វែង និងដោយអត្តន័យពេញលេញ៖ គោលបំណងរបស់ TA គឺ ដោះស្រាយបញ្ហាប្រឈមលើសមត្ថភាពបច្ចេកទេស និងស្ថាប័ន ដូចនេះសកម្មភាពរបស់គម្រោងគឺនាំទៅរកការផ្លាស់ប្តូរផ្ទាល់នៅមូលដ្ឋាន។ ដើម្បីសម្រេចបានគោលបំណងនេះ ក្រុមការងាររបស់គម្រោងនឹងអភិវឌ្ឍនិងអនុវត្តការផ្តួចផ្តើមការកសាងសមត្ថភាព ដែលចូលរួមចំណែកបង្កើតប្រព័ន្ធប្រកបដោយប្រសិទ្ធិភាព និងយូរអង្វែងសម្រាប់ពង្រឹងភាពធន់នឹងអាកាសធាតុ។

96. ជាផ្នែកមួយនៃប្រព័ន្ធនេះ ការផ្តោតរបស់ក្រុមការងារអន្តរវិស័យបន្សាំការប្រែប្រួលអាកាសធាតុ នឹងធានាលទ្ធផលនៃសកម្មភាពបណ្តុះបណ្តាលគឺយូរអង្វែង កែលម្អសមត្ថភាពធ្វើផែនការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ។ បន្ថែមទៀត លទ្ធផលនៃការសិក្សាលទ្ធភាពលើគម្រោងបន្សាំការប្រែប្រួលអាកាសធាតុ នឹង

រៀបចំទៅជាសំណើគម្រោងដើម្បីជម្រុញសមត្ថភាពនាពេលអនាគត ដើម្បីទទួលបានថវិកាសម្រាប់សកម្មភាពការប្រែប្រួលអាកាសធាតុ។ ជាពិសេស ការកសាងសំណើគម្រោង គឺគោលដៅសម្រាប់មូលនិធិបន្សាំ និងមូលនិធិអាកាសធាតុបៃតង។ បន្ថែមទៀត ក្រុមការងារគម្រោងនឹងបង្កើតនូវផលិតផលចំណេះដឹង ទំនាក់ទំនងជាច្រើន និងកិច្ចអន្តរាគមន៍លើការលើកកម្ពស់ការយល់ដឹង ដើម្បីពង្រឹងការយល់ដឹងពីការប្រែប្រួលអាកាសធាតុជាសាធារណៈ និងគាំទ្រការប្តេជ្ញារបស់រាជរដ្ឋាភិបាលលើសកម្មភាពពាក់ព័ន្ធប្រធានបទនេះ។

97. មានការកិច្ចខិតខំប្រឹងប្រែង ដើម្បីកសាងសមត្ថភាពសម្រាប់បញ្ជ្រាបភាពធន់នឹងអាកាសធាតុរយៈពេល២ ឬ៣ឆ្នាំកន្លងមក ដែលដឹកនាំដោយក្រសួងបរិស្ថាន តាមរយៈនាយកដ្ឋានការប្រែប្រួលអាកាសធាតុ រួមទាំងការងាររបស់ CCCA និង PPCR ដំណាក់កាលទី១។ បន្ថែមទៅទៀត គឺមានគម្រោងតាមវិស័យនីមួយៗរបស់ក្រសួងធនធានទឹក និងក្រសួងកសិកម្ម ដែលឆ្លើយតបការបញ្ជ្រាបការភាពធន់នឹងអាកាសធាតុ។ ក្រុម TA នឹងបង្កើតលើកិច្ចខិតខំប្រឹងប្រែងក្នុងការបញ្ជ្រាបដំបូងៗនេះ។ ជាពិសេស ការកសាងផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពការប្រែប្រួលអាកាសធាតុតាមវិស័យនីមួយៗ ដែលផ្តល់មូលនិធិតាមរយៈ CCCA គឺផ្តល់ជាមូលដ្ឋានសម្រាប់អនាគតការងារនេះ។ ឯកសារទាំងនេះ គឺបានកំណត់ផ្នែកដែលការបញ្ជ្រាបត្រូវបានតម្រូវសម្រាប់គម្រោងនីមួយៗ។

98. ផលិតផលពី PPCR ដំណាក់កាលទី១ រួមបញ្ចូលទាំងគោលការណ៍ណែនាំមួយចំនួនលើការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ និងការកាត់បន្ថយគ្រោះមហន្តរាយទៅក្នុងផែនការវិនិយោគថ្នាក់ជាតិ ឧបករណ៍វិភាគអាកាសធាតុ ការចូលរួម និងការកសាងសមត្ថភាពនៃសង្គមស៊ីវិល និងវិស័យឯកជន និងព័ត៌មានស្តីពីប្រព័ន្ធព័ត៌មានព្យាករណ៍ និងឧតុនិយមរបស់កម្ពុជា និងសេណារីយ៉ូបង្រួមមាត្រដ្ឋានអាកាសធាតុចម្រុះម៉ូឌែល។ តែគោលការណ៍ណែនាំ និងព័ត៌មានទាំងនេះគឺត្រូវត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាពដើម្បីឆ្លើយតបតាមតម្រូវការនាពេលបច្ចុប្បន្ន។

## 4.2 ការរៀបចំគោលនយោបាយ និងការចងក្រងអនុសាសន៍

99. ក្រុមការងារគម្រោងនឹងពិនិត្យឡើងវិញលើគោលការណ៍ណែនាំតាមវិស័យ និងរៀបចំស្តង់ដារ និងផ្តល់អនុសាសន៍លើការប្រែប្រួលដើម្បីបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងផែនការតាមវិស័យ អាស្រ័យលើមេរៀនដែលបានរៀនពីបទពិសោធន៍របស់គម្រោង និងការសមាហរណកម្មការវាយតម្លៃភាពងាយរងគ្រោះនៅមូលដ្ឋាន។ ភ្នាក់ងារមួយចំនួនបានអនុវត្តការវាយតម្លៃភាពងាយរងគ្រោះការប្រែប្រួលអាកាសធាតុ និងអនុវត្តកសាងផែនការបន្សាំនៅក្នុងប្រទេសកម្ពុជា។ ក្រុមការងារគម្រោង នឹងកសាងការងារនៅមូលដ្ឋាននេះ និងប្រើឧបករណ៍ និងវិធីសាស្ត្រដែលងាយយល់សម្រាប់វិស័យគន្លឹះនីមួយៗ និងអ្នកពាក់ព័ន្ធរបស់រដ្ឋាភិបាល។

100. ក្រុមការងារគម្រោងនឹងប្រើវិធីសាស្ត្រកសាងផែនការបន្សាំតាមវិស័យរបស់ ICEM ដោយផ្អែកលើក្របខណ្ឌដើម្បីកំណត់ចំនុចចាប់ផ្តើម និងផ្តល់ជាអនុសាសន៍សម្រាប់បញ្ជ្រាបភាពធន់នឹងអាកាសធាតុតាមវិស័យ។ វិធីសាស្ត្រកសាងផែនការបន្សាំតាមវិស័យគឺជាវិធីសាស្ត្រមួយដែលមានលក្ខណៈបត់បែន ដែល

កើតចេញពីសកម្មភាពអនុវត្តផ្ទាល់ដោយក្រុមការងាររបស់គម្រោង។ វិធីសាស្រ្តកសាងផែនការបន្សាំតាមវិស័យ គឺជួយនិងទាញផលចំណេញពីការប្រើប្រាស់លទ្ធផលពីសកម្មភាពការប្រែប្រួលអាកាសធាតុផ្សេងៗទៀត ដូចជារាជរដ្ឋាភិបាលបានផ្តួចផ្តើមការវាយតម្លៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ឬសកម្មភាពការវាយតម្លៃការប្រែប្រួលអាកាសធាតុនានាដែលគាំទ្រដោយអ្នកផ្តល់ជំនួយជាដើម។

101. មានចំនុចចាប់ផ្តើមជាច្រើន សម្រាប់សមាហរណកម្មការប្រែប្រួលអាកាសធាតុទៅក្នុងវដ្តនៃផែនការអភិវឌ្ឍន៍ ដូចជា៖ (ក) ការពិនិត្យឡើងវិញលើគោលនយោបាយ និងការកសាងប្លង់មេ (ខ) វដ្តនៃការរៀបចំ និងអនុវត្តគម្រោង (គ) ការកែសម្រួលដើម្បីរៀបចំស្តង់ដារ (ឃ) ដំណាក់កាលត្រួតពិនិត្យ និងវាយតម្លៃ និង (ង) ការធ្វើសវនកម្មនៃការអភិវឌ្ឍទ្រព្យសម្បត្តិ។ ក្រាហ្វិច៤.២ បង្ហាញពីចំនុចចាប់ផ្តើមផ្សេងៗគ្នា នៅក្នុងវដ្តនៃការកសាងផែនការហេដ្ឋារចនាសម្ព័ន្ធ។ អាស្រ័យលើសកម្មភាពតាមវិស័យជាច្រើន ក្រុមការងារគម្រោងនឹងធ្វើការជាមួយអ្នកពាក់ព័ន្ធសំខាន់ៗពីក្រសួងគោលដៅ ដើម្បីកំណត់ពីចំនុចចាប់ផ្តើមដែលទាក់ទិនបំផុតសម្រាប់ក្រសួងរបស់គេនីមួយៗ។

**ក្រាហ្វិច ៩៖** ចំនុចចាប់ផ្តើម និងឧបករណ៍សម្រាប់ដោះស្រាយភាពធន់នឹងអាកាសធាតុក្នុងវដ្តនៃការកសាងផែនការដែលជាផ្នែកមួយនៃវិធីសាស្រ្តកសាងផែនការបន្សាំ




102. ទស្សនទាននៃវិធីសាស្រ្តកសាងផែនការបន្សាំបានកសាងឡើងដោយ ICEM ដោយមានការគាំទ្រពី ADB តាមរយៈ TA7984៖ ការបញ្ជ្រាបការគ្រប់គ្រងហានីភ័យការប្រែប្រួលអាកាសធាតុក្នុងការអភិវឌ្ឍន៍ក្នុងប្រទេសនេប៉ាល់ នៅក្រោមកម្មវិធី SPCR របស់នេប៉ាល់ នឹងពាក់ព័ន្ធលើកិច្ចខិតខំប្រឹងប្រែងបញ្ជ្រាបនៅ

ក្រោមកញ្ចប់ទី១ នៃTA8179។ វិធីសាស្ត្រកសាងផែនការបន្សុំាគឺផ្អែកលើការឯកសារបទពិសោធន៍នៃការអនុវត្តល្អៗ សម្រាប់ការគ្រប់គ្រងហានីភ័យការប្រែប្រួលអាកាសធាតុ។ សម្រាប់វិធីសាស្ត្របន្សាំនៅកម្ពុជា ក្រុមការងារគម្រោងនឹងធ្វើការដើម្បីធានាថា កម្មវិធីគោលនយោបាយ និងដំណើរការកែទម្រង់គឺះ

- ឆ្ពោះទៅរកវិស័យនានា ដោយការកំណត់ចំណុចចាប់ផ្តើមពិតប្រាកដ និងឧបករណ៍សម្រាប់វិស័យនីមួយៗ
- ជាផ្នែកធំមួយដែលភ្នាក់ងារនានាមានការពាក់ព័ន្ធ និងដំណើរការធ្វើការសម្រេចចិត្តរបស់គេ
- ដំណើរការឆ្ពោះទៅមុខ ដែលអាចអនុវត្តបានលឿន និងដោយងាយស្រួល
- ប្រើប្រាស់ឧបករណ៍ និងដំណើរការកសាងផែនការដែលមានស្រាប់ និងដែលអាចបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ
- ធ្វើដោយតម្លាភាព ដូចនេះ ហេតុផល និងការសន្និដ្ឋានជម្រើសបន្សុំាដែលបានលើកឡើង ត្រូវបានចងក្រងជាឯកសារ និងសម្រាប់ប្រើប្រាស់នាពេលអនាគត
- ផ្អែកលើនិទស្សន៍ដោយប្រើទិន្នន័យបង្រួមមាត្រដ្ឋានចុងក្រោយបង្អស់លើការប្រែប្រួលអាកាសធាតុ និងព្រឹត្តិការអាកាសធាតុអាក្រក់បំផុតនានា ដូចនេះការសិក្សាផ្សេងៗទៀត គឺអាចរួមបញ្ចូលគ្នាយ៉ាងងាយស្រួលតាមលក្ខខណអនាគត
- មានភាពបត់បែន ងាយស្រួលក្នុងការកែសម្រួល និងធ្វើបច្ចុប្បន្នភាព ដោយផ្អែកលើបទពិសោធន៍ និងទិន្នន័យអាកាសធាតុ និងការនិទស្សន៍ពីការប្រែប្រួលចុងក្រោយ
- បានរួមបញ្ចូលជាមួយការកសាងសមត្ថភាព ដើម្បីកសាងការអនុវត្តក្របខណ្ឌនៅក្រមិតខុសៗគ្នាសម្រាប់វិស័យនីមួយៗ។

103. ក្រុមការងារគម្រោងនឹងអភិវឌ្ឍចងក្រងអនុសាសន៍គោលនយោបាយ និងដំណើរការកែទម្រង់កម្មវិធីតាមវិស័យ ដើម្បីជម្រុញភាពធន់នឹងអាកាសធាតុឆ្ពោះទៅរកប្រតិបត្តិការបរិស្ថានជាក់លាក់សម្រាប់ក្រសួងគោលដៅនីមួយៗ។ ក្រុមការងារនឹងចងក្រងវិធីសាស្ត្រ និងមេរៀនល្អៗ ពីការវាយតម្លៃការប្រែប្រួលអាកាសធាតុផ្សេងៗ និងការអនុវត្តផែនការបន្សុំានៅក្នុងប្រទេសកម្ពុជា ដើម្បីបំពេញបន្ថែមលើកិច្ចខិតខំប្រឹងប្រែងទាំងនេះ។

104. PPCR ដំណាក់កាលទី១ បានរៀបចំគោលការណ៍ណែនាំសម្រាប់ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងដំណើរការកសាងផែនការថ្នាក់ជាតិសម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងផែនការ។ ជាផ្នែកមួយនៃដំណើរការពិនិត្យឡើងវិញ ក្រុមការងារTA នឹងពិចារណាលើគោលការណ៍ណែនាំទាំងនេះ និងការអនុវត្តនាពេលបច្ចុប្បន្នរបស់គេ សម្រាប់ដំណើរការកសាងផែនការជាតិ ទៅជាផែនការជាតិអភិវឌ្ឍសង្គម ផែនការជាតិអភិវឌ្ឍន៍បៃតង និងផែនការកាត់បន្ថយភាពក្រីក្រ។ ការពិនិត្យឡើងវិញ និងការចងក្រងអនុសាសន៍ នឹងពិភាក្សាជាមួយគណកម្មការសម្របសម្រួលកម្មវិធី SPCR ។

105. ផ្នែកមួយទៀតនៃចំនុចចាប់ផ្តើម គឺឧបករណ៍វិភាគដែលវាបង្កលក្ខណៈងាយស្រួលក្នុងការកំណត់ហានិភ័យអាកាសធាតុ សម្រាប់គម្រោងអភិវឌ្ឍន៍នានា ដូចនេះវិធានការបន្សុំាចាំបាច់នានាគឺអាចបញ្ចូលទៅក្នុង

ការរៀបចំនៅដំណាក់កាលនីមួយៗនៃគម្រោង។ ក្នុង PPCR ដំណាក់កាលទី១ គោលការណ៍ណែនាំលើឧបករណ៍វិភាគទាំងនេះគឺបានបង្កើតឡើង។ ទោះជាយ៉ាងណា គោលការណ៍ណែនាំទាំងនោះត្រូវបានពិនិត្យនិងសន្និដ្ឋាន ដោយការជំនួសដោយគោលការណ៍ណែនាំដែលប្រសើរជាង ដែលឆ្ពោះទៅរកតម្រូវការពិតៗរបស់ក្រសួង និងគម្រោងវិនិយោគអភិវឌ្ឍន៍របស់រដ្ឋាភិបាល។ សកម្មភាពមួយនៃសកម្មភាពចាប់ផ្តើមដំបូង គឺក្រុមការងារTA នឹងពិនិត្យឡើងវិញលើរាល់ឧបករណ៍វិភាគដែលមាននៅតាមវិស័យនីមួយៗ និងធ្វើសំណើរសម្រាប់ការធ្វើការចំរាញ់។ ឧបករណ៍ទាំងនេះ គឺរួមទាំងសំនួរដែលបុគ្គលិករដ្ឋាភិបាលអាចប្រើបានភ្លាមៗ និងសាមញ្ញដើម្បីជួយក្នុងការសម្រេច ប្រសិនបើការអភិវឌ្ឍត្រូវការការគិតគូរពីភាពងាយរងគ្រោះ និងការងារបន្សាំបន្ថែមទៀត។ វិធីសាស្ត្រគឺអនុវត្តដោយឧបករណ៍អាស្រ័យលើគេហទំព័រកម្រិតសកលលោក (global web-based tools) ដូចជា AWARE ដែលត្រូវប្រើដើម្បីរៀបចំឆ្ពោះទៅកាន់វិធីសាស្ត្រវិភាគ ស្របតាមស្ថានភាពប្រទេសកម្ពុជា និងតម្រូវការក្នុងវិស័យនីមួយៗ។

106. វិធានការផ្សេងៗទៀតចេញពីវិធីសាស្ត្រកសាងផែនការបន្សាំគឺរួមបញ្ចូលនូវទម្រង់ផ្សេងៗនៃការណែនាំ និងឯកសារណែនាំនានាលើវិធានការបន្សាំ ការផ្លាស់ប្តូរការបន្សាំក្នុងការរៀបចំស្តង់ដា តម្រូវការការប្រែប្រួលអាកាសធាតុដែលត្រូវបញ្ចូលទៅក្នុងការវាយតម្លៃយុទ្ធសាស្ត្របរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការវាយតម្លៃនិងតាមដានភាពធន់នឹងអាកាសធាតុ។ ការណែនាំពីឯកសារទាំងនេះ នឹងជាផ្លូវចង្អុលបង្ហាញសម្រាប់ការវាយតម្លៃភាពងាយរងគ្រោះ និងវិធីសាស្ត្រធ្វើផែនការបន្សាំ។

## 4.3 ការវាយតម្លៃសេដ្ឋកិច្ច

107. ក្រុមការងារ TA មិនទាន់មានអ្នកឯកទេសផ្នែកសេដ្ឋកិច្ចនៅឡើយទេ តែអ្នកឯកទេសផ្នែកនេះគឺត្រូវការចាំបាច់នៅដំណាក់កាលនេះ។ របាយការណ៍នេះ គឺរួមបញ្ចូលទាំងអនុសាសន៍សម្រាប់តំណែងអ្នកឯកទេសផ្នែកសេដ្ឋកិច្ច ទាំងអ្នកឯកទេសជាតិ និងអន្តរជាតិ។ អ្នកឯកទេសនេះ គឺមានមុខងារតួនាទីសំខាន់ៗចំនួនពីរគឺៈ

(i) ធ្វើការសិក្សាវិភាគ និងវាយតម្លៃពីសេដ្ឋកិច្ច ដែលជាផ្នែកមួយនៃដំណើរការសិក្សាលទ្ធភាពលើគម្រោងបន្សាំទាំង៦ និងការរៀបចំសំណើរគម្រោង២។

(ii) បង្កើតយន្តការ និងការកសាងសមត្ថភាពដើម្បីសមាហរណកម្មបន្សាំទៅក្នុងថវិកាតាមវិស័យ និងថវិកាជាតិ

108. ក្រុមការងារTA នឹងរៀបចំការសិក្សាលទ្ធភាពគម្រោងបន្សាំចំនួន៦ និងរៀបចំសំណើគម្រោងបន្សាំយ៉ាងតិចពីរ សម្រាប់ស្វែងរកថវិកាពីមូលនិធិអាកាសធាតុពិភពលោក។ ភស្តុតាងដែលវិធានការបន្សាំគឺបង្ហាញលទ្ធភាពខាងផ្នែកសេដ្ឋកិច្ច និងសន្សំសំចៃសេដ្ឋកិច្ចតាមរយៈការបញ្ចៀសផលខូចខាត និងការបាត់បង់ និងតាមរយៈការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពខ្ពស់ គឺជាផ្នែកមួយសំខាន់នៃការសិក្សាលទ្ធភាពគម្រោងនេះ។

109. ការសិក្សាលទ្ធភាពគម្រោងគឺអាចទាញចេញពីភាពជោគជ័យនៃការអនុវត្តជាក់ស្តែងនៃគម្រោងបន្សាំក្នុងខេត្ត SPCR នៃប្រទេសកម្ពុជា។ ការអនុវត្តជាក់ស្តែងអាចជាវិធានការបន្សាំជាក់ស្តែងដែលក្រុមការងារTA បានកំណត់ក្នុងកំឡុងពេលដំបូងនៃបេសកកម្មសំខាន់របស់គេ គឺមានគោលបំណងដើម្បីកត់ត្រាទុកនូវការអនុវត្តល្អៗ សម្រាប់រួមបញ្ចូលក្នុងការណែនាំតាមវិស័យ។ ការសិក្សាគឺផ្តោតលើករណីសិក្សាល្អៗ ដែលបង្ហាញពីសក្តានុពលក្នុងការចម្លង និងពង្រីកទំហំគម្រោងទៅកាន់កន្លែងផ្សេងទៀត ជាមួយការគាំទ្រថវិកាពីមូលនិធិអាកាសធាតុពិភពលោក។ ការវិភាគ និងវាយតម្លៃសេដ្ឋកិច្ច អាចជាធាតុគន្លឹះមួយក្នុងការកែតម្រូវការវិនិយោគការបន្សាំ។

110. កត្តាផ្សេងៗទៀតលើការស្នើអ្នកជំនាញផ្នែកសេដ្ឋកិច្ចសម្រាប់ក្រុមការងារ គឺអាចធ្វើការជាមួយក្រសួង និងភ្នាក់ងារអនុវត្តកម្មវិធី SPCR ដើម្បីសមាហរណកម្មពេញលេញក្នុងការបន្សាំទៅក្នុងវិស័យ និងថវិកាជាតិ។ ក្រុមការងារ CCCA និង GIZ នៅនាយកដ្ឋានការប្រែប្រួលអាកាសធាតុ នឹងធ្វើសមាហរណកម្មថវិកាដោយផ្តោតជាសំខាន់លើការងាររបស់គេ។ អ្នកឯកទេសសេដ្ឋកិច្ចរបស់ TA នឹងសហការយ៉ាងជិតស្និទ្ធជាមួយ CCCA និង GIZ ក្នុងការពង្រីកកិច្ចការសមាហរណកម្ម ដើម្បីផ្សារភ្ជាប់ការងាររបស់ MOWRAM និង MRD ជាមួយកិច្ចខិតខំភ្ជាប់ជាមួយការសិក្សាលទ្ធភាពគម្រោងបន្សាំ ដែលទាក់ទិនអាណត្តិរបស់ MAFF និងMPWT។ ការវាយតម្លៃដែលក្រុមTAត្រូវធ្វើ គឺការកំណត់ដើម្បីអោយរដ្ឋាភិបាលមានថវិកាគ្រប់គ្រាន់ តាមរយៈការដាក់សំណើទៅកាន់មូលនិធិអាកាសធាតុ។

## 4.4 ការសម្របសម្រួលកម្មវិធី SPCR

111. ការសម្របសម្រួលកម្មវិធី SPCR គឺជាទិដ្ឋភាពដ៏សំខាន់មួយនៃទិដ្ឋភាពសំខាន់ៗនានានៃក្រុមការងារTA។ ក្រសួងបរិស្ថានជាភ្នាក់ងារអនុវត្តកម្មវិធី SPCR និងនាយកដ្ឋានការប្រែប្រួលអាកាសធាតុគឺជានាយកដ្ឋានសំខាន់ក្នុងការទទួលបន្ទុកលើការអនុវត្តកម្មវិធីនេះ។ តួនាទីរបស់ក្រុមការងារTA គឺផ្តល់ការគាំទ្រដល់ក្រសួងបរិស្ថានក្នុងការសម្របសម្រួលការអនុវត្តគម្រោងវិនិយោគ SPCR ទាំង៧ ក៏ដូចជាកញ្ចប់ពីរនៃTA ។

112. ការងារនេះគឺអនុវត្តតាមរយៈការសម្របសម្រួលលើកិច្ចប្រជុំក្រុមការងារសម្របសម្រួលSPCR ដែលរៀបចំប្រជុំពីរដងក្នុងមួយឆ្នាំ និងតាមរយៈកិច្ចប្រជុំជាទៀងទាត់ជាមួយគម្រោងវិនិយោគSPCR ដែលធ្វើការប្រជុំជារៀងរាល់បីខែម្តង។ គោលបំណងនៃការបង្កើតក្រុមការងារសម្របសម្រួលគឺដើម្បីធ្វើការសម្របសម្រួលជាផ្លូវការរវាងក្រសួងនានាដែលពាក់ព័ន្ធនឹងការងាររបស់ SPCR ទីពីរគឺផ្តោតលើកម្រិតបច្ចេកទេស ដើម្បីចែករំលែកបទពិសោធន៍ និងដោះស្រាយបញ្ហានានាក្នុងការអនុវត្ត។

113. ក្រុមការងារTA ក៏មានតួនាទីផ្ទាល់ក្នុងការចងក្រងឯកសារលើបទពិសោធន៍ និងមេរៀនដែលបានរៀនសូត្រ ក្នុងការអនុវត្តគម្រោងវិនិយោគទាំង៧។ ការអនុវត្តការវាយតម្លៃភាពងាយរងគ្រោះ សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ គម្រោងអភិវឌ្ឍន៍នានា និងវិធានការបន្សាំដែលបានលើកឡើងដើម្បីបង្កើនការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ និងភាពធន់កាន់តែប្រសើរ នឹងត្រូវបានប្រើជាករណីសិក្សាសម្រាប់ពង្រីកការបណ្តុះបណ្តាលក្នុងក្រសួងផ្សេងៗគ្នា។

114. គម្រោងវិនិយោគខុសគ្នានឹងផ្តល់បទពិសោធន៍ និងព័ត៌មានជាដំបូងដែលអាចប្រើសម្រាប់ចងក្រងជាអនុសាសន៍គោលនយោបាយសម្រាប់ចំម្រាញ់យកនូវគោលនយោបាយ និងដំណើរការដើម្បីបញ្ចូលភាពធន់ទៅក្នុងការងាររបស់ក្រសួងនីមួយៗ។ ករណីសិក្សាទាំងនោះ ការសង្កេត និងលំហាត់នៅមូលដ្ឋាន និងការពិគ្រោះយោបល់នឹងជួយក្នុងការរៀបចំឯកសារណែនាំ គោលការណ៍ណែនាំ និងការអនុវត្តស្តង់ដារ។

115. វិធីដ៏មានសារៈសំខាន់ក្នុងការបកស្រាយការងារបញ្ជ្រាបភាពធន់នៃគម្រោងវិនិយោគ គឺតាមរយៈការចុះសិក្សានៅមូលដ្ឋានសម្រាប់សមាជិកគណៈកម្មាការសម្របសម្រួល SPCR។ នេះត្រូវបានស្នើសុំដោយគណកម្មាការ ហើយការចុះសិក្សាលើកទី១ គឺនៅដើមឆ្នាំ២០១៦។

116. ការគាំទ្ររបស់ក្រុមការងារTA ដល់ក្រសួងបរិស្ថាននឹងរួមបញ្ចូលទាំងការរៀបចំជាទៀតទាត់នូវផែនការការងារ និងថវិកាអនុវត្តបុរេប្រទាន (Advance Payment Facility) ដែលផ្តល់ដោយ ADB ដើម្បីគាំទ្រលើមុខងារសម្របសម្រួលកម្មវិធី SPCR។

## 4.5 វិស័យផ្តោត – វិធីសាស្ត្របង្កើតក្រុមការងារបន្សាំរបស់ SPCR

117. ក្រុមការងារ TA គឺស្នើសុំដើម្បីបង្កើតក្រុមការងារបច្ចេកទេសបន្សាំរបស់ SPCR មួយ (AWG), ដែលសមាជិកក្រុមការងារនេះគឺយកចេញពីក្រុមការងារការប្រែប្រួលអាកាសធាតុរបស់ក្រសួងនីមួយៗ ដើម្បីអភិវឌ្ឍន៍ការសម្របសម្រួល និងភាពជាដៃគូប្រកបដោយប្រសិទ្ធភាព ជាមួយភ្នាក់ងារផ្សេងៗ ដែលមានការពាក់ព័ន្ធក្នុងវិស័យនីមួយៗ។ សមាជិកក្រុមការងារបច្ចេកទេសបន្សាំ (AWG) គឺមានសមាជិកបីនាក់ជាមន្ត្រីបច្ចេកទេសពីក្រសួងគន្លឹះនីមួយៗ និងសមាជិកម្នាក់មកពីក្រសួងសម្របសម្រួលរបស់ SPCR រួមទាំងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងផែនការ និងគណៈកម្មាធិការជាតិដើម្បីអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ទម្រង់បង្កើតក្រុមការងារបច្ចេកទេសបន្សាំគឺបង្ហាញក្នុងក្រាហ្វិច ៤.៣។ ឯកសារបរិយាយពីការងារ សម្រាប់ក្រុមការងារនេះ គឺមាននៅក្នុងឧបសម្ព័ន្ធទី៦។

118. ក្រុមការងារបច្ចេកទេសបន្សាំរបស់ SPCR គឺមានសមាជិកចំនួន២១នាក់ ហើយនឹងត្រូវជួយគាំទ្រដោយក្រុមការងារTA ។ កិច្ចប្រជុំនៃក្រុមការងារនេះ គឺនឹងធ្វើជារៀងរាល់ត្រីមាស និងផ្តោតទៅលើការណែនាំបច្ចេកទេស ទៅលើថាតើគម្រោងគួរដោះស្រាយលើការកសាងសមត្ថភាព ការរៀបចំសំណើគម្រោងបន្សាំយ៉ាងដូចម្តេច។

119. កិច្ចការរបស់ក្រុមការងារបច្ចេកទេសបន្សាំរបស់ SPCR គឺដឹកនាំក្នុងការអភិវឌ្ឍន៍វិធីសាស្ត្រ ករណីសិក្សាវាយតម្លៃពីភាពងាយរងគ្រោះ ការធ្វើផែនការបន្សាំ និងការចងក្រងអនុសាសន៍ គោលការណ៍ណែនាំតាមវិស័យ។ សមាជិកជាតំណាងនឹងចូលរួមក្នុងការរៀបចំ លើការបណ្តុះបណ្តាលតាមរយៈការអនុវត្តផ្ទាល់ រួមបញ្ចូលទាំងការចុះសិក្សានៅមូលដ្ឋាន និងកិច្ចប្រជុំតុមូល។ សមាជិកនៃក្រុមការងារគឺជាអ្នកបង្កើតជ័យលាភីលើការផ្លាស់ប្តូរក្នុងក្រសួងរបស់ពួកគាត់។

120. សមាជិកក្រុមការងារគឺជាមន្ត្រីបច្ចេកទេសកម្រិតមធ្យម និងជាសមាជិកក្រុមការងារការប្រែប្រួលអាកាសធាតុរបស់ក្រសួង។ សមាជិកនៃក្រុមការងារនេះ គឺមានមុខតំណែងទាបជាងសមាជិកក្រុមការងារសម្រប

សម្រួល SPCR មកពីក្រសួងរបស់ពួកគាត់។ ពួកគាត់គឺជាអ្នកគោលដៅក្នុងការទំនាក់ទំនងជាប្រចាំថ្ងៃ រវាងក្រុមការងារTA និងក្រសួងនានាដែលជាសមាជិក។

**ក្រាហ្វិច 10៖** ការបង្កើតក្រុមការងារបច្ចេកទេសបន្សុាំ




## 4.6 ការកំណត់ភូមិសាស្ត្រ

121. គោលដៅចំបងនៃការគាំទ្ររបស់ក្រុមការងារTA គឺក្រសួងដែលអនុវត្តកម្មវិធីSPCR ដែលក្នុងនោះមាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧត្តិនិយម ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងបរិស្ថាន និងគម្រោងវិនិយោគ SPCR របស់ក្រសួងទាំងនេះ។ ក្រុមការងារTA នឹងដោះស្រាយគោលនយោបាយ ទម្រង់ការ និង ភូមិសាស្ត្របរិស្ថាន លើផ្នែកដែលពួកគេកំពុងធ្វើការ។ ក្រសួងសំខាន់ផ្សេងៗទៀតដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ និងក្រសួងមហាផ្ទៃ គឺជាសមាជិកសំខាន់ផងដែរសម្រាប់ការកសាងផែនការ។ ការកំណត់ភូមិសាស្ត្រ គឺផ្តល់ជាការលើកទឹកចិត្តជាក្របខណ្ឌ និងជាទិសដៅសម្រាប់សកម្មភាពអភិវឌ្ឍន៍របស់ក្រសួងផ្សេងៗ។ ក្រុមការងារTA នឹងពាក់ព័ន្ធក្រសួងគោលដៅសំខាន់ៗ និងក្រសួងផែនការក្នុងការអនុវត្តផ្ទាល់នៅមូលដ្ឋាន ការបណ្តុះបណ្តាល និងការរៀនសូត្រ។ ការអនុវត្តផ្ទាល់រួមបញ្ចូលទាំងការវាយតម្លៃភាពងាយរងគ្រោះ និងការកសាងគម្រោងបន្សុាំ ការពិនិត្យឡើងវិញ និងការរៀនសូត្រពីបទពសោធន៍របស់គម្រោង SPCR និងស្វែងរកគំនិតថ្មីៗ និងគោលការណ៍ណែនាំ ដែលត្រូវការសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុ។ ការងារនេះតម្រូវការកំណត់ភូមិសាស្ត្រ (ការកំណត់ខេត្ត)។

122. ការកំណត់ខេត្តនឹងផ្តល់ដល់គម្រោង ដើម្បីបង្កើតទំនាក់ទំនងការងារស៊ីជម្រៅ និងប្រកបដោយប្រសិទ្ធភាពជាមួយអាជ្ញាធរខេត្ត ស្រុកនៃខេត្តដែលបានជ្រើសរើស។ ការសិក្សានៅមូលដ្ឋានតម្រូវក្រុមការងារ TA

មានចំណេះដឹង និងការយល់ដឹងលើការអភិវឌ្ឍន៍ និងការប្រឈមការប្រែប្រួលអាកាសធាតុនៃខេត្តគោលដៅ។ ការកំណត់ខេត្ត ក៏ផ្តល់ភាពងាយស្រួលដល់ក្រុមការងារTA ក្នុងការកសាងបណ្តាញរឹងមាំសម្រាប់បុគ្គលិកបច្ចេកទេស និងភ្នាក់ងារក្នុងមូលដ្ឋាន និងដើម្បីចូលរួមជាអ្នកពាក់ព័ន្ធផ្សេងៗទៀតនៅកម្រិតមូលដ្ឋាន។ សារៈសំខាន់នៃការកំណត់ខេត្តនេះផងដែរ គឺតម្រូវផ្តោតលើផ្នែកដែលភាពងាយរងគ្រោះនិងជម្រើសបន្សាំសម្រាប់ហេដ្ឋារចនាសម្ព័ន្ធជាក់លាក់ ប្រព័ន្ធសង្គម និងធម្មជាតិ អាចត្រូវបានវាយតម្លៃយ៉ាងម៉ត់ចត់។ ការសិក្សានៅក្នុងខេត្តអាទិភាពទាំងនេះ គឺផ្តល់នូវការរៀនសូត្រ និងការគិតគូរថ្មីៗរបស់ក្រសួងនិងដៃគូរនៅមូលដ្ឋាន។

### *4.6.1 ដំណើរការជ្រើសរើសខេត្តគោលដៅ*

123. ក្រុមការងារTA គឺអនុវត្តដំណើរការជ្រើសរើសខេត្តគោលដៅ ប្រកបដោយតម្លាភាព និងដោយមានការពិគ្រោះយោបល់ជាមួយក្រសួង SPCR និងផ្អែកតាមភស្តុតាងតាមបែបវិទ្យាសាស្ត្រ ក្នុងការវាយតម្លៃជម្រើសនានាក្នុងការជ្រើសរើសខត្តគោលដៅនេះ។ តាមរយៈការពិគ្រោះយោបល់ជាមួយដៃគូរគម្រោង ដំណើរការជ្រើសរើស និងការកំណត់លក្ខណៈវិនិច្ឆ័យ ត្រូវបានកំណត់ និងចាប់ផ្តើមដោយកំណត់ខេត្តចំនួន ៦ សម្រាប់ក្រុមការងារ TA ចុះធ្វើការ។ ដំណើរការជ្រើសរើសបានពិពណ៌នាក្នុងផ្នែកនេះ និងបញ្ជីខេត្តដែលបានជ្រើសរើសតាមគោលបំណងរបស់គម្រោង និងតម្រូវការលទ្ធផល។ ខេត្តគោលដៅគឺជ្រើសរើស ដោយប្រើវិធីសាស្ត្រពហុលក្ខណៈវិនិច្ឆ័យ ដែលបានមកពីកិច្ចប្រជុំពិភាក្សាជាមួយក្រសួងពាក់ព័ន្ធ។ ក្រុមការងារTA បន្ទាប់មកទៀតគឺរៀបចំឯកសារសង្ខេបស្តីពីការកំណត់ភូមិសាស្ត្រសម្រាប់ចែកចាយទៅកាន់ក្រសួងទាំងនោះដើម្បីពិនិត្យ និងផ្តល់យោបល់។ លទ្ធផលចុងក្រោយបង្អស់គឺត្រូវបានបង្ហាញ និងពិភាក្សានៅក្នុងសិក្ខាសាលាថ្នាក់ជាតិជាមួយអ្នកពាក់ព័ន្ធទាំងអស់នៅរាជធានីភ្នំពេញនៅថ្ងៃទី ០៧ កក្កដា ឆ្នាំ២០១៥។

124. ដំណើរការជ្រើសរើសគឺពាក់ព័ន្ធជំហានដូចតទៅៈ

(i) **កំណត់លក្ខណៈវិនិច្ឆ័យជ្រើសរើស៖** ការពិភាក្សាជាលើកដំបូងជាមួយក្រសួងសំខាន់ៗនីមួយៗ និងធ្វើសេចក្តីព្រាងលក្ខណៈវិនិច្ឆ័យដោយផ្អែកការពិភាក្សាទាំងនោះ

(ii) **ការវិភាគតាមពហុលក្ខណៈវិនិច្ឆ័យ** (Multi-criteria analysis)

(iii) **កិច្ចប្រជុំតុមូលជាមួយក្រសួង៖** បង្ហាញ និងពិភាក្សាជាដំបូងជាដំបូងជាមួយខេត្តគោលដៅ តាមរយៈកិច្ចប្រជុំតុមូលរយៈពេល១ថ្ងៃ ជាមួយក្រសួងទាំង៥

(iv) **ឯកសារសង្ខេបស្តីពីការកំណត់ខេត្ត៖** ការកែតម្រូវ និងការដាក់បញ្ចូលគ្នា បង្កើតជាឯកសារសង្ខេប ហើយឯកសារសង្ខេបនេះ ផ្ញើរទៅកាន់ក្រសួងនីមួយៗដើម្បីពិនិត្យ និងផ្តល់យោបល់។

(v) តាមលទ្ធផលនៃកិច្ចប្រជុំតុមូលជាមួយក្រសួង SPCR នីមួយៗ

(vi) **បញ្ចប់ការចាត់ចំណាត់ថ្នាក់ខេត្ត៖** កែតម្រូវបញ្ជីនៃខេត្តគោលដៅសម្រាប់គម្រោង ដោយផ្អែកលើយោបល់ត្រឡប់ពីក្រសួង

(vii) **សិក្ខាសាលាចាប់ផ្តើម៖** បង្ហាញ និងពិភាក្សាបញ្ជីចុងក្រោយនៅសិក្ខាសាលាថ្ងៃទី០៧ ខែកក្កដា ឆ្នាំ ២០១៥។

125. ដំណើរការគឺត្រូវបានពិពណ៌នាលម្អិតក្នុងផ្នែកខាងក្រោម

### *4.6.2 ការកំណត់លក្ខណៈវិនិច្ឆ័យជ្រើសរើស*

126. ក្រុម TA បានកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសខេត្ត ដោយអនុវត្តតាមកិច្ចពិភាក្សាដំបូងៗជាមួយក្រសួង។ លក្ខណវិនិច្ឆ័យគឺចែកចេញជាបីក្រុម ទី១គឺក្រុមលក្ខណៈវិនិច្ឆ័យសំខាន់ និងត្រូវបានប្រើដើម្បីបង្កើតបញ្ជីដំបូងនៃខេត្តជ្រើសរើស។ ទី២ គឺក្រុមលក្ខណៈវិនិច្ឆ័យដែលប្រើសម្រាប់ជ្រើសរើសខេត្តក្នុងបញ្ជីសម្រាំង សម្រាប់ពិភាក្សាជាមួយក្រសួងដៃគូរ។

**លក្ខណៈវិនិច្ឆ័យសំខាន់**

(i) ជាខេត្តដែលកម្មវិធី និងគម្រោងវិនិយោគ SPCR របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងបរិស្ថានតាំងនៅ

(ii) ជាខេត្តដែលតំណាងអោយតំបន់អេកូឡូស៊ីទាំង៥នៃប្រទេសកម្ពុជា (តំបន់អេកូឡូស៊ីទាំងនេះរួមមាន៖ តំបន់ភ្នំ តំបន់ខ្ពង់រាប តំបន់មាត់សមុទ្រ តំបន់ដីសណ្ត និងតំបន់ជុំវិញបឹងទន្លេសាប)

(iii) ជាខេត្តដែលមានលំដាប់ភាពក្រីក្រខ្ពស់ (ADB 2014)

(iv) ជាខេត្តដែលផ្ទៃដីគ្របដណ្តប់ដោយជីវចម្រុះខ្ពស់ (គ្របដោយព្រៃ)

(v) ជាខេត្តដែលបាននិទស្សន៍ឃើញថា មានភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុខ្ពស់

(vi) ជាខេត្តដែលចង់បានរបស់ក្រសួង អាចជាខេត្តដែលពាក់ព័ន្ធគម្រោង និងការងារកម្មវិធីរបស់ពួកគាត់

**លក្ខណៈវិនិច្ឆ័យបន្ថែម**

127. បន្ទាប់ពីបញ្ជីដំបូងនៃខេត្តដែលបានជ្រើសរើសតាមរយៈការប្រើលក្ខណៈវិនិច្ឆ័យ៣សំខាន់ៗបានរៀបចំឡើង បញ្ជីខេត្តត្រូវបានចម្រាញ់បន្តដោយប្រើលក្ខណៈវិនិច្ឆ័យបន្ថែមទាំងនេះ៖

(i) ការដាក់ពិន្ទុ គឺផ្តល់ទម្ងន់លើខេត្តដែលមានវត្តមានគម្រោងវិនិយោគ SPCR ២ ឬច្រើនជាង២

(ii) ការឱ្យមានតុល្យភាពរវាងតំបន់នានានៃប្រទេស គឺតំបន់ភាគខាងកើត ខាងលិច ខាងជើង និងខាងត្បូងនៃប្រទេស

(iii) ជាខេត្តដែលក្រសួងបានកំណត់អាទិភាពក្នុងផែនការសកម្មភាពការប្រែប្រួលអាកាសធាតុរបស់ខ្លួន

(iv) ជាខេត្តដែលមានព័ត៌មានស្តីពីការគំរាមកំហែងលើការប្រែប្រួលអាកាសធាតុ សេដ្ឋកិច្ចសង្គម និងព័ត៌មានដើមគ្រានៃជីវរូប

(v) ជាខេត្តមានការគាំទ្រខ្លាំងពីអាជ្ញាធរមូលដ្ឋាន និងពួកគេគឺមានបទពិសោធន៍លើសកម្មភាពការឆ្លើយតបការប្រែប្រួលអាកាសធាតុ

(vi) ជាខេត្តដែលមានសក្តានុពលសម្រាប់ការអនុវត្តផ្ទាល់ និងការចម្លងភាពជោគជ័យទៅកាន់ខេត្តផ្សេងៗទៀត

(vii) ជាខេត្តដែលមានសក្តានុពលក្នុងអនុវត្តគម្រោងពហុវិស័យលើការបន្សុំាការប្រែប្រួលអាកាសធាតុ

### *4.6.3 ការវិភាគដោយប្រើពហុលក្ខណៈវិនិច្ឆ័យ*

128. ការវិភាគដោយប្រើពហុលក្ខណវិនិច្ឆ័យគឺបានបង្កើត និងប្រើប្រាស់ប៉ារ៉ាម៉ែត្រដូចខាងក្រោម៖

1. លំដាប់ថ្នាក់ភាពក្រីក្រ (ADB 2014)
2. តម្លៃជីវចម្រុះលើដី (ព្រៃគ្របដណ្តប់ - 2006)[3]
3. ចំណាត់ថ្នាក់តាមការនិទស្សន៍ពីការប្រែប្រួលអាកាសធាតុ
4. ជាខេត្ត ដែលចង់របស់ក្រសួង
5. ជាខេត្តដែលគម្រោងវិនិយោគ SPCR តាំងនៅ
6. ជាខេត្តតំណាងអោយតំបន់អេកូហ្សូននានានៃប្រទេសកម្ពុជា

129. រូបមន្តសម្រាប់ផ្តល់ពិន្ទុតាមវិធីសាស្ត្រការវិភាគដោយប្រើពហុលក្ខណៈវិនិច្ឆ័យ៖

F1 = ភាពក្រីក្រ+

F2 = ជីវចម្រុះលើដី+

F3 = ការដាក់ត្រួតស៊ីគ្នានៃព័ត៌មានការប្រែប្រួលអាកាសធាតុ (4) +

F4 = ការចង់បានរបស់រដ្ឋាភិបាល

F5 = ខេត្ត SPCR (បាទ/ចាស)

F6 = អេកូហ្សូន (តំណាងទាំងអស់)

ពិន្ទុចុងក្រោយ **= (F1 + F2 + F3) x F4 x F5** (F6 ជាមួយតំណាងអេកូហ្សូនទាំងអស់)

ការពិពណ៌នាពីការវិភាគដោយប្រើពហុលក្ខណៈវិនិច្ឆ័យ ដោយមានការបកស្រាយលើវិធីសាស្ត្រដាក់ពិន្ទុ និងការចាត់ចំណាត់ថ្នាក់

[3] www.Cambodiaopendevelopment.com

### 1. ពិន្ទុភាពក្រីក្រទាំង២៥ខេត្ត

130. ការវិភាគពីភាពក្រីក្រថ្មីៗបំផុតសម្រាប់កម្ពុជា ដែលសិក្សាដោយ ADB ក្នុងឆ្នាំ ២០១៤-៥ គឺផ្តល់ទិន្នន័យជាបីក្រុម៖ (i) សម្រាប់ថ្នាក់ឃុំ/សង្កាត់ (ii) សម្រាប់គ្រួសារក្រីក្រ និង (iii) សន្ទស្សន៍នៃភាពក្រីក្រពហុផ្នែក (multidimensional poverty index) (Table 4.1).

**តារាង** 4-1 ៖ ចំណាត់ថ្នាក់ភាពក្រីក្រតាមខេត្តនៃប្រទេសកម្ពុជា ឆ្នាំ ២០១៤

| ល.រ | ខេត្ត/ក្រុង | ទិន្នន័យឃុំ/សង្កាត់ 2012 (%) | ខេត្ត/ក្រុង | លេខសម្គាល់គ្រួសារក្រីក្រ 2009–2011 (%) | ខេត្ត/ក្រុង | សន្ទស្សន៍ភាពក្រីក្រពហុភាគី 2010* (%) |
|---|---|---|---|---|---|---|
| 1 | ព្រះវិហារ | 37 | កោះកុង | 44 | មណ្ឌលគិរី | 44 |
| 2 | ស្ទឹងត្រែង | 37 | កំពង់ឆ្នាំង | 37 | រតនគិរី | 44 |
| 3 | រតនគិរី | 36 | ក្រចេះ | 36 | ព្រះវិហារ | 39 |
| 4 | ឧត្តរមានជ័យ | 34 | បាត់ដំបង | 34 | ស្ទឹងត្រែង | 39 |
| 5 | មណ្ឌលគិរី | 33 | ពោធិ៍សាត់ | 34 | ក្រចេះ | 29 |
| 6 | ក្រចេះ | 29 | ព្រះវិហារ | 32 | ពោធិ៍សាត់ | 25 |
| 7 | កំពង់ធំ | 28 | បៃលិន | 32 | កំពង់ធំ | 24 |
| 8 | សៀមរាប | 29 | សៀមរាប | 31 | កំពង់ឆ្នាំង | 23 |
| 9 | ពោធិ៍សាត់ | 28 | កំពង់ធំ | 31 | កំពង់ចាម | 20 |
| 10 | កំពង់ឆ្នាំង | 28 | ស្ទឹងត្រែង | 30 | សៀមរាប | 19 |

**ប្រភព៖** ADB, 2014, កម្ពុជា៖ ការវិភាពពីក្រីក្រសម្រាប់ប្រទេស 2014 ភ្នំពេញ កម្ពុជា

131. ការកំណត់តំបន់ខេត្តដោយប្រើការវិភាគតាមពហុលក្ខណៈវិនិច្ឆ័យ ចំណាត់ថ្នាក់ចំនួន៣ត្រូវបានប្រើ ខេត្តដែលទទួលបានពិន្ទុកើន ៣ សម្រាប់ចំណាត់ថ្នាក់ខេត្តខ្ពស់ជាងគេចំនួន១០ ដែលបានជ្រើសរើសឡើង។ ឧទាហរណ៍ដូចជា ខេត្តកំពង់ធំ បានឆ្លើយតបចំណាត់ថ្នាក់ទាំងបី ហើយបានទទួលពិន្ទុចំនួន៩។ ខេត្តមណ្ឌលគីរី ឆ្លើយតបចំណាត់ថ្នាក់ចំនួន២ និងបានទទួលពិន្ទុចំនួន៦។

### 2. ការដាក់ពិន្ទុជីវចម្រុះ សម្រាប់២៥ រាជធានី ខេត្ត

132. ជីវចម្រុះលើដីត្រូវបានវាយតម្លៃតាមវិធីសាស្រ្តតំណាង ដោយភាគរយព្រៃឈើគ្របដណ្តប។ ខេត្តត្រូវបានចាត់ថ្នាក់ដោយភាគរយព្រៃឈើគ្របដណ្តបពីកម្រិតខ្ពស់ និងកម្រិតទាប។ ខេត្តចំនួន១០ដំបូង គឺបានផ្តល់ពិន្ទុចំនួន៩។ ខេត្ត១០ បន្ទាប់ (ចំណាត់ថ្នាក់ពី១១ ទៅ ២០) បានផ្តល់ពិន្ទុចំនួន៦។ ខេត្តផ្សេងៗទៀត ដែលនៅសល់គឺទទួលបានពិន្ទុ៣។

### 3. ការផ្តល់ពិន្ទុនិទស្សន៍ការប្រែប្រួលអាកាសធាតុសម្រាប់រាជធានីខេត្តទាំង២៥

133. ប៉ារ៉ាម៉ែត្រចំនួន៤ សម្រាប់ការប្រែប្រួលអាកាសធាតុ រហូតដល់ឆ្នាំ២០៥០ ត្រូវបានប្រើដើម្បីចាត់ចំណាត់ថ្នាក់ និងផ្តល់ពិន្ទុសម្រាប់ខេត្ត។ ប៉ារ៉ាម៉ែត្រទាំងនេះរួមមាន៖ (i)ភាគរយនៃការផ្លាស់ប្តូរកម្ពស់ទឹកភ្លៀងក្នុងរដូវវស្សា (ii) ការផ្លាស់ប្តូរសីតុណ្ហភាពក្នុងរដូវប្រាំង, (iii) ចំនួនខែរាំងស្ងួត និង (iv) ការផ្លាស់ប្តូរចំនួនខែរាំងស្ងួតក្នុងឆ្នាំ។ ខេត្តនីមួយៗក្នុងចំណោមខេត្តទាំង២៥ ត្រូវបានចាត់ចំណាត់ថ្នាក់ដោយប៉ារ៉ា

ម៉ែត្រទាំង៤ ពីលំដាប់ខ្ពស់បំផុតទៅទាបបំផុត។ សម្រាប់ខេត្ត១០ដំបូង ប៉ារ៉ាម៉ែត្រនីមួយៗគឺផ្ដល់ពិន្ទុ៣។ ខេត្ត១០បន្ទាប់គឺផ្ដល់ពិន្ទុ២។ ឯខេត្តនៅសល់ក្រោយគឺផ្ដល់ពិន្ទុ១។

134. ពិន្ទុត្រូវបានបន្ថែម (ie F3 = F3a + F3b + F3c + F3d) ការផ្ដល់ពិន្ទុខ្ពស់បំផុតសម្រាប់ខេត្តសក្ដានុពលមួយគឺ១២ និងខេត្តពិន្ទុទាបបំផុតគឺ៤។

### 4. ពិន្ទុផ្ដល់ដោយក្រសួងដៃគូរ

135. ការជ្រើសរើសខេត្តដើម្បីធ្វើការ គឺត្រូវបានពិភាក្សាជាមួយក្រសួងពាក់ព័ន្ធទាំងអស់ តាមរយៈកិច្ចប្រជុំនានា។ សេចក្ដីសន្និដ្ឋាន គឺត្រូវបានចងក្រងជាឯកសារជ្រើសរើសខេត្ត ដែលគ្របដណ្ដប់ការពិពណ៌នាលើដំណើរការ តារាង និងផែនទីគាំទ្រ។ ឯកសារទាំងនេះគឺបានបញ្ជូនមកក្រុមការងារការប្រែប្រួលអាកាសធាតុក្នុងក្រសួងទាំង៥នៃកម្មវិធីSPCR ដើម្បីពិនិត្យ និងផ្ដល់យោបល់។ ឯកសារនេះក៏បានបញ្ជូនទៅកាន់អ្នកបច្ចេកទេសដែលជាតំណាងរបស់ក្រសួងផងដែរ។ អ្នកឯកទេសតាមវិស័យរបស់ក្រុមការងារTA គឺចូលរួមនិងសម្របសម្រួលកិច្ចប្រជុំបច្ចេកទេសផ្ទៃក្នុងក្រសួងនីមួយៗ ដើម្បីពីនិត្យលើឯកសារសង្ខេប កត់ត្រាការពិភាក្សា និងផ្ដល់យោបល់។

136. ក្រសួងដៃគូរគឺតម្រូវឱ្យពិនិត្យពីដំណើរការ លក្ខណៈវិនិច្ឆ័យ និងលទ្ធផលនៃដំណើរការជ្រើសរើស ការសម្រេច ឬកែសម្រួលបញ្ជីខេត្តសម្រាំង ដែលជាខេត្តគោលដៅរបស់គម្រោង។ ប្រសិនបើក្រសួងមានភស្ដុតាងបន្ថែម ដែលត្រូវកែតម្រូវព័ត៌មានលើជម្រើសខេត្ត ពីក្នុងបញ្ជីខេត្តអាទិភាព គឺក្រសួងអាចស្នើសុំខេត្តទាំងនោះ ដោយមានឯកសារគាំទ្រ។ លទ្ធផលកិច្ចពិភាក្សាជាបន្តបន្ទាប់គឺបានសង្ខេបក្នុងតារាង ៤.២។ ខេត្តចំនួន៦ដែលបានផ្ដល់អាទិភាពខ្ពស់គឺៈ (1) ខេត្តព្រៃវែង (2) ខេត្តបាត់ដំបង (3) ខេត្តកំពង់ចាម (4) ខេត្តកំពង់ស្ពឺ (5) ខេត្តកំពង់ធំ និង (6) ខេត្តកោះកុង។ ខេត្តពីរផ្សេងទៀត គឺខេត្តពោធិ៍សាត់ និងខេត្តមណ្ឌលគីរី គឺត្រូវបានកំណត់ និងផ្ដល់អាទិភាពទាប។

137. ក្នុងដំណើរការដាក់ពិន្ទុតាមលក្ខណពហុលក្ខណៈវិនិច្ឆ័យ ខេត្ត៦ដែលបានទទួលចំណាត់ខ្ពស់ជាងគេ គឺបានទទួលពិន្ទុ២ ក្នុងខណៈខេត្តដែលមានអទិភាពទាបគឺបានពិន្ទុ១។ ខេត្តដែលនៅសល់គឺទទួលបានពិន្ទុសូន្យ។ កក្តានេះគឺត្រូវវាស់តាមរូបមន្ត (F1 + F2 + F3) x F4 ដូចនេះ ការសរុបបន្តគ្នានៃ F1 ទៅ 3 គឺគុណជាមួយពិន្ទុដាក់ដោយក្រសួង ដោយលុបចេញនូវខេត្តមួយចំនួន។

138. ក្រសួងដៃគូរគឺបានស្នើសុំលក្ខខណ្ឌសម្រាប់ការចាត់ចំណាត់ថ្នាក់ភាពក្រីក្រនាពេលបច្ចុប្បន្ន ដោយឆ្លុះបញ្ចាំងក្នុងការសិក្សាឆ្នាំ២០១៤ និងរាប់បញ្ចូលកត្តាជីវចម្រុះលើដី។

**តារាង** ៤.២៖ ការចង់បានរបស់ក្រសួងលើខេត្តដដែលគម្រោងគួរផ្តោត

| ខេត្ត/ក្រុង | គម្រោង SPCR | តំបន់អនុវត្តន៍គម្រោង | ក្រសួងធនធានទឹក និងឧត្តនិយម | ក្រសួងសាធារណៈការ និងដឹកជញ្ជូន | ក្រសួងអភិវឌ្ឍន៍ជនបទ | ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | តម្រូវការក្រសួង |
|---|---|---|---|---|---|---|---|
| ព្រៃវែង | 3 | តំបន់ដីសណ្តរ | ✓ | ✓ | ✓ | ✓ | 4 |
| បាត់ដំបង | 2 | TS | ✓ | ✓ | | ✓ | 3 |
| កំពង់ចាម | 2 | TS | ✓ | ✓ | ✓ | | 3 |
| កំពង់ស្ពឺ | 1 | Plat &M | ✓ | | ✓ | ✓ | 3 |
| ពោធិ៍សាត់ | 2 | TS | ✓ | ✓ | | | 2 |
| កោះកុង | 1 | តំបន់សមុទ្រ | | | | ✓ | 1 |
| មណ្ឌលគិរី | 1 | Plat &M | | | | ✓ | 1 |
| កំពង់ធំ | 1 | TS | ✓ | | ✓ | បម្រុង | 2 |
| កណ្តាល | 0 | TS | | ✓ | ✓ | | 2 |
| បន្ទាយមានជ័យ | 2 | TS | | | ✓ | ✓ | 2 |
| ត្បូងឃ្មុំ | 1 | TS | | | ✓ | | 1 |
| កំពង់ឆ្នាំង | 2 | TS | | ✓ | | | 1 |
| សៀមរាប | 1 | TS | | ✓ | | | 1 |
| ព្រះសីហនុ | 0 | តំបន់សមុទ្រ | បម្រុង | | | | 0 |
| ព្រះវិហារ | 0 | Plat &M | | | | | 0 |

### 5. ពិន្ទុខេត្ត SPCR

139. ការផ្តល់ពិន្ទុសម្រាប់ខេត្ត SPCR គឺអាស្រ័យលើថាតើខេត្តមានគម្រោង SPCR ១ ឬ ច្រើន (ក្រាហ្វិច៤.៤)។ ខេត្តដែលមានគម្រោងវិនិយោគ SPCR នោះទទួលបានពិន្ទុ១ និង ខេត្តដែលមិនមានគម្រោង SPCR នោះទទួលបានពិន្ទុសូន្យ។ ក្នុងរូបមន្តពហុលក្ខណៈវិនិច្ឆ័យ កត្តានេះត្រូវបានផ្តល់ទម្ងន់ ដូចនេះផលសរុបបន្តគ្នា សម្រាប់ F1 ដល់ F4 គឺត្រូវគុណដោយពិន្ទុ SPCR - (F1 + F2 + F3) x F4 x F5 ជាលទ្ធផលនៃការលុបចោលខេត្តដែលមិនមានគម្រោងវិនិយោគ SPCR។

**រូបភាព 1៖** ទីតាំងគម្រោងវិនិយោគ SPCR




140. លទ្ធផលនៃការវិភាគចម្រុះលក្ខខ័ណ្ឌ គឺត្រូវបានសង្ខេបក្នុងតារាង ៤.៣ និងតារាង ៤.៤ និងក្រាហ្វិច ៤.៦។ ក្នុងនោះផងដែរ ជំហានចុងក្រោយ គឺធ្វើការធានាថាតំបន់អេកូឡូស៊ីទាំងបួន គឺត្រូវបានតំណាងឱ្យតំបន់សំខាន់ និងអាទិភាពសម្រាប់ខេត្តទាំង ៦ដូចមានក្នុងតារាងខាងក្រោម (មើលក្រាហ្វិច ៤.៥)។

**តារាង ៤.៣: ខេត្តដែលត្រូវបានជ្រើសរើស**

| ខេត្ត/ក្រុង | ពន្ទុចុងក្រោយ | ចំណាត់ថ្នាក់ចុងក្រោយ | តំបន់អនុវត្តគម្រោង (6) | អាទិភាព |
|---|---|---|---|---|
| កំពង់ធំ | 52 | 1 | ទន្លេសាប | 1 |
| កំពង់ចាម | 44 | 2 | ទន្លេសាប | 1 |
| កោះកុង | 36 | 3 | តំបន់សមុទ្រ | 1 |
| កំពង់ស្ពឺ | 34 | 4 | តំបន់ខ្ពង់រាប និងតំបន់ភ្នំ | 1 |
| បាត់ដំបង | 30 | 5 | ទន្លេសាប | 1 |
| ព្រៃវែង | 26 | 6 | តំបន់ដីសណ្ត | 1 |
| មណ្ឌលគិរី | 25 | 7 | តំបន់ខ្ពង់រាប និងតំបន់ភ្នំ | 2 |
| ពោធិ៍សាត់ | 24 | 8 | ទន្លេសាប | 2 |

## រូបភាព 2: តំបន់អេកូឡូស៊ីនៃប្រទេសកម្ពុជា




## រូបភាព 3: ខេត្តដែលត្រូវបានជ្រើសរើសសម្រាប់គម្រោងអនុវត្ត



## តារាង៤.៤: ការវិភាគលក្ខខ័ណ្ឌចម្រុះក្នុងការជ្រើសរើសខេត្តសម្រាប់អនុវត្តគម្រោង

| ខេត្ត/ក្រុង | ភាពក្រីក្រ (ADB 2014) | | | | ជីវចម្រុះដីគោក | | ការស្ទៀបស្ទង់ការប្រែប្រួលអាកាសធាតុ (4) | | | | | | | តម្រូវការរដ្ឋាភិបាល | | | SPCR project | | | តំបន់អេកូឡូស៊ី |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សង្កាត់ឆ្នាំ 2012 | លេខសំគាល់ គ្រួសារក្រីក្រ | ណត់ដោយ ADB | ភាពក្រីក្រ (1) | គម្របព្រៃឈើ (%) | ចម្រុះដីគោក (2) | CC1 សំណើម ទឹកភ្លៀង | CC2 Tmax សំងួត | ចំនួនខែរាំង ស្ងួត CC3 | ការប្រែប្រួល កាពាំងស្ងួត CC4 | ការប្រែប្រួល អាកាសធាតុ | (1) + (2) + (3) | របស់រដ្ឋាភិបាល | តម្រូវការក្នុង ការដាក់ពន្ធ របស់រដ្ឋាភិបាល (4) | (1+2+3)x(4) | ចំនួនគម្រោង SPCR | សេចក្តី សម្រេចរបស់ SPCR បាទ/ទេ (5) | ក្រោយ = Acum.2 x (5) | ការដាក់ចំណាត់ ថ្នាក់ចុងក្រោយ | តំណាងតំបន់អេកូឡូស៊ី (6) |
| បន្ទាយមានជ័យ | | | | 0 | 16.7 | 6 | 1 | 1 | 3 | 1 | 6 | 12 | | | 0 | 2 | 1 | 0 | | ទន្លេសាប |
| បាត់ដំបង | | 34 | | 3 | 44.1 | 6 | 1 | 1 | 2 | 2 | 6 | 15 | 2 | 2 | 30 | 2 | 1 | 30 | 5 | ទន្លេសាប |
| កំពង់ចាម | 28 | | 20 | 6 | 11.4 | 6 | 3 | 3 | 1 | 3 | 10 | 22 | 3 | 2 | 44 | 2 | 1 | 44 | 2 | ទន្លេសាប |
| កំពង់ឆ្នាំង | | 37 | 23 | 6 | 38.4 | 6 | 2 | 3 | 1 | 3 | 9 | 21 | | | 0 | 2 | 1 | 0 | | ទន្លេសាប |
| កំពង់ស្ពឺ | | | | 0 | 58.2 | 9 | 2 | 2 | 2 | 2 | 8 | 17 | 4 | 2 | 34 | 1 | 1 | 34 | 4 | ខ្ពង់រាប និងតំបន់ភ្នំ |
| កំពង់ធំ | 28 | 31 | 24 | 9 | 48.2 | 6 | 3 | 3 | 2 | 3 | 11 | 26 | 5 | 2 | 52 | 1 | 1 | 52 | 1 | ទន្លេសាប |
| កំពត | | | | 0 | 48.1 | 6 | 2 | 2 | 2 | 3 | 9 | 15 | | | 0 | | 0 | 0 | | តំបន់សមុទ្រ |
| កណ្តាល | | | | 0 | 5.3 | 3 | 2 | 3 | 3 | 1 | 9 | 12 | | | 0 | | 0 | 0 | | ដីសណ្តរ |
| កែប | | | | 0 | 19.5 | 6 | 2 | 2 | 2 | 3 | 9 | 15 | | | 0 | | 0 | 0 | | តំបន់សមុទ្រ |
| កោះកុង | | 44 | | 3 | 80.9 | 9 | 1 | 2 | 1 | 2 | 6 | 18 | 6 | 2 | 36 | 1 | 1 | 36 | 3 | តំបន់សមុទ្រ |
| ក្រចេះ | 29 | 36 | 29 | 9 | 77.9 | 9 | 3 | 3 | 3 | 3 | 12 | 30 | | | 0 | | 0 | 0 | | ខ្ពង់រាប និងតំបន់ភ្នំ |
| មណ្ឌលគិរី | 33 | | 44 | 6 | 90.5 | 9 | 3 | 3 | 2 | 2 | 10 | 25 | 8 | 1 | 25 | 1 | 1 | 25 | 7 | ខ្ពង់រាប និងតំបន់ភ្នំ |
| ឧត្តរមានជ័យ | 34 | | | 3 | 62.8 | 9 | 2 | 1 | 3 | 1 | 7 | 19 | | | 0 | | 0 | 0 | | ខ្ពង់រាប និងតំបន់ភ្នំ |
| ប៉ៃលិន | | 32 | | 3 | 48.9 | 6 | 1 | 1 | 3 | 2 | 7 | 16 | | | 0 | | 0 | 0 | | ទន្លេសាប |
| ភ្នំពេញ | | | | 0 | 0.0 | 3 | 3 | 3 | 3 | 1 | 10 | 13 | | | 0 | | 0 | 0 | | ដីសណ្ត |
| ព្រះសីហនុ | | | | 0 | 53.4 | 9 | 2 | 2 | 1 | 3 | 8 | 17 | | | 0 | | 0 | 0 | | តំបន់សមុទ្រ |
| ព្រះវិហារ | 37 | 32 | 39 | 9 | 93.3 | 9 | 3 | 2 | 3 | 3 | 11 | 29 | | | 0 | | 0 | 0 | | ខ្ពង់រាប និងតំបន់ភ្នំ |
| ព្រៃវែង | | | | 0 | 1.7 | 3 | 3 | 3 | 2 | 2 | 10 | 13 | 1 | 2 | 26 | 3 | 1 | 26 | 6 | ដីសណ្ត |
| ពោធិ៍សាត់ | 28 | 34 | 25 | 9 | 71.2 | 9 | 1 | 2 | 1 | 2 | 6 | 24 | 7 | 1 | 24 | 2 | 1 | 24 | 8 | ទន្លេសាប |
| រតនគិរី | 36 | | 44 | 6 | 78.9 | 9 | 2 | 3 | 2 | 2 | 9 | 24 | | | 0 | | 0 | 0 | | ខ្ពង់រាប និងតំបន់ភ្នំ |
| សៀមរាប | 29 | 31 | 19 | 9 | 47.1 | 6 | 2 | 1 | 3 | 2 | 8 | 23 | | | 0 | 1 | 1 | 0 | | ទន្លេសាប |
| ស្ទឹងត្រែង | 37 | 30 | 39 | 9 | 86.9 | 9 | 3 | 3 | 3 | 3 | 12 | 30 | | | 0 | | 0 | 0 | | ខ្ពង់រាប និងតំបន់ភ្នំ |
| ស្វាយរៀង | | | | 0 | 4.2 | 3 | 3 | 2 | 2 | 2 | 9 | 12 | | | 0 | | 0 | 0 | | ដីសណ្ត |
| តាកែវ | | | | 0 | 4.4 | 3 | 2 | 2 | 3 | 1 | 8 | 11 | | | 0 | | 0 | 0 | | ដីសណ្ត |
| ត្បូងឃ្មុំ | | | | 0 | 20.9 | 6 | 3 | 3 | 2 | 3 | 11 | 17 | | | 0 | 1 | 1 | 0 | | ទន្លេសាប |

## 4.7 ហេដ្ឋារចនាសម្ព័ន្ធបៃតងសម្រាប់ធ្វើឲ្យមានភាពធន់ និងចីរភាព

141. គម្រោងនេះផ្តោតទៅលើការសម្រេចបាននៃការអភិវឌ្ឍ ដែលការអភិវឌ្ឍនោះមានន័យថា កាត់បន្ថយគុណវិបត្តិ បង្កើនការចូលរួមរបស់ពលរដ្ឋ សង្គម និងសេដ្ឋកិច្ច ព្រមទាំងផ្តល់នូវសំលេង និងការទទួលខុសត្រូវឲ្យភាគីពាក់ព័ន្ធបានច្រើនជាងមុន។ គោលការណ៍សម្រាប់ការអភិវឌ្ឍទាំងនោះរួមមាន៖

- ការកសាងសមត្ថភាពដោយផ្អែកលើភាពខ្លាំងរបស់បុគ្គល និងសហគមន៍
- ការប្រើប្រាស់ភស្តុតាងសម្រាប់ផ្តល់មតិយោបល់សម្រាប់ធ្វើគោលនយោបាយ
- ការកសាងភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធ
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មដែលសមស្រប
- ការផ្តល់អាទិភាពខ្ពស់ដល់ការអន្តរាគមន៍មុន និងការបង្ការ និង
- គម្រោងការសម្រាប់ភាពធន់ និងចីរភាព[4]

142. គម្រោងនេះកំពុងធ្វើការជាមួយនិងក្រសួងដែលធ្វើការលើការសាងសង់ផ្លូវថ្នល់ ស្ពាន និងលូ។ ជាមួយគ្នានោះដែរ គម្រោងនេះក៏បានធ្វើការជាមួយនឹងក្រសួងដែលធ្វើការលើការគ្រប់គ្រងធនធានទឹក ការកសាងប្រព័ន្ធធារាសាស្ត្រ និងវិធានការដើម្បីរក្សាស្តុកទុក អភិរក្ស និងដឹកជញ្ជូនទឹកផងដែរ។ មិនត្រឹមប៉ុណ្ណោះទេ គម្រោងក៏បានធ្វើការទៅលើគម្រោងការ និងការគ្រប់គ្រងដោយផ្អែកលើផែនទី/រូបភាពពីលំហរដោយប្រើប្រាស់ធនធានធម្មជាតិដែលមាននៅក្នុងតំបន់ទេសភាព។ បន្ថែមលើនោះ វារួមបញ្ចូលទាំងការដោះស្រាយចំពោះបច្ចេកវិទ្យាកសិកម្ម និងវិធីសាស្ត្រផលិតដំណាំ ក៏ដូចជារបៀបដែលកសិដ្ឋាន និងតំបន់ទីក្រុងអភិវឌ្ឍដោយផ្សារភ្ជាប់ទៅនឹងព្រៃឈើ និងតំបន់ធម្មជាតិដែលនៅជុំវិញខ្លួន។ ដូច្នេះការប្រែប្រួលអាកាសធាតុមានឥទ្ធិពលលើជាតុនៃការអភិវឌ្ឍទាំងអស់នោះ។

143. ប្រធានបទសំខាន់មួយរបស់គម្រោងនេះ គឺជាតម្រូវការក្នុងការទទួលស្គាល់ប្រព័ន្ធធម្មជាតិដែលជាគ្រឹះសំខាន់សម្រាប់ការអភិវឌ្ឍ និងដើម្បីស្តារ និងលើកកម្ពស់ធម្មជាតិ ហើយក៏ជាយុទ្ធសាស្ត្រគន្លឹះមួយសម្រាប់ការកសាងឱ្យមានចីរភាព និងភាពធន់នៅក្នុងប្រទេសកម្ពុជាផងដែរ។ សមាសភាពទាំងពីរខាងលើ (ភាពធន់ និងចីរភាព) គឺផ្សាភ្ជាប់គ្នា។ ដំណោះស្រាយសម្រាប់រឿងមួយអាចបំពេញតម្រូវការនៃរឿងផ្សេងទៀតបាន។ ភាពធន់ និងចីរភាពគឺជាមរតកសំខាន់ក្នុងការចូលរួមក្នុងការអភិវឌ្ឍ។

---

[4] Adapted from Australian Government, 2008, *'Social Inclusion Principles for Social Inclusion in Australia'* http://www.socialinclusion.gov.au/

144. គម្រោងនេះផ្តោតលើហេដ្ឋារចនាសម្ព័ន្ធបៃតង ដែលជាមូលដ្ឋានគ្រឹះមួយ សម្រាប់សម្រេចបាននូវដំណោះស្រាយតាមបែបធម្មជាតិចំពោះការប្រែប្រួលអាកាសធាតុ ហើយធ្វើឱ្យប្រសើឡើងនូវការរស់នៅក្នុងទីក្រុង និងជនបទ ក៏ដូចជាសម្រេចឲ្យបាននូវកិច្ចការអភិវឌ្ឍផងដែរ។ ដូចគ្នានេះដែរ គម្រោងក៏បានផ្តល់នូវការណែនាំសម្រាប់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធបៃតងឲ្យបានទូលំទូលាយ ដែលជាជម្រើស និងជំនួយពិសេសសម្រាប់រៀបចំផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធឱ្យមានលក្ខណៈសាមញ្ញ។

145. ការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជាភាគច្រើនស្ថិតក្នុងកម្រិតគម្រោង ដែលត្រូវគិតពិចារណាឲ្យគ្រប់គ្រាន់សម្រាប់ព្រឹត្តិការ ផលប៉ះពាល់ទូទាំងតំបន់ ចីរភាព និងការប្រើប្រាស់ផ្សេងៗចំពោះតំបន់ដែលរងផលប៉ះពាល់នោះ។ ការប្រែប្រួលអាកាសធាតុកម្រួមបញ្ចូលនូវស្ថានភាពធ្ងន់ធ្ងរដោយសារតែភាពខ្វះចន្លោះរវាងភ្នាក់ងារមោត្រសាស្ត្រវារី និងអ្នកអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធណាស់។ ព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុដែលផ្តល់ដោយភ្នាក់ងារមោត្រសាស្ត្រវារីគឺជាញឹកញាប់ត្រូវបានប្រើប្រាស់តិចតួចណាស់ដោយវិស្វករ និងអ្នកធ្វើផែនការអភិវឌ្ឍន៍។ ផែនការបន្សាំការប្រែប្រួលអាកាសធាតុមានទំនោរទៅតាមតំបន់ និងវិស័យជាក់លាក់ ហើយផ្ទុយទៅវិញ វិធីសាស្ត្រដែលនឹងត្រូវបានបង្កើតឡើងនឹងវាយតម្លៃសំណើហេដ្ឋារចនាសម្ព័ន្ធនោះជាលក្ខណៈប្រព័ន្ធនៅទូទាំងតំបន់ទាំងមូលដោយប្រើប្រាស់ព័ត៌មានផែនទី/រូបភាពពីលំហរដែលសមស្របមួយស្តីពីព្រឹត្តិការណ៍អាកាសធាតុធម្មតា និងធ្ងន់ធ្ងរ។

146. ហេដ្ឋារចនាសម្ព័ន្ធបៃតងសំដៅទៅលើការរៀបចំ និងការគ្រោងប្រកបដោយយុទ្ធសាស្ត្រនៃបណ្តាញសួនបៃតង និងបណ្តាផ្នែកបរិស្ថានសំខាន់ៗដទៃទៀត ហើយវាក៏ផ្តោតទៅលើបច្ចេកវិទ្យាសំខាន់ៗដើម្បីឱ្យមានចីរភាពនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងតំបន់ដែលនៅជុំវិញវាផងដែរ។ ហេដ្ឋារចនាសម្ព័ន្ធបៃតងប្រើដំណើរការរុក្ខជាតិ ដី ធម្មជាតិ និងបច្ចេកវិទ្យាច្នៃប្រឌិតថ្មីដើម្បីគ្រប់គ្រង ទឹក ដី សីតុណ្ហភាព និងគុណភាពខ្យល់ដើម្បីបង្កើតសុខភាព និងភាពធន់សម្រាប់បរិស្ថាន។

147. ចំពោះតំបន់ទេសភាពវិញ ហេដ្ឋារចនាសម្ព័ន្ធបៃតងសំដៅទៅលើតំបន់ព្រៃធម្មជាតិដែលផ្តល់ជាទីជម្រកការការពារទឹកជំនន់ ខ្យល់បរិសុទ្ធ ទឹកស្អាត អាហារ និងការកំសាន្ត។ រីឯនៅកម្រិតមូលដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធបៃតងរួមបញ្ចូលទាំងប្រព័ន្ធគ្រប់គ្រងព្យុះ និងការបង្ហូរទឹកដែលដំណើការទៅតាមលក្ខណៈធម្មជាតិដូចជាការស្រូប ការក្សោស្តុកទឹក និងធ្វើឱ្យប្រសើឡើងនូវគុណភាពទឹកជាដើម។ ហេដ្ឋារចនាសម្ព័ន្ធបៃតងបានធ្វើឲ្យហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតដូចជាផ្លូវថ្នល់ ស្ពាន និងប្រព័ន្ធធារាសាស្ត្រមានភាពរឹងមាំ និងគុណភាពច្រើនឆ្នាំជាងមុនដោយការដាក់បញ្ចូលនូវសមាសធាតុធម្មជាតិ និងវិធីសាស្ត្រជីវវិស្វកកម្ម។ សម្រាប់ការធ្វើកសិកម្មតាមបែបប្រព័ន្ធអេកូឡូស៊ីវិញ វាក៏បានធ្វើឱ្យគុណភាពដី ការគ្រប់គ្រងទឹក និងផលិតកម្មកសិកម្មមានភាពប្រសើឡើងដែរ។ ម្យ៉ាងវិញទៀត ហេដ្ឋារចនាសម្ព័ន្ធ

បៃតងសង្កត់ធ្ងន់ទៅលើដំណោះស្រាយតាមបែបធម្មជាតិ និងប្រើប្រាស់ធនធាន និងសម្ភារៈដែលមាននៅក្នុងមូលដ្ឋានសម្រាប់កសាងភាពពឹងអាស្រ័យ និងភាពធន់របស់សហគមន៍ខ្លួនឯងផ្ទាល់។

148. ឧទាហរណ៍នៃហេដ្ឋារចនាសម្ព័ន្ធបៃតងរួមមានបច្ចេកវិទ្យាបៃតងសម្រាប់ការបន្សាំ និងកាបំពេញលក្ខណៈសម្រាប់អាគារ និងហេដ្ឋារចនាសម្ព័ន្ធ (ដូចជាផ្លូវថ្នល់ ប្រព័ន្ធជារាសាស្ត្រ ទ្វារទឹក និងប្រឡាយទឹកជាដើម) ដែលធ្វើឲ្យមានប្រសិទ្ធភាពក្នុងការទប់ទល់និងគ្រោះទឹកជំនន់ ខ្យល់ព្យុះ និងកម្ដៅ។ ហេដ្ឋារចនាសម្ព័ន្ធបៃតងនេះផ្តោតទៅលើប្រព័ន្ធគ្រប់គ្រងទឹកធម្មជាតិ វិធីសាស្ត្ររក្សាស្ថេរភាពទីជម្រាលវិធានអភិរក្សថាមពល វិធីសាស្ត្រ និងសម្ភារៈធម្មជាតិផ្សេងៗទៀត។ វាក៏បានរួមបញ្ចូលទាំងការធ្វើកសិរុក្ខកម្ម សួនបៃតង ដូចជាឧទ្យាន តំបន់ដីសើម និងច្រករបៀងបង្ហូរទឹកបៃតងផងដែរ។ ហេដ្ឋារចនាសម្ព័ន្ធបៃតងត្រូវបានអនុវត្តទៅតាមលក្ខណៈធម្មជាតិដើម្បីឱ្យការអនុវត្ត និងភាពធន់នៃហេដ្ឋារចនាសម្ព័ន្ធផ្សេងៗមានភាពប្រសើរឡើងជាងមុន ហើយជាញឹកញាប់វាអាចជំនួសបានទាំងស្រុងដោយចំណាយតិច និងមានគុណភាពរឹងមាំដែលអាចឱ្យសហគមន៍មូលដ្ឋានធ្វើការតាមដានថែរក្សា និងប្រើប្រាស់បាន។

149. សកម្មភាពចម្បងនៅក្នុងគម្រោងដែលបានទទួលពីការផ្តល់មតិយោបល់ ពីសិក្ខាសាលាចាប់ផ្តើមគម្រោងនោះគឺ ការបង្កើតឯកសារសម្រាប់ក្រសួងអនុវត្តកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុដែលមានដូចជា ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងបរិស្ថាន ដែលហេដ្ឋារចនាសម្ព័ន្ធបៃតងនេះមានភាពសមស្របបំផុតសម្រាប់នីតិកាលនៃការអភិវឌ្ឍរបស់ខ្លួន។ វិធានការមួយចំនួននៃវិធានការទាំងនោះត្រូវបានធ្វើការសាកល្បង និងលើកឡើងនៅក្នុងប្រទេសកម្ពុជា ហើយបានប្រើប្រាស់រួចហើយនៅតាមក្រសួងទៅតាមស្ថានភាពផ្សេងៗ។ វិធានការមួយចំនួនទៀតក៏បានដាក់ស្នើឡើងក្នុងលក្ខខ័ណ្ឌទូទៅថាជាធាតុសំខាន់សម្រាប់គម្រោងផ្សេងៗទៀត នៃកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុផងដែរ។ ដោយឡែក វិធានការផ្សេងៗមួយចំនួនទៀតជាវិធានការមានលក្ខណៈប្រពៃណីសម្រាប់ការគ្រប់គ្រងកសិកម្ម ទឹក និងដី ដែលបង្ហាញឲ្យឃើញនូវប្រសិទ្ធភាពក្នុងការកសាងភាពធន់ទៅនឹងទឹកជំនន់ និងគ្រោះរាំងស្ងួត។ ការរៀបចំសេចក្តីណែនាំសម្រាប់ហេដ្ឋារចនាសម្ព័ន្ធបៃតងសម្រាប់វិស័យនិមួយៗ នឹងផ្តល់នូវបញ្ជីនៃវិធានការបន្សាំដែលសមស្របសម្រាប់គម្រោងរៀបចំថវិកាសម្រាប់អាកាសធាតុ។ សេចក្តីណែនាំនេះនឹងលើកឡើងនូវវិធានការបន្សាំដែលនឹងត្រូវបានផ្តល់អាទិភាពចំបង និងដាក់បញ្ចូលទៅតាមវិស័យ គោលនយោបាយ និងការធ្វើឲ្យមានស្តង់ដារជាដើម។

150. ធនធានឧបករណ៍ដែលរៀបចំដោយ ICEM តាមរយៈគម្រោង ADB TA 8186-REG: *Greater Mekong Subregion (GMS): ដែលជាគម្រោងភាពធន់នឹងអាកាសធាតុនៅក្នុងក្រុង* បានផ្តល់ជា

មូលដ្ឋានគ្រឹះសម្រាប់ការងារនេះ។ ដើម្បីបង្កើតឱ្យមានឧបករណ៍នេះឡើង គម្រោងបានធ្វើការជាមួយក្រុមស្នូលដែលធ្វើការលើការប្រែប្រួលអាកាសធាតុ ដែលបានបង្កើតឡើងជាផ្លូវការក្នុងខេត្តបាត់ដំបង និងខេត្ត kaysone ប្រទេសឡាវ ព្រមទាំងខេត្ត Dong Ha ប្រទេសវៀតណាម។ បច្ចុប្បន្នឧបករណ៍នេះមានជាភាសាខ្មែរ និងភាសាអង់គ្លេសហើយ ហើយនឹងត្រូវបានប្រើប្រាស់សម្រាប់ការបណ្តុះបណ្តាល និងសេចក្តីណែនាំនៅក្នុងគម្រោងនេះ។[5]

## 4.8 ការដាក់បញ្ចូលវិធីសាស្រ្តទៅក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សុំាការប្រែប្រួលអាកាសធាតុ

151. ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR) គឺជាសមាសភាគសំខាន់មួយនៃភាពធន់អាកាសធាតុ និងបំពេញនូវវិធានការរយៈពេលវែងមួយសម្រាប់ដោះស្រាយហានិភ័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ហើយជាធម្មតាជាប់ពាក់ព័ន្ធទៅនឹងការបន្សុំាការប្រែប្រួលអាកាសធាតុ (CCA)។ គ្រោះមហន្តរាយ សំដៅទៅលើស្ថានភាពដែលមានការរំខានធ្ងន់ធ្ងរ និងរាលដាលដល់ជីវិតនៅក្នុងសហគមន៍ ឬសង្គមមួយ ហើយដែលមនុស្សភាគច្រើនមិនអាចងើបឡើងវិញបានដោយគ្មានជំនួយពីអ្នកដទៃ។ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR) សំដៅទៅលើសកម្មភាពដើម្បីកាត់បន្ថយ ហានិភ័យនៃគ្រោះមហន្តរាយ និងផលប៉ះពាល់ដែលជាប់ទាក់ទងតាមរយៈការខិតខំជាលក្ខណៈប្រព័ន្ធដើម្បី វិភាគ និងគ្រប់គ្រងកត្តាធ្វើអោយមានគ្រោះមហន្តរាយទាំងនោះ។ ការបន្សុំាការប្រែប្រួលអាកាសធាតុ (CCA) សំដៅទៅលើសកម្មភាពក្នុងការគ្រប់គ្រង និងកាត់បន្ថយហានិភ័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ ហានិភ័យគ្រោះមហន្តរាយ និងហានិភ័យការប្រែប្រួលអាកាសធាតុគឺមានន័យត្រួតគ្នាដែលមានន័យថា ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR) និង ការបន្សុំាការប្រែប្រួលអាកាសធាតុ (CCA) ដែលផ្តោតទៅលើការប្រមើលមើល និងការគ្រប់គ្រងនូវបាតុភូតស្រដៀងៗគ្នា ហើយក៏ប្រើប្រាស់វិធីសាស្រ្ត និងឧបករណ៍ស្រដៀងគ្នាដែរ។

---

[5] The resource kit will be available in July 2015 for download from the ICEM website www.icem.com.au in English and Khmer. In the meantime it is available for download in English from the following link: https://drive.google.com/folderview?id=0Bwc7fmsDQpslb1p6THR5N1VpVEU&usp=sharing

## ក្រាហ្វិច 11៖ ការដាក់បញ្ចូលគ្នា DRR និង CCA




ប្រភព៖ Adapted from Turnbull. et al. 2013

152. ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR) និងការបន្សាំការប្រែប្រួលអាកាសធាតុ (CCA) គឺទាក់ទងទៅនឹងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងហានិភ័យការប្រែប្រួលអាកាសធាតុដែលហានិភ័យទាំងនោះបណ្តាលមកពីភាពប្រឈម និងភាពងាយរងគ្រោះទៅនឹងគ្រោះមហន្តរាយជាក់លាក់មួយ ឬក៏ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ដោយឃើញថាការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR) និងការបន្សាំការប្រែប្រួលអាកាសធាតុ (CCA) មានមូលដ្ឋានស្រដៀងគ្នា និងត្រួតស៊ីគ្នានោះ ក្រុមការងារគម្រោងនឹងបង្កើតវិធីសាស្ត្រមួយនៃភាពធន់អាកាសធាតុដោយដាក់បញ្ចូលការអនុវត្តនូវវិធីសាស្ត្រទាំងពីរនេះទៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុតែមួយ។ ក្នុងការអនុវត្តនោះមានន័យថា គឺជាសកម្មភាពដែលបង្កើតឡើងដោយក្រុមការងារគម្រោងដើម្បីកាត់បន្ថយភាពប្រឈមនៃវិស័យដែលបានកំណត់ និងភាពងាយរងគ្រោះចំពោះការកាត់បន្ថយហានិភ័យការប្រែប្រួលអាកាសធាតុរយៈពេលវែង (CCA) ដែលនឹងបញ្ចូលផងដែរនូវសកម្មភាពដើម្បីធ្វើឱ្យប្រសើឡើងនូវសមត្ថភាពអ្នកពាក់ព័ន្ធគម្រោងដើម្បីប្រមើលមើល និងឆ្លើយតបទៅនឹងហានិភ័យទាក់ទងនឹង

អាកាសធាតុ ហើយនិងត្រឡប់ទៅស្ថានភាពនៃការប្រតិបត្តិការមុនការចាប់ផ្តើម នៃគ្រោះមហន្តរាយវិញ។

ឧទាហរណ៍នៃការដាក់បញ្ចូលនូវការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងការបន្សុំការប្រែប្រួលអាកាសធាតុនៅក្នុងទស្សនទានគឺមាននៅក្នុង

153. រូបភាពទី5៖ នៅក្នុងរូបភាពទិន្នផលកសិកម្មត្រូវបានវាស់វែងពីមួយពេលទៅមួយពេល។ ហើយបើយោងទៅតាមពេលវេលាបញ្ជាក់ថាឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុអាចមានផលបង្កគ្រោះថ្នាក់ដល់វិស័យនេះ។ តែទោះជាយ៉ាងណាក៏ដោយក៏ប្រសិទ្ធភាពនៃគោលនយោបាយ និងការអនុវត្តនៃការបន្សុំការប្រែប្រួលអាកាសធាតុអាចឱ្យវិស័យនេះដើរទៅមុខបាន។ ជាទូទៅគ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុអាចនឹងវាយប្រហារដល់វិស័យនេះ ដែលនឹងនាំឲ្យមានការថយចុះជាបន្ទាន់នៅក្នុងផលិតផលកសិកម្ម។ ប្រសិទ្ធភាពនៃយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យគ្រោះមហន្តរាយបានកាត់បន្ថយភាពខូចខាតទៅនឹងវិស័យនេះ និងអាចស្តារឡើងវិញយ៉ាងឆាប់រហ័សបាននូវទិន្នផលកសិកម្ម។

154. ក្នុងទស្សនៃការអនុវត្តជាក់ស្តែង ក្រុមការងារគម្រោងនឹងលើកយកនូវវិធីសាស្ត្រដាក់បញ្ចូលភាពធន់អាកាសធាតុដោយបញ្ចូលគ្នានូវទស្សនទានហានិភ័យគ្រោះមហន្តរាយ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងករណីសិក្សានៃកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ ហើយនឹងការវាយតម្លៃហេដ្ឋារចនាសម្ព័ន្ធដូចមានពណ៌នាខាងក្រោម៖

**ក្រាហ្វិច 12: ទស្សនទាននៃការដាក់បញ្ចូលការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំការប្រែប្រួលអាកាសធាតុទៅក្នុងវិស័យកសិកម្ម**




ប្រភព៖ Adapted from Turnbull et al. 2010

## 4.9 ការចូលរួមជាមួយគម្រោង កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ

155. គម្រោងកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុជាករណីសាកល្បងដ៏មានតម្លៃមួយដែលអាចឱ្យភាពធន់អាកាសធាតុអាចត្រូវបានដាក់បញ្ចូលក្នុងការបង្កើត និងអនុវត្តគម្រោងអភិវឌ្ឍន៍បាន (ឧបសម្ព័ន្ធ ២)។ ហើយនោះក៏រួមបញ្ចូលទាំងសមាសធាតុការបន្សាំការប្រែប្រួលអាកាសធាតុដែលអាចពង្រឹងភាពធន់នៃការវិនិយោគសំខាន់ៗ និងត្រូវបានចាត់ទុកថាជាផ្នែកសំខាន់មួយនៃកម្មវិធីយុទ្ធសាស្ត្រភាពធន់នឹងអាកាសធាតុទាំងមូលផងដែរ។

156. ឧទាហរណ៍ផ្សេងៗនៃការបញ្ច្រាបភាពធន់អាកាសធាតុទៅក្នុងវិស័យអភិវឌ្ឍន៍ ដែលមាននៅក្នុងគម្រោងកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុគឺជាទ្រព្យសម្បត្តិមួយសម្រាប់ហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស។ ដោយមានការគាំទ្រពីក្រសួងបរិស្ថាន និងក្រសួងជាបណ្តាញដៃគូរដទៃទៀតក្នុងការបង្កើតឯកសារ និងការឆ្លុះបញ្ចាំងពីវិធីសាស្ត្រផ្សេងៗ នោះហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសនឹងទទួលបានពីបទពិសោធន៍ និងមេរៀនដែលមានភាពច្បាស់លាស់ដើម្បីឱ្យការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុទៅតាមវិស័យ និងប្រព័ន្ធជាតិទាំងមូលឱ្យមានភាពរឹងមាំឡើង។

157. ការអនុវត្តនៃការបញ្ជ្រាបភាពធន់អាកាសធាតុដែលប្រើប្រាស់ក្នុងគម្រោងកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុនឹងត្រូវបានប្រើប្រាស់ក្នុងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសដែលបានលើកឡើងក្នុងគោលបំណងបណ្តុះបណ្តាល និងការអភិវឌ្ឍជំនាញ។ ហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសនេះនឹងត្រូវកត់ត្រានូវរាល់បទពិសោធន៍ និងមេរៀនដែលបានរៀនសូត្រទៅក្នុងករណីសិក្សាដែលជាផ្នែកមួយនៃការសិក្សារៀនសូត្រផងដែរ។ ឆ្លងកាត់តាមការទាក់ទងគ្នាជារឿយៗជាមួយក្រុមការងារគម្រោងកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ ក៏ដូចជាជាមួយនឹងបណ្តាក្រសួង និងក្រុមអ្នកប្រឹក្សាយោបល់នោះ ហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសនេះបានធ្វើសំណើសម្រាប់ភាពច្នៃប្រឌិតដែលត្រូវការចំពោះគោលនយោបាយ នីតិវិធី និងសម្ភារៈផ្សេងៗ។ បង្ហាញពីទំនាក់ទំនងការងារយ៉ាងជិតស្និទ្ធរវាងគម្រោងកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ ហើយនឹងការប្រើប្រាស់ប្រព័ន្ធដែលបានកំណត់ទុកដើម្បីកសាងសមត្ថភាពទៅតាមក្រសួងនីមួយៗផងដែរ។

158. កិច្ចប្រជុំត្រីមាសស្តីអំពី ផែនការវិនិយោគកម្មវិធីយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុត្រូវបានឯកភាពបន្ទាប់ពីមានការប្រជុំពិភាក្សាតុមូលពេញមួយថ្ងៃ ដែលមានតំណាងមកពីក្រុមនីមួយៗបានចូលរួម កាលពីពាក់កណ្តាលខែឧសភាកន្លងមក។ ជាមួយគ្នានេះផងដែរ ក្រុមការងារនេះក៏តម្រូវឱ្យមានជាកិច្ចប្រជុំរួមទៀងទាត់មួយផងដែរ ដែលកិច្ចប្រជុំនោះប្រព្រឹត្តឡើងក្នុងគោលបំណងពិភាក្សាលើបញ្ហាជារួម និងធ្វើការរៀបចំផែនការសម្រាប់ការធ្វើទស្សនកិច្ចសិក្សាទៅកាន់តំបន់គម្រោង ដែលទស្សនកិច្ចសិក្សានេះធ្វើឡើង ដើម្បីទទួលបានលទ្ធផលមួយចំនួន សម្រាប់ចងក្រងជាករណីសិក្សា និងយកធ្វើជាគោលបំណងនៃការបណ្តុះបណ្តាល។ ជាមួយគ្នានេះផងដែរ ក្រុមផ្នែកហិរញ្ញប្បទានសហប្រតិបត្តការបច្ចេកទេស នឹងធ្វើការបង្កើតជាទម្រង់រួមមួយសម្រាប់ការធ្វើកម្មសិក្សាខាងលើ ដើម្បីជាទុន និងគ្រឹះក្នុងការប្រមូលទិន្នន័យកំឡុងពេលចុះកម្មសិក្សា។ ផ្នែកហិរញ្ញប្បទានសហប្រតិបត្តការបច្ចេកទេស ក៏នឹងបង្កើត ឬរៀបចំវិធីសាស្ត្រក្នុងការប្រមូលឯកសារនានា ដើម្បីឱ្យជានាបានថាបទពិសោធន៍ដែលទទួលបានពី ការអនុវត្តកម្មវិធីយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ អាចគ្របដណ្តប់រាល់ព័ត៌មានដែលជាតម្រូវការក្នុងការឆ្លើយតបនឹងការវាស់វែងនៃកំណែទម្រង់ពាក់ព័ន្ធនឹងភាពធន់។

## ក្រាហ្វិច 13៖ ប្រព័ន្ធនៃការធ្វើការងាររបស់កម្មវិធីយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមបណ្តាលខេត្តទាំង៦របស់គម្រោងវិនិយោគ




## 4.10 ការវាយតម្លៃហេដ្ឋារចនាសម្ព័ន្ធចម្រុះតាមខេត្តដែលបានជ្រើសរើស

159. ការចុះអនុវត្តផ្ទាល់តាមទីវាល គឺនឹងត្រូវធ្វើនៅតាមបណ្តាលខេត្តចំនួន៦ ដែលខេត្តនីមួយៗមានគម្រោងពាក់ព័ន្ធនឹងកម្មវិធីយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ការចុះអនុវត្តតាមទីវាល នឹងត្រូវបានរៀបបញ្ចូលរួមមាន៖ ការបណ្តុះបណ្តាល ការវាយតម្លៃជាក់ស្តែង និងការចង់ក្រងជាករណីសិក្សា ដែលរាល់សកម្មភាពទាំងនេះ គឺមានការពាក់ព័ន្ធនឹងកម្មវិធីយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងមានការពាក់ព័ន្ធជាមួយនឹងផ្នែកចម្រុះនៃក្រុមការងារការបន្សាំ។ ក្រុមការងារការបន្សាំនេះ នឹងមានតួនាទី និងឱកាសក្នុងការតាមដាន និងសម្រួលរាល់ការអនុវត្តនិតិវិធីក្នុងការវាយតម្លៃភាពងាយរងគ្រោះ និងការបន្សាំនានា ដែលរៀបរៀង និងអនុម័តដោយក្រុមការងារកម្មវិធីយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនីមួយៗ។ ក្រុមការងារការបន្សាំ ក៏មានតួនាទី

ក្នុងការកំណត់ និងវាយតម្លៃរាល់ឱកាស និងឧបសគ្គដែលកើតមានឡើងក្នុងពេលកំពុងអនុវត្តផង ដែរ។ ដំណើរការខាងលើនេះ នឹងជួយឱ្យមានការកំណត់បង្ហាញពីការយល់ដឹង នឹងតម្រូវការរបស់ក្រសួងនីមួយៗទាំងផ្នែកគោលនយោបាយ រចនាសម្ព័ន្ធ និងនិតិវិធី។

160. សម្រាប់ខេត្តចំនួនពីរ គឺខេត្តបាត់ដំបង និងខេត្តព្រៃវែង ក្រុមការងារការបន្សាំ និងជួយសម្របសម្រួលបន្ថែមក្នុងការរៀបចំការវាយតម្លៃភាពងាយរងគ្រោះ និងការធ្វើផែនការក្នុងការបន្សាំចាប់ពីកិច្ចចាប់ផ្តើម រហូតដល់ចប់នៃវគ្គបណ្តុះបណ្តាល។ ពួកគេនឹងធ្វើការដាក់លាក់លើរចនាសម្ព័ន្ធដែលមានស្រាប់ និងបណ្តាញដែលមានស្រាប់ សម្រាប់រាល់តម្រូវការក្នុងការស្តារឡើងវិញ និង/ឬ ការធ្វើផែនការប្រព័ន្ធដែលទាំងនោះអាចជាប្រយោជន៍សម្រាប់លទ្ធផលនៃការបន្សាំ ដល់ក្រសួងដែលមានការពាក់ព័ន្ធនានា។ ការដោះស្រាយរាល់តម្រូវការនៃការបន្សាំ សម្រាប់រចនាសម្ព័ន្ធដែលមានស្រាប់ គឺជាការផ្តល់នូវការអនុវត្តជាក់ស្តែងមួយ ដល់អ្នកពាក់ព័ន្ធដែលបានចូលក្នុងការបណ្តុះបណ្តាល និងក៏ជាការផ្សារភ្ជាប់ក្រុមជំនាញវិស្វករផងដែរ ដើម្បីស្វែងរកជម្រើសក្នុងការស្តារឡើងវិញ។ បន្ទាប់ពីវគ្គបណ្តុះបណ្តាលខាងលើ ក្រុមការងារការបន្សាំ នឹងធ្វើបានបណ្តុះបណ្តាលសារជាថ្មី ក្រោមយុទ្ធសាស្ត្រ នឹងផែនការដូចខាងលើ។ ប្រព័ន្ធរចនាសម្ព័ន្ធដែលត្រូវវាយតម្លៃ នឹងត្រូវលើកឡើងដោយរដ្ឋាភិបាលថ្នាក់ក្រោមជាតិ នៃខេត្តបាត់ដំបង និងព្រៃវែង ព្រមទាំងមានការចូលរួមពីដៃគូរពាក់ព័ន្ធនានា ដែលផ្តោតសំខាន់លើយន្តការក្នុងការអភិវឌ្ឍ ដែលរួមបញ្ចូលស្ថាប័នពីរ ឬច្រើនជាងនេះ។

161. ការវាយតម្លៃ និងការធ្វើផែនការជាក់ស្តែងតាមទីវាលសម្រាប់កំណត់តំបន់ដែលប្រសើរ និងប្រព័ន្ធដែលជាក់លាក់ គឺនឹងអាចជួយឱ្យក្រុមការងារមើលឃើញពីមុខងារសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- បង្កើតជាកម្មវិធីនៃការកសាងសមត្ថភាពយ៉ាងសំខាន់ និងបង្កើតជាព្រឹត្តិការ និងការចុះអនុវត្តជាក់ស្តែងតាមទីវាល
- ផ្តល់ឱ្យនូវព័ត៌មានក្នុងការវាយតម្លៃ និងការធ្វើផែនការជាមុន ដើម្បីរៀបចំការសិក្សាបឋមចំនួន៦ករណីសិក្សា ដែលជាតម្រូវការ មុនពេលការសេសេរសំណើហិរញ្ញប្បទាន សម្រាប់មូលនិធិក្នុងការបន្សាំ។
- បង្កើតឱ្យមានជាឱកាសសម្រាប់ធ្វើការពិសោធន៍ និងបង្ហាញពីការវាយតម្លៃភាពងាយរងគ្រោះ និងយុទ្ធសាស្ត្រក្នុងការបន្សាំខ្លះៗ ដែលក្រុមការងារបានដាក់ជូនរដ្ឋាភិបាលក្នុងការអនុម័ត។

- ធ្វើការចងក្រងបណ្តាញក្រុមការងារឆ្លងស្ថាប័ន ស្តីពីការឆ្លើយតបនឹងការបន្សាំចម្រុះ និងបង្កើនកិច្ចសហប្រតិបត្តិការឱ្យទូលាយសម្រាប់ភាពធន់ និរន្តរភាពក្នុងការបង្កើតជារចនាសម្ព័ន្ធ និងការអភិវឌ្ឍនានា។

162. ក្រុមការងារការបន្សាំ នឹងតម្រូវឱ្យមានការដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំមួយចំនួនសម្រាប់ការធ្វើការជ្រើសរើសទស្សនៈល្អៗក្នុងការអភិវឌ្ឍរបស់គម្រោង ទៅលើការវាយតម្លៃភាពងាយរងគ្រោះ និងផែនការក្នុងការបន្សាំរបស់ខេត្តទាំងពីរខាងលើ។

## លក្ខខ័ណ្ឌទូទៅ

163. គម្រោងសំខាន់ទាក់ទងនឹងការបន្សាំដែលមានសក្តានុពល គឺត្រូវការលក្ខណៈដូចខាងក្រោម៖
- ធ្វើការគូសបង្ហាញតំបន់ដែលងាយរងគ្រោះនៅក្នុងកម្មវិធីយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដូចមានចែងក្នុងផែនការសកម្មភាពការប្រែប្រួលអាកាសធាតុរបស់ក្រសួង
- គប្បីជាហេដ្ឋារចនាសម្ព័ន្ធដែលមានការអាទិភាពមួយ ឬក៏ជាផ្នែកនៃការអភិវឌ្ឍសម្រាប់ក្រសួងមួយ ឬច្រើន
- លើកកម្ពស់ជំនាញក្នុងការបន្សាំ ដល់បុគ្គលិកផ្នែកបច្ចេកទេសរបស់ក្រសួង
- គប្បីជាផ្នែកមួយដែលសមស្របទៅតាមគោលបំណង និងការគាំទ្រផ្នែកថវិកាពីមូលនិធិអាកាសធាតុបៃតង

## លក្ខខ័ណ្ឌសម្រាប់ថ្នាក់តំបន់

164. គម្រោងសំខាន់ទាក់ទងនឹងការបន្សាំដែលមានសក្តានុពល សម្រាប់ថ្នាក់ក្រោមជាតិ/ថ្នាក់តំបន់ គឺត្រូវការល័ក្ខខ័ណ្ឌដូចខាងក្រោម៖
- ត្រូវមានសក្តានុពល ក៏ដូចជាភាពដែលអាចប្រព្រឹត្តទៅបាន និងបង្ហាញពីភាពជាតំណាងនៃការឆ្លើយតបទៅនឹងការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ
- ធ្វើការគូសបង្ហាញពីតម្រូវការក្នុងការអភិវឌ្ឍ ក៏ដូចជាមានសក្តានុពលខ្ពស់ទាក់ទងនឹងតម្រូវការថ្នាក់តំបន់
- មានព័ត៌មានជាក់លាក់ និងគ្រប់គ្រាន់ដើម្បីជាការវាយតម្លៃហេតុប៉ះពាល់ និងភាពងាយរងគ្រោះ

- តម្រូវឱ្យមានការចូលរួមពីរាល់ការធ្វើផែនការការបន្សុំដោយមានការចូលរួម នឹងមានការចូលរួមចំណែកពីពហុភាគី រាល់កម្មវិធីយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ក្រសួង

165. ការវាយតម្លៃភាពងាយរងគ្រោះ និងដំណើរការក្នុងការធ្វើផែនការបន្សុំ នឹងត្រូវបានប្រើប្រាស់ក្នុងការជម្រុញឱ្យមានផែនការចម្រុះនៃការបន្សុំ ឬក៏ជារបាយការណ៍នៃការសិក្សាវាយតម្លៃពីលទ្ធភាពនៃការអនុវត្តគម្រោង។ ដំណើរការនៃការប្រតិបត្តិ មានដូចជាការវាយតម្លៃភាពងាយរងគ្រោះ និងការរៀបចំផែនការការបន្សុំលើផ្នែកដែលបានកំណត់រួចមកហើយចំពោះការអភិវឌ្ឍ មិនសូម្បីតែគម្រោងដែលមានស្រាប់ និងគំនិតបង្កើតថ្មី នឹងត្រូវបានគូសបង្ហាញពីការវាស់វែងសក្ដានុពលនៃការបន្សុំ ដែលអាចបន្តអភិវឌ្ឍន៍ទៅជាគម្រោងសាកល្បងតូចៗបាន។ ការប្រើប្រាស់នូវលទ្ធផលដែលទទួលបានពីការសិក្សានេះ ក្រុមការងារអាចបង្កើតជាសំណើស្រាវជ្រាវបែបវិទ្យាសាស្ត្រ ដើម្បីទាក់ទាញមូលនិធិដើម្បីអនុវត្តបាន។ ក្នុងនោះផងដែរ គឺមានរបាយការណ៍យ៉ាងហោចណាស់ចំនួន៦ (យ៉ាងហោចណាស់មាន១របាយការណ៍មកពីគ្រប់កម្មវិធីយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ) ទោះបីជារបាយការណ៍ខ្លះត្រូវបានបញ្ចូលទៅក្នុងនិតិវិធីរួមមួយក៏ដោយ។

166. របាយការណ៍ស្រាវជ្រាវបឋម នឹងត្រូវបានផ្ដល់ព័ត៌មានដែលជាតម្រូវការទាំងឡាយ ដើម្បីរៀបចំឱ្យបាននូវគម្រោងចំនួន៥។ គ្រប់កម្មវិធីយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ក្រសួងទាំងអស់នឹងត្រូវបានគាំទ្រក្នុងការដាក់ស្នើយ៉ាងហោចមួយ។ ក្នុងករណីរបស់មូលនិធិអាកាសធាតុបៃតង គឺសំណើសុំដែលមានគម្រោងនៃការបន្សុំចម្រុះ ត្រូវបានលើកទឹកចិត្ត។

167. សម្រាប់ការអនុម័តលើសំណើនីមួយៗ គឺត្រូវបានឯកភាពរបស់មូលនិធិខាងលើ គឺសំណើទាំងនោះត្រូវបានរៀបចំឡើង និងដាក់ជូនដោយតំណាងក្រសួង។ ក្រុមហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសនឹងធ្វើការពិនិត្យថារាល់ក្រសួងដែលមានកម្មវិធីយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ គឺត្រូវបានដាក់សំណើស្រាវជ្រាវឱ្យ ដើម្បីទទួលបានការគាំទ្រផ្សេងៗទាក់ទងការបន្សុំ។ រាល់ឯកសារទាំងអស់ គឺត្រូវបានរៀបចំដោយមានការចុះត្រួតពិនិត្យជាមួយក្រុមការងារនៃការបន្សុំ។

168. តាមរយៈដំណើរការយ៉ាងល្អិតល្អន់ទាំងនេះ គ្រប់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងត្រូវបានកសាងសមត្ថភាព សម្រាប់ការវាយតម្លៃភាពងាយរងគ្រោះ និងរៀបចំផែនការ និងសំណើស្រាវជ្រាវ និងអនុវត្តទៅកាន់មូលនិធិអាកាសធាតុបៃតង។ ដំណើរការទាំងនេះនឹងត្រូវបានបង្ហាញក្នុងរូបភាពទី៥.៥។

169. ផ្នែកហិរញ្ញប្បទានសហប្រតិបត្តការបច្ចេកទេស ដែលមានតម្លៃពីរលានដុល្លារ សម្រាប់ធ្វើការសិក្សា និងស្រាវជ្រាវ ដែលជាកត្តាភ្ជាប់ទៅនឹងការអភិវឌ្ឍ និងបង្ហាញពីការវាស់វែងការបន្សុំ ដែលបង្កើតជាទម្រង់នៃផ្នែកមួយនៃសំណើគម្រោងស្រាវជ្រាវ ដើម្បីដាក់ទៅមូលនិធិអាកាសធាតុសកល។ កំឡុងពេលខែសីហា ដល់កញ្ញា ឆ្នាំ២០១៥ ក្រុមការងារហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស នឹងដាក់ឡើងនូវពេលវេលាជាក់លាក់ក្នុងការអនុវត្តកិច្ចការស្រាវជ្រាវទៅតាមខេត្ត ដែលជាគោលដៅទាំង៦ ដើម្បីធ្វើការស្វែងរកនូវដំណើរការនៃការអនុវត្តល្អក្នុងការបន្សុំ។ ការចុះវាយតម្លៃខាងលើមានគោលបំណងពីរសំខាន់ៗ។ ទីមួយ វាគឺជាឱកាសក្នុងការប្រមូលនូវឧទាហរណ៍ល្អៗ ក្នុងការអនុវត្តការវាស់វែងការបន្សុំក្នុងប្រទេសកម្ពុជា និងធ្វើការចងក្រងទៅជាគោលការណ៍ណែនាំសម្រាប់ដៃគូរបស់ក្រសួងនានា។ ទីពីរ គឺវាជាការផ្តល់ឲ្យនូវភាពជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅ ក្នុងការងារនៃការបន្សុំ និងដាក់ចូលរាល់លទ្ធផលទាំងនោះទៅក្នុងសំណើស្រាវជ្រាវដែលកំពុងរៀបចំ។ មូលនិធិអាកាសធាតុបៃតង ដែលជាឧទាហរណ៍ តម្រូវឲ្យមានជាសក្ខីភាពជាក់លាក់ ដែលថាការវាស់វែងត្រូវបានបង្ហាញ និងលើកកម្ពស់ឱ្យកាន់តែប្រសើរ។

170. រាល់ថវិកាគាំទ្រទាំងនោះ នឹងត្រូវបានប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ លើការវិភាគផ្នែកសេដ្ឋកិច្ច និងការវាយតម្លៃនៃការវាស់វែងការបន្សុំដែលបានដាក់សំណើឡើង ក៏ដូចជាផ្នែកមួយសំខាន់ក្នុងការសម្រួល និងកំណត់ថវិកាគាំទ្រ និងថវិកាសម្រាប់រដ្ឋាភិបាល។

**ក្រាហ្វិច 14៖ ប្រព័ន្ធនៃការវាយតម្លៃចម្រុះក្នុងខេត្តពីរ ដែលជាខេត្តដំបូងក្នុងការអនុវត្តគម្រោង**




## 4.11 ការចូលទៅកាន់មូលនិធិអាកាសធាតុ

171. ក្រោមលទ្ធផលដែលទទួលបានពីផ្នែកទី២ ក្រុមការងារនឹងធ្វើការងារជាមួយក្រុមនៃកម្មវិធីយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ក្រសួង៥ MOE, MOWRAM, MRD, MPWT, និងក្រសួង MAFF ក្នុងការរៀបចំកិច្ចសិក្សាបឋមចំនួន៦ និងធ្វើការរៀបចំសំណើស្រាវជ្រាវចំនួន២ ដើម្បីដាក់ទៅកាន់មូលនិធិអាកាសធាតុសកល។ គោលដៅនេះ គឺមានទិសដៅជាក់លាក់ក្នុងការដាក់សំណើស្រាវជ្រាវទាក់ទងនឹងការបង្កើតក្របខណ្ឌគម្រោង និងការតាមដានត្រួតពិនិត្យ។ សកម្មភាពនេះ គឺជាលទ្ធផលសំខាន់ នងជាការគាំទ្រផ្នែកបច្ចេកទេសសម្រាប់ក្រសួងបរិស្ថាន ក៏ដូចជាភ្នាក់ងារនៃការប្រែប្រួលអាកាសធាតុផងដែរ។ ក្រសួងទាំង៥ ដូចបានបង្ហាញខាងលើ គឺនឹងមិនធ្វើការងារប្រកួតប្រជែងគ្នានោះទេ។ ដើម្បីឱ្យមានភាពប្រសើរឡើង ក្រសួងទាំង៥ខាងលើ នឹងចូលរួមក្នុងការបង្កើតជារបាយការណ៍សិក្សាបឋមទាំង៦ ដែលមានការពាក់ព័ន្ធជាមួយនឹងអាណត្តិរបស់គ្រប់ក្រសួង។

172. ផ្នែកហិរញ្ញប្បទានសហប្រតិបត្តការបច្ចេកទេស នឹងធ្វើការខិតខំគាំទ្រគ្រប់ក្រសួងទាំង៥ ក្នុងការរៀបចំនឹងដាក់សំណើពេញលេញសម្រាប់ការស្រាវជ្រាវ។ សំណើស្រាវជ្រាវអាចមានរហូតដល់ទៅ៥ ឬច្រើនដោយផ្អែកលើកិច្ចសហការរបស់ក្រសួងនីមួយៗ។

173. **កិច្ចសហការរវាងកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា និង GIZ ៖** ដំណើរការនៃការរៀបចំនឹងត្រូវបានអនុវត្ត ដោយមានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងបរិស្ថាន កិច្ចសហការរវាងកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា និង GIZ ដែលជាការគាំទ្រមួយឆ្ពោះទៅកាន់គម្រោងនៃការគាំទ្រយូរអង្វែង សម្រាប់ក្រសួងបរិស្ថាន និង NAP នៅពាក់កណ្តាលឆ្នាំ២០១៥។ គម្រោងទាំងពីរនេះ នឹងផ្តោតសំខាន់លើការកំណត់ថវិកា និងការគាំទ្រថវិកាសម្រាប់ការវាស់វែងការបន្សាំ និងផ្សារភ្ជាប់ជាមួយការវាយតម្លៃផ្នែកសេដ្ឋកិច្ចនៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ កិច្ចពិភាក្សាដំបូង ត្រូវបានធ្វើឡើងរវាង កិច្ចសហការរវាងកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា និង GIZ។ កិច្ចព្រមព្រៀងក្នុងការសហការ គឺត្រូវបានសម្រេច ដោយមានការរួមបញ្ចូលទាំងក្រុមការងារបច្ចេកទេសនៃក្រសួងបរិស្ថាន/កិច្ចសហការរវាងកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា/កម្មវិធីយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដើម្បីជាយានក្នុងការដឹកនាំ និងអនុវត្តរាល់សកម្មភាពផ្សេងៗ។ GIZ នឹងត្រូវបានរាប់បញ្ចូលក្នុងទម្រង់ការនៃការសហការ នៅពេលដែលក្រុមការងាររបស់ខ្លួនបានចុះមូលដ្ឋានរួចរាល់។

174. **ការគាំទ្រមូលនិធិ៖** សកម្មភាពដំបូងនៃកិច្ចការងារអនុវត្ត គឺការរៀបចំក្រុមការងារជំនាញរបស់ក្រសួងបរិស្ថានក្នុងទម្រង់ជាផ្នែកសង្ខេបលើមូលនិធិការប្រែប្រួលអាកាសធាតុសម្រាប់ជាការចែករំលែកទៅកាន់ផ្នែកពាក់ព័ន្ធ ក្នុងការប្រើប្រាស់ក្នុងវគ្គបណ្តុះបណ្តាល។ ទម្រង់សម្រាប់សេចក្តីសង្ខេបទាំងនោះនឹងត្រូវបានបង្ហាញក្នុងឧបសម្ព័ន្ធ៧។ មូលនិធិដែលនឹងត្រូវគាំទ្រគឺរួមមាន៖

- មូលនិធិអាកាសធាតុបៃតង៖ គម្រោងខ្នាតតូច/ចាប់ពី១០លានដុល្លារ និងគម្រោងខ្នាតធំគឺមានតម្លៃចាប់ពី២៥០លានដុល្លារ
- មូលនិធិវិនិយោគអាកាសធាតុ៖ គម្រោងខ្នាតតូច/ចាប់ពី១លានដុល្លារ និងគម្រោងខ្នាតធំគឺមានតម្លៃចាប់ពី៥០លានដុល្លារ
- មូលនិធិការបន្សាំ៖ គម្រោងខ្នាតតូច/ចាប់ពី១លានដុល្លារ និងគម្រោងខ្នាតធំគឺមានតម្លៃចាប់ពី១០លានដុល្លារ

- សម្ព័ន្ធភាពការប្រែប្រួលអាកាសធាតុសកលៈ គម្រោងខ្នាតតូច/ចាប់ពី១០លានដុល្លារ និងគម្រោងខ្នាតធំគឺមានតម្លៃចាប់ពី២៥០លានដុល្លារៈ សម្ព័ន្ធមូលនិធិអាកាសធាតុសហភាពអ៊ឺរ៉ុប ចូលរួមតាមរយៈរដ្ឋជាសមាជិក EU មូលនិធិការអភិវឌ្ឍសហភាពអ៊ឺរ៉ុប និងការជួយជាមូលនិធិលឿនៗ
- មូលនិធិបរិស្ថានពិភពលោកៈ គម្រោងខ្នាតតូច/ចាប់ពី១លានដុល្លារ និងគម្រោងខ្នាតធំគឺមានតម្លៃចាប់ពី៥០លានដុល្លារ
- សហប្រជាជាតិ- ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងរេចរិលព្រៃឈើៈ មូលនិធិដែលចេញពីការគាំទ្រទ្វេរ និងពហុភាគីផ្សេងៗ។

175. សម្រាប់សំណើគម្រោងនៃការបន្សាំ ក្រុមការងារហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសនឹងធ្វើការផ្តោតសំខាន់លើ មូលនិធិអាកាសធាតុបៃតង ជាមួយនឹងតម្លៃចាប់ពី ៣០ ទៅ ៥០ លានដុល្លារ។

176. **តម្រូវការសម្រាប់នីតិវិធីយុទ្ធសាស្ត្រៈ** នីតិវិធីនៃការសហការចំណោមរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា គឺជាផ្នែកមួយសំខាន់ក្នុងការស្វែងរកការគាំទ្រថវិកានៃការបន្សាំ ពីព្រោះតម្រូវការទាំងនោះ គឺជាការចំបាច់ក្នុងការជម្រុញគាំទ្ររដ្ឋាភិបាលឱ្យខិតខំដឹកនាំ និងសម្រួលជាកម្រិតផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ។ រហូតមកទល់ពេលបច្ចុប្បន្ន ការចូលខ្លួនទៅកាន់មូលនិធិអាកាសធាតុ គឺត្រូវបានចូលរួមក្រោមការដឹកនាំពីម្ចាស់ជំនួយ។ នីតិវិធីសម្រាប់មូលនិធិបរិស្ថានពិភពលោក ដែលក្រសួងបរិស្ថានបានស្នើទៅកាន់ភ្នាក់ងារកំពុងប្រតិបត្តិ ដើម្បីដាក់បញ្ចូលទៅក្នុងគម្រោង និងបន្ទាប់មកគឺនឹងដាក់រួមបញ្ចូលគ្នាជាកញ្ចប់រួម ដែលអាចជាកម្មវិធីគំរូ ដែលអាចអនុវត្តតាមបាន។ សម្រាប់ការប្រែប្រួលអាកាសធាតុ មូលនិធិដែលធំជាងគេ គឺមូលនិធិអាកាសធាតុបៃតង ដែលមានប្រមាណជា ២០ ទៅ ៤០លានដុល្លារសម្រាប់ការអនុវត្តក្នុងប្រទេសកម្ពុជា។ GIZ មានគោលបំណងក្នុងការរៀបចំយុទ្ធសាស្ត្រផែនការហិរញ្ញវត្ថុថ្នាក់ជាតិ និងជួយក្រសួងបរិស្ថានឱ្យក្លាយទៅជាអាជ្ញាធរចាត់តាំងថ្នាក់ជាតិសម្រាប់មូលនិធិអាកាសធាតុបៃតង។ កញ្ចប់ចុងក្រោយសម្រាប់ដាក់សំណើទៅកាន់មូលនិធិអាកាសធាតុបៃតង គឺនឹងត្រូវបានត្រួតពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពថ្មី ដោយក្រសួងបរិស្ថានជាអ្នកដឹកនាំស្តីទី។

177. **ផ្នែកឥណទាន និងពេលវេលានៃការដាក់សំណើៈ** ដំណើរការនេះត្រូវការចំណាយពេលវេលាយ៉ាងហោចណាស់ពីរឆ្នាំដើម្បីបំពេញឱ្យរួចរាល់នូវសំណើនៃការដាក់ចូលនៃមូលនិធិអាកាសធាតុបៃតង ដែលពេលវេលាពីរឆ្នាំនេះគឺជារយៈពេលល្អក្នុងការរៀបចំកញ្ចប់នៃមូលនិធិអាកាសធាតុបៃតងនេះ។ មូលនិធិការបន្សាំក៏តម្រូវឲ្យមានការដាក់ចូលផងដែរ ដែលវាជាដំណើរការមួយដ៏វែង ដែលមិនចាំបាច់

មានការទាក់ទងក្នុងការគាំទ្ររដ្ឋាភិបាល ក្នុងការបំពេញតម្រូវការរបស់មូលនិធិ។ ចាត់តាំងពីមូលនិធិអាកាសធាតុបៃតងត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៦ ក្រសួងបរិស្ថានគឺត្រូវការការគាំទ្រយ៉ាងចាំបាច់ក្នុងការបង្កើតឡើងនូវកម្មវិធីសម្រាប់ឆ្នាំ២០១៧។ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ជាអ្នកគ្រប់គ្រងមូលនិធិសម្រាប់ USAID និង Nordic Development Fund ដែលនឹងផ្តល់ជាមូលនិធិជាក់លាក់ និងឱកាសក្នុងការដាក់សំណើសុំខ្នាតតូចផ្សេងៗ។

178. ក្នុងកំឡុងពេលនៃការដាក់បញ្ចូលសម្រាប់មូលនិធិអាកាសធាតុបៃតង និងដំណាក់កាលនៃការដាក់សំណើផ្សេងៗទៀត គឺប្រហែលជាត្រូវការពេលយ៉ាងហោចណាស់៣ឆ្នាំ។ ដំណើរការនៃការដាក់បញ្ចូលនេះ គឺត្រូវការការគាំទ្រដែលមិនបានគិតទុកជាមុនសម្រាប់ការជួយជាបច្ចេកទេសរបស់ MCRDP។ ក្រុមហិរញ្ញប្បទានសហប្រតិបត្តការបច្ចេកទេសនឹងធ្វើការពិភាក្សាជាមួយ GIZ និងកម្មវិធីសម្ព័ន្ធភាពការប្រែប្រួលអាកាសធាតុកម្ពុជា ទៅលើឱកាសនៃការគាំទ្រផ្នែកថវិកាក្នុងការដាក់បញ្ចូលនូវសំណើខាងលើ។

179. **ការសិក្សាវាយតម្លៃពីលទ្ធភាពនៃការអនុវត្តគម្រោងការបន្សាំ៖** កម្មវិធីយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស នឹងត្រូវបានដាក់បញ្ចូល និងពាក់ព័ន្ធជាមួយក្រសួងបណ្តាញជាច្រើនដែលទាក់ទងជាមួយនឹងការវាយតម្លៃភាពងាយរងគ្រោះ និងការធ្វើផែនការក្នុងតំបន់គោលដៅទាំងអស់ ក៏ដូចជាមូលដ្ឋានគ្រឹះមួយសម្រាប់ការសិក្សាវាយតម្លៃពីលទ្ធភាពរបស់គម្រោង និងការបង្កើតជាសំណើសម្រាប់ការបន្សាំ។ ការវាយតម្លៃចំនួន៦ និងដំណើរការនៃការធ្វើផែនការ គឺនឹងធ្វើការកសាងសមត្ថភាពទាំងថ្នាក់ជាតិ និងថ្នាក់តំបន់ ព្រមទាំងធ្វើការសម្របសម្រួលឱ្យទៅជានិតិវិធីចម្រុះនៃការបន្សាំមួយក្នុងការបង្កើតគម្រោង។

180. **ការវាយតម្លៃត្រួតពិនិត្យតាមដាន និងការការតម្លៃប៉ាន់ប្រមាណសេដ្ឋកិច្ច៖** ការពិភាក្សាដំបូងត្រូវបានធ្វើឡើងជាមួយកម្មវិធីសម្ព័ន្ធភាពការប្រែប្រួលអាកាសធាតុកម្ពុជា ដើម្បីជាការសហការក្នុងការវាយតម្លៃតាមដានសេដ្ឋកិច្ច ដោយភ្ជាប់ទៅកាន់ការសិក្សាវាយតម្លៃពីភាពដែលអាចទៅបានរបស់គម្រោង ហើយការធ្វើការងារជាមួយកម្មវិធីសម្ព័ន្ធភាពការប្រែប្រួលអាកាសធាតុកម្ពុជា គឺត្រូវបានផ្តួចផ្តើមឡើងជាមួយ MAFF និង MPWT។ ការពិភាក្សាលម្អិតផ្សេងៗទៀត គឺជាតម្រូវការចាំបាច់ដើម្បីកំណត់ឲ្យមានការសហការល្អជាមួយការរៀបចំរាល់ការវាយតម្លៃទាំងនេះ។ ក្នុងដំណាក់កាលនេះ ក្រុមការងារហិរញ្ញប្បទានសហប្រតិបត្តការបច្ចេកទេស គឺមិនត្រូវបានរាប់បញ្ចូលក្រុមជំនាញផ្នែកសេដ្ឋកិច្ចនោះទេ។

## 4.12 ការកសាងសមត្ថភាព

### *4.12.1 គោលការណ៍សម្រាប់ការកសាងសមត្ថភាព*

181. ក្នុងការលើកកម្ពស់សមត្ថភាពបុគ្គលិក ក្រុមការងារបានរៀបចំយុទ្ធសាស្ត្រផែនការជាច្រើន ដូចខាងក្រោម៖

I. **គាំទ្រវាល់ការអនុវត្តរបស់ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុរបស់ក្រសួងនីមួយៗ៖** ក្រសួងសំខាន់ៗ ក្រសួងផ្សេងៗដែលមានកម្មវិធីយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងភ្នាក់ងារពាក់ព័ន្ធ គឺចាំបាច់ត្រូវមានផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ។ មាតិកា គឺចាំបាច់បរិយាយអំពីភាពទូទៅ និងក្នុងគោលបំណងបង្ហាញអំពីការបន្សាំ ដូចដែលផ្នែកខ្លះមិនត្រូវបានរាប់បញ្ចូលក្នុងទស្សនទាននៃការអភិវឌ្ឍនោះទេ។ ការអនុវត្តរបស់ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ គឺត្រូវផ្តល់ឲ្យមានលក្ខណៈជាប្រព័ន្ធលម្អិត ប្រកបដោយជំនាញ និងមានឯកសារគ្រប់គ្រាន់ ដែលបញ្ជាក់ពីបញ្ហាអាកាសធាតុ។ ផែនការសកម្មភាពទាំងនោះ គឺត្រូវបានចាប់ផ្តើមពីចំណុចសមស្របមួយ ដើម្បីកំណត់ឲ្យបាននូវរាល់ការអភិវឌ្ឍផ្នែកសមត្ថភាព។

II. **ការធ្វើការងារជាមួយក្រុមការងារប្រែប្រួលអាកាសធាតុតាមក្រសួងនីមួយៗ៖** ក្រុមការងារការប្រែប្រួលអាកាសធាតុតាមក្រសួងនីមួយៗ គឺត្រូវបានបង្កើតឡើងដើម្បីអនុវត្តរាល់ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ ធ្វើការយ៉ាងម៉ត់ចត់ និងយកចិត្តទុកដាក់លើការងារនៃការប្រែប្រួលអាកាសធាតុ និងមានតំណាងបីនាក់មកពីក្រុមការងារប្រែប្រួលអាកាសធាតុ ត្រូវបានចូលរួមក្នុងក្រុមការងារបន្សាំកម្មវិធីយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ដូចដែលជំនាញ និងការយល់ដឹងរបស់ក្រុមខាងលើត្រូវបានពង្រឹង និងពង្រីក ក្រុមងារងារខាងលើ និងតម្រូវឱ្យមានការចូលរួមក្នុងការបណ្តុះបណ្តាល និងការអភិវឌ្ឍជំនាញក្នុងក្រុមធំមួយដែលមានសមាជិកពីគ្រប់ក្រសួងពាក់ព័ន្ធ។

III. **ការផ្តោតសំខាន់លើក្រសួងចំនួន៥ ប៉ុន្តែត្រូវបានរួមបញ្ចូលដំណាងពីគ្រប់ក្រសួងក្នុងគណៈកម្មការសម្របសម្រួលកម្មវិធីយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ៖** ខណៈពេលដែលការផ្តោតសំខាន់លើក្រសួងដែលទទួលខុសត្រូវផ្នែកធនធានទឹក កសិកម្ម និងផ្លូវថ្នល់ និងរចនាសម្ព័ន្ធជនបទ ព្រមទាំងក្រសួងសាម៉ី គឺក្រសួងបរិស្ថាន និងក្រសួងដែលធ្វើការលើកម្មវិធីយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ គឺសុទ្ធសឹងតែមានការចូលរួមចំណែកយ៉ាងសំខាន់ក្នុងរាល់

ដំណើរការនៃការអភិវឌ្ឍផ្សេងៗគ្នា។ គ្រប់ក្រសួងទាំងនោះនឹងត្រូវបានរាប់បញ្ចូលក្នុងសកម្មភាពហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស ឧទាហរណ៍ក្រុមការងារការបន្សាំវិធីយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដែលនឹងត្រូវចូលរួមក្នុងកម្មវិធីទស្សនកិច្ចសិក្សា និងវាយតម្លៃភាពងាយរងគ្រោះ ព្រមទាំងសកម្មភាពក្នុងការបណ្តុះបណ្តាល និងសិក្ខាសាលាក្នុងការលើកកម្ពស់ចំណេះដឹងជាដើម។ ក្នុងនោះដែរ វាគឺជាការចាំបាច់ និងសំខាន់ណាល់ក្នុងការអនុវត្តការប្រជុំពិភាក្សាតុមូលជាមួយក្រសួង ដែលមានការពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាភាពធន់នឹងអាកាសធាតុក្នុងក្រសួងនីមួយៗ។ ជាមួយគ្នានោះផងដែរ ក្រសួងមួយចំនួនដូចជាក្រសួងកិច្ចការនារី និង NCDD គឺមានរួចហើយនូវគោលការណ៍ណែនាំ បទពិសោធន៍ និងការរៀបចំស្ថាប័នសម្រាប់អនុវត្តន៍លើគម្រោងការប្រែប្រួលអាកាសធាតុ និងធ្លាប់បានផ្តល់ព័ត៌មានដល់ក្រសួងមន្ទីរពាក់ព័ន្ធជាច្រើនផងដែរ។

IV. **គោលដៅ និងការអភិវឌ្ឍការកសាងសមត្ថភាពឆ្ពោះទៅកាន់តម្រូវការជាក់លាក់នៅតាមក្រសួង និងនាយកដ្ឋានរបស់ខ្លួន៖** នេះគឺមិនមែនជាយុទ្ធសាស្ត្រមួយដែលសមស្របសម្រាប់គ្រប់ស្ថាប័ននោះទេលើការងារទាក់ទងនឹងភាពធន់នឹងអាកាសធាតុ។ ផ្ទុយទៅវិញ គឺមានវិធីសាស្ត្រច្រើនដើម្បីយកមកធ្វើការអនុវត្ត ជាក់ស្តែងការត្រួតពិនិត្យលម្អិត ការវាយតម្លៃភាពងាយរងគ្រោះ និងការធ្វើផែនការបន្សាំជាដើម។ ប៉ុន្តែគ្រប់ការដាក់ឱ្យមានការអនុវត្តទាំងនោះ គឺត្រូវឱ្យមានការសមស្របតាមលទ្ធភាព និងតម្រូវការរបស់ក្រសួងនីមួយៗផងដែរ។ ដើម្បីឱ្យដំណើរការកាន់តែប្រសើរ គឺតម្រូវឱ្យមានការយល់ច្បាស់អំពីដំណើរការមុខងារ និងកម្មវិធីលម្អិតតាមផ្នែករដ្ឋបាលនីមួយៗ ដើម្បីជានាឱ្យមានការអនុវត្តល្អលើយុទ្ធសាស្ត្រនៃភាពធន់នឹងអាកាសធាតុ។

V. **វិធីសាស្ត្រក្នុងការបណ្តុះបណ្តាលផ្សេងៗ និងការយល់ដឹងដោយការចុះអនុវត្តផ្ទាល់៖** វិធីសាស្ត្រមួយដែលល្អបំផុតសម្រាប់ការអភិវឌ្ឍសមត្ថភាពនោះ គឺការអភិវឌ្ឍតាមរយៈបទពិសោធន៍ជាក់ស្តែងដែលធ្លាប់បានធ្វើកន្លងមក ក៏ដូចជាការធ្វើផែនការស្ថានភាពផ្សេងៗជាដើម។ ជាក់ស្តែងដូចជាតាមរយៈការវាយតម្លៃហេដ្ឋារចនាសម្ព័ន្ធចម្រុះតាមបណ្តាលខេត្តនីមួយៗ។ បទពិសោធន៍ទាំងអស់នេះនឹងធ្វើឱ្យវិធីសាស្ត្រនៃការកសាងសមត្ថភាពនេះមានភាពកាន់តែប្រសើរឡើង ដើម្បីជាការឆ្លើយតបតាមតម្រូវការជាក់ស្តែង។ ក្នុងនោះផងដែរ វាក៏ជាកត្តាជម្រុញមួយផងដែរសម្រាប់ការផ្តល់ជាអនុសាសន៍ផ្នែកគោលនយោបាយ ក៏ដូចជាគោលការណ៍ណែនាំផ្សេងៗ។

### *4.12.2 និតិវិធី ៧S*

182. កម្មវិធីយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងហិរញ្ញប្បទានសហប្រតិបត្តការបច្ចេកទេស គឺផ្តោតសំខាន់លើការបញ្ចៀបភាពធន់នៃអាកាសធាតុទៅក្នុងផ្នែកនិមួយៗក្នុងប្រទេសកម្ពុជា ដូចជា ធនធានទឹក កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ ដែលមានផ្នែកដឹកជញ្ជូន (តាមបណ្តាលខេត្ត និងផ្លូវថ្នល់) និងការអភិវឌ្ឍជនបទ (ការផ្គត់ផ្គងទឹក និងអនាម័យ ជាដើម)។

183. ការឆ្លើយតបជាធម្មតាសម្រាប់ការវាយតម្លៃតម្រូវការសមត្ថភាពគឺការកំណត់ពីជំនាញ និងការគាំទ្របច្ចេកទេសដែលមន្ត្រីតាមវិស័យនីមួយៗត្រូវការ- នោះគឺអ្វីដែលជាចន្លោះប្រហោងនៃចំណេះដឹងឥរិយាបទ និងការអនុវត្ត។ ហើយបន្ទាប់មកចន្លោះប្រហោងទាំងនេះត្រូវបានដោះស្រាយតាមរយៈ មគ្គុទេសក៍ និងសៀវភៅណែនាំ និងតាមរយៈការបណ្តុះបណ្តាលជំនាញដោយការអនុវត្តផ្ទាល់។ ការសន្មតដ៏សាមញ្ញ គឺថាប្រសិនបើមន្ត្រីបានបណ្តុះបណ្តាលនូវជំនាញទាំងនោះរួចហើយ នោះការកសាងភាពធន់អាកាសធាតុដែលបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ និងគម្រោងនានា នឹងត្រូវបានអនុវត្តជាធម្មតានៅតាមវិស័យនីមួយៗ។

184. ក៏ប៉ុន្តែ យុទ្ធសាស្ត្របញ្ជ្រាបភាពធន់អាកាសធាតុ វាលើសពីអ្វីដែលជាការផ្តល់វគ្គបណ្តុះបណ្តាលដល់មន្ត្រី។ ជាញឹកញាយ វិស័យនីមួយៗ តែងមានឧបសគ្គផ្នែកគ្រប់គ្រងស្ថាប័ន និងគោលនយោបាយក្នុងការកសាងភាពធន់អាកាសធាតុដែលអាចជាផ្នែកដ៏សំខាន់ក្នុងដាក់កំហិតទៅលើសមត្ថភាពរបស់បុគ្គលម្នាក់ៗ។ សកម្មភាពសំខាន់មួយនៅក្នុងអំឡុងពេលនៃដំណាក់កាលចាប់ផ្តើម ការវិភាគដែលមានលក្ខណៈជាប្រព័ន្ធទៅលើសមត្ថភាពរបស់ស្ថាប័នជាតិតាមវិស័យនីមួយៗ ត្រូវបានប្រើប្រាស់ដើម្បីបង្កើតជាទំនាក់ទំនងការងាររវាងស្ថាប័នជាដៃគូឲ្យបានរឹងមាំ ដើម្បីលើកកំពស់ការយល់ដឹងពីបញ្ហា និងសមត្ថភាពដែលជាតម្រូវការសម្រាប់ការបន្សាំ និងដើម្បីកសាងផែនការឆ្លើយតប និងផ្តោតចំគោលដៅយ៉ាងល្អសម្រាប់ការអនុវត្តគម្រោងជំនួយបច្ចេកទេស។

185. ក្រុមការងារជំនួយបច្ចេកទេស(TA) បានបង្កើតក្របខណ្ឌវិភាគដើម្បីវាយតម្លៃសមត្ថភាពស្ថាប័នដែលគេដឹងថា វាគឺជាក្របខណ្ឌ ៧អេស[6] ដែលមានប្រាំពីរផ្នែកសម្រាប់សមត្ថភាពស្ថាប័ន។ ការវាយតម្លៃតម្រូវសមត្ថភាពត្រូវបានដាក់ដោយឡែកនៅក្នុងឧបសម្ព័ន្ធ ៨។

1. យុទ្ធសាស្ត្រ – ទិសដៅ និងវិសាលភាពរបស់ស្ថាប័នរយៈពេលវែង
   a. មានផែនការយុទ្ធសាស្ត្រ និងសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុតាមវិស័យ និងការអនុវត្តផែនការយុទ្ធសាស្ត្រ និងសកម្មភាពដែលបានអនុម័ត ។
2. រចនាសម្ព័ន្ធ –ទំនាក់ទំនងជាមូលដ្ឋានរបស់ស្ថាប័នដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រ និងសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុ
   a. ការសម្របសម្រួលការប្រែប្រួលអាកាសធាតុក្នុងក្រសួង
   b. កំណត់តួនាទី និងការទទួលខុសត្រូវលើផ្នែកការប្រែប្រួលអាកាសធាតុក្នុងក្រសួង
3. ប្រព័ន្ធ – នីតិវិធីផ្លូវការ និងមិនផ្លូវការដែលគាំទ្រយុទ្ធសាស្ត្រ និងរចនាសម្ព័ន្ធការប្រែប្រួលអាកាសធាតុ
   a. នីតិវិធី ដំណើរការ និងទង្វើជាទម្លាប់ដែលសំគាល់ថាតើ ការងារការប្រែប្រួលអាកាសធាតុគួរធ្វើយ៉ាងដូចម្តេចដូចជា៖ ប្រព័ន្ធហិរញ្ញវត្ថុ ការជ្រើសរើសមន្ត្រី ការតែងតាំង និងការវាយតម្លៃការអនុវត្តប្រព័ន្ធព័ត៌មាន និងប្រព័ន្ធថវិការ។
   b. ការត្រួតពិនិត្យ និងតាមដានភាពធន់អាកាសធាតុ
   c. ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ
4. បែបបទ –តើប្រធានគាំទ្រការអនុវត្តផែនការសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុយ៉ាងដូចម្តេច
   a. ការយល់ដឹងពីភាពធន់អាកាសធាតុ និងការគាំទ្ររបស់មន្ត្រីជាន់ខ្ពស់ (ឬប្រធាន)

---

[6] យកតាម Stephen, P. and Triraganon, R. (2009) *ការពង្រឹងសម្លេងដើម្បីជម្រើសកាន់តែប្រសើរឡើង: ដំណើរការវាយតម្លៃតម្រូវការសមត្ថភាព។* អង្គការ IUCN, Gland, ប្រទេសស្វីស។ កំណត់សំគាល់ថា Sទី៧ ត្រូវបានចុះបញ្ជីថាជា ៉តម្លៃបានចែករំលែក៉ ។ ក្រុមការងារ បានផ្លាស់ប្តូរផ្នែកនៃសមត្ថភាពនេះទៅជា ៉ការគាំទ្រ៉ វិញ។

5. មន្ត្រី ឬបុគ្គលិក – ធនធានមនុស្សរបស់ស្ថាប័ន និងថាតើមន្ត្រី/បុគ្គលិកមានការអភិវឌ្ឍន៍ បណ្ដុះបណ្ដាល និងបានលើកទឹកចិត្តយ៉ាងដូចម្ដេច

a. សមត្ថភាពមន្ត្រី/បុគ្គលិកដែលជាតម្រូវការសម្រាប់អនុវត្តន៍ផែនការសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុ

b. មន្ត្រី/បុគ្គលិកជំនាញ

c. ការបរិយាយអំពីការងារ

6. ជំនាញ – សមត្ថភាព និងសមត្ថកិច្ចផ្នែកភាពធន់អាកាសធាតុនៅក្នុងក្រសួង និងនាយកដ្ឋានចំណុះក្រសួង

a. ជំនាញដែលត្រូវការសម្រាប់អនុវត្តផែនការសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុ

b. ជំនាញដែលត្រូវការសម្រាប់បង្កើតគម្រោងភាពធន់ការប្រែប្រួលអាកាសធាតុ

7. ការគាំទ្រ – ការគ្រប់គ្រងចំណេះដឹង ទិន្នន័យ មគ្គុទេសក៍ និងសៀវភៅណែនាំដែលបានផ្ដល់ឱ្យសម្រាប់ការគាំទ្រដល់មន្ត្រីក្នុងការអនុវត្តផែនការសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុ

(i) សៀវភៅណែនាំ មគ្គុទេសក៍ និងឧបករណ៍

(ii) ទិន្នន័យការប្រែប្រួលអាកាសធាតុ ផែនទី និងប្រភពព័ត៌មាន

186. រចនាសម្ព័ន្ធនេះត្រូវបានប្រើប្រាស់ធ្វើជាក្របខណ្ឌដើម្បីណែនាំការវាយតម្លៃស្ដីពីការវាយតម្លៃតម្រូវការសមត្ថភាពផ្នែកការប្រែប្រួលអាកាសធាតុនៅកម្ពុជាដែលបានធ្វើពីមុន និងដើម្បីធ្វើការវាយតម្លៃតម្រូវការសមត្ថភាពយ៉ាងលម្អិតមួយសម្រាប់គោលដៅបញ្ជ្រាបភាពធន់អាកាសធាតុទៅក្នុងក្រសួងអនុវត្តកម្មវិធី SPCR សំខាន់ៗ។ យើងបានរៀបចំផែនការ និងវិធីសាស្ត្រពង្រឹងសមត្ថភាពសម្រាប់ SPCR TA ដើម្បីដោះស្រាយពីតម្រូវការដែលបានកំណត់តាមរយៈការវាយតម្លៃ។

## *4.12.3 វិធីសាស្ត្រដែលប្រើសម្រាប់ការវាយតម្លៃតម្រូវការសមត្ថភាពឲ្យចំគោលដៅ*

187. វិធីសាស្ត្រដែលប្រើសម្រាប់ការវាយតម្លៃតម្រូវការសមត្ថភាពបានដកចេញពីការសិក្សាមុនៗរួមមាន៖ ការសិក្សារបស់ Hatfield ក្នុងឆ្នាំ២០១៤ និងការសិក្សាផ្សេងៗទៀតដែលបានសិក្សាសម្រាប់នាយកដ្ឋានការប្រែប្រួលអាកាសធាតុ CCD និងសម្ព័ន្ធភាពការប្រែប្រួលអាកាសធាតុកម្ពុជា CCCA ។ ការសិក្សាថ្មីៗទាំងនោះបានផលិតចេញនូវរបាយការណ៍ទូទៅមួយដែលបង្ហាញពីកង្វះខាតនូវសមត្ថភាពក្នុងការបញ្ជ្រាបភាពធន់អាកាសធាតុ ជាជាងបង្ហាញពីតម្រូវការការបណ្ដុះបណ្ដាលឲ្យចំគោលដៅ។

188. សម្រាប់ TA នេះ យើងបានប្រើប្រាស់វិធីសាស្ត្រវាយតម្លៃសមត្ថភាពស្ថាប័នទាំងមូលដើម្បីបញ្ជ្រាបភាពធន់អាកាសធាតុ ដោយប្រើប្រាស់នូវប្រព័ន្ធ7S សម្រាប់ធ្វើការវិភាគ។ យើងបង្កើតបញ្ជីសំនួរដែលមាន ៣០ សំនួរ គ្រប់ដណ្តប់នូវទិដ្ឋភាពទាំងអស់នៃផ្នែកនីមួយៗនៃសមត្ថភាពស្ថាប័ន និងធ្វើការដាក់ពិន្ទុះពី 0 ទៅដល់ ១០ (គ្មាន– តិចតួច– មួយចំនួន– ពេញលេញ)។ សំនួរមួយចំនួនបង្កើតឡើងដើម្បីគ្រប់ដណ្តប់លើសូចនាករឲ្យដូចគ្នាទៅនឹងសូចនាករដែលប្រើនៅក្នុងប្រព័ន្ធត្រួតពិនិត្យ និងរាយការណ៍ប្រចាំឆ្នាំរបស់មូលនិធិវិនិយោគអាកាសធាតុ(CIF) ដូច្នេះការវាយតម្លៃលើតម្រូវការសមត្ថភាព និងការខិតខំត្រួតពិនិត្យ និងវាយតម្លៃអាចត្រូវបានដាក់បញ្ចូលជាមួយគ្នា។

189. សំនួរទាំងនេះត្រូវបានប្រើប្រាស់សម្រាប់ក្រសួងសំខាន់ៗទាំងប្រាំ និងក្រសួងដែលគាំទ្រកម្មវិធី SPCR ទាំងប្រាំមួយ ដើម្បីធ្វើការវាយតម្លៃខ្លួនឯងនៅក្នុងអំឡុងពេលនៃកិច្ចប្រជុំតុមូល។ ភស្តុតាងនៃការជជែកពិភាក្សាលើការដាក់ពិន្ទុះសម្រាប់វាយតម្លៃខ្លួនឯងនៅក្នុងកិច្ចប្រជុំតុមូលទាំងអស់ វាមានសារៈសំខាន់ណាស់ពីព្រោះវាបានផ្តល់នូវហេតុផលសម្រាប់ការដាក់ពិន្ទុ: និងកំណត់វិសាលភាពសម្រាប់ដោះស្រាយតម្រូវការសមត្ថភាព។ បន្ទាប់ពីកិច្ចប្រជុំតុមូល ភស្តុតាង និងតារាងពិន្ទុះទាំងអស់ត្រូវបានបូកសរុបបញ្ចូលដោយក្រុមការងារ ហើយបន្ទាប់មកត្រូវបានធ្វើការត្រួតពិនិត្យឡើងវិញដោយក្រសួងនីមួយៗដើម្បីកំណត់ពីភាពត្រឹមត្រូវនៃលទ្ធផលនោះ ។

190. លទ្ធផលនៃការដាក់ពិន្ទុះទាំងនោះ ត្រូវបានបង្ហាញនៅក្នុងដ្យាក្រាមសំបុកពីងពាងសម្រាប់ក្រសួងនីមួយៗ ។ រូបភាព ៤.១១ បង្ហាញពីពិន្ទុះជាមធ្យមសម្រាប់ក្រសួងទាំងប្រាំ។ ពិន្ទុះសម្រាប់ក្រសួងនីមួយៗ ត្រូវបានវិភាគនៅក្នុងរបាយការណ៍ការវាយតម្លៃតម្រូវការសមត្ថភាពក្នុងទម្រង់ជាឧបសម្ព័ន្ធទី ៨ នៅក្នុងរបាយការណ៍ចាប់ផ្តើមនេះ។ សមិទ្ធិផលនៃការវាយតម្លៃតម្រូវការសមត្ថភាពរបស់ក្រសួងកសិកម្មដែលបានធ្វើឡើងនៅក្នុងកិច្ចប្រជុំតុមូលត្រូវបានបង្ហាញនៅក្នុងប្រអប់ ៤.២។

**ក្រាហ្វិច 15៖ សំបុកពីងពាងសរុបពិន្ទុះជាមធ្យម 7S សម្រាប់ក្រសួងសំខាន់ទាំងប្រាំ**



191. ការវិភាគ 7S មានគោលបំណងជាច្រើនៈ

(i) ការវិភាគ 7S វាអាចកំណត់បាននូវចំណុចខ្លាំង និងចំណុចខ្សោយនៃសមត្ថភាពស្ថាប័ន ។ ការរួមបញ្ចូលក្របខណ្ឌនេះ និងការ ពិនិត្យឯកសារយុទ្ធសាស្ត្រសំខាន់ៗដូចជា ផែនការសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុ(CCAPs) របស់ក្រសួងនីមួយៗ បានហុចជាលទ្ធផលសម្រាប់ធ្វើផែនការកសាងសមត្ថភាពដែលឆ្លើយតបទៅនឹងការផ្លាស់ប្តូរសមត្ថភាពស្ថាប័ន និងជំនាញនានាដែលពាក់ព័ន្ធ។

(ii) វាផ្តល់ជាវិធានការវាយតម្លៃសមត្ថភាពដោយខ្លួនឯងមួយដែលអាចប្រើប្រាស់សម្រាប់តាមដានពីវឌ្ឍនភាព។ ជាឧទាហរណ៍ ការប្រើប្រាស់ពិន្ទុៈសម្រាប់សំនួរ 7s ផ្តល់ជាទិន្នន័យមូលដ្ឋាន។ ការធ្វើលំហាត់អនុត្តន៍ដដែលៗដូចគ្នានេះនៅពាក់កណ្តាល និងចុងបញ្ចប់គម្រោង វានឹងផ្តល់ឱ្យយើងនូវសូចនាករត្រួតពិនិត្យ និងវាយតម្លៃដ៏ល្អមួយសម្រាប់ឆ្លុះបញ្ចាំងពី សមត្ថភាពស្ថាប័នដែលត្រូវបានធ្វើការពង្រឹង។

(iii) លទ្ធផលនឹងត្រូវបានប្រើប្រាស់ផងដែរ ដើម្បីធ្វើជាកស្តុតាងសម្រាប់តម្រូវការធ្វើរបាយការណ៍ប្រចាំឆ្នាំរាយការណ៍ជូនមូលនិធិវិនិយោគអាកាសធាតុ CIF។

192. របាយការណ៍ការវាយតម្លៃតម្រូវការសមត្ថភាពនៅក្នុងឧបសម្ព័ន្ធ ៨ បានកំណត់ពីវិធីសាស្ត្រ និងសកម្មភាពដែលមានសក្តានុភាពសម្រាប់ផែនការពង្រឹងសមត្ថភាពរបស់ក្រសួងសំខាន់នីមួយៗ និងសម្រាប់ឲ្យដឹងថានៅទីណាឲ្យប្រាកដដែលអន្តរាគមន៍ទាំងនោះ នឹងត្រូវបានលើកជាផែនការជាមួយនឹងក្រសួងទាំងប្រាំមួយផ្សេងទៀត ឬក៏គណកម្មាធិការជាតិ។ ប្រអប់ ៤.២ សង្ខេបលទ្ធផលសម្រាប់ក្រសួងមួយគឺ ក្រសួងកសិកម្ម ។

**ប្រអប់ ៤.២: លទ្ធផលបញ្ជីសំនួរ 7s របស់ក្រសួងកសិកម្ម**



យុទ្ធសាស្ត្រ (៣៤%) គឺជាពិន្ទុៈសរុបសម្រាប់សំនួរទាំងប្រាំនៅក្នុងផ្នែកយុទ្ធសាស្ត្រត្រូវបានប៉ាន់ប្រមាណថា ៉តិចតួច ៉ ។ ពិន្ទុៈខ្ពស់ជាងពិន្ទុៈមធ្យមគឺ ជាក់ស្តែងព្រោះតែក្រសួងកសិកម្មមានផែនការពីរគឺផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព។ វានៅតែតិចតួចពីព្រោះតែកង្វះធនធាន និងមនុស្សសម្រាប់អនុវត្តផែនការទាំងនោះ។ ក្រសួងមានអារម្មណ៍ថា TA 8179 អាចនឹងជួយបង្កើតគម្រោងជាច្រើននៅក្រោមផែនការសកម្មភាពនេះបន្តទៀត។

រចនាសម្ព័ន្ធ (៦៥%) គឺជាពិន្ទុៈសរុបសម្រាប់សំនួរពីរនៅក្នុងផ្នែករចនាសម្ព័ន្ធដែលត្រូវបានប៉ាន់ប្រមាណថាច្រើននេះដោយសារជាក់ស្តែងក្រសួងមានយន្តការសម្របសម្រួលមួយក្នុងទម្រង់ ជាក្រុមការងារបច្ចេកទេសសម្រាប់ការប្រែប្រួលអាកាសធាតុ(CCWG) ដែលហាក់បីដូចជាកំពុងដំណើរការយ៉ាងល្អ។

ប្រព័ន្ធ (២៦%) គឺជាពិន្ទុៈសរុបសម្រាប់សំនួរទាំងប្រាំនៅក្នុងផ្នែកប្រព័ន្ធដែលត្រូវបានប៉ាន់ប្រមាណថាតិចតួច។ លទ្ធផលនេះបញ្ជាក់ថា នៅមិនទាន់មានប្រព័ន្ធត្រួតពិនិត្យគ្រប់គ្រាន់សម្រាប់ត្រួតពិនិត្យដើម្បីធានាថា ភាពធន់អាកាសធាតុត្រូវបានដាក់បញ្ចូលទៅក្នុងផែនការ និងនៅមិនទាន់មានប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃសមស្របនៅឡើយ។ ក្រសួងកសិកម្មបានប្រឹក្សាជាមួយសាធារណជនតាមរយៈ អង្គការមិនមែនរដ្ឋាភិបាល NGOs និងវិស័យឯកជន។ នាយកដ្ឋានមួយចំនួន ជាពិសេស នាយកដ្ឋានផែនការ និងស្ថិតិ បានចូលរួមធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថាន ឬការវាយតម្លៃប្រហាក់ប្រហែលគ្នានេះ និងការវាយតម្លៃភាពធន់អាកាសធាតុចម្រុះ។ ជាចំណាប់អារម្មណ៍ នាយកដ្ឋានកសិកម្មមិនបានធ្វើការងារនេះទេ។

បែបបទ (៥៨%) គឺជាពិន្ទុៈសរុបសម្រាប់សំនួរទាំងបួននៅក្នុងផ្នែកបែបបទត្រូវបានប៉ាន់ប្រមាណថាមួយចំនួនដែលជាកម្រិតមធ្យមមួយ ដោយសារតែ ជាក់ស្តែង (ក) មន្ត្រីជាន់ខ្ពស់របស់កសិកម្មយល់ដឹងពីផែនការសកម្មភាពឆ្លើយតបការប្រែប្រួលអាកាសធាតុ (ខ) ឯកភាពថា ភាពធន់អាកាសធាតុគឺជាធាតុសំខាន់មួយទោះបីវាមិនបានដាក់ចេញជាអទិភាពក៏ដោយ (គ) មន្ត្រីមានពេលវេលាគ្រប់គ្រាន់សម្រាប់ធ្វើការងារនេះ ប៉ុន្តែធនធានដែលចាំបាចើនៅមានការខ្វះខាត និង(ឃ) មានគោលនយោបាយដឹកនាំគ្រប់គ្រាន់សម្រាប់ជម្រុញការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ។

មន្ត្រី/បុគ្គលិក (១៩%) គឺជាពិន្ទុៈសរុបសម្រាប់សំនួរទាំងប្រាំនៅក្នុងផ្នែកមន្ត្រី/បុគ្គលិកត្រូវបានប៉ាន់ប្រមាណថាតិចតួច ពីព្រោះមានមន្ត្រី/បុគ្គលិកមួយចំនួនតូចដែលមានបទពិសោធន៍ផ្នែកការប្រែប្រួលអាកាសធាតុ ។ ជាមួយគ្នានោះផងដែរ សមត្ថភាពយល់ដឹងផ្នែកការប្រែប្រួលអាកាសធាតុរបស់មន្ត្រីដែលជ្រើសរើសថ្មី នៅមាន

កម្រិត។ លក្ខខណ្ឌការងារមិនបានអធិប្បាយដោយបញ្ចូលនូវទស្សននៃភាពធន់អាកាសធាតុនៅឡើយ ពីព្រោះក្រសួងកសិកម្មចាត់ទុកថា ទស្សននេះគឺជាទស្សនទានថ្មី។ ជាងនេះទៀត វាមិនបានទទួលស្គាល់ថាជាផ្នែកសំខាន់សម្រាប់ការវាយតម្លៃការអនុវត្តការងាររបស់មន្ត្រី/បុគ្គលិកទេ។

| បញ្ជ្រាបការបន្សុាំនឹងការប្រែប្រួលអាកាសធាតុក្នុងការរៀបចំផែនការអភិវឌ្ឍន៍ប្រកបដោយចីរភាព ។ | B2. យ៉ាងតិច ២០% នៃគម្រោងវិនិយោគផ្តោតទៅលើការអាកាសធាតុបានធ្វើឱ្យប្រសើរឡើង ។<br>B3. យន្តការសម្របសម្រួលសម្រាប់ភាពបន្សុាំនឹងការប្រែប្រួលអាកាសធាតុបានបង្កើតឡើងក្នុងចំណោម វិស័យសំខាន់ៗបានធ្វើឱ្យប្រសើរឡើង ។<br>B4. កម្រិតនៃការដាក់បញ្ចូលភាពបន្សុាំនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំ ។<br>B5.ការអនុវត្តជាប្រចាំលើព័ត៌មានអាកាសធាតុទៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត<br>B6. ហានិភ័យអាកាសធាតុ និងការវិភាគភាពងាយរងគ្រោះបានក្លាយជាបទដ្ឋាន គំរូក្នុងរៀបចំផែនការអភិវឌ្ឍ ។<br>B7. ការវិភាជន៍ថវិកាសម្រាប់ការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយគ្រោះ មហន្តរាយបានកើនឡើង ១០% ។ | វឌ្ឍនភាពគម្រោង ការតាមដាន និង វាយតម្លៃ<br>ការទំនាក់ទំនងថ្នាក់ជាតិទៅកាន់ UNFCCC |
| C. លទ្ធផល | | |
| C1. សមត្ថភាពបច្ចេកទេសគាំទ្រ និង ការសម្របសម្រួលរបស់ SPCR | C1.1. ការបង្កើតអង្គភាពគាំទ្របច្ចេកទេសរបស់ PPCR នៅក្រសួងបរិស្ថាននៅឆ្នាំ ២០១៣ ។<br>C1.2.របាយការណ៍ប្រជុំក្រុមការងារសម្របសម្រួល PPCR នៅពាក់កណ្តាលឆ្នាំចំនួន ២ លើកនឹងវាយតម្លៃពីការរីកចំរើនក្នុងការបញ្ជ្រាបយេនឌ័រ និងការអនុវត្ត PPCR រហូតដល់ខែ ធ្នូ ឆ្នាំ ២០១៩ | របាយការណ៍បឋម និង វឌ្ឍនភាពរបស់គម្រោងកំណត់ហេតុ និង របាយការណ៍នានាពីការពិភាក្សាគោលនយោបាយរដ្ឋាភិបាល ។ |

| | | |
|---|---|---|
| ដើម្បីបញ្ជ្រាបភាពធន់ទៅនឹងអាកាសធាតុទៅក្នុងកសាងផែនការអភិវឌ្ឍន៍ត្រូវបានពង្រឹង ។ | C1.3. ក្របខណ្ឌលទ្ធផលបរិយាប័ន្ដយយេនឌ័រសម្រាប់តាមដាន និង វាយតម្លៃលើគម្រោងវិនិយោគចំនួន ៧ របស់ PPCR ត្រូវបានបង្កើតឆ្នាំ ២០១៥ ។<br><br>C1.4. ការផ្តល់ដល់បុគ្គលិកបច្ចេកទេស រួមទាំង ស្ត្រី យ៉ាងតិចក៏មានក្រសួងតាមវិស័យសំខាន់ចំនួន ០៣ មានសមត្ថភាព ដើម្បីរៀបចំផែនការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅឆ្នាំ ២០១៦។<br><br>C1.5. យ៉ាងតិចក៏មាន ជនបង្គោលចំនួន ២០ នាក់ ត្រូវបានបណ្តុះបណ្តាលឱ្យទទួលខុសត្រូវ ផការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅក្នុងភ្នាក់ងាររដ្ឋាភិបាល ឆ្នាំ ២០១៧ ។<br><br>C1.6. យ៉ាងតិចក៏មានមន្ត្រីរដ្ឋាភិបាលសំខាន់ចំនួន ១០០ នាក់ រួមទាំង ស្ត្រី ៣០ នាក់ ត្រូវបានបណ្តុះបណ្តាលអំពីភាពបន្សាំនឹងការប្រែម្រូលអាកាសធាតុឆ្នាំ ២០១៩ (ផ្ទេរពីលទ្ធផល ៤ ) ។<br><br>C1.7. ឧបករណ៍ជ្រើសរើសហានិភ័យអាកាសធាតុបានអនុវត្តនៅក្នុងគម្រោងវិនិយោគសំខាន់ៗ និងការវាយតម្លៃភាពងាយរងគ្រោះត្រូវបានធ្វើឡើងសម្រាប់គម្រោងងាយរងគ្រោះឆ្នាំ ២០១៩។<br><br>C1.8. ការគ្រប់គ្រងហានិភ័យអាកាសធាតុត្រូវបានដាក់បញ្ចូលទៅក្នុងផែនការ កម្មវិធី និង គម្រោងនានា យ៉ាងតិចមាន ០៣ វិស័យ នៅឆ្នាំ២០១៩ ។<br><br>C1.9. យន្តការចំពោះ មូលនិធិបន្សាំនឹងការប្រែម្រូលអាកាសធាតុដល់រដ្ឋបាលថ្នាក់ក្រោមជាតិដាក់ឱ្យដំណើរការ នៅឆ្នាំ២០១៩ ។ | |
| C2. ការសិក្សាលទ្ធ | 2a. យ៉ាងតិចការសិក្សាលទ្ធភាពគម្រោង ៦ របស់ កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួល | របាយការណ៍សិក្សាលទ្ធភាពគម្រោង |

| | | |
|---|---|---|
| ភាពសម្រាប់បន្សាំនឹងការប្រែប្រួលអាកាសធាតុត្រូវបានអនុវត្ត ។ | អាកាសធាតុ(បន្សាំនឹងការប្រែប្រួលអាកាសធាតុ) បានបញ្ចប់ សម្រាប់វិស័យចំនួន ០៣ (ឧ: ទឹក កសិកម្ម ) នៅឆ្នាំ ២០១៩ ។<br>2b. យ៉ាងតិចគម្រោង NAPA ចំនួន ០២ (ភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ) ដែលផ្តល់ផលប្រយោជន៍ដោយផ្ទាល់ដល់ក្រុមងាយរងគ្រោះ រួមទាំង ស្ត្រី ត្រូវបានរកឃើញសម្រាប់ ការគាំទ្រពីមូលនិធិភាពបន្សាំនឹងការប្រែម្រូលអាកាសធាតុសកល នៅឆ្នាំ២០១៩ ។<br>2c. យ៉ាងតិចសំណើរគម្រោងចំនួន ០២ បានរៀបចំដោយជោគជ័យ និង ដាក់ជូនដោយមន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ នៅឆ្នាំ ២០១៩។ | របាយការណ៍អនុវត្តរបស់ TA<br>ទស្សនាទានគម្រោងភាពធន់ទៅនឹងអាកាសធាតុ |
| C3. យន្តការគាំទ្រសង្គមស៊ីវិលត្រូវបានបង្កើត និង សមត្ថភាពរបស់ NGOs និង CBOs បញ្ជ្រាបភាពធន់ទៅនឹងអាកាសធាតុ និង ការកាត់ បន្ថយគ្រោះមហន្តរាយ | C3.1. ក្របខ័ណសម្រាប់ភាពធន់ទៅនឹងអាកាសធាតុផ្អែកលើសហគមន៍ និង ការសិក្សា ពីការកាត់បន្ថយគ្រោះមហន្តរាយ និង គម្រោងត្រូវបានរៀបចំឡើង នៅឆ្នាំ ២០១៩។<br>C3.2. ផលប័ត្រនៃការបន្សាំនឹងការប្រែម្រូលអាកាសធាតុផ្អែកលើសហគមន៍យ៉ាងតិចចំនួន ២០ និង គម្រោងកាត់បន្ថយគ្រោះមហន្តរាយនៅក្នុងវិស័យយ៉ាងតិចចំនួន ០៣ (យ៉ាងតិចគម្រោង ៣០% ធ្វើឱ្យប្រសើរឡើងដល់ភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុរបស់ស្ត្រី) ត្រូវបានកំណត់ផ្តល់<br>ថវិកា និង អនុវត្ត នៅឆ្នាំ២០១៧ ។<br>C3.3 យ៉ាងតិចរបាយការណ៍ចំនួន ១៥ ស្តីពី នៃ ភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុផ្អែកលើសហគមន៍ ត្រូវបានផលិតនៅឆ្នាំ២០១៧ ។ | របាយការណ៍បណ្តាញបន្សាំនឹងការប្រែប្រួលអាកាសធាតុរបស់ Asia Pacific<br>របាយការណ៍ស្រាវជ្រាវ<br>របាយការណ៍អនុវត្តរបស់ TA<br>យន្តការសិក្សារៀនសូត្រអំពីការបន្សាំរបស់ UNDP |

| | | |
|---|---|---|
| C4. លទ្ធផលចំណេះដឹងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុត្រូវបានអភិវឌ្ឍន៍ និងផ្សព្វផ្សាយ ។ | C4.1. គេហទំព័រ PPCR ជាភាសាខ្មែរ និង ភាសាអង់គ្លេសត្រូវបានបង្កើត និងធ្វើបច្ចុប្បន្នភាពនៅឆ្នាំ ២០១៣ ។ ស្ថានភាពគេហទំព័រ PPCR ត្រូវបានជួសជុល ឬធ្វើបច្ចុប្បន្នភាពឡើងវិញនៅចុងឆ្នាំ ២០១៥ ។<br><br>C4.2. ត័ត៌មានពីគម្រោង SPCR ចំនួន ៧ ត្រូវបានប្រមូលចងក្រង គ្រប់គ្រង និង ផ្សព្វផ្សាយដល់ឆ្នាំ ២០១៩ ។<br><br>C4.3. យ៉ាងតិចបំផុត ៦000 លើក នៃការចូលរទៅរកព័ត៌មាន ។<br><br>C4.4. យ៉ាងតិចបំផុតការផ្សព្វផ្សាយចំនួន ១០ និង សិក្ខាសាលាតាមវិស័យជាក់លាក់ ដោយ មានអ្នកពាក់ព័ន្ធផ្សេងៗគ្នាចូលរួម (បរិយាប័ន្ត យេនឌ័រ) ត្រូវបានរៀបចំ ឆ្នាំ ២០១៩ ។<br><br>C4.5. ប្រព័ន្ធផ្សព្វផ្សាយ និង មាតិកាត្រូវបានបង្កើត ដោយមានជំនួយបច្ចេកទេសពី អង្គការសមាគមមូលដ្ឋាន (CSO) អង្គការមិនមែនរដ្ឋាភិបាល (NGO) ក្នុងការទំនាក់ទំនងត័ត៌មានប្រកបដោយប្រសិទ្ធភាពនៅចន្លោះឆ្នាំ ២០១៧ ។<br><br>C4.6. ឆ្នាំ កម្មវិធីសិក្សាសម្រាប់ ភាពបន្សុាំនឹងការប្រែប្រួលអាកាសធាតុនិង ការកាត់បន្ថយ គ្រោះមហន្តរាយ ត្រូវបានបង្កើតឡើង ការអប់នៅកំរិត ២ និង កំរិត ៣ នៅឆ្នាំ ២០១៩ ។<br><br>c.4.7. យ៉ាងតិចបំផុត មាន ២៥ អត្ថបទស្តីពី ភាពបន្សុាំនឹងការប្រែប្រួលអាកាសធាតុ និង ការកាត់បន្ថយគ្រោះមហន្តរាយ ត្រូវបានផលិត និង ផ្សព្វផ្សាយនៅលើគេហ៍ទំព័រកម្ពុជា និង សកល នៅឆ្នាំ ២០១៩ ។ | របាយការណ៍បណ្តាញភាពធន់ទៅនឹងអាកាសធាតុ Asia Pacific<br>របាយការណ៍ស្រាវជ្រាវ<br>របាយការណ៍អនុវត្តរបស់ TA<br>យន្តការសិក្សារៀនសូត្រអំពីការបន្សុាំរបស់ UNDP |

**<u>ចំណាំ</u>:** លទ្ធផល C3. យន្តការគាំទ្រសង្គមស៊ីវិលត្រូវបានបង្កើតឡើង និង សមត្ថភាពរបស់អង្គការសមាគមមូលដ្ឋាន (CSO) អង្គការមិនមែនរដ្ឋាភិបាល (**NGO**) ក្នុងការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយគ្រោះមហន្តរាយគឺស្ថិតនៅក្រោមការអនុវត្ត កញ្ចប់ទី ២ ដោយអង្គការផ្លែនអន្តរជាតិ ។

## វិធីសាស្រ្តសូចនាករសន្លឹកទី ១

A. **ផលប៉ះពាល់៖** ការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជាត្រូវបានពង្រឹង ។

**សូចនាករ ៖** ការកាត់បន្ថយ ២០ % ពីទិន្នន័យមូលដ្ឋានឆ្នាំ ២០១២ ( រយៈពេល ៥ ឆ្នាំជាមធ្យមពី ឆ្នាំ ២០០៨ ដល់ ២០១២) ក្នុងចំនួនគ្រួសារដែលរងផលប៉ះពាល់ និង វិបត្តិសេដ្ឋកិច្ចពីការប្រែប្រួលអាកាសធាតុធ្ងន់ធ្ងរ ។

A1. ការកាត់បន្ថយ ២០ % ពីទិន្នន័យដំបូងឆ្នាំ ២០១២ នៃ វិបត្តិសេដ្ឋកិច្ចពីការប្រែប្រួល អាកាសធាតុ ។

A2.ការកាត់បន្ថយ ២០ % ពីទិន្នន័យដំបូងឆ្នាំ ២០១២ នៃចំនួនគ្រួសារ ដែលរងផលប៉ះពាល់ពីការប្រែប្រួល អាកាសធាតុ ។

**សេចក្តីបរិយាយបន្ថែម៖** សូចនាករនេះមានលក្ខណៈទូលំទូលាយ ដែលឆ្ងាយពីចំណុចផ្តោតមានវិស័យនៃគម្រោងជំនួយហិរញ្ញបទានបច្ចេកទេស (TA) ដូច្នោះភ្ជាប់ទំនាក់ទំនងរវាង ការងារដែលអនុវត្តដោយ SPCR TA និង ចំនួនគ្រួសារទទួលរងផលប៉ះពាល់ដោយ ការប្រែប្រួលអាកាសធាតុធ្ងន់ធ្ងរគឺលក្ខណៈប្រយោល។ យកល្អអាចផ្តោតទៅលើការខាងបង់ផ្នែកសេដ្ឋកិច្ចពីការប្រែប្រួលអាកាសធាតុធ្ងន់ធ្ងរ ជាផ្នែកមួយនៃការខូចខាតហេដ្ឋរចនាសម្ព័ន្ធ និងការវិនិយោគតាមវិស័យជាជាងផ្តោតទៅលើគ្រួសារ ។

**ប្រភពទិន្នន័យ៖** ប្រភពទិន្នន័យដែលបានស្រង់រួមមាន ស្ថិតិថ្នាក់ជាតិ និង មូលដ្ឋាន រួមទាំង គណកម្មការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ជាតិ (NCDM) របាយការណ៍នានាពីភ្នាក់ងារអភិវឌ្ឍន៍ និង ទិន្នន័យទទួលបានពី ប្រព័ន្ធទិន្នន័យគ្រោះមហន្តរាយថ្នាក់អន្តរជាតិ ។

**វិធីសាស្រ្តនៃការវិភាគ៖** ប្រភពនានានឹងត្រូវពិនិត្យមើលទៅលើ មូលដ្ឋានព័ត៌មានប្រចាំឆ្នាំពាក់ព័ន្ធទៅនឹង a) ព្រឹត្តិការធ្ងន់ធ្ងរ (ដូចជា ព្យុះភ្លៀង ជា ព្យុះទីហ្វុង ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ជាព្យុះ និង រន្ទះបាញ់ ជាដើម ។ល។ ) b) ចំនួនគ្រួសារទទួលរងផលប៉ះពាល់ c) ការខូចខាត់ដល់ហេដ្ឋរចនាសម្ព័ន្ធតាមប្រភេទ (ដូចជា ផ្លូវ ស្ពាន ទ្វារបង្ហូរទឹក ប្រឡាយជាពសាស្រ្ត និង ប្រព័ន្ធផ្គត់ផ្គង់ទឹក ជាដើម ។ល។ និង d) ការប៉ាន់ប្រមាណចំណាយនៃការខូចខាតផ្សេងៗទៀត ។

**ភាពញឹកញាប់៖** ព័ត៌មាននេះនឹងត្រូវបានគណនា និង កត់ត្រាទុកជាមូលដ្ឋានប្រចាំឆ្នាំ និង រៀបចំ ៥ ឆ្នាំជាមធ្យមនឹងត្រូវបានគណនាតាមឆ្នាំនីមួយៗ រហូតដល់បញ្ចប់នៃគម្រោង ។

**ទិន្នន័យដំបូង៖** ទិន្នន័យដំបូងត្រូវយក ៥ ឆ្នាំគិតជាមធ្យម នៅចន្លោះឆ្នាំ ២០០៨ និង ២០១២ ។

**វិធីសាស្ត្រសូចនាករសន្លឹកទី ២**

**B. លទ្ធផលកំរិតគោលបំណង៖** ការអភិវឌ្ឍសមត្ថភាពបច្ចេកទេស និង ស្ថាប័ន ដើម្បីបញ្ជ្រាបភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងកសាងផែនការ អភិវឌ្ឍន៍ប្រកបដោយចេរិភាព ។

**សូចនាករ B1:** ធ្វើឱ្យប្រសើរនូវយុទ្ធសាស្ត្រសំខាន់នៃសំនួរទាំង ៧ ស្តីពីភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ និង ការកាត់បន្ថយគ្រោះមហន្តរាយត្រូវ បាន បញ្ចូលទៅក្នុងវិស័យយ៉ាងតិចចំនួន ០៣ នៅកម្រិតថ្នាក់ខេត្ត និង ថ្នាក់ជាតិ នៅឆ្នាំ ២០១៩ ។

**សេចក្តីបរិយាយបន្ថែម៖** សូចនាករសំដៅទៅលើយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ និង ផែនការសកម្មភាព ដែលត្រូវបានបង្កើតឡើង និង អនុម័តសម្រាប់វិស័យ ផ្សេងៗអំឡុងពេល ឆ្នាំ ២០១៤ ។ សូចនាករសំដៅទៅលើកម្រិតនៃការដាក់បញ្ចូល ជាជាងការផលិតយុទ្ធសាស្ត្រ ឬ ផែនការសកម្មភាព ។ កត់សំគាល់ថា កាលបរិច្ឆេទគួតែនៅចុងបញ្ចប់ជំនួយ ឆ្នាំ ២០១៩ ។
**ប្រភពទិន្នន័យ៖**ឯកសារគោលនយោបាយ និង ផែនការអភិវឌ្ឍន៍ ការរក្សាទុកឯកសារគម្រោង វឌ្ឍនភាពគម្រោង និង ការតាមដាន និង វាយតម្លៃ ការទំនាក់ទំនងថ្នាក់ជាតិទៅកាន់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ។
**វិធីសាស្ត្រនៃការវិភាគ៖** ឯកសារគន្លឹះសម្រាប់សូចនាករគឺជាផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (CCSP) និង វិស័យសំខាន់ របស់ គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុ (CCAP) ។ នៅក្នុងដំណាក់នៃកាលកិច្ចប្រជុំតុមូលជាលើកដំបូងរបស់ក្រសួង SPCR ។ មានសំនួរជា ច្រើន បានលើ ឡើងអំពីយុទ្ធសាស្ត្រ និង ផែនការសកម្មភាព ។ ភាពលម្អិតដែលបានផ្តល់ពិន្ទុ ដែលបានកត់ត្រា ដោយក្រុមឆ្លើយតបដូចគ្នា អាចត្រូវបានប្រើប្រាស់ ដើម្បីវាយ តម្លៃពីកំរិត នៃការដាក់បញ្ចូលផែនការសកម្មភាពទៅក្នុងក្រសួងនៅថ្នាក់ជាតិ ប៉ុន្តែមិនមែននៅកំរិតថ្នាក់ក្រោមជាតិទេ ដែលជាការទទួលខុសត្រូវ របស់ កញ្ចប់ ការងារទី ៣ ។

- តើផែនការសកម្មភាព និង យុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុត្រូវបានអនុម័តដែរ ឬ ទេ និង តើការអនុវត្តទទួលបានប្រសិទ្ធភាពដែរ ឬទេ ?
- តើមានវិធានការដាក់លាក់លើកឡើងពីភាពធន់ទៅនឹងការអាកាសធាតុត្រូវបានកំណត់ ហើយ ត្រូវបានគេចាត់អាទិភាពដែរ ឬ ទេ (ឧ: ច្បាប់ បទបញ្ញាតិ និង ការលើកទឹកចិត្តនៅក្នុងផែនការសកម្មភាព និង យុទ្ធសាស្ត្រ ) ?
- តើមន្ទីរពាក់ព័ន្ធមានកម្មវិធី និង ការវិនិយោគជាក់លាក់ ដើម្បីលើកឡើងពីភាពបន្សាំ និង ត្រូវបានគេចាត់ជាអាទិភាពចូលទៅក្នុងផែនការសម្មភាពដែរ ឬ ទេ ?
- តើមានធនធានគ្រប់គ្រាន់សម្រាប់អនុវត្តផែនការ និង យុទ្ធសាស្ត្រ និង តើមូលនិធិបានមកពីណា? (ឧ: រដ្ឋាភិបាល ឬ ដៃគូអភិវឌ្ឍន៍)?
- តើការអនុវត្តផែនការសកម្មភាព និង យុទ្ធសាស្ត្រជួបការលំបាកយ៉ាងដូចម្តេច ហើយ ត្រូវបានគេដោះស្រាយបានត្រឹមកំរិតណា ?

**ភាពញឹកញាប់៖** ទិន្នន័យដំបូង ពាក់កណ្តាលវគ្គ និង នៅចុងបញ្ចប់នៃគម្រោង ។

**ទិន្នន័យដំបូង៖** ការដាក់ពិន្ទុទិន្នន័យមូលដ្ឋានសម្រាប់ក្រសួងសំខាន់ៗចំនួន ០៥ និង ក្រសួងគាំទ្រ SPCR ០៦ ត្រូវបានកត់ត្រាទុកទៅក្នុងរបាយការណ៍ CBNA នៅឧបសម្ព័ន្ធ ៨ ។ មធ្យមភាគពិន្ទុ ៧ សម្រាប់យុទ្ធសាស្ត្រក្រសួងសំខាន់ៗចំនួន ០៦ ស្ថិតនៅក្រោមពិន្ទុសរុប ៥០% ។

## វិធីសាស្ត្រសូចនាករសន្លឹកទី ៤

B. **លទ្ធផលកំរិតគោលបំណង៖** សមត្ថភាពបច្ចេកទេស និង ស្ថាប័នក្នុងការដាក់បញ្ចូលភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុទៅក្នុងកសាងផែនការអភិវឌ្ឍ ។

**សូចនាករ** B3៖ យន្តការសម្របសម្រួលសម្រាប់ភាពធន់ទៅនឹងអាកាសធាតុត្រូវបានបង្កើតក្នុងចំណោមវិស័យសំខាន់បានធ្វើឱ្យប្រសើរឡើងនៅឆ្នាំ ២០១៩។

**សេចក្តីបរិយាយបន្ថែម៖** សូចនាករទាក់ទងនឹងការសម្របសម្រួលរវាង ភ្នាក់ងារតាមវិស័យសំខាន់ៗ និង ក្នុងចំណោមវិស័យទាំងនោះ ។ គណៈកម្មការ សម្របសម្រួល SPCR ដែលមានស្រាប់គឺជាយន្តការមួយសម្រាប់សម្របសម្រួលរវាងក្រសួង ។ ប៉ុន្តែផ្សេងៗទៀតរួមមាន កិច្ចប្រជុំក្រុមប្រឹក្សាភិបាល របស់ CCCA និង គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) និង គណៈកម្មាធិការអភិវឌ្ឍប៉ៃតងថ្នាក់ជាតិ(NGGC) ។ ផងដែរអាច តម្រូវឱ្យមានការសម្របសម្រួលទ្វេភាគី នៅពេលដែលរៀបចំផែនការ ឬ បង្កើកការវិនិយោគដែលអាចអនុភាពទៅលើការងារ និង ផលប្រយោជន៍ របស់ ក្រសួងផ្សេងៗ ។ ការភ្ជាប់ទំនាក់ទំនងជាមួយ ក្រសួងផែនការ ឬ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានសារៈសំខាន់ក្នុងការសម្រេច ដល់ការអនុម័តគម្រោង វិនិយោគអាកាសធាតុ ។ SPCR CC គឺជាវេទិកា មួយសម្រាប់ចែករំលែកមេរៀន និង បទពិសោធន៍ ប៉ុន្តែនៅពេលបច្ចុប្បន្នវេទិកានេះបាន រៀបចំតែ ២ ដងប៉ុណ្ណោះ ។ នៅក្នុងក្រសួងនីមួយៗ គួរតែមានយន្ត ការសម្របសម្រួលផងដែរ នៅពេលបច្ចុប្បន្នទទួលបានការលើកស្ទួយដោយ ក្រុមការងារប្រែប្រួលអាកាសធាតុនៅក្នុងវិស័យនីមួយៗ ។

**ប្រភពទិន្នន័យ៖** ឯកសារគោលនយោបាយ និង ផែនការអភិវឌ្ឍន៍ ការរក្សាទុកឯកសារគម្រោង វឌ្ឍនភាពគម្រោង និង ការតាមដាន និង វាយតម្លៃ ការទំនាក់ទំនងថ្នាក់ជាតិទៅកាន់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ។

**វិធីសាស្ត្រនៃការវិភាគ៖** បញ្ជីវត្តមាន និង ការវិភាគកំណត់ហេតុនៃកិច្ចប្រជុំរបស់គណកម្មការសម្របសម្រួល SPCR ក្រុមប្រឹក្សាភិបាល CCCA គណៈកម្មា ធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) គណៈកម្មាធិការអភិវឌ្ឍប៉ៃតងថ្នាក់ជាតិ(NGGC) ប្រធានពាក់ព័ន្ធ និង ព័ត៌មានត្រូវបានពិចារណា និង ចែករំលែក ។ សំនួរពិភាក្សាតុមូលនៅក្នុងក្រសួងនីមួយៗមានសំនួរជាច្រើនពាក់ព័ន្ធទៅនឹងប្រសិទ្ធភាពនៃការសម្របសម្រួលផ្ទៃក្នុង និង ការដាក់ពិន្ទុនឹងត្រូវវាយតម្លៃចំនួន ៣ លើកក្នុងរយះពេលគម្រោង ។
**ភាពញឹកញាប់៖** ការវាយតម្លៃកំណត់ហេតុនៃកិច្ចប្រជុំប្រចាំឆ្នាំ ។ ការវាយតម្លៃពីប្រសិទ្ធភាពនៃការសម្របសម្រួលផ្ទៃក្នុងចំនួន ៣ លើកៈ លើកដំបូង ពាក់កណ្តាល និង ចុងបញ្ចប់គម្រោង ។

**ទិន្នន័យដំបូង** : ការវិភាគបញ្ជីសំណួរលេខ #3 ដែលបានអនុវត្តនៅកិច្ចប្រជុំ SPCR CC (ខែ កញ្ញា ឆ្នាំ ២០១៥ ) និង ការដាក់ពិន្ទុទៅលើសំណួរទី #6 ។
តើយន្តការសម្រសម្រួលមានមុខងារអ្វីខ្លះ ដើម្បីសម្រសម្រួលសកម្មភាពពាក់ព័ន្ធទៅនឹងការប្រែប្រួលអាកាសធាតុ នៅថ្នាក់ក្រសួង ហើយវាមាន ប្រសិទ្ធភាពកំរិណា? តើមានការបញ្ចូលគ្នាដែរ ឬ ទេ សម្រាប់ក្រសួងនីមួយៗ ?

## វិធីសាស្រ្តសូចនាករសន្លឹកទី ៥

**B. លទ្ធផលកំរិតគោលបំណង៖** សមត្ថភាពបច្ចេកទេស និង ស្ថាប័នក្នុងការដាក់បញ្ចូលភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុទៅក្នុងការកសាងផែនការអភិវឌ្ឍ

**សូចនាករB4:**កំរិតនៃការដាក់បញ្ចូលភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុនិងការកាត់បន្ថយគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំនៅឆ្នាំ២០១៨ ។

**សេចក្តីបរិយាយបន្ថែម៖** សូចនាករនេះគឺជាការវាស់វែងពីវិសាលភាព ដែលដំណើរការធន់ទៅនឹងអាកាសធាតុត្រូវបានគេដាក់បញ្ចូលទៅក្នុង ផែនការអភិវឌ្ឍ ប្រចាំនៃក្រសួងនីមួយៗ ។ ជាការពិត យកល្អគួរពិចារណាលើផែនការរយៈពេល ៥ ឆ្នាំរបស់ក្រសួងនីមួយៗ ជាជាងផែនការប្រចាំឆ្នាំរំកិល ។

**ប្រភពទិន្នន័យ៖** ឯកសារគោលនយោបាយ និង ផែនការអភិវឌ្ឍន៍ ការរក្សាទុកឯកសារគម្រោង វឌ្ឍនភាពគម្រោង និង ការតាមដាន និង វាយតម្លៃ ការទំនាក់ទំនងថ្នាក់ជាតិទៅកាន់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ។

**វិធីសាស្រ្តនៃការវិភាគ៖** ផែនការរយៈពេល ៥ ឆ្នាំ និង ផែនការរំកិលប្រចាំឆ្នាំ នឹងត្រូវពិនិត្យសារឡើងវិញ និង វាយតម្លៃទល់នឹង លក្ខណៈវិនិច្ឆ័យមួយ ចំនួន ដែលភាពបន្សាំនឹងអាកាសធាតុ និង ការកាត់បន្ថយគ្រោះមហន្តរាយត្រូវបានគេដាក់បញ្ចូលទៅក្នុង ផែនការទាំងនោះ ។ គម្លោងពី " គ្មានការបរិយាយ " " ការបរិយាយ ប៉ុន្តែគ្មានការវិភាគ ឬ គ្មានចំណុចសកម្មភាព " ។ " ជំពូកដាច់ដោយឡែកស្តីពី ការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយគ្រោះមហន្តរាយ ដោយមានចំណុចសកម្មភាពជាក់លាក់ " ដើម្បីបង្ហាញពីការវិភាពភាពធន់នឹងការប្រែប្រួលអាកាសធាតុ ដែលបានដាក់បញ្ចូល និង ចំណុចសកម្មភាព នៅក្នុងផ្នែកនីមួយៗ ។

**ភាពញឹកញាប់៖** ការវាយតម្លៃប្រចាំឆ្នាំ ។

**ទិន្នន័យដំបូង៖** កម្មវិធីវិនិយោគរយៈពេល ៥ ឆ្នាំ និង ផែនការប្រចាំឆ្នាំ (ឆ្នាំ ២០១៤) ។

- ក្រសួងធនធានទឹក និង ឧតុនិយម ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងសាធារណៈការ និង ដឹកជញ្ជូន និង ក្រសួងអភិវឌ្ឍន៍ជនបទ ។

**វិធីសាស្ត្រសូចនាករសន្លឹកទី ៦**

**B. លទ្ធផលកំរិតគោលបំណង៖** សមត្ថភាពបច្ចេកទេស និង ស្ថាប័នក្នុងការដាក់បញ្ចូលភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុទៅក្នុងការកសាងផែនការអភិវឌ្ឍន៍ ។

**សូចនាករ B5៖** ការប្រើព័ត៌មានអាកាសធាតុជាប្រចាំក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅឆ្នាំ ២០១៨ ។

**សេចក្តីបរិយាយបន្ថែម៖** នេះគឺជាសូចនាករមួយពិបាកក្នុងការវាស់វែង ចាប់តាំងពីប្រភេទ និង កំរិតនៃការធ្វើសេចក្តីសម្រេចចិត្តមិនបានកំណត់ និង ការប្រើព័ត៌មានអាកាសធាតុមិនបានកំណត់ និង វាយតម្លៃពីការប្រើជាប្រចាំផ្អែកទៅលើការវិនិច្ឆ័យរបស់ភ្នាក់ងារពាក់ព័ន្ធ ។ វាជាការចំបាច់ត្រូវធ្វើឲ្យជាក់លាក់នៅ ក្នុងវិធីសាស្ត្រ នៃការវិភាគ ដូចបានសំនូមពរខាងក្រោម:

**ប្រភពទិន្នន័យ៖** ឯកសារគោលនយោបាយ និង ផែនការអភិវឌ្ឍន៍ ការរក្សាទុកឯកសារគម្រោង វឌ្ឍនភាពគម្រោង និង ការតាមដាន និង វាយតម្លៃ ការទំនាក់ទំនងថ្នាក់ជាតិទៅកាន់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ។

**វិធីសាស្ត្រនៃការវិភាគ៖** វិធីសាស្ត្រមួយចំនួនអាចត្រូវបានពិចារណា ឧ: ១) ចំនួនឱកាសដែល លទ្ធផលបង្រួញមាត្រដ្ឋានអាកាសធាតុជាក់លាក់ (លទ្ធផលការព្យាករណ៍ ផែនទី និង ម៉ូដែលជលសាស្ត្រ ) ត្រូវបានស្នើសុំដោយក្រសួងសំខាន់នីមួយៗ នៅតាមឆ្នាំនីមួយៗ ពីភ្នាក់ងារជាក់លាក់ ។ ឧ: ក្រសួងបរិស្ថាន ក្រសួងគ្រប់គ្រង ធនធានទឹន និង ឧតុនិយម ។ល។ ២) ភស្តុតាងនៃការប្រើប្រាស់លទ្ធផលនៅក្នុងឯកសារសំខាន់ (ផែនការ ៥ ឆ្នាំ ផែនការប្រចាំឆ្នាំ ឬ គម្រោងត្រូវ បានអនុម័ត ។ល។) និង ភាពញឹមញាប់នៃការប្រើប្រាស់ ។

**ភាពញឹកញាប់៖** ការវាយតម្លៃប្រចាំឆ្នាំ ។

**ទិន្នន័យដំបូង៖** គ្រប់ឯកសារនឹងត្រូវបានពិនិត្យ ។

**វិធីសាស្ត្រសូចនាករសន្លឹកទី ៧**

B. **លទ្ធផលកម្រិតគោលបំណង៖** សមត្ថភាពបច្ចេកទេស និង ស្ថាប័នក្នុងការដាក់បញ្ចូលភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុទៅក្នុងការកសាងផែនការអភិវឌ្ឍន៍

**សូចនាករ B6៖** ការវិភាគហានិភ័យអាកាសធាតុ និង ភាពងាយរងគ្រោះបានក្លាយជានិតិវិធីបទដ្ឋានគំរូនៅក្នុងការកសាងផែនការអភិវឌ្ឍន៍ នៅ ឆ្នាំ ២០១៨ ។

**សេចក្តីបរិយាបន្ថែម៖** ចំនួនវិធីសាស្ត្រផ្សេងៗគ្នា និង ឧបករណ៍ជ្រើសរើសសម្រាប់វាយតម្លៃហានិភ័យ និង ភាពងាយរងគ្រោះ គម្រោងហេដ្ឋារចនាសម្ព័ន្ធ និង វិនិយោគខុសគ្នាត្រូវបានគេយកមកប្រើប្រាស់ច្រើនជាងមួយទសវត្សរ៍កន្លងមកហើយ ។ វាមិនមែនជានិតិវិធីបទដ្ឋានគំរូនៅឡើយទេ សម្រាប់ការវិភាគប្រភេទ នេះ និង មិនទាន់មានការចាំបាច់ត្រូវមាននិតិវិធីបទដ្ឋានគំរូទោលតែមួយ ប៉ុន្តែ ជាជាងដំណើរ មួយសម្រាប់នាំយកនូវព័ត៌មានពាក់ព័ន្ធនានា ។ ទោះបីជា ការប្រើ ដំណើរ និង ឧបករណ៍នានាបែបនេះ ដើម្បីបង្ហាញពីវិសាលភាពដែលភាពបន្សាំនឹងអាកាសធាតុត្រូវបានបញ្ជ្រាបទៅ ក្នុងកិច្ចការងាររបស់ក្រសួងនីមួយៗ។

**ប្រភពទិន្នន័យ៖** ឯកសារគោលនយោបាយ និង ផែនការអភិវឌ្ឍន៍ ការរក្សាទុកឯកសារគម្រោង វឌ្ឍនភាពគម្រោង និង ការតាមដាន និង វាយតម្លៃ ការទំនាក់ទំនងថ្នាក់ជាតិទៅកាន់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ។

**វិធីសាស្ត្រនៃការវិភាគ៖** ព័ត៌មានអំពីការប្រើវិធីសាស្ត្រវាយតម្លៃហានិភ័យអាកាសធាតុ និង ភាពងាយរងគ្រោះ និង ឧបករណ៍នានានៅក្នុងក្រសួងនីមួយៗ គឺជាផ្នែកមួយនៃកម្រងបញ្ជីសំនួរប៉ាន់ប្រមាណតម្រូវការអភិវឌ្ឍសតម្ថភាព និង ការដាក់ពិន្ទុត្រូវបានអនុវត្តនៅកិច្ចប្រជុំតុមូលដើកដំបូង ។

- តើមានគោលការណ៍ និង សៀវភៅណែនាំត្រូវបន្ថែមសម្រាប់ដាក់បញ្ចូលភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការ និង បង្កើតគម្រោង អភិវឌ្ឍ ដូចជា គម្រោងហេដ្ឋារចនាសម្ព័ន្ធ ?
- តើទិន្នន័យប្រែប្រួលអាកាសធាតុត្រឹមត្រូវ និង ការព្យាករជលសាស្ត្រអាចដំណើរនៅកំរិតដ៏ត្រឹមត្រូវ ដែរ ឬ ទេ?
- តើមានឧបករណ៍អ្វីត្រូវពង្រីកសម្រាប់ដាក់បញ្ចូលភាពធន់នឹងការប្រែប្រួលអាកាសធាតុទៅក្នុងថ្នាក់ងារ ?
- តើមានឧបករណ៍វិភាគសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រឹមត្រូវនៅក្នុងថ្នាក់ងារសម្រាប់ធ្វើយុត្តិកម្មនៃភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ?
- តើក្រសួងប្រើប្រាស់ព័ត៌មានប្រែប្រួលអាកាសធាតុ និង វេទិកាទំនាក់ទំនងបន្ថែមទៀតដែរ ឬទេ ?
- តើមានឧទាហរណ៍ និង ករណីសិក្សាពាក់ព័ន្ធនៃវាយតម្លៃភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុបន្ថែមសម្រាប់បុគ្គលិកក្រសួង ដែរ ឬ ទេ ?

**ភាពញឹកញាប់៖** ការវិភាគអាចពិចារណាលើការពិភាក្សា និង ការដាក់ពន្ទុគ្រប់សំនួរនៅពេលចាប់ផ្តើមដំបូង បន្ទាប់ពី ៣ ឆ្នាំ និង ចុងបញ្ចប់គម្រោង ។

**ទិន្នន័យដំបូង៖** ព័ត៌មានពិន្ទុពី ២៥ ទៅ ៣០ ចំពោះសំនួរចំនួន ០៧ ដែលបានប្រមូលក្នុងកុំឡុងពេលកិច្ចប្រជុំតុមូលលើដំបូង ត្រូវបានរួមបញ្ចូល ទៅក្នុង របាយការណ៍ CBNA សម្រាប់គ្រប់ក្រសួងទាំងអស់ ។

**វិធីសាស្រ្តសូចនាករសន្លឹកទី ៨**

**B. លទ្ធផលកម្រិតគោលបំណង :** សមត្ថភាពបច្ចេកទេស និង ស្ថាប័នក្នុងការដាក់បញ្ចូលភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុទៅក្នុងការកសាងផែនការអភិវឌ្ឍន៍ ។
**សូចនាករ B7:** ការវិភាជន៍ថវិកាម្រាប់ភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និង ការកាត់បន្ថយគ្រោះមហន្តរាយបានកើនឡើង ១០% នៅ ឆ្នាំ ២០១៨ ។
**សេចក្តីបរិយាបន្ថែម:** សូចនាករគឺជាការវាស់វែងពីវិភាលភាពដែលថវិកាតាមវិស័យបានយកមកពិចារណាប្រើលើភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ពិតជាមានការវាស់វែងរួមហើយ ដែលត្រូវបានគេអនុវត្តនៅកំរិតថ្នាក់ជាតិ ដើម្បីវាយតម្លៃពីការវិភាជន៍ថវិកាជាតិដល់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ សូចនាករផ្តោតទៅលើថវិកានៅក្នុងវិស័យអភិវឌ្ឍន៍សំខាន់ ដូចជា វិស័យកសិកម្ម ធនធានទឹក ផ្លូវ និង ហេដ្ឋារចនាសម្ព័ន្ធនៅទីក្រុង ។
**ប្រភពទិន្នន័យ:** ឯកសារគោលនយោបាយ និង ផែនការអភិវឌ្ឍន៍ ការរក្សាទុកឯកសារគេម្រោង វឌ្ឍនភាពគម្រោង និង ការតាមដាន និង វាយតម្លៃ ការទំនាក់ ទំនងថ្នាក់ជាតិទៅកាន់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ។
**វិធីសាស្រ្តនៃការវិភាគ:** សំដៅទៅលើសំនួរមួយនៅក្នុងកម្រង់បញ្ជីសំនួរ CBNA។

- សំនួរទី ២៨: តើមានឧបករណ៍វិភាគសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រឹមត្រូវនៅក្នុងភ្នាក់ងារសម្រាប់ធ្វើយុត្តិកម្មនៃភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ?

អាចប្រើសម្រាប់ការវិភាក្សាអំពីការវិភាជន៍ថវិកានៅក្នុងក្រសួងនីមួយៗ ។ ការវិភាគផែនការ និង ការវិភាជន៍ថវិកាប្រចាំឆ្នាំអាចត្រូវបានបង្កើតឡើង ដោយមានការវិនិច្ឆ័យ ដើម្បីកំណត់ឲ្យឃើញពីប្រភេទសម្រាប់ ការវាស់វេង ភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និង ការកាត់បន្ថយគ្រោះមហន្តរាយ ។

**ភាពញឹកញាប់:** ទិន្នន័ដំបូងតាមផែនការប្រចាំឆ្នាំ ២០១៤ បន្ទាប់មក ធ្វើការវិភាគប្រចាំឆ្នាំ ។

**ទិន្នន័យដំបូង:** សំដៅទៅលើរបាយការណ៍ *CPEIR* របស់ UNDP នៅក្នុងតំបន់ *Asia-Pacific* ។ តើយើងបានរៀនសូត្រអ្វីខ្លះនៅឆ្នាំ ២០១២ ?

- ការចំណាយពាក់ព័ន្ធនឹងអាកាសធាតុសម្រាប់ប្រទេសកម្ពុជា **= 14.9 – 16.9%** នៅថវិកាជាតិទាំងមូល និង **3.1 – 6.9%** នៃផលិតផលក្នុងស្រុកសរុប ដែលបានមកពីការវិភាគនៃការចំណាយគ្រប់ដណ្តប់ទៅលើកម្មវិធី និង គម្រោង រដ្ឋាភិបាលទាំងអស់ និង រួមទាំង ថវិកាគាំទ្រពីប្រភពម្ចាស់ជំនួយ ផ្សេងៗទៀត ។
- ភ្នាក់ងារចំណាយខ្ពស់បំផុតពាក់ព័ន្ធនឹងអាកាសធាតុនៅក្នុងប្រទេសកម្ពុជាគឺ ក្រសួងធនធានទឹក និង ឧតុនិយម (13%) និង ក្រសួងសាធាណ:ការ និង ដឹកជញ្ជូន (27%)។
- សមាមាត្រនៃចំណាយពាក់ព័ន្ធនឹងអាកាសធាតុទទួលបានថវិកាពីប្រាក់ចំណូលក្នុងស្រុក គឺ 13% និង 87% ជំនួយក្រៅស្រុក ឬ 27%) ជាកម្ចី

## តារាង៦.៣៥៖ ស្នើការផ្លាស់ប្តូរទៅសូចនាករលទ្ធផល

| C. លទ្ធផល | សូចនាករ | ស្នើការផ្លាស់ប្តូរ | ស្ថានភាពទិន្នន័យដំបូង |
|---|---|---|---|
| C1. សមត្ថភាព ការគាំទ្របច្ចេកទេស និង ការសម្របសម្រួលរបស់ SPCR ក្នុងការបញ្ជ្រាបភាព<br><br>បន្សុំានឹងការប្រែប្រួលអាកាស<br><br>ធាតុទៅក្នុងការរៀបចំផែន<br><br>ការអភិវឌ្ឍន៍ត្រូវបានពង្រឹង | C1.1. ការបង្កើតអង្គភាគគាំទ្របច្ចេកទេសរបស់ PPCR នៅក្រសួងបរិស្ថាននៅឆ្នាំ ២០១៣ ។<br><br>C1.2.របាយការណ៍ប្រជុំក្រុមការងារសម្របសម្រួល PPCR នៅពាក់កណ្តាលឆ្នាំចំនួន ២ លើក ដើម្បី<br><br>វាយតម្លៃពីការរីកចំរើនក្នុងការបញ្ជ្រាបយេនឌ័រ និង<br><br>ការអនុវត្ត PPCR រហូតដល់ខែ ធ្នូ ឆ្នាំ ២០១៧ ។<br><br>C1.3. ក្របខណ្ឌលទ្ធផលបរិយាប័ន្នយេនឌ័រសម្រាប់<br><br>តាមដាន និង វាយតម្លៃនៃការវិនិយោគចំនួន ៧ របស់ PPCR ត្រូវបានបង្កើតឆ្នាំ ២០១៣ ។<br><br>C1.4. ការផ្តល់ដល់បុគ្គលិកបច្ចេកទេស រួមទាំង ស្ត្រី យ៉ាងតិចក៏មានក្រសួងតាមវិស័យសំខាន់ ចំនួន ០៣ មានសមត្ថភាព ដើម្បីរៀបចំផែនការភាព បន្សុំានឹង ការប្រែប្រួលអាកាសធាតុនៅឆ្នាំ ២០១៤ ។<br><br>C1.5. យ៉ាងតិចក៏មាន ជនបង្គោលចំនួន ២០ នាក់ ត្រូវបានបណ្តុះបណ្តាល ឲ្យទទួលខុសត្រូវ លើភាព ប | • គ្មានការផ្លាស់ប្តូរ<br>• កាលបច្ឆេទផ្លាស់ប្តូរ ខែ មេសា ឆ្នាំ ២០១៩<br><br>• កាលបច្ឆេទផ្លាស់ប្តូរដល់ ឆ្នាំ ២០១៦<br><br>• លទ្ធភាពនៃ បុគ្គលិកបច្ចេកទេស រួមមានស្ត្រីនៅក្នុងក្រសួងតាមវិស័យ សំខាន់ៗ ៤សម្រាប់ការពង្រឹងសមត្ថភាព ដើម្បីរៀបចំផែនការភាពបន្សុំានឹងអាកាសធាតុ នៅឆ្នាំ ២០១៥ ។<br><br>• គ្មានការផ្លាស់ប្តូរ ក្រៅពី កាលបច្ឆេទ ផ្លាស់ប្តូរដល់ ឆ្នាំ ២០១៦ ។<br><br>• គ្មានការផ្លាស់ប្តូរ ក្រៅពី កាលបច្ឆេទ ផ្លាស់ប្តូរដល់ ឆ្នាំ ២០១៩ ។<br><br>• កាលបច្ឆេទផ្លាស់ប្តូរដល់ ឆ្នាំ ២០១៦ | ក្រុមអង្គភាគគាំទ្របច្ចេកទេសចាប់ផ្តើការងារនៅក្នុង ខែ កុម្ភៈ ឆ្នាំ ២០១៥។<br><br>កិច្ចប្រជុំលើកទី ១ បានរៀបចំនៅក្នុងឆ្នាំ ២០១៤ និង លើកទី ២ នៅក្នុងខែ មីនា ឆ្នាំ ២០១៥។<br>គម្រោងវិនិយោគ ៣ របស់ SPCR ត្រូវបានអនុវត្ត និង ផ្សេងទៀតចាប់ផ្តើម។<br><br>លទ្ធផលរាយការណ៍របស់ CIF ឆ្នាំ ២០១៥<br><br>បុគ្គលិកបច្ចេកទេសនៅក្នុងក្រសួងសំខាន់ៗ<br>នឹងត្រូវបានកំណត់តាមរយៈ ដំណើរការពិគ្រោះយោបល់ ។<br>ជនបង្គោល ២០ នាក់ នឹងបង្កើតក្រុមការងារបន្សុំានឹងការប្រែប្រួលអាកាសធាតុ SPCR |

| C. លទ្ធផល | សូចនាករ | ស្នើការផ្លាស់ប្តូរ | ស្ថានភាពទិន្នន័យដំបូង |
|---|---|---|---|
| | ន្សាំនឹងការប្រែប្រួលអាកាសធាតុនៅក្នុងភ្នាក់ងាររដ្ឋាភិបាល ឆ្នាំ ២០១៥ ។ | | សំនួរជំនាញពីសំនួរទាំង ៧<br>ទិន្នន័យដំបូង<br>សំនួរគាំទ្រដល់សំនួរទាំង ៧ |
| | C1.6. យ៉ាងតិចក៏មានមន្រ្តីរដ្ឋាភិបាលសំខាន់ចំនួន ១០០ នាក់ រួមទាំង ស្រ្តី ៣០ នាក់ ត្រូវបានបណ្តុះបណ្តាលអំពីភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ ឆ្នាំ ២០១៨ (ផ្ទេរពីលទ្ធផល ៤ ) ។ | • កាលបច្ចេទផ្លាស់ប្តូរដល់ ឆ្នាំ ២០១៩ | |
| | C1.7. ឧបករណ៍វិភាគហានិភ័យអាកាសធាតុបានអនុវត្តនៅក្នុងគម្រោងវិនិយោគសំខាន់ៗ និងការវាយតម្លៃភាពងាយរងគ្រោះត្រូវបានធ្វើឡើងសម្រាប់គម្រោងងាយរងគ្រោះឆ្នាំ ២០១៧។ | • គ្មានការផ្លាស់ប្តូរ ក្រៅពី កាលបច្ចេទ ផ្លាស់ប្តូរដល់ ឆ្នាំ ២០១៩ ។ | សំនួរគាំទ្រដល់សំនួរទាំង ៧<br>ទិន្នន័យដំបូង<br>ពីសំនួរយុទ្ធសាស្រ្តទាំង ៧ |
| | C1.8. ការគ្រប់គ្រងហានិភ័យអាកាសធាតុត្រូវបានដាក់បញ្ចូលទៅក្នុងផែនការ កម្មវិធី និង គម្រោងនានា យ៉ាងតិចមាន ៣ វិស័យនៅឆ្នាំ ២០១៧ ។ | • គ្មានការផ្លាស់ប្តូរ ក្រៅពី កាលបច្ចេទ ផ្លាស់ប្តូរដល់ ឆ្នាំ ២០១៩ ។ | |

| C. លទ្ធផល | សូចនាករ | ស្នើការផ្លាស់ប្តូរ | ស្ថានភាពទិន្នន័យដំបូង |
|---|---|---|---|
| | C1.9. យន្តការចំពោះ មូលនិធិបន្សុាំនឹងអាកាសធាតុ ដល់រដ្ឋបាលថ្នាក់ក្រោមជាតិដាក់ឱ្យដំណើរការ នៅឆ្នាំ ២០១៧ ។ | | |
| C2. ការសិក្សាលទ្ធភាព គម្រោងសម្រាប់គម្រោង បន្សុាំនឹងការប្រែប្រួល អាកាសធាតុត្រូវបាន អនុវត្ត ។ | យ៉ាងតិចបុគ្គលិក ២ នាក់ត្រូវបានបណ្តុះបណ្តាល នៅផ្នែកនីមួយៗ នៃ ភ្នាក់ងារចំនួន ៥ គោលដៅ ទៅ លើរបៀបចាត់អាទិភាព វាយតម្លៃភាពងាយ រងគ្រោះ និង រៀបចំផែនការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ និង ប្រតិបត្តិនៃយន្តការផ្តល់ហិរញ្ញ ប្បទានសកល ។<br>យ៉ាងតិចការសិក្សាលទ្ធភាពគម្រោងចំនួន ៦ អំពី កម្មវិធីសកម្មភាពជាតិបន្សុាំនឹងការប្រែប្រួលអាកាស ធាតុ ( NAPA ) បានញ្ចប់ សម្រាប់វិស័យ ៣<br>( ឧ: ទឹក កសិកម្ម និង ហេដ្ឋារចនាសម្ព័ន្ធ )<br>នៅឆ្នាំ ២០១៥ ។ | គ្មានការផ្លាស់ប្តូរ ទោះបីជា បុគ្គលិកដែល បណ្តុះបណ្តាលរួច អាចចូលធ្វើការនៅចុង បញ្ចប់នៃកំណើរការរៀបចំគម្រោងក៏ដោយ ។<br>**បញ្ចូលចំណុចដៅបន្ថែម** : យ៉ាងតិចករណីសិក្សា ចំនួន ៦ ស្តីពី ការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានអនុវត្តសម្រាប់ ៣ វិស័យ<br>( ឧ: ទឹក កសិកម្ម និង ហេដ្ឋារចនាសម្ព័ន្ធ )<br>ផ្លាស់ប្តូរគម្រោង NAPA ទៅ គម្រោង បន្សុាំនឹងការ ប្រែប្រួលអាកាសធាតុ<br>• កាលបច្ឆេទផ្លាស់ប្តូរដល់ ឆ្នាំ ២០១៦ | ស្ថានភាពទិន្នន័យមូលដំបូងមិនទាន់មាន |

| C. លទ្ធផល | សូចនាករ | ស្នើការផ្លាស់ប្តូរ | ស្ថានភាពទិន្នន័យដំបូង |
|---|---|---|---|
| | យ៉ាងតិចគម្រោង NAPA ចំនួន ០២ ដែលផ្តល់ ផលប្រយោជន៍ដោយផ្ទាល់ដល់ក្រុម ងាយរងគ្រោះ រួមទាំង ស្ត្រី ត្រូវបានរកឃើញសម្រាប់ការគាំទ្រពី បន្សាំនឹងការប្រែប្រួលអាកាសធាតុសកល នៅឆ្នាំ ២០១៥ ។<br><br>យ៉ាងតិចសំណើគម្រោងចំនួន ០២ បានរៀបចំដោយជោគជ័យ និង ដាក់ជូន ដោយមន្ត្រីរដ្ឋា ភិបាលថ្នាក់ ជាតិនៅឆ្នាំ ២០១៧។ | យ៉ាងតិចការសិក្សាលទ្ធភាពគម្រោង NAPA ចំនួន ៦ បានបញ្ចប់ យ៉ាងតិច ១ គម្រោង សម្រាប់ផ្នែកនីមួយៗនៃក្រសួងគោលចំនួន ៥ នៅចុងឆ្នាំ ២០១៥ ។<br><br>ផ្លាស់ប្តូរគម្រោង NAPA ទៅ គម្រោង បន្សាំនឹងការប្រែប្រួលអាកាសធាតុ<br>• កាលបច្ឆេទផ្លាស់ប្តូរដល់ ឆ្នាំ ២០១៦<br><br>**បញ្ចូលចំណុចដៅបន្ថែម** : យ៉ាងតិច ៦ សំណើគម្រោង ក្នុងនោះ យ៉ាងតិច ១ គម្រោងសម្រាប់ក្រសួងគោលដៅនីមួយៗ ត្រូវបានរៀបចំ និង ដាក់ជូនដល់បន្សាំនឹងការប្រែប្រួលអាកាសធាតុសកលដោយបុគ្គលិករដ្ឋាភិបាលថ្នាក់ជាតិនៅឆ្នាំ ២០១៨ ។<br>• កាលបច្ឆេទផ្លាស់ប្តូរដល់ ឆ្នាំ ២០១៨<br>យ៉ាងតិចសំណើគម្រោងចំនួន ០២ បានរៀប ចំដោយជោគជ័យ និង ដាក់ជូន ដោយមន្ត្រីរដ្ឋា | |

| C. លទ្ធផល | សូចនាករ | ស្នើការផ្លាស់ប្តូរ | ស្ថានភាពទិន្នន័យដំបូង |
|---|---|---|---|
| | | ភិបាលថ្នាក់ជាតិ នៅឆ្នាំ ២០១៨ ។ | |
| C3. យន្តការគាំទ្រសង្គម សីវិលត្រូវបានបង្កើត និង សមត្ថភាពរបស់ NGOs និង CBOs ក្នុងការ បញ្ជ្រាបភាពបន្សាំនឹងការ ប្រែប្រួលអាកាសធាតុ និង ការកាត់បន្ថយគ្រោះ មហន្តរាយ | C3.1. ក្របខ័ណ្ឌសម្រាប់បន្សាំនឹងការប្រែប្រួល អាកាសធាតុផ្អែកលើសហគមន៍ និង ការសិក្សា ពីការកាត់បន្ថយគ្រោះមហន្តរាយ និង គម្រោង នានាត្រូវបានរៀបចំ នៅឆ្នាំ ២០១៣ ។<br><br>C3.2. ផលប័ត្រនៃភាពបន្សាំនឹងប្រែប្រួលអាកាសធាតុ ផ្អែក លើសហគមន៍យ៉ាងចិតចំនួន ២០ និង គម្រោងកាត់បន្ថយគ្រោះមហន្តរាយនៅក្នុងវិស័យយ៉ាងចិតចំនួន ០៣ ( យ៉ាងតិចគម្រោង ៣០% ធ្វើឲ្យប្រសើរឡើងដល់ ភាពធន់ទៅនឹងអាកាសធាតុរបស់ស្ត្រី ) ត្រូវបាន កំណត់ ផ្តល់ហិរញ្ញប្បទាន និង អនុវត្តនៅឆ្នាំ ២០១៧។<br><br>C3.3 យ៉ាងតិចរបាយការណ៍ចំនួន ១៥ ស្តីពី ភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុផ្អែកលើសហគមន៍ ត្រូវបានផលិតនៅឆ្នាំ២០១៧ ។ | សូចនាករសម្រាប់កញ្ចប់ទី ២ | |

| C. លទ្ធផល | សូចនាករ | ស្នើការផ្លាស់ប្តូរ | ស្ថានភាពទិន្នន័យដំបូង |
|---|---|---|---|
| C4. លទ្ធផលចំណេះដឹងភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុត្រូវបានអភិវឌ្ឍន៍ និង ផ្សព្វផ្សាយ ។ | C4.1. គេហ៍ទំព័រ PPCR ជាភាសាខ្មែរ និង ភាសា អង្គ្លេសន៍ត្រូវបានបង្កើត និង ថែទាំនៅឆ្នាំ ២០១៣ ។ ស្ថានភាពគេហ៍ទំព័រ PPCR ត្រូវបានជួសជុល ឬ ធ្វើបច្ចុប្បន្នភាពឡើងវិញនៅចុងឆ្នាំ ២០១៥ ។ | • គ្មានការផ្លាស់ប្តូរ និងបន្តរហូតដល់ចុងឆ្នាំ ២០១៦ ។ | គេហ៍ទំព័រ PPCR មានស្រាប់ នៅតែដំណើរការ |
| | C4.2. ត័ត៌មានពីគម្រោង SPCR ចំនួន ៧ ត្រូវបានប្រមូលចងក្រង គ្រប់គ្រង និង ផ្សព្វផ្សាយរហូតដល់ឆ្នាំ ២០១៧ ។ | • គ្មានការផ្លាស់ប្តូរ និងបន្តរហូតដល់ចុងឆ្នាំ ២០១៩ ។<br>• វាស់វែងដោយ:<br>• យ៉ាងតិចបុគ្គលិករដ្ឋាភិបាលសំខាន់ៗ ៣០០ នាក់ រួមទាំង ស្ត្រី ៣០% អាចចូលស្វែងរកព័ត៌មានថ្មី ចំណេះដឹង ឬ ឧបករណ៍ស្តីពី ផលទ្ធផលចំណេះទទួលបាន ប្រព័ន្ធផ្សព្វផ្សាយ គេហ៍ទំព័រ ឆ្នាំ ២០១៩ ។ | គម្រោង SPCR ចំនួន ៣ ត្រូវបានអនុវត្តនៅពេលបច្ចុប្បន្ន ។<br><br>ចាប់ផ្តើមពីចំណុចសូន្យ |
| | C4.3. យ៉ាងតិចបំផុតការផ្សព្វផ្សាយចំនួន ១០ និងសិក្ខាសាលាតាមវិស័យជាក់លាក់ ដោយ មានអ្នកពាក់ព័ន្ធពីប្រភពផ្សេងៗបានចូលរួម (បរិយាប័ន្ន | • មានអ្នកមើលគេហ៍ទំព័រ យ៉ាងតិច ៦០០០ ដងដើម្បីស្វែងរកព័ត៌មានពាក់ព័ន្ធ ។<br>• ផ្លាស់ប្តូររហូតដល់ឆ្នាំ ២០១៩ ។ | ចាប់ផ្តើមពីចំណុចសូន្យ |

| C. លទ្ធផល | សូចនាករ | ស្នើការផ្លាស់ប្តូរ | ស្ថានភាពទិន្នន័យដំបូង |
|---|---|---|---|
| | យេនឌ័រ) ត្រូវបានរៀបចំ ឆ្នាំ ២០១៨ ។ | • កាលបរិច្ឆេទផ្លាស់ប្តូរដល់ ឆ្នាំ ២០១៩ និង សូចនាករ<br>• វាស់វែងដោយ:<br>• យ៉ាងតិចឧបករណ៍ទំនាក់ទំនងចំនួន ២០ (ដូចជាផ្ទាំងរូបភាព ខិតប័ណ្ណ ព្រឹត្តិបត្តិ ប្រចាំសប្តាហ៍) ត្រូវបានបង្កើត ដើម្បីទាក់ ទាញការផ្សព្វផ្សាយព័ត៌មានប្រកបដោយប្រសិទ្ធភាព ។ | |
| | C4.4. ប្រព័ន្ធផ្សព្វផ្សាយ និង មាតិកាត្រូវបានបង្កើតដោយមានជំនួយបច្ចេកទេសពី អង្គការសមាគម មូលដ្ឋាន (CSO) អង្គការមិនមែនរដ្ឋាភិបាល (NGO) ក្នុងការទំនាក់ទំនងព័ត៌មាន ប្រកបដោយប្រសិទ្ធ ភាពនៅចន្លោះឆ្នាំ ២០១៥ ។ | • សារព័ត៌មានថ្នាក់ជាតិចំនួន ៤ អំពី *MCRDP / SPCR* | ចាប់ផ្តើមពីចំណុចសូន្យ |
| | C4.5. កម្មវិធីសិក្សាសម្រាប់ភាពបន្សាំនឹងការប្រែប្រួល អាកាសធាតុ និង ការកាត់បន្ថយគ្រោះមហន្តរាយ ត្រូវបានផលិត និង ផ្សព្វផ្សាយ នៅលើគេហ៍ទំព័រកម្ពុជា និង សកល នៅឆ្នាំ ២០១៧ ។ | • កាលបរិច្ឆេទផ្លាស់ប្តូរដល់ ឆ្នាំ ២០១៨<br>• វាស់វែងដោយ: ១) យ៉ាងតិចកម្មវិធី សកលវិទ្យាល័យចំនួន ៣ បានធ្វើបច្ចុប្បន្នកម្មវិធីសិក្សាស្តីពី ភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ ២) យ៉ាងតិចនិសិត្សចំនួន២០០ នាក់ បានចូលទៅរៀនសិក្សានៅ ៣ សកល វិទ្យាល័យ ។ | ចាប់ផ្តើមពីចំណុចសូន្យ |

# 7 ផែនការការងារសម្រាប់រយៈពេល៦ខែបន្ទាប់

408. តារាងទី0-1 បង្ហាញពីផែនការការងារសម្រាប់រយៈពេល៦ខែពីខែសីហា ឆ្នាំ២០១៥ ដល់ខែមករា ឆ្នាំ២០១៦។ ផែនការនេះត្រូវបានរៀបចំឡើងយោងទៅតាមធាតុចេញសំខាន់ៗ និងរួមបញ្ចូលទាំងកាលបរិច្ឆេទនៃកិច្ចប្រជុំសម្របសម្រួល កិច្ចប្រជុំក្រុមការងារ របាយការណ៍ និងឯកសារចំណេះដឹងផ្សេងៗទៀត។

**តារាង៧.១៖ ផែនការការងារសម្រាប់រយៈពេល៦ខែពីខែសីហា ឆ្នាំ២០១៥ ដល់ខែមករា ឆ្នាំ២០១៦**

| Program | | 2015 | | | | | 2016 |
|---|---|---|---|---|---|---|---|
| Activities | | August | September | October | November | December | January |
| 0. Office operation | | | | | | | |
| 0.1 | Preparing quarterly and annual reports | | | | | | |
| 0.2 | Prepare 6-month work program and budget plan (February to July 2016) | | | | | | |
| Output 1: SPCR Coordination, technical support, and capacity development | | | | | | | |
| 1.1 | SPCR adaptation working group meetings | | | | | | |
| 1.2 | SPCR investment project group meetings | | | | | | |
| 1.3 | Regular round table meetings in each of the key ministries | | | | | | |
| 1.4 | Initial Field visits to SPCR provinces | | | | | | |
| 1.5 | Literature and field research of sector adaptation measures and traditional practices guidance | | | | | | |
| 1.6 | Literature research and consultation on screening tools | | | | | | |
| 1.7 | Prepare and organize 3rd SPCR Coordination Team Meeting | | | | | | |
| 1.8 | Inter Ministerial Field Visit to SPCR Investment project | | | | | | |
| 1.9 | Develop guideline and tool kits for CC for key ministries | | | | | | |
| Output 2: Conduct NAPA feasibility studies | | | | | | | |
| 2.1 | Initial scoping visits by team to two provinces working with provincial agencies | | | | | | |
| 2.2 | Integrated Vulnerability assessment training for AWG members in one province | | | | | | |
| 2.3 | Identifying and characterising adaptation funding sources | | | | | | |
| 2.4 | Participate and contribute in process of NAP development | | | | | | |
| Output 4: Develop and Disseminate CCA and DRR knowledge products | | | | | | | |
| 4.1 | Publishing knowledge products: | | | | | | |
| 4.2 | Preparation of baseline M & E report | | | | | | |
| 4.3 | Preparation of report on screening tools | | | | | | |
| 4.4 | Drafting of guidelines on adaptation practices for each sector | | | | | | |
| 4.5 | Drafting of report on traditional adaptation practices | | | | | | |
| 4.6 | Preparation and publishing of climate change adaptation glossary | | | | | | |
| 4.7 | Preparation and publishing quarterly newsletter | | | | | | |
| 4.8 | Establishing SPCR web site, Facebook, Youtube, Twitter | | | | | | |
| 4.9 | Event to launch new web site | | | | | | |
| 4.10 | Prepare and publish promotional materials - folder, bookmark etc | | | | | | |
| 4.11 | Preparation of video clips from field visits, recruit specialist company to produce 1st of four videos | | | | | | |
| 4.12 | Meetings with selected universities to progress curriculum development | | | | | | |
| | TOTAL BUDGET | | | | | | |

# 8 អនុសាសន៍នានាសម្រាប់ការអនុវត្តដែលមានប្រសិទ្ធភាព

## 8.1 ការបកស្រាយក្របខណ្ឌបង្កើតគម្រោង និងការត្រួតពិនិត្យតាមដាន

409. របាយការណ៍នេះបង្ហាញផែនការ ដែលអាចយល់ដឹងសម្រាប់ការអនុវត្តសកម្មភាពកញ្ចប់ទី១ជាគម្រោងTA8179។ ផែនការបានបង្ហាញតាមការបកស្រាយក្របខណ្ឌបង្កើតគម្រោង និងការត្រួតពិនិត្យតាមដាន និងលំដាប់នៃសកម្មភាពគម្រោង។ ផែនការដែលបានបង្ហាញគឺបញ្ជាក់ពីការងារបន្ថែមមួយចំនួន និងការកែសម្រួលបំពេញបន្ថែមដល់កិច្ចសន្យាការងាររបស់ទីប្រឹក្សា។ ការកែសម្រួលទាំងនេះ ត្រូវបានបង្ហាញតាមអនុសាសន៍ដែលត្រូវបានចែកចេញជាការអនុវត្តតាមប្រភេទដូចខាងក្រោម (I) កិច្ចសន្យាការងារ និងថវិកា(C)។

### *8.1.1 ការកែសម្រួលពាក្យ "កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុNAPA" ទៅជា" "គម្រោងការបន្សាំ"*

**អនុសាសន៍** *I.1*

យោងតាមពាក្យ គម្រោងកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុក្នុងក្របខណ្ឌបង្កើតគម្រោង និងការត្រួតពិនិត្យតាមដានត្រូវបានបកស្រាយដើម្បីដាក់បញ្ចូលគម្រោងការបន្សាំដែលទូលំទូលាយ

410. ការរកឃើញកំឡុងពេលពិគ្រោះយោបល់នៃការចាប់ផ្ដើមអនុវត្តគម្រោងដែលយោងតាមការបង្កើតគម្រោងកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ*NAPA* ប្រហែលជាមិនទាន់បច្ចុប្បន្នភាពទេ និងវិសាលភាពមានលក្ខណៈតូចពេក។ ជាលទ្ធផល ក្រុមការងារគម្រោងបានផ្ដល់អនុសាសន៍ថា ពេលវេលាដែលនៅសល់សម្រាប់គម្រោង សកម្មភាពទាំងនេះគួរត្រូវបានអនុវត្តសម្រាប់ការបង្កើត " គម្រោងការបន្សាំ" ដែលទាញចេញពីវិស័យអាទិភាពបច្ចុប្បន្ន និងបទពិសោធន៍ពីតំបន់គោលដៅ។

### *8.1.2 សកម្មភាពបន្ថែមដើម្បីបង្កើតប្រព័ន្ធព័ត៌មានភូមិសាស្ត្រដែលផ្អែកលើឧបករណ៍គាំទ្រការធ្វើសេចក្ដីសម្រេចចិត្តការប្រែប្រួលអាកាសធាតុ*

**អនុសាសន៍** *I.2*

សកម្មភាពមួយត្រូវបានបន្ថែមក្រោមធាតុចេញទី១ដើម្បីបង្កើតប្រព័ន្ធព័ត៌មានភូមិសាស្ត្រផ្អែកលើឧបករណ៍គាំទ្រការធ្វើ
សេចក្ដីសម្រេចចិត្តការប្រែប្រួលអាកាសធាតុផ្អែកលើទិន្នន័យចុងក្រោយដែលមិនទាន់វិភាគសម្រាប់ការបង្រួញមាត្រដ្ឋានថ្នាក់តំបន់ និងថវិកាបន្ថែមគម្រោងTA ត្រូវដាក់ចូលក្នុងកញ្ចប់ទី១របស់ទីប្រឹក្សាដើម្បីអនុវត្តសកម្មភាព។

411. ការកសាងបន្ថែមលើការពិភាក្សាក្នុងផ្នែកទី៣នៃរបាយការណ៍ ក្រុមហ៊ុនICEM ស្នើឱ្យបន្ថែមសកម្មភាពទី1.7 ដែលនឹងចូលរួមបង្កើតប្រព័ន្ធព័ត៌មានភូមិសាស្ត្រដែលផ្អែកលើឧបករណ៍គាំទ្រ

ការធ្វើសេចក្តីសម្រេចចិត្តការប្រែប្រួលអាកាសធាតុដែលបំពេញបន្ថែមដល់ឯកសារក្រសួងធនធានទឹក និងឧតុនិយមដែលគាំទ្រដោយធនាគារADB ប៉ុន្តែត្រូវយកទិន្នន័យចុងក្រោយដែលមិនទាន់វិភាគសម្រាប់ការបង្រួញមាត្រដ្ឋានថ្នាក់តំបន់ពី CSIRO ។

412. គោលបំណងនៃសកម្មភាពទាំងនេះ នឹងជួយដល់រាជរដ្ឋាភិបាលកម្ពុជាឲ្យមានប្រព័ន្ធកម្រិតខ្ពស់ដែលភ្នាក់ងាររាជរដ្ឋាភិបាលកម្ពុជាអាចស្វែងរកទិន្នន័យប្រែប្រួលអាកាសធាតុ និងឯកសារប្រព័ន្ធព័ត៌មានភូមិសាស្ត្រពីគម្រោងមួយទៅគម្រោងមួយ និងដើម្បីផលិតឧបករណ៍ទាំងអស់សម្រាប់រដ្ឋាភិបាលឲ្យមានលក្ខណៈស្ថិតស្ថេរដែលប្រើដោយវិស័យទាំងអស់ក្នុងការអភិវឌ្ឍ ការធ្វើផែនការ និងការគ្រប់គ្រង។ ការបន្ថែមលើសកម្មភាពទាំងនេះមានលក្ខណៈស្ថិតស្ថេរជាមួយផលប៉ះពាល់ដែលបានគ្រោងទុក និងធាតុចេញរបស់គម្រោង TA8179 និងសកម្មភាព1.7។ ការពិពណ៌នាសកម្មភាពលម្អិត និងថវិកានឹងត្រូវបានធ្វើជាច់ដោយឡែក។

### *8.1.3 ពង្រឹងអ្នកជំនាញការគម្រោងដើម្បីវិភាគសេដ្ឋកិច្ចសង្គម*

**អនុសាសន៍** *I.3*

ថវិកាបន្ថែមគម្រោង TA ត្រូវបានដាក់ទៅក្នុងកញ្ចប់ទី១របស់ទីប្រឹក្សា ដើម្បីពង្រឹងសមត្ថភាពរបស់ក្រុមការងារគម្រោងលើការវិភាគសេដ្ឋកិច្ចសង្គម ដោយបន្ថែមតួនាទីដែលត្រូវជ្រើសរើសទីប្រឹក្សាជាតិ និងអន្តរជាតិ។

413. កំឡុងពេលសិក្ខាសាលាចាប់ផ្តើមការអនុវត្តគម្រោង TA8179 មានការកត់សម្គាល់ថាធនធានរដ្ឋាភិបាលមានកំណត់ និងការធ្វើសេចក្តីសម្រេចចិត្តវិនិយោគហេដ្ឋារចនាសម្ព័ន្ធទាំងអស់សុទ្ធតែពាក់ព័ន្ធនឹងដេញថ្លៃដែលមិនអាចជៀសផុត។ មានការកត់សម្គាល់ដែរថា ទស្សនទានដែលមានការទទួលខុសត្រូវលើការប្រែប្រួលអាកាសធាតុក្នុងគោលនយោបាយ ផែនការ និងជាពិសេសគម្រោងវិនិយោគ ជាប់ទាក់ទងតម្លៃបន្ថែម។ អ្នកចូលរួមមួយចំនួនមានគំនិតផ្សេងថា ការកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការទទួលខុសត្រូវសម្រាប់ផលប៉ះពាល់ដែលមានសក្តានុពលភាពនាពេលអនាគត អាចចំណាយតិចជាតិវិធីសាស្ត្រនាពេលបច្ចុប្បន្ន។ អ្នកចូលរួមបានផ្តល់អនុសាសន៍ទៀតថា ក្រុមការងារគម្រោងគួរបញ្ចូលការវិភាគសេដ្ឋកិច្ច និងវាយតម្លៃជម្រើសការបន្ស៊ាំផ្សេងៗទៅក្នុងសកម្មភាពរបស់កម្មវិធី។

414. ក្នុងការឆ្លើយតបនឹងមតិត្រលប់វិញនេះ វាត្រូវបានផ្តល់ជាអនុសាសន៍ថា ក្រុមការងារគម្រោងត្រូវបញ្ចូលការវិភាគសេដ្ឋកិច្ចសង្គមទៅក្នុងសកម្មភាព 1.6, 2.2, 2.4 និង 2.6 ដើម្បីពង្រឹងករណីសិក្សា ការសិក្សាពីលទ្ធភាពលម្អិត និងសំណើគម្រោងការបន្ស៊ាំដែលនឹងបង្កើតឡើងដោយក្រុមការងារគម្រោង។ ដើម្បីអនុវត្តការងារនេះ ថវិកាបន្ថែមត្រូវបានស្នើឡើងសម្រាប់តួនាទីអ្នកសេដ្ឋ

សាស្ត្រសង្គម។ លក្ខខណ្ឌការងារលម្អិត និងថវិកាសម្រាប់តួនាទីទីប្រឹក្សាបន្ថែមនេះ នឹងផ្ញើជូនដាច់ដោយឡែក។

## 8.2 ផែនការការងារ និងសកម្មភាព និងរបាយការណ៍បច្ចេកទេស

415. វិធីសាស្ត្រការអនុវត្តស្នើដោយក្រុមការងារគម្រោងក្នុងផ្នែកទី7បញ្ជាក់ការកែសម្រួលដល់ការបែងចែកថវិកា និងសកម្មភាព និងកញ្ចប់សកម្មភាព ក៏ដូចជារបាយការណ៍បច្ចេកទេសផងដែរ។

### *8.2.1 ការបែងចែកថវិកា និងសកម្មភាពគម្រោង*

**អនុសាសន៍** *I.4*

ការបែងចែកថវិកា និងសកម្មភាពគម្រោង ត្រូវបានលម្អិតក្នុងតារាងទី6-1 ត្រូវបានទទួលយកជាមូលដ្ឋានសម្រាប់ផែនការការងារគម្រោងសម្រាប់រយៈពេលដែលនៅសល់។

416. តារាងទី6-1 ផ្តល់គណនេយ្យលម្អិតនៃការបែងចែកថវិកា និងសកម្មភាពក្របខណ្ឌបង្កើតគម្រោង និងការត្រួតពិនិត្យតាមដានស្នើដោយក្រុមការងារក្នុងរបាយការណ៍នេះ។ ស្របពេលដែលទស្សនទាននៃសកម្មភាពក្របខណ្ឌបង្កើតគម្រោង និងការត្រួតពិនិត្យតាមដានដែលបានពិពណ៌នា នឹងមិនចេញជាលទ្ធផលនៅក្នុងការផ្លាស់ប្តូរសំខាន់ៗដើម្បីសកម្មភាពគម្រោង វាបញ្ជាក់ពីការផ្លាស់ប្តូរទៅជាសកម្មភាពជាក់លាក់ដែលនឹងមានផលប៉ះពាល់ ដល់កាលបរិច្ឆេទសម្រាប់របាយការណ៍បច្ចេកទេសដែលនឹងផលិតដោយក្រុមការងារគម្រោង។ វាក៏បញ្ជាក់ពីការកែសម្រួលមួយចំនួនដល់របៀបដែលក្រុមការងារគម្រោងនឹងរៀបចំ។

### *8.2.2 កាលបរិច្ឆេទនៃការផ្តល់របាយការណ៍បច្ចេកទេស និងការអនុម័ត*

**អនុសាសន៍** *I.5*

កាលបរិច្ឆេទផ្តល់របាយការណ៍បច្ចេកទេស ត្រូវបានកែសម្រួលដូចក្នុងតារាង8.1

417. ផ្អែកលើការកែសម្រួលការបែងចែកថវិកា និងសកម្មភាពគម្រោង និងផែនការការងារ ត្រូវបានពិភាក្សាខាងលើ វាជាការស្នើបន្ថែមដែលកាលបរិច្ឆេទជាក់លាក់នៃរបាយការណ៍បច្ចេកទេស គួរត្រូវបានកែសម្រួលដូចក្នុងតារាងទីត្រូវបានកែសម្រួលដូចក្នុងតារាងទី8.1 ។

**តារាង៨.១ ៖ កាលបរិច្ឆេទត្រូវបានកែសម្រួលសម្រាប់របាយការណ៍បច្ចេកទេសដែលជាប់កិច្ចព្រមព្រៀង**

| No. | Original No. | Technical Report Title<br>**មួយចំណងជើងរបាយការណ៍បច្ចេកទេស** | **កាលបរិច្ឆេទដែលគ្រោងទុក** |
|---|---|---|---|
| T1 | T3 | របាយការណ៍ស្តីពីឧបករណ៍ជ្រើសរើសហានិភ័យដែលអាចប្រើប្រាស់សម្រាប់ស្ថានភាពប្រទេសកម្ពុជា | ខែតុលា ឆ្នាំ២០១៥ |
| T2 | T6 | របាយការណ៍បច្ចេកទេសស្តីពីការត្រួតពិនិត្យ តាមដាន និងវាយតម្លៃការបន្ស៊ាំ | ខែមេសា ឆ្នាំ២០១៦ |
| T3 | T14 | របាយការណ៍ស្តីពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ | ខែមេសា ឆ្នាំ២០១៦ |
| T4 | T9 | របាយការណ៍ស្តីពីការសិក្សាពីលទ្ធភាពលម្អិតរបស់កម្មវិធីសកម្មភាពជាតិបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុឬផែនការជាតិបន្ស៊ាំ | ខែតុលា ឆ្នាំ២០១៦ |
| T5 | T13 | របាយការណ៍ស្តីពីការបន្ស៊ាំតាមបែបប្រពៃណីឬជនជាតិភាគតិចពីការអនុវត្តការបន្ស៊ាំ និងការកាត់បន្ថយគ្រោះមហន្តរាយ | ខែតុលា ឆ្នាំ២០១៦ |
| T6 | T8 | របាយការណ៍ស្តីពីសហគមន៍ដែលពឹងផ្អែកលើការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយគ្រោះមហន្តរាយ | ខែមេសា ឆ្នាំ២០១៧ |
| T7 | T10 | ឯកសារការបង្កើតគម្រោងចំនួន២ ដើម្បីទទួលបានមូលនិធិអន្តរជាតិការបន្ស៊ាំ | ខែមេសា ឆ្នាំ២០១៧ |
| T8 | T4 | មគ្គុទេសក៏សម្រាប់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ក្នុងវិស័យកសិកម្ម | ខែតុលា ឆ្នាំ២០១៧ |
| T9 | T5 | មគ្គុទេសក៏សម្រាប់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ក្នុងវិស័យធនធានទឹក | ខែតុលា ឆ្នាំ២០១៧ |
| T10 | T11 | មគ្គុទេសក៏សម្រាប់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ក្នុងវិស័យដឹកជញ្ជូន | ខែមករា ឆ្នាំ២០១៨ |
| T11 | T12 | មគ្គុទេសក៏សម្រាប់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ទីក្រុង | ខែមករា ឆ្នាំ២០១៨ |
| T12 | T7 | របាយការណ៍ស្តីពីការដាក់បញ្ចូលភាពធន់នឹងអាកាសធាតុ និងការកាត់បន្ថយគ្រោះមហន្តរាយទៅក្នុងកម្មវិធីសិក្សា | ខែមេសា ឆ្នាំ២០១៨ |

| No. | Original No. | Technical Report Title<br>**មួយចំណងជើងរបាយការណ៍បច្ចេកទេស** | **កាលបរិច្ឆេទដែលគ្រោងទុក** |
|---|---|---|---|
| T13 | T1 | មគ្គុទេសក៏សម្រាប់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍នៅថ្នាក់ជាតិ | ខែកក្កដា ឆ្នាំ២០១៨ |
| T14 | T2 | មគ្គុទេសក៏សម្រាប់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ | ខែកក្កដា ឆ្នាំ២០១៨ |

418. របាយការណ៍បច្ចេកទេសដែលបានរៀបរាប់ក្នុងតារាង*9.1* មិនមែនត្រឹមតែជាឯកសារចំណេះដឹងផលិតចេញពីគម្រោងប៉ុណ្ណោះទេ ថែមទាំងជាសមិទ្ធផលដើម្បីកំណត់នូវការចំណាយថវិកាសម្រាប់ទីប្រឹក្សាក្នុងកញ្ចប់ទី១ផងដែរ។ ជាលទ្ធផល វាបញ្ជាក់ថាដំណើរការច្បាស់លាស់ត្រូវបានបង្កើតឡើង និងព្រមព្រៀងសម្រាប់ ១) ការចាប់ផ្តើមពិនិត្យឡើងវិញ និងអនុម័តរបាយការណ៍បច្ចេកទេសដើម្បីវាស់វែងការចំណាយថវិកាដែលមានគោលដៅ និង២) ការអនុម័តដើម្បីបញ្ចប់របាយការណ៍ សម្រាប់ការបោះពុម្ព និងការផ្សព្វផ្សាយទូលំទូលាយ។

### *8.2.3 ការអនុម័តរបាយការណ៍បច្ចេកទេស ដើម្បីវាស់វែងការចំណាយថវិកាដែលមានគោលដៅ*

**អនុសាសន៍** *I.6*

ដំណើរការនៃការអនុម័តរបាយការណ៍បច្ចេកទេសដែលបានបង្ហាញគ្រួសៗក្នុងរបាយការណ៍នេះ ត្រូវបានព្រមព្រៀង។

419. នៅពេលរបាយការណ៍បច្ចេកទេស ត្រូវការធ្វើដោយក្រុមការងារគម្រោង ត្រូវបានអនុម័ត វាជាចំណុចគោលដៅនៃការវាស់វែងការចំណាយថវិកាសម្រាប់ទីប្រឹក្សាក្នុងកញ្ចប់ទី១។ ដើម្បីត្រូវបានទទួលការពិចារណាលើការអនុម័ត របាយការណ៍គួរតែត្រូវបានបំពេញគ្រប់ដំណើរការនៃការអនុម័តដូចខាងក្រោម៖

***ជំហានទី១៖ពិនិត្យឡើងវិញដោយប្រធានសម្របសម្រួលកម្មវិធីSPCR និងនាយកដ្ឋានប្រែប្រួលអាកាសធាតុ***

420. សេចក្តីព្រាងរបាយការណ៍បច្ចេកទេស ត្រូវបានផ្ញើជូនប្រធានដឹកនាំកម្មវិធីSPCR លោក មាស សុផល និងប្រធានគ្រប់គ្រងកម្មវិធី SPCR នៃនាយកដ្ឋានប្រែប្រួលអាកាសធាតុ លោក អ៊ុំ ច័ន្ទធារិទ្ធ។ ប្រធានដឹកនាំ និងប្រធានគ្រប់គ្រង នឹងទទួលខុសត្រូវសម្រាប់ការសម្របសម្រួលការពិនិត្យរបាយការណ៍ដោយប្រធានសម្របសម្រួលកម្មវិធីSPCR និងមន្រ្តីពាក់ព័ន្ធនៅនាយកដ្ឋានប្រែប្រួលអាកាសធាតុ។

421. មតិ និងអនុសាសន៍ត្រលប់វិញលើរបាយការណ៍បច្ចេកទេស ត្រូវបានសម្របសម្រួលក្នុងរយៈពេល ២សប្តាហ៍គិតចាប់ពីថ្ងៃទទួលបានរបាយការណ៍។ បន្ទាប់មកមតិ និងអនុសាសន៍ទាំងនោះនឹង

ប្រគល់ឲ្យក្រុមការងារគម្រោង ហើយក្រុមការងារគម្រោង នឹងទទួលខុសត្រូវក្នុងការផ្តល់សេចក្តីព្រាងរបាយការណ៍បច្ចេកទេសជាមួយមតិ និងអនុសាសន៍ដែលទទួលបានពីប្រធានសម្របសម្រួលកម្មវិធីSPCR និងនាយកដ្ឋានប្រែប្រួលអាកាសធាតុ ទៅឲ្យអ្នកជំនាញការប្រែប្រួលអាកាសធាតុនៃធនាគារADB។

422. ប្រសិនបើមតិ ឬអនុសាសន៍ត្រលប់វិញទាំងនោះ មិនបានទទួលក្នុងរយៈពេល២សប្តាហ៍ទេ ទីប្រឹក្សាគម្រោងនឹងផ្តល់សេចក្តីព្រាងរបាយការណ៍បច្ចេកទេសជូនទៅអ្នកជំនាញការប្រែប្រួលអាកាសធាតុនៃធនាគារADBដោយផ្ទាល់។ មតិ ឬអនុសាសន៍ដែលផ្តល់ឲ្យបន្ទាប់ពី២សប្តាហ៍ នឹងត្រូវបានដាក់បញ្ចូលជាមួយមតិ ឬអនុសាសន៍ដែលទទួលបានពីអ្នកជំនាញការប្រែប្រួលអាកាសធាតុ ADB។

### *ជំហានទី២៖ពិនិត្យឡើងវិញដោយអ្នកជំនាញការប្រែប្រួលអាកាសធាតុនៃធនាគារADB*

423. នៅពេលទទួលបានសេចក្តីព្រាងរបាយការណ៍បច្ចេកទេសខាងលើ ហើយមតិ និងអនុសាសន៍ត្រលប់វិញ ត្រូវបានដាក់បញ្ចូលគ្នាដែលបានមកពីប្រធានសម្របសម្រួលកម្មវិធីSPCR នាយកដ្ឋានប្រែប្រួលអាកាសធាតុ អ្នកជំនាញការប្រែប្រួលអាកាសធាតុនៃធនាគារADB នឹងមានរយៈពេល២សប្តាហ៍ទៀតដើម្បីពិនិត្យឡើងវិញ និងផ្តល់មតិ និងអនុសាសន៍ត្រលប់វិញ ។ កំឡុងពេលពិនិត្យឡើងវិញនេះ អ្នកជំនាញការប្រែប្រួលអាកាសធាតុនៃធនាគារADB អាចយោង និងកសាងបន្ថែមលើមតិ និងអនុសាសន៍ត្រលប់វិញ ពីប្រធានសម្របសម្រួលកម្មវិធីSPCR និងនាយកដ្ឋានប្រែប្រួលអាកាសធាតុ។

### *ជំហានទី៣៖ របាយការណ៍ដែលបានអនុម័តដើម្បីវាស់វែងគោលដៅចំណាយថវិកាលើទីប្រឹក្សា និងការកែសម្រួលរបាយការណ៍*

424. បន្ទាប់ពី២សប្តាហ៍ដែលរបាយការណ៍ ត្រូវបានកែសម្រួលដោយអ្នកជំនាញការប្រែប្រួលអាកាសធាតុនៃធនាគារADB ឬមតិ និងអនុសាសន៍ត្រលប់វិញត្រូវបានទទួល អាចខាងណាមុនក៏បាន របាយការណ៍បច្ចេកទេស ក៏ត្រូវបានពិចារណាថាបានអនុម័តសម្រាប់គោលបំណងទូទាត់ការចំណាយ។

425. នៅពេលដាក់បញ្ចូលរួច រាល់មតិត្រលប់វិញ និងអនុសាសន៍នានាដែលផ្តល់ឲ្យក្រុមការងារគម្រោង វាតម្រូវឲ្យក្រុមការងារគម្រោងដោះស្រាយរាល់មតិនិងអនុសាសន៍ ដែលបានលើកឡើង និងពិពណ៌នារបៀបដោះស្រាយមតិនីមួយៗក្នុងតារាង។

426. ប្រសិនក្នុងហេតុផលណាក៏ដោយ ក្រុមការងារគម្រោងប្រចាំការិយាល័យSPCR ឬអ្នកជំនាញការប្រែប្រួលអាកាសធាតុនៃធនាគារADB មិនទាន់ពេញចិត្តជាមួយរបាយការណ៍បច្ចេកទេសដែលផ្ត

ល់ជូនតាមរយៈដំណើរការនេះ ដំណើរការនេះនឹងធ្វើដដែលៗរហូតដល់របាយការណ៍ត្រូវបានពិចារណាថាចូលក្នុងស្តង់ដារពេញចិត្ត។

**ក្រាហ្វិច 21៖ ការពិនិត្យឡើងវិញបច្ចេកទេសដែលជាប់កិច្ចព្រមព្រៀង និងដំណើរការអនុម័ត**




**អនុសាសន៍** *I.7*

ដំណើរការដែលអនុម័តសម្រាប់របាយការណ៍បច្ចេកទេសដែលជាប់កិច្ចព្រមព្រៀងក្នុងរបាយការណ៍នេះត្រូវបានឯកភាព។

427. នៅពេលបញ្ចប់ដំណើរការពិនិត្យនិងអនុម័ត សេចក្តីព្រាងរបាយការណ៍បច្ចេកទេសដែលបានកែសម្រួល ត្រូវដាក់ឲ្យឯកភាពយល់ព្រមតាមរយៈគណៈកម្មការសម្របសម្រួលកម្មវិធីSPCR ។ ដើម្បីទទួលបានការយល់ព្រម របាយការណ៍ត្រូវឆ្លងកាត់ដំណើរការដូចខាងក្រោម៖

### *ជំហានទី១៖ ការពិនិត្យឡើងវិញដោយក្រុមការងារការបន្សាំកម្មវិធីSPCR*

428. សេចក្តីព្រាងរបាយការណ៍បច្ចេកទេសដែលបានកែសម្រួល គួរត្រូវបានចែកជូនសមាជិកនៃក្រុមការងារការបន្សាំនៅក្រសួងគោលដៅនីមួយៗដើម្បីពិនិត្យ។ ក្រុមការងារនឹងផ្តល់រយៈពេល៤សប្តាហ៍ដើម្បីពួកគាត់ពិនិត្យមើលចាប់ពីថ្ងៃទទួលបានរបាយការណ៍។

### *ជំហានទី២៖ ការកែសម្រួលរបាយការណ៍*

429. នៅពេលមតិ និងអនុសាសន៍ត្រលប់វិញ ត្រូវបានទទួលពីក្រុមការងារការបន្សាំ ក្រុមការងារគម្រោងតម្រូវឲ្យដោះស្រាយរាល់មតិទាំងអស់ និងពិពណ៌នាពីរបៀបដែលមតិនីមួយៗត្រូវបានដោះស្រាយក្នុងតារាងផ្តល់មតិ។

430. បន្ទាប់មករបាយការណ៍កែសម្រួលចុងក្រោយនឹងផ្ញើជូនមន្ត្រីគម្រោងកម្មវិធីSPCR និងអ្នកជំនាញការប្រែប្រួលអាកាសធាតុនៃធនាគារADB ដើម្បីពិនិត្យចុងក្រោយ។ ទន្ទឹមពេលនោះ រាល់មតិត្រលប់វិញដែលនៅសល់ នឹងត្រូវបានដោះស្រាយដោយក្រុមការងារគម្រោង។

***ជំហានទី៣៖ ការអនុម័តចុងក្រោយដោយគណៈកម្មការសម្របសម្រួលកម្មវិធីSPCR***

431. បន្ទាប់ពីរបាយការណ៍កែសម្រួលចុងក្រោយ និងតារាងមតិ នឹងត្រូវផ្ញើជូនសមាជិកនីមួយៗរបស់គណៈកម្មការសម្របសម្រួលកម្មវិធីSPCR យ៉ាងហោចណាស់៤សប្តាហ៍មុនកិច្ចប្រជុំរបស់គណៈកម្មការសម្របសម្រួលកម្មវិធីSPCR ។ ក្រុមការងារគម្រោងនឹងជួបប្រជុំជាមួយសមាជិកគណៈកម្មការសម្របសម្រួលកម្មវិធីSPCR ដើម្បីពិភាក្សាលើរបាយការណ៍មុនកិច្ចប្រជុំ និងដំណើរការនៃការចងក្រងបង្កើតរបាយការណ៍។

432. កំឡុងពេលកិច្ចប្រជុំរបស់គណៈកម្មការសម្របសម្រួលកម្មវិធីSPCR ក្រុមការងារគម្រោងធ្វើបទបង្ហាញពីរបាយការណ៍ សម្រាប់គណៈកម្មការពិចារណា។ ដរាបណាគោលបំណង ឬមតិត្រលប់មកវិញត្រូវបានដាក់ក្នុងរបៀបវារៈកំឡុងកិច្ចប្រជុំ របាយការណ៍ ត្រូវបានពិចារណាអនុម័ត និងត្រៀមរួចរាល់សម្រាប់ការកែសម្រួលចុងក្រោយ ការរៀបចំតាក់តែង និងផ្សព្វផ្សាយឲ្យទូលំទូលាយ។

433. ប្រសិនបើមានមតិបន្ថែមទៀត ត្រូវបានដាក់ក្នុងរបៀបវារៈកំឡុងកិច្ចប្រជុំ ក្រុមការងារគម្រោងនឹងតម្រូវឲ្យធ្វើការកែសម្រួលចុងក្រោយលើរបាយការណ៍ និងបន្ទាប់មកជួបជាមួយសមាជិកនីមួយៗរបស់គណៈកម្មការ ដើម្បីធានាថាមតិទាំងនោះត្រូវបានដោះស្រាយ។ នៅពេលសមាជិកគណៈកម្មការពេញចិត្ត ក្រុមការងារគម្រោងប្រហែលធ្វើការបញ្ចប់របាយការណ៍នោះ។ ក្រុមការងារគម្រោងនឹងតម្រូវឲ្យផ្តល់របាយការណ៍ខ្លីពីការផ្តល់ដំណោះស្រាយលើមតិត្រលប់វិញសម្រាប់កិច្ចប្រជុំគណៈកម្មការលើកក្រោយ។

**ក្រាហ្វិច 22៖ ដំណើរការអនុម័តរបាយការណ៍បច្ចេកទេសដែលជាប់កិច្ចព្រមព្រៀង**




## 8.3 ការរៀបចំក្រុមការងារ និងធាតុចូល

434. វិធីសាស្ត្រការអនុវត្តដែលស្នើដោយក្រុមការងារគម្រោងក្នុងផ្នែកទី៧ ក៏បញ្ជាក់ពីការកែសម្រួលខ្លះៗលើការរៀបចំ និងការផ្តល់ធាតុចូលរបស់ក្រុមអ្នកជំនាញរបស់គម្រោង។ អនុសាសន៍នានា

សម្រាប់ធ្វើឲ្យប្រសើរឡើងលក្ខខណ្ឌការងាររបស់អ្នកជំនាញនៃគម្រោង និងការបន្ថែមចំនួនអ្នកជំនាញដើម្បីដោះស្រាយសកម្មភាពជាតុចេញទី១ ដើម្បីបង្កើតប្រព័ន្ធព័ត៌មានភូមិសាស្ត្រដែលផ្អែកលើឧបករណ៍គាំទ្រការធ្វើសេចក្តីសម្រេចចិត្តការប្រែប្រួលអាកាសធាតុសម្រាប់រដ្ឋាភិបាល ដូចផ្តល់ជូនខាងក្រោម៖

### *8.3.1 ទីប្រឹក្សាបន្ថែម*

**អនុសាសន៍** *I.8*

ប្រសិនបើអនុសាសន៍ I.2 ត្រូវបានព្រមព្រៀង លក្ខខណ្ឌការងារសម្រាប់ទីប្រឹក្សាបន្ថែមម្នាក់ នឹងត្រូវបានឯកភាពផ្អែកលើ
សេចក្តីព្រាងផ្តល់ក្នុងរបាយការណ៍នេះ។

តាមការពិភាក្សាខាងលើ ក្រោមអនុសាសន៍ I.8 ក្រុមការងារ កំពុងស្នើអនុវត្តសកម្មភាពបន្ថែមមួយក្រោមជាតុចេញទី១ ដើម្បីបង្កើតប្រព័ន្ធព័ត៌មានភូមិសាស្ត្រដែលផ្អែកលើឧបករណ៍គាំទ្រការធ្វើសេចក្តីសម្រេចចិត្តការប្រែប្រួលអាកាសធាតុសម្រាប់រដ្ឋាភិបាលដោយផ្អែកលើទិន្នន័យចុងក្រោយមិនទាន់វិភាគសម្រាប់ការបង្រួញមាត្រដ្ឋានថ្នាក់តំបន់។ លក្ខខណ្ឌការងារសម្រាប់ទីប្រឹក្សាបន្ថែមនេះដោយមានសកម្មភាពលម្អិត និងថវិកានឹងត្រូវបានរៀបចំដោយឡែក។

**អនុសាសន៍** *I.9*

ប្រសិនបើអនុសាសន៍ I.3 ត្រូវបានព្រមព្រៀង លក្ខខណ្ឌការងារសម្រាប់ទីប្រឹក្សាជាតិ និងអន្តរជាតិខាងសេដ្ឋសាស្ត្រសង្គម នឹងត្រូវបានរៀបចំឡើង។

### *8.3.2 ការធ្វើឲ្យប្រសើរឡើងលក្ខខណ្ឌការងាររបស់ក្រុមការងារគម្រោង*

**អនុសាសន៍** *I.10*

ការកែសម្រួលដល់តួនាទី និងលក្ខខណ្ឌការងារដែលកំណត់ក្នុងរបាយការណ៍នេះ ត្រូវបានឯកភាព។

435. កំឡុងពេលដំណាក់កាលចាប់ផ្តើម ក្រុមការងារគម្រោងបានពិនិត្យមើលលក្ខខណ្ឌការងាររបស់ខ្លួនផ្អែកលើផែនការអនុវត្តគម្រោងដែលបានស្នើឡើង និងស្នើសុំការកែសម្រួលខ្លះៗ។ លក្ខខណ្ឌការងារដែលកែសម្រួលត្រូវបានផ្តល់ជូននៅឧបសម្ព័ន្ធទី១១។

436. អនុសាសន៍ទី I.1 ក៏បានណែនាំថាតួនាទីពនាក់សម្រាប់អ្នកជំនាញបង្កើតគម្រោងក្រោមកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ គួរប្តូរជាអ្នកឯកទេសកសាងគម្រោងបន្សាំការប្រែប្រួលអាកាសធាតុ។

## 8.4 កិច្ចសហការជាមួយគំនិតផ្តួចផ្តើមការប្រែប្រួលអាកាសធាតុផ្សេងទៀត

### *8.4.1 កិច្ចសហការជាមួយកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា*

**អនុសាសន៍** *I.11*

ក្រុមការងារគម្រោង និងកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា អនុវត្តតាមកិច្ចព្រមព្រៀងជាផ្លូវការសម្រាប់កិច្ចសហប្រតិបត្តិការដែលបានផ្តល់ក្នុងរបាយការណ៍នេះ។

437. កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ត្រូវបានពិពណ៌នាក្នុងផ្នែកទី4.3 គឺស្របនឹងគំនិតផ្តួចផ្តើមអាកាសធាតុក្នុងនាយកដ្ឋានប្រែប្រួលអាកាសធាតុ។ មានការបំពេញឲ្យគ្នាទៅវិញទៅមករវាងកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា និងកម្មវិធីSPCR។ កិច្ចពិភាក្សាបានរៀបចំឡើងជាមួយកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ដើម្បីបង្កើតចំណងមិត្តភាពការងាររវាងកម្មវិធីទាំងពីរ និងកំនត់ចំនុចច្បាស់លាស់នៃកិច្ចសហការ និងការឯកភាពផ្លូវការបានដាក់ចេញសម្រាប់គោលបំណងនេះ។ មានភ្ជាប់មកជាមួយនៅក្នុងឧបសម្ព័ន្ធទី១២។

438. គោលបំណងសំខាន់នៃកិច្ចព្រមព្រៀងនេះគឺដើម្បីធានាថាកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា និងSPCR គាំទ្រដល់តួនាទីរបស់នាយកដ្ឋានប្រែប្រួលអាកាសធាតុក្នុងការសម្របសម្រួលដោយមានការរំពឹងទុកនៃការផ្តល់ធាតុចេញច្បាស់លាស់ពីកម្មវិធីទាំងពីរ ពិសេសសកម្មភាពដែលអាចត្រួតស៊ីគ្នា។ ដើម្បីជាក់លាក់សម្រាប់កម្មវិធីSPCR គោលបំណងបន្ថែមមួយទៀត គឺពង្រឹងការសហការ និងសម្របជាមួយក្រសួងបរិស្ថាន/នាយកដ្ឋានប្រែប្រួលអាកាសធាតុ ជម្រុញផ្តល់ភាពជាម្ចាស់ដល់រដ្ឋាភិបាល និងការធ្វើសេចក្តីសម្រេចចិត្ត។

439. កិច្ចសហការចំបងៗរួមមាន៖

- ការរៀបចំផែនការគម្រោងទាំងមូល និងការសម្របសម្រួល
- សហការជាមួយក្រសួងពាក់ព័ន្ធនៅកម្រិតគម្រោង និងវិស័យ
- បង្កើតប្រព័ន្ធព័ត៌មានប្រែប្រួលអាកាសធាតុ
- សម្របសម្រួលក្នុងសកម្មភាពផ្សព្វផ្សាយ
- ការរៀបចំផែនការប្រែប្រួលអាកាសធាតុ និងថវិកា

